ព្រះ
ត្រៃបិដក

ប្រែរួមនឹង
ព្រះអដ្ឋកថា

ភាគ៥

បាលីប្រែ ៦ - ៧

ពុទ្ធសកាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

ព្រះ
វិនយបិដក
និង
សមន្តបាសាទិកា អដ្ឋកថា
សេចក្តីប្រែជាភាសាខ្មែរ

មហាវគ្គ
បឋមភាគ ទុតិយភាគ

๕
ចាលីប្រែ ๖-๗



ជោះពុម្ពលើកទី ๑ ពុទ្ធសករាជ ๒๕๕๓

กฺขาลธิ ๕

ព្រះវិនយបិដក

សូមនមស្ការចំពោះ

ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

មហាខន្ធកៈ ពោធិកថា

[๑] *សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគ បានគ្រាស់ជាដំបូងទ្រង់គង់ក្រោមម្លប់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់ដោយព្រះភ្នែនតែមួយអស់ ๗ ថ្ងៃក្រោមម្លប់ពោធិព្រឹក្សទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺពិចារណាបណ្តាយចុះនិងច្រាសឡើង អស់បឋមយាមនៃរាត្រីដោយនយ័ថា សង្ខារ[๑] ទាំងឡាយកើតមានព្រោះមានអវិជ្ជា[๒] ជាហេតុ វិញ្ញាណកើតមាន*

๑-ក្នុងគម្ពីរវិសុទ្ធិមគ្គថា សង្ខារ ๓ គឺបុញ្ញាភិសង្ខារ ๑ អបុញ្ញាភិសង្ខារ ๑ អានេញ្ជាភិសង្ខារ ๑ ។ បុញ្ញាភិសង្ខារនោះ បានខាងចេតនា ๑๓ គឺកាមាវចរកុសលចេតនា ๘ និងរូបាវចរកុសល-ចេតនា ๕ ប្រព្រឹត្តទៅដោយអំណាចកាវនា ឯអបុញ្ញាភិសង្ខារ បានខាងអកុសលចេតនា ๑๒ ។ អានេញ្ជាភិសង្ខារ គឺ អរូបាវចរកុសលចេតនា ๔ ប្រព្រឹត្តទៅដោយអំណាចកាវនា រួមទាំងអស់ជា ๒๙ ។ ๒-ដែលហៅថា អវិជ្ជានោះ បានខាងសេចក្តីមិនដឹងក្នុងសច្ចៈទាំងបួន មានទុក្ខសច្ចជាដើម ។ (នេះជាបរិយាយក្នុងសូត្រ ឯបរិយាយក្នុងអភិធម្មថា) បានខាងសេចក្តីមិនដឹងនូវវត្ថុ ๘ មានមិនដឹងក្នុងចំណែកខាងអតីតជាដើម ម្យ៉ាងទៀតថា បានខាងមោហចេតសិក មានលក្ខណៈធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍ ។

ព្រោះមានសង្ខារជាហេតុ សឡាយតនៈកើតមាន ព្រោះមាននាមរូបជាហេតុ ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាហេតុ វេទនាកើតមាន ព្រោះមានផស្សៈជាហេតុ តណ្ហាកើតមាន ព្រោះមានវេទនាជាហេតុ ឧបាទានកើតមាន ព្រោះមានតណ្ហាជាហេតុ ភពកើតមាន ព្រោះមានឧបាទានជាហេតុ ជាតិកើតមាន ព្រោះមានភពជាហេតុ សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយកើតមាន ព្រោះមានជាតិជាហេតុ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ម្យ៉ាងទៀត សេចក្តីរលត់សង្ខារកើតមាន ព្រោះវិនាស និងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ទើបបន្ទឺនូវឧទានគាថានេះ ក្នុងវេលានោះថា ធម៌ទាំងឡាយរមែងប្រាកដដល់ឱណាសវៈ-

ព្រាហ្មណ៍ អ្នកមានព្យាយាម ញុាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ទីណាសវព្រាហ្មណ៍ នោះ ក៏សឹងតែរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ទីណាសវព្រាហ្មណ៍ នោះ ដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

[๒] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺពិចារណាបណ្តាយចុះនឹងច្រាសឡើង អស់មជ្ឈិមយាមនៃរាត្រីដោយនយថា សង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះមានសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះមាននាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះមានផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះមានវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះមានតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះមានឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះមានភពជាបច្ច័យ សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតណែនក្នុងចិត្តទាំងឡាយកើតមាន ព្រោះមានជាតិជាបច្ច័យ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតមានយ៉ាងនេះឯង ម្យ៉ាងទៀត សេចក្តីរលត់សង្ខារកើតមាន ព្រោះវិនាសនឹងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈកើត

มាន ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនាក៏តមាន ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហាក៏តមាន ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទានក៏តមាន ព្រោះរលត់តណ្ហា សេចក្តីរលត់កពក៏តមាន ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិក៏តមាន ព្រោះរលត់កព សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីរលត់កងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ទើបបន្ទឺនូវឧទានគាថានេះ ក្នុងវេលានោះថា ធម៌ទាំងឡាយប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាសវព្រាហ្មណ៍នោះ តែងរម្ងាប់អស់ទៅ ក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ បានជីងច្បាស់នូវព្រះនិព្វានជាទីអស់ទៅនៃបច្ច័យ ។

[๓] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ជាអនុលោមប្បដិលោម គឺពិចារណាបណ្តាយចុះនឹងច្រាសឡើង អស់បច្ឆិមយាមនៃរាត្រីដោយន័យថា សង្ខារទាំងឡាយក៏តមាន ព្រោះមានអវិជ្ជា ជាបច្ច័យ វិញ្ញាណក៏តមាន ព្រោះមានសង្ខារជាបច្ច័យ នាមរូបក៏តមាន ព្រោះមានវិញ្ញាណជាបច្ច័យ សឡាយតនៈក៏តមាន ព្រោះមាននាមរូបជាបច្ច័យ ផស្សៈក៏តមាន ព្រោះមានសឡាយតនៈជាបច្ច័យ វេទនាក៏តមាន ព្រោះមានផស្សៈជាបច្ច័យ តណ្ហាក៏តមាន ព្រោះមានវេទនាជាបច្ច័យ ឧបាទានក៏ត

មាន ព្រោះមានតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះមានឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះមានភពជាបច្ច័យ សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតណែនក្នុងចិត្តទាំងឡាយ កើតមាន ព្រោះមានជាតិជាបច្ច័យ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ម្យ៉ាងទៀត សេចក្តីរលត់សង្ខារកើតមាន ព្រោះវិនាស និងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្តីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ក៏បន្ទឺនូវឧទានគាថានេះ ក្នុងវេលានោះថា ធម៌ទាំងឡាយប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារហើយ ស្ថិតនៅ ក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើង

ធ្វើអាកាសឲ្យរុងរឿង ដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹត ស្ថិតនៅជួញ្ជោះឯង ។

ពោធិកថា ចប់

อัฏฐกถา

ตติยสมันตปาสาทิกา

พระวินัยปิฎก มหาขันธกวัณณนา

มหาวรรค

อัปปโลกคาถา

พระมหาเถระทั้งหลาย ผู้ชื่อว่าทรงไว้ซึ่งอรรถในขันธกะ ได้สังคายนาขันธกะใด ขันธกะนั้น เป็นที่สุดแห่งการสังคายนาทั้งปวง ๒ ครั้ง บัดนี้ ข้าพเจ้าจักถึงที่สุดแห่งการพรรณนาขันธกะนั้น เพราะฉะนั้น การพรรณนานี้ จึงชื่อว่าเป็นการแสดงเนื้อความที่ยังไม่ได้สังคายนาในขันธกะนั้น ก็อรรถทั้งหลายใด บททั้งหลายใด ข้าพเจ้าได้กล่าวแล้วในบททั้งหลายใด ในบทกัปปิยภูมิ ถ้าข้าพเจ้าจักกล่าวอรรถแห่งบทนั้นอีก การพรรณนาก็จักไม่มีที่สุด ฉะนั้น ข้าพเจ้าจักไม่กล่าวอรรถแห่งบทนั้นอีก ก็อรรถแห่งบทใดที่ยังไม่ได้กล่าวไว้ในบทนั้น ข้าพเจ้าจักกล่าวอรรถแห่งบทนั้น ถ้าอรรถแห่งบทใดที่ข้าพเจ้ากล่าวแล้วในบทนั้น ก็ยังมีอรรถแห่งบทอื่นอีก ข้าพเจ้าก็จักกล่าวอรรถแห่งบทนั้นเหมือนกัน ก็อรรถแห่งบทใดที่ข้าพเจ้าไม่กล่าวไว้ในที่ไหน ๆ ข้าพเจ้าจักกล่าวอรรถแห่งบทนั้นในที่นี้ ฉะนั้น การพรรณนานี้ จึงชื่อว่าเป็นการแสดงเนื้อความที่ยังไม่ได้สังคายนาในขันธกะนั้น ๆ

โคจิกถา

[๑] ในบทว่า **เตน สมเยน พุทฺโธ ภควา พาราณสิยา วิหรติ**

ฉฏฺฐา เสรพฺภายา តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ *នេះ* សូម្បីមិនមានហេតុពិសេស ព្រោះតតិយាវិភត្តិ ដូចក្នុងបទថា **តេន សមយេន ពុទ្ធោ ភគវា សេរពฺภายំ** ជាដើមក៏ពិត តែវោហារនេះ លោកលើកទ្បើងដោយតតិយាវិភត្តិដូចគ្នា ព្រោះសម្ដែងវិនัយ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសណ្ឋានថា ពាក្យនោះ លោកពោលតាមទំនងវោហារ ដែលលើកទ្បើងអំពីជំបូងនោះឯង ក្នុងពាក្យជនៃៗ ក្រៅអំពីពាក្យនេះជនៃទៀត អំពីពាក្យបែបនេះ ក៏ក្នុងន័យនេះ ។

សួរថា អ្វីជាប្រយោជន៍ក្នុងការពោលពាក្យនោះ *ឆ្លើយថា* ការសម្ដែងហេតុតាំងអំពីដំបូងនៃវិនយកម្មទាំងឡាយ មានបព្វជ្ជាជាដើមជាប្រយោជន៍ ។

ពិតហើយ អ្នកសិក្សាគប្បីជ្រាបប្រយោជន៍ក្នុងការពោលពាក្យនោះ គឺការសម្ដែងហេតុតាំងអំពីដំបូងនៃវិនយកម្មទាំងឡាយ មានបព្វជ្ជាជាដើមទាំងនោះ យ៉ាងនេះថា បព្វជ្ជា និងឧបសម្បទាឯណា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណាគមន៍ទាំងឡាយនេះ ដូច្នេះ និងវត្តទាំងឡាយ មានឧបជ្ឈាយវត្ត អាចរិយវត្តជាដើមទាំងឡាយណា ដែលទ្រង់អនុញ្ញាតក្នុងទីទាំងឡាយ មានក្រុងរាជគ្រឹះជាដើម បព្វជ្ជាឧបសម្បទា និងឧបជ្ឈាយវត្តទាំងនោះជាដើម ព្រះមានព្រះភាគ ទ្រង់ជល់នូវអភិសម្ពោធិញ្ញាណហើយ ឲ្យសប្តាហ៍៧កន្ទងទៅត្រង់ពោធិមណ្ឌល ទ្រង់ប្រកាសធម្មចក្កក្នុងក្រុងពារាណសី ហើយទ្រង់យាងជល់ទីកន្លែងនេះដោយលំដាប់ ទ្រង់បញ្ញត្តហើយ ព្រោះរឿង

นោះៗ ។

ក្នុងបទទាំងនោះ បទថា **ឧរុវេលាយំ** *បានដល់ ទីដែនធំ ។ អធិប្បាយ ថា ត្រង់គំនរខ្សាច់ធំ ។ ប្រការមួយទៀត ដីខ្សាច់ ហៅថា ឧរុ ទេត្តខណ្ឌ ហៅថា វេលា ។ ដូច្នេះគប្បីឃើញន័យក្នុងបទនេះ យ៉ាងនេះថា ខ្សាច់ដែល គេជញ្ជូនមក ព្រោះហេតុដែលរំលងព្រំដែន ឈ្មោះឧរុវេលា ។*

បានឮថា ក្នុងអតីតសម័យ កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង កុល-បុត្រមួយម៉ឺននាក់ បួសជាតាបសនៅត្រង់ប្រទេសនោះ ថ្ងៃមួយ បានប្រជុំគ្នា ធ្វើកតិការត្តថា ធម្មតាកាយកម្ម វចីកម្ម ជារបស់ប្រាកដដល់អ្នកដទៃបាន ឯ មនោកម្ម មិនប្រាកដឡើយ ព្រោះដូច្នោះ អ្នកណាមានកាមវិតក្កក្តី ព្យាបាទ-វិតក្កក្តី វិហិង្សាវិតក្កក្តី បុគ្គលដទៃដែលនឹងចោទបុគ្គលនោះ រមែងមិនមាន បុគ្គលនោះត្រូវចោទខ្លួនឯងដោយខ្លួនឯង ហើយយកកញ្ចប់នៃស្មៅឈើជញ្ជូន ខ្សាច់មកវេយក្នុងទីនេះ ដោយតាំងចិត្តថា នេះជាទណ្ឌកម្ម ចាប់ពីពេលនោះ មក អ្នកណាត្រិះរិះក្នុងវិតក្កដែលមានសភាពដូច្នោះ អ្នកនោះរមែងប្រើកញ្ចប់ ស្មៅឈើជញ្ជូនខ្សាច់មកវេយទីនោះ ។ ដោយប្រការយ៉ាងនេះ ទើបគំនរ ខ្សាច់ក្នុងទីនោះធំឡើងដោយលំដាប់ ។ ក្រោយមក ទើបប្រជុំជនខាងក្រោយ ព័ទ្ធបង់ជុំវិញគំនរខ្សាច់ធំនោះ ធ្វើជាចេតិយដ្ឋាន ។

ខ្ញុំសំដៅយកគំនរខ្សាច់នោះ ពោលថា បទថា **ឧរុវេលាយំ** *បានដល់ ទួលធំ អធិប្បាយថា មានគំនរខ្សាច់ធំ ។ សំដៅយកគំនរខ្សាច់នោះឯង ពោល ថា ប្រការមួយទៀត ខ្សាច់ហៅថា ឧរុ ទីព្រំដែន ហៅថា វេលា ។ គប្បី*

ឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ខ្សាច់ដែលគេជញ្ជូនមក ព្រោះហេតុដែលកន្ទងដែនកំណត់ ឈ្មោះថា ឧរុវេលា ។

បទថា **ពោធិរុក្ខមូលេ** *សេចក្តីថា ញាណក្នុងមគ្គ ๔ ហៅថាពោធិញ្ញាណ ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិញ្ញាណនោះត្រង់ដើមឈើនេះ ព្រោះដូច្នោះ ទើបដើមឈើអនុលោមបាននាមថា ពោធិព្រឹក្ស ត្រង់គល់នៃពោធិព្រឹក្សនោះ ឈ្មោះថា* **ពោធិរុក្ខមូល ។**

បទថា **បឋមាភិសម្ពុទ្ធោ** *បានដល់ ត្រាស់ដឹងជំបូង អធិប្បាយថា ជាអ្នកត្រាស់ដឹងព្រមសម្រេចជាបឋមគ្រប់យ៉ាងនោះឯង ។*

បទថា **ឯកបល្លង្កេន** *សេចក្តីថា ប្រថាប់គង់ដោយបល្ល័ង្ក (ព្រះភ្នែន) តែមួយ តាមដែលទ្រង់ពែនហើយប៉ុណ្ណោះ ទ្រង់មិនក្រោកឡើងសូម្បីតែម្តង ។*

បទថា **វិមុត្តិសុខបដិសំវេទី** *សេចក្តីថា សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។*

បទថា **បដិច្ចសមុប្បាទំ** *បានដល់ បច្ចយាការ ។ ពិតហើយ បច្ចយាការលោកហៅថា បដិច្ចសមុប្បាទ ព្រោះអត្ថវិគ្គហៈថា អាស្រ័យគ្នានិងគ្នា ញុំងធម៌ដែលជាប់ទាក់ទងគ្នាឲ្យកើតឡើង ។ សេចក្តីសង្ខេបក្នុងបទថា* **បដិច្ច-សមុប្បាទំ** *នេះ ប៉ុណ្ណោះ ។ ឯសេចក្តីពិស្តារ អ្នកប្រាថ្នាវិនិច្ឆ័យដែលដល់ព្រមដោយអាការទាំងពួង គប្បីកាន់យកក្នុងវិសុទ្ធិមគ្គ និងមហាបករណ៍ ។*

បទថា **អនុលោមបដិលោមំ** *មានវិគ្គហៈថា តាមលំដាប់ផង បញ្ច្រាស់*

លំដាប់ផង ឈ្មោះថា ទាំងតាមលំដាប់ និងបញ្ច្រាស់លំដាប់ ។ អ្នកសិក្សាគប្បីឃើញអត្ថក្នុងបទយ៉ាងនេះឯងថា ក្នុងអនុលោម និងបដិលោមទាំង ២ នោះ បច្ចយាការ មានអវិជ្ជាជាដើម ដែលលោកពោលដោយនយថា **អវិជ្ជាបច្ចយា សង្ខារា** *ដូច្នេះ ហៅថា អនុលោម ព្រោះធ្វើកិច្ចដែលខ្លួនគប្បីធ្វើ ។ បច្ចយាការនោះឯង ដែលលោកពោលដោយនយជាដើមថា* **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** *ដូច្នេះ កាលរលត់ព្រោះនិរោធ គឺមិនកើតទៀង រមែងមិនធ្វើកិច្ចនោះ ព្រោះដូច្នោះ ទើបហៅថា បដិលោម ព្រោះមិនធ្វើកិច្ចនោះ ម្យ៉ាងទៀត បច្ចយាការដែលពោលហើយតាមនយមុននោះឯង ប្រព្រឹត្តទៅតាមបវត្តិហេតុ ក្រៅអំពីនេះ ប្រព្រឹត្តទៅបញ្ច្រាស់បវត្តិហេតុ ។ ភាពជាអនុលោម និងបដិលោមក្នុងបច្ចយាការនេះ មិនទាន់ត្រូវដោយអត្ថជទៃអំពីនេះ ព្រោះលោកមិនបានពោលតាំងអំពីដើម រហូតដល់ចុង និងតាំងអំពីចុងរហូតដល់ដើម ។*

បទថា **មនសាកាសិ** *កាត់បទជា* **មនសិ អកាសិ** *ប្រែថា បានធ្វើក្នុងព្រះទ័យក្នុងអនុលោម និងបដិលោមទាំង ២ នោះ ព្រះមានព្រះភាគ ទ្រង់បានធ្វើក្នុងព្រះទ័យដោយអនុលោម ដោយប្រការណា ដើម្បីសម្តែងប្រការនេះជាមុន ទើបព្រះធម្មសង្គាហកាចារ្យពោលបទថា* **អវិជ្ជាបច្ចយា សង្ខារា** *ជាដើម ។ ក្នុងបទនោះ អ្នកសិក្សាគប្បីជ្រាបអត្ថក្នុងទីទាំងពួងដោយនយនេះថា អវិជ្ជានោះផង ជាបច្ច័យផង ព្រោះដូច្នោះ ឈ្មោះថា អវិជ្ជាជាបច្ច័យសង្ខារទាំងឡាយ រមែងកើតព្រមព្រោះអវិជ្ជាជាបច្ច័យនោះ សេចក្តីសង្ខេប*

ក្នុងបទថា **មនសាកាសិ** *នេះ មានប្រមាណប៉ុណ្ណេះ ។ ឯបុគ្គលត្រូវការសេចក្តីវិនិច្ឆ័យពិស្តារ ដែលជល់ព្រមដោយអាការគ្រប់យ៉ាង គប្បីកាន់យកអំពីវិសុទ្ធិមគ្គ សម្មោហវិនោទនី និងអដ្ឋកថានៃមហាវិភង្គចុះ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើព្រះហឫទ័យដោយបដិលោម ដោយប្រការណា ដើម្បីសម្តែងប្រការនេះ ទើបទ្រង់ពោលពាក្យថា* **អវិជ្ជាយ ត្វេវ អសេសវិរាគ-និរោធា សង្ខារនិរោធោ** *ជាដើម ។*

ក្នុងពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បទថា **អវិជ្ជាយ ត្វេវ** *កាត់បទជា* **អវិជ្ជាយ តុ ឃវ ។**

បទថា **អសេសវិរាគនិរោធា** *សេចក្តីថា ព្រោះរលត់មិនមានសេសសល់ដោយមគ្គ ពោល គឺវិរាគៈ ។*

បទថា **សង្ខារនិរោធោ** *បានជល់ ការរលត់ គឺការមិនកើតឡើងនៃសង្ខារទាំងឡាយ ។ ដើម្បីសម្តែងថា ការរលត់នៃវិញ្ញាណមាន ក៏ព្រោះរលត់នៃសង្ខារទាំងឡាយ ដែលរលត់ទៅហើយយ៉ាងនោះ ធម៌ទាំងឡាយមាននាមរូបជាដើម ទោះជាធម៌ដែលរលត់ល្អហើយនោះឯង ក៏ព្រោះរលត់នៃធម៌ទាំងឡាយ មានវិញ្ញាណជាដើម ទើបលោកពោលពាក្យថា* **សង្ខារនិរោធោ វិញ្ញាណនិរោធោ** *ជាដើម ហើយពោលពាក្យថា គំនរទុក្ខទាំងអស់នេះ ឈ្មោះថា រលត់ទៅដោយប្រការយ៉ាងនេះ ។*

ក្នុងបទទាំងនោះ បទថា **កេវលស្ស** *បានជល់ ទាំងមូល ឬ សុទ្ធ សេចក្តីថា ព្រោសចាកសត្វ ។*

បទថា **ទុក្ខក្ខន្ធស្ស** *បានដល់ គំនរទុក្ខ ។*

ពីរបទថា **ឯវមេតស្ស ខោ** *សេចក្តីថា ការមិនកើតរមែងមាន ។*

ពីរបទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា អត្ថនេះឯណា ដែលព្រះធម្ម-សង្គាហកាចារ្យពោលថា គំនរទុក្ខ មានសង្ខារជាដើម ជាការកើតឡើងដោយអំណាចនៃបច្ច័យ មានអវិជ្ជាជាដើម និងឈ្មោះថារលត់ទៅដោយអំណាចការរលត់នៃបច្ច័យ មានអវិជ្ជាជាដើម ដូច្នេះ ទ្រង់ជ្រាបអត្ថនោះដោយអាការទាំងពួង ។ ពីរបទថា* **តាយំ វេលាយំ** *បានដល់ ក្នុងវេលាដែលទ្រង់ជ្រាបអត្ថនោះៗ ។*

បទថា **ឥមំ ឧទានំ ឧទានេសិ** *សេចក្តីថា ទ្រង់បន្លឺឧទាន មានញាណដែលសម្បយុត្តដោយសោមនស្សជាដែនកើត សេចក្តីថា* **យទា ហវេ ចាតុ-ភវន្តិ** *ជាដើមនេះ ដែលសម្តែងអានុភាពនៃការដែលទ្រង់ជ្រាបហេតុ និងធម៌ដែលកើតអំពីហេតុ ក្នុងអត្ថដែលទ្រង់ជ្រាបហើយនោះ មានពាក្យអធិប្បាយថា ទ្រង់បន្លឺព្រះវាចាសម្តែងការត្រេកអរ ។*

អត្ថនៃឧទាននោះថា បទថា **យទា ហវេ** *បានដល់ ក្នុងកាលណា ។*

បទថា **ចាតុភវន្តិ** *បានដល់ រមែងកើត ។ ពោធិបក្ខិយធម៌ដែលឲ្យសម្រេច ការត្រាស់ដឹងបច្ចយាការដោយអនុលោម ឈ្មោះថា ធម៌ ។*

ម្យ៉ាងទៀត បទថា **ចាតុភវន្តិ** *សេចក្តីថា ជាក់ច្បាស់ គឺជារបស់ជាក់ច្បាស់ ប្រាកដដោយអំណាចការត្រាស់ដឹង ។ ធម៌ គឺអរិយសច្ច ៤ ឈ្មោះថា ធម៌ ។ សេចក្តីព្យាយាម ហៅថា* **អាតាប** *ព្រោះអត្ថថា ដុតកិលេស*

ឲ្យក្តៅ ។ បទថា **អាតាបិនោ** *បានដល់ មានសេចក្តីព្យាយាម ដែលបុគ្គលគប្បីតាំងទុកប្រពៃ ។ បទថា* **ឈាយតោ** *សេចក្តីថា ដែលសម្លឹងដោយឈាន ២ គឺដោយការកំណត់ គឺអារម្មណូបនិជ្ឈាន ១ ដោយការកំណត់ គឺលក្ខណូបនិជ្ឈាន ១ ។ បទថា* **ព្រាហ្មណស្ស** *បានដល់ ព្រះខីណាស្រពដែលបន្សាត់បាបហើយ ។*

ច្រើនបទថា **អថស្ស កង្ខា វបយន្តិ** *សេចក្តីថា កាលនោះសេចក្តីសង្ស័យរបស់ព្រាហ្មណ៍នោះ គឺដែលមានធម៌ច្រោកដហើយយ៉ាងនោះ រមែងអស់ទៅ ។*

បទថា **សញ្ញា** *សេចក្តីថា ការសង្ស័យក្នុងបច្ចយាការដែលលោកពោលទុកដោយនយជាដើមថា បើគេសួរថា បពិត្រព្រះអង្គដ៏ចម្រើន នរណាវិញហ្ន៎ តែងពាល់ត្រូវខ្ញុំ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះ មិនត្រូវទេ ដូច្នេះ និងដោយនយជាដើមថា កាលគេសួរថា បពិត្រព្រះអង្គដ៏ចម្រើន ជរា និងមរណៈ តើដូចម្តេចហ្ន៎ មួយទៀត ជរា និងមរណៈនេះ ជារបស់អ្នកណា ។ ព្រះមានព្រះភាគត្រាស់តបថា ប្រស្នានេះ មិនត្រូវទេ ដូច្នេះ ។ និងសេចក្តីសង្ស័យ ១៦ យ៉ាងជាដើមថា ក្នុងអតីតកាល អាត្មាអញមានហើយឬហ្ន៎ ដែលមកហើយព្រោះមិនទាន់បានត្រាស់ដឹងបច្ចយាការនោះឯង ទាំងអស់នេះ រមែងអស់ទៅ គឺរមែងប្រាសទៅ រមែងរលត់ទៅ ។ ព្រោះហេតុអ្វី ព្រោះជ្រាបធម៌ ព្រមទាំងហេតុ ។ អធិប្បាយថា ព្រោះជ្រាប គឺជ្រាបច្បាស់ត្រាស់ដឹងធម៌ គឺកងទុក្ខទាំងមូល មានសង្ខារជាដើមនេះ មួយអន្ទើដោយ*

ហេតុ មានអវិជ្ជាជាដើម ។

[๒] *គប្បីជ្រាបក្នុងទុតិយវារៈដូច្នេះ បើបទថា* **ឥមំ ឧធានំ ឧធានេសិ** *សេចក្តីថា ទ្រង់បន្ទឺឧទានមានប្រការដូចពោលហើយនេះ ដែលសម្តែងអានុភាពនៃការត្រាស់ដឹងការអស់បច្ច័យ ពោល គឺនិព្វាន ដែលប្រាកដហើយ យ៉ាងនេះថា* **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** *ក្នុងអត្ថដែលទ្រង់ជ្រាបហើយនោះ ។*

សេចក្តីសង្ខេបក្នុងឧទាននោះដូចតទៅនេះថា ព្រោះបានដឹង គឺបានជ្រាបច្បាស់ បានត្រាស់ដឹងនិព្វាន ពោល គឺការអស់បច្ច័យទាំងឡាយ កាលណាធម៌ទាំងឡាយ មានប្រការដូចពោលហើយ ប្រាកដដល់ព្រាហ្មណ៍នោះ ជាអ្នកមានព្យាយាមសម្លឹងជានិច្ច កាលនោះ សេចក្តីសង្ស័យគ្រប់យ៉ាងដែលនឹងគប្បីកើតទ្បើង ព្រោះមិនដឹងនិព្វាន រមែងអស់ទៅ ។

[๓] *គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយវារៈថា បើបទថា* **ឥមំ ឧធានំ ឧធានេសិ** *សេចក្តីថា ទ្រង់បន្ទឺឧទានមានប្រការដូចពោលហើយនេះ សុទ្ធសឹងសម្តែងអានុភាពនៃអរិយមគ្គដែលជាហេតុ ទ្រង់ជ្រាបអត្ថ ពោល គឺការកើត និងការរលត់នៃកងទុក្ខនោះ ដោយអំណាចកិច្ច និងដោយធ្វើឲ្យជាអារម្មណ៍ ។*

*សេចក្តីសង្ខេបក្នុងឧទាននោះ ដូចតទៅនេះថា កាលណាធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ ដែលមានព្យាយាមសម្លឹងជានិច្ច កាលនោះ ព្រាហ្មណ៍នោះ រមែងកម្ចាត់សេនាមារ ដោយពោធិបក្ខិយធម៌ ដែលកើតហើយទាំង

នោះផង ដោយអរិយមគ្គជាគ្រឿងប្រាកដនៃចតុសច្ចធម៌ផង ប្រព្រឹត្តទៅ ។ បទថា **វិជ្ឈបយំ តិដ្ឋតិ មារសេនំ** *សេចក្តីថា រមែងកម្ចាត់ គឺផ្ចាញ់ បង្ក្រាបសេនាមារ មានប្រការដូចពោលហើយ ដោយន័យជាដើមថា កាមទាំងឡាយជាសេនាទី ១ របស់អ្នក ដូច្នេះ ប្រព្រឹត្តទៅ ។*

សួរថា កម្ចាត់ដូចម្តេច ឆ្លើយថា ដូចព្រះអាទិត្យញ៉ាំងអាកាសឲ្យភ្លឺដូច្នោះ អធិប្បាយថា ព្រះអាទិត្យកាលរះឡើងហើយ តែងញ៉ាំងអាកាសឲ្យភ្លឺដោយរស្មីរបស់ខ្លួន ឈ្មោះថា កម្ចាត់បង់នូវងងឹត សេចក្តីនេះយ៉ាងណា ព្រាហ្មណ៍នោះ កាលត្រាស់ដឹងសច្ចៈទាំងឡាយ ដោយធម៌ទាំងនោះក្តី ដោយមគ្គនោះឯង ឈ្មោះថា កម្ចាត់សេនាមារបាន សេចក្តីនេះក៏ដូច្នោះ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានក្នុងនិទានទាំង ៣ នេះ ឧទានទី ១ កើតឡើងដោយអំណាចនៃការពិចារណាបច្ចយាការ ឧទានទី ២ កើតឡើងដោយអំណាចការពិចារណាព្រះនិព្វាន ឧទានទី ៣ កើតឡើងដោយអំណាចការពិចារណាមគ្គ ដោយប្រការដូច្នេះ ។

ឯក្នុងឧទាន (គម្ពីរឧទាន) លោកពោលថា ទ្រង់ពិចារណាបដិច្ចសមុប្បាទដោយអនុលោមអស់បឋមយាមនៃរាត្រី ដោយបដិលោមអស់យាមទី ២ ដោយអនុលោម និងបដិលោម អស់យាមទី ៣ ពាក្យនោះ លោកសំដៅយកមនសិការ ដែលព្រះមានព្រះភាគ ទ្រង់ឲ្យកើតឡើងរហូតអស់រាត្រី ដោយទ្រង់តាំងព្រះទ័យថា ស្អែកនេះតថាគត នឹងក្រោកចាកអាសនៈ ព្រោះគ្រប់ ៧ ថ្ងៃ ។ ពិតហើយ គ្រានោះ ព្រះមានព្រះភាគ ទ្រង់បានពិចារណា

ចំណែកមួយៗ ប៉ុណ្ណោះ អស់បឋមយាម និងមជ្ឈិមយាម ដោយអំណាចនៃការជ្រាបច្បាស់នូវបច្ចយាការ និងការសម្រេចការអស់នូវបច្ច័យ ដែលមានអានុភាព ដែលឧទានគាថា ២ ខាងដើមសម្តែងទុក តែក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់បានពិចារណាយ៉ាងនោះ ក្នុងរាត្រីថ្ងៃចាជិបទ ។ ពិតហើយ ក្នុងរាត្រី ១៥ កើត ខែពិសាខ ព្រះមានព្រះភាគ ទ្រង់រឭកបុព្វេនិវាសក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងមជ្ឈិមយាម ទ្រង់ពិចារណាបដិច្ចសមុប្បាទ ដោយអនុលោម និងបដិលោម ក្នុងបច្ឆិមយាម ទ្រង់សម្រេចភាពជាព្រះ-សព្វញ្ញូ ក្នុងខណៈដែលគប្បីពោលថា អរុណនឹងរះឥទ្បូវនេះ ។ អរុណរះក្នុងវេលាជាប់នឹងវេលា ដែលទ្រង់បានសម្រេចភាពជាព្រះសព្វញ្ញូនោះឯង ។ បន្ទាប់អំពីនោះ ព្រះអង្គទ្រង់ឲ្យថ្ងៃនោះកន្លងផុតទៅ ដោយការគង់ពត់ព្រះភ្នែននោះឯង ហើយទ្រង់ពិចារណាយ៉ាងនោះ បន្ទឹឧទាននេះ ក្នុងយាមទាំង ៣ នៃរាត្រីថ្ងៃចាជិបទ ដែលជល់ព្រមហើយ ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាយ៉ាងនោះក្នុងរាត្រីថ្ងៃចាជិបទ ឲ្យថ្ងៃទី ៧ ដែលលោកពោលយ៉ាងនេះថា គង់ប្រថាប់ដោយបល្ល័ង្កមួយ ត្រង់ពោធិវ្រុក្ខមូលអស់ ៧ ថ្ងៃនោះ កន្លងផុតទៅ ត្រង់ពោធិវ្រុក្ខមូលនោះឯង ដោយប្រការដូច្នេះ ។

ពោធិកថា ចប់

អជបាលនិគ្រោធកថា

[๔] លុះថ្ងៃ ๗ កន្លងទៅហើយ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ចេញចាកសមាធិនោះ ហើយទ្រង់ចេញពីមូលព្រះពោធិព្រឹក្ស យាងចូលទៅកាន់ដើមអជបាលនិគ្រោធ លុះចូលទៅដល់ហើយ ទ្រង់គង់ពែនភ្នែនតែមួយបង្គុយអស់ ๗ ថ្ងៃក្រោមម្លប់អជបាលនិគ្រោធព្រឹក្ស[๑] សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។

គ្រានោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើនូវសំឡេងគម្រាមថា ហុំហុំ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏វីកាយមួយអន្ទើដោយព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួរជាទីរីករាយ គួរជាទីរឭកឲ្យសម្រេចហើយក៏ស្ថិតនៅក្នុងកន្លែងដ៏សមគួរ ។ លុះព្រាហ្មណ៍នោះស្ថិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលដែលបានឈ្មោះថា ព្រាហ្មណ៍ ដោយហេតុប៉ុន្មានយ៉ាង ម្យ៉ាងទៀត ធម៌អ្វីខ្លះសម្រាប់ធ្វើបុគ្គលឲ្យជាព្រាហ្មណ៍ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏បន្ទូលនូវឧទានគាថានេះ ក្នុងវេលានោះថា ព្រាហ្មណ៍ណា មានធម៌បណ្តែតចោលហើយ មានសំឡេងគំរាមថា ហុំហុំ លះចោលហើយ មានទឹកមូត់ គឺរាគាទិក្លេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ (គឺមគ្គញ្ញាណទាំង ๔) មានមគ្គព្រហ្មចរិយៈនៅរួចហើយ

๑- ដើមជ្រៃដែលជាទីជ្រកអាស្រ័យ នៃពួកជនអ្នកឃ្វាលពពែ ។

ម្យ៉ាងទៀត ព្រាហ្មណ៍ណាមិនមានគំនរ គឺរាគាទិក្លិសក្នុងអារម្មណ៍បន្តិចបន្តួចក្នុងលោកសន្និវាស ព្រាហ្មណ៍នោះគួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយជម្រិបាន ។

អជបាលនិគ្រោធកថា ចប់

อัฏฐกถา

อชปาลนิโครธกถา

[๔] ในบทว่า **อถ โข ภควา ตสฺสา สมาธิมฺหา วุฏฺฐหิตฺวา พาหิรกมฺหา ยถา อชปาลนิโครเธ เตนุปสงฺกมิ** นี้ อาจารย์ทั้งหลายย่อมวินิจฉัยอย่างนี้ว่า พระผู้มีพระภาคเสด็จออกจากสมาธินั้นแล้ว เสด็จเข้าไปสู่ต้นไทรชื่ออชปาลนิโครธ ในขณะแห่งความคิดเพียงครู่เดียวนั่นเอง ดังในคำที่กล่าวกันว่า บุคคลนี้ ลุกขึ้นแล้วก็เดิน ไม่ใช่มีคำพูดอธิบายอย่างนี้ว่า บุคคลนั้นไม่ยืน ไม่นั่ง ไม่นอน ไม่ไปสู่ที่อื่น ไม่ประกอบการสนทนาปราศรัยกับใครๆ แล้วจึงเดิน แต่ในคำนี้มีอธิบายว่า บุคคลนั้นเดินในขณะหลังแต่เวลาที่ลุกขึ้น บุคคลนั้นไม่ได้เดิน ก็ไม่ใช่ ฯ ก็ความนี้อย่างไร แม้ในคำนี้ก็ควรกล่าวว่า มีคำพูดอธิบายว่า พระผู้มีพระภาคเสด็จออกจากสมาธินั้นแล้ว เสด็จเข้าไปสู่ต้นไทรชื่ออชปาลนิโครธในขณะแห่งความคิดเพียงครู่เดียวนั่นเอง ก็ไม่ใช่ ความจริงในคำนี้มีอธิบายว่า พระผู้มีพระภาคเสด็จออกจากสมาธินั้นแล้ว ไม่ทรงประทับนั่งในขณะหลังแต่เวลาที่เสด็จออก ไม่ได้ประทับนั่ง ก็ไม่ใช่ ฯ

ถามว่า พระผู้มีพระภาคไม่ประทับนั่งตลอดกาลนานๆ ทรงกระทำอย่างไรเล่า ตรัสว่า ทรงให้ล่วงไป ๗ สัปดาห์ ในที่ไม่ไกลต้นโพธิพฤกษ์ ในขณะแห่งความคิดเพียงครู่เดียวนั่นเอง ฯ

ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូច្នេះថា *បានឮថា កាលព្រះមានព្រះ*
ភាគបានត្រាស់ដឹងជាព្រះពុទ្ធហើយ ប្រថាប់គង់ដោយការគង់ពត់ព្រះក្នែន
នោះឯង អស់មួយសប្តាហ៍ ពួកទេវតាខ្លះ កើតសេចក្តីសន្ទិះសង្ស័យឡើងថា
ព្រះមានព្រះភាគ ទ្រង់មិនក្រោកឡើង ធម៌ដែលធ្វើភាពជាព្រះពុទ្ធដទៃ នៅ
មានទៀតទេដឹង លំដាប់នោះ ព្រះមានព្រះភាគ ចេញអំពីសមាបត្តិក្នុងថ្ងៃទី
៨ ទ្រង់ជ្រាបការសង្ស័យនៃពួកទេវតា ដើម្បីកាត់សេចក្តីសង្ស័យ ទើបទ្រង់
ហោះឡើងទៅលើអាកាស សម្តែងយមកប្បាដិហារ្យ កម្ចាត់សេចក្តីសង្ស័យ
របស់ពួកទេវតាទាំងនោះហើយ ប្រថាប់ឈរសម្លឹងមើល ដោយមិនប៉ះប៉ិច
ព្រះនេត្រ នូវរតនបល្ល័ង្ក និងព្រះពោធិព្រឹក្ស ដែលជាទីកន្លែងសម្រេចផល
នៃបារមី ដែលទ្រង់សាងសន្សំមកអស់ ៤ អសង្ខ្យៃ និងមួយសែនកប្ប
ឲ្យ ១ សប្តាហ៍កន្លងផុតទៅត្រង់ទិសឧត្តរ ឆៀងទិសខាងកើតបន្តិច (ទិស
ឦសាន) អំពីរតនបល្ល័ង្ក ទីនោះឈ្មោះថា **អនិមិសចេតិយ ។**

លំដាប់នោះ ទ្រង់យាងចង្ក្រមក្នុងរតនចង្ក្រមដែលលាតសន្ធឹងទៅខាង
មុខ និងខាងក្រោយ *ចន្លោះរតនបល្ល័ង្ក* និងទីដែលទ្រង់ប្រថាប់ឈរ (*អនិមិស*
ចេតិយ) *ញុំងសប្តាហ៍ ១ ឲ្យកន្លងទៅ។ ទីនោះឈ្មោះថា* **រតនចង្កមចេតិយ ។**

បន្ទាប់អំពីនោះ ទេវតាទាំងឡាយ និម្មិតផ្ទះកែវឡើងត្រង់ទិសខាងលិច
ព្រះមានព្រះភាគ ទ្រង់គង់ពត់ក្នែនក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាអភិធម្មបិដក
គឺសមន្តបដ្ឋាន ដែលមានន័យមិនមានទីបំផុតក្នុងអភិធម្មបិដកនោះ ដោយ
ពិស្តារ ញុំងសប្តាហ៍ ១ ឲ្យកន្លងទៅ ។ ទីនោះឈ្មោះថា **រតនឃរចេតិយ ។**

ព្រះមានព្រះភាគ ឲ្យសប្តាហ៍ទី ៤ កន្លងទៅក្នុងបទេសក្បែរៗ ពោធិ-ព្រឹក្សនោះឯង ។ ក្នុងសប្តាហ៍ទី ៥ ទ្រង់ចេញអំពីគល់ពោធិព្រឹក្ស ចូលទៅកាន់ត្រង់ដើមអជបាលនិគ្រោធ ដោយប្រការដូច្នេះ ។

បានឮថា អ្នកចិញ្ចឹមពពែ តែងទៅអង្គុយត្រង់ម្លប់នៃដើមនិគ្រោធនោះ ព្រោះហេតុនោះ ទើបដើមនិគ្រោធនោះ បានឈ្មោះថា **អជបាលនិគ្រោធ** *។*

ពីរបទថា **សត្តាហំ វិមុត្តិសុខប្បដិសំវេទី** *សេចក្តីថា កាលទ្រង់ពិចារណាធម៌ត្រង់ដើមអជបាលនិគ្រោធនោះឯង ឈ្មោះថា ប្រថាប់សោយវិមុត្តិសុខត្រង់ដើមឈើនោះនាទិសខាងកើត អំពីដើមពោធិព្រឹក្ស ។ កាលព្រះមានព្រះភាគប្រថាប់គង់យ៉ាងនោះ ត្រង់ដើមអជបាលនិគ្រោធនោះ ព្រាហ្មណ៍ម្នាក់ បានមកទូលសួរបញ្ហាជាមួយព្រះអង្គ ។ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យពោលបទថា* **អថ ខោ អញ្ញតរោ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **ហុំហុំកជាតិកោ** *សេចក្តីថា បានឮថា ព្រាហ្មណ៍នោះ ឈ្មោះទិដ្ឋមង្គលិក ដើរទន្ទេញថា* **ហឺហឺ** *ដោយការប្រកាន់ខ្លួន និងដោយអំណាចសេចក្តីក្រោធ ព្រោះដូច្នោះ ទើបគេហៅគាត់ថា* **ហុំហុំ-កជាតិព្រាហ្មណ៍** *អាចារ្យខ្លះពោលថា* **ហុហុំកជាតិព្រាហ្មណ៍** *ក៏មាន ។*

ពីរបទថា **ឯតមត្ថំ វិទិត្វា** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាបអត្ថសំខាន់នៃពាក្យដែលគាត់ពោលនោះ ទើបបន្ទឺឧទាននេះក្នុងវេលានោះ ។*

អត្ថនៃឧទាននោះថា ព្រាហ្មណ៍ណា មានបាបធម៌បណ្តែតចោលហើយ មានសំឡេងគំរាមថា **ហុំហុំ** *និងកិលេសដូចទឹកមូត់ជាដើម ព្រោះតម្លៃដែល*

មកប្រកាន់ថា វត្តុដែលឃើញហើយជាមង្គល ប្តេជ្ញាខ្លួនជាព្រាហ្មណ៍ដោយ ហេតុត្រឹមតែជាតិតែម្យ៉ាងក៏ទេ ព្រាហ្មណ៍នោះ ឈ្មោះថា ជាអ្នកមានបាបធម៌ ដែលបន្សាត់ហើយ ព្រោះជាអ្នកបន្សាត់បាបធម៌ចោល ឈ្មោះថា ជាអ្នកមិន មានកិលេសជាគ្រឿងសម្លុតអ្នកដទៃថា **ហឺហឺ** *ព្រោះលះកិលេសជាគ្រឿង សម្លុតអ្នកដទៃថា* **ហឺហឺ** *ចេញបាន ឈ្មោះថា ជាអ្នកមិនមានកិលេសដូចទឹក ចត់ ព្រោះមិនមានកិលេសដូចទឹកចត់ មានរាគៈជាដើម ឈ្មោះថា មានខ្លួន សង្រួមហើយ ព្រោះជាអ្នកមានចិត្តប្រកបដោយការទានុយោគ ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានខ្លួនសង្រួមហើយ ព្រោះជាអ្នកមានចិត្តសង្រួមហើយ ដោយសីលសំវរៈ ឈ្មោះថា ជាអ្នកដល់ត្រើយនៃវេទ ព្រោះជាអ្នកដល់ទីបំផុត នៃវេទទាំងឡាយ ពោលគឺ ចតុមគ្គញ្ញាណ ឬ ព្រោះជាអ្នករៀនចប់ត្រៃវេទ ឈ្មោះថា ជាអ្នកចប់ព្រហ្មចរិយៈហើយ ព្រោះព្រហ្មចរិយៈ គឺ មគ្គ ៤ ដែលខ្លួនបាននៅ សម្រេចហើយ ។*

បាទព្រះគាថាថា **ធម្មេន សោ ព្រហ្មវាទំ វេទេយ្យ** *សេចក្តីថា កិលេស ជាគ្រឿងពុះកញ្ជ្រោលឡើង ៥ យ៉ាង គឺរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ព្រោះអារម្មណ៍បន្តិចបន្តួច គឺសូម្បីព្រោះអារម្មណ៍ណាមួយ ក្នុងលោកទាំង មូលមិនមានដល់ព្រាហ្មណ៍ណា ព្រាហ្មណ៍នោះពោលដោយធម៌ គួរពោល វាទៈនេះថា អាត្មាអញជាព្រាហ្មណ៍ ។*

អដ្ឋកថាសិនិគ្រោធកថា ចប់

មុចលិន្ទកថា

[៥] លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកចាកសមាធិនោះ ហើយទ្រង់ចេញអំពីមួប់អជបាលនិគ្រោធព្រឹក្ស យ៉ាងចូលទៅកាន់ដើមរាំង លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្នែនតែមួយបង្គុយអស់ ៧ ថ្ងៃ ក្រោមមួប់រាំង សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។

សម័យនោះឯង មហាមេឃពុំជូកាល ក៏បណ្តាលឡើងជាភ្លៀង ។ មានភ្លៀងរលឹមអស់ ៧ ថ្ងៃបណ្តាលឲ្យអាប់ពន្លឺព្រះអាទិត្យដោយអំណាចខ្យល់ត្រជាក់ ។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួន ហើយពេនព័ន្ធព្រះកាយព្រះដ៏មានព្រះភាគ ៧ ជុំដោយភ្នែន (របស់ខ្លួន) ហើយលើកពពារដ៏ធំចាំងពីខាងលើព្រះសីរ្សព្រះដ៏មានព្រះភាគ ហើយស្ថិតនៅដោយគិតថា រឯាកុំបីបៀតបៀនព្រះដ៏មានព្រះភាគ ក្តៅក៏កុំបីបៀតបៀនព្រះដ៏មានព្រះភាគ សម្ងួស្ស រជាម មូស ខ្យល់ កម្តៅថ្ងៃ ពស់តូចពស់ធំក៏កុំបីបៀតបៀនព្រះដ៏មានព្រះភាគឡើយ ។ លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ មុចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃស្រឡះហើយ ក៏រំសាយភ្នែនចេញចាកព្រះកាយព្រះដ៏មានព្រះភាគ ហើយប្រែកេទរបស់ខ្លួន និម្មិតជាកេទមាណព (មនុស្សកំលោះ) ឈរប្រណម្យអញ្ជលី នមស្ការព្រះដ៏មានព្រះភាគពីខាងទីចំពោះព្រះភក្ត្រព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីនេះហើយ ក៏បន្ទឺនូវឧទានគាថាក្នុងវេលានោះថា សេចក្តីស្ងាត់

ចាកកិលេសរបស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើតសេចក្តីសុខ សេចក្តីមិនព្យាបាទ និងសេចក្តីសង្រួមមិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក សេចក្តីណាយចាកវាគៈ និងការប្រព្រឹត្តកន្ទងកាមទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក កិរិយាកម្ចាត់បង់នូវអស្មិមានៈ កិរិយាកម្ចាត់បង់នូវអស្មិមានៈនុ៎ះ ជាសុខយ៉ាងក្រៃលែង ។

មុចលិន្ទកថា ចប់

อัฏฐกถา

มุจลินทกถา

[๕] *ពពកដែលកើតឡើងក្នុងកាលមិនទាន់ដល់រដូវភ្លៀង ឈ្មោះថា អកាលមេឃ (ភ្លៀងពុំជូកាល) ឯពពកនេះកើតឡើងក្នុងខែខាងចុងនៃរដូវក្តៅ ។*

បទថា **សត្តាហវទ្ធលិកា** *សេចក្តីថា កាលពពកនោះកើតឡើងហើយ ក៏មានភ្លៀងធ្លាក់ជោកជាំអស់ ๗ ថ្ងៃ ។*

បទថា **សីតវាតទុទ្ទិនី** *សេចក្តីថា ភ្លៀងធ្លាក់ ๗ ថ្ងៃនោះ បានឈ្មោះថា ភ្លៀងលាយខ្យល់ត្រជាក់ ព្រោះថា ថ្ងៃដែលខ្យល់ត្រជាក់លាយគ្រាប់ភ្លៀងបក់ផាត់ទៅដោយជុំវិញពាល់ត្រូវហើយ ។*

ច្រើនបទថា **អថ ខោ មុចលិន្ទោ នាគរាជា** *សេចក្តីថា ស្តេចនាគមានអានុភាពធំ កើតឡើងត្រង់ស្រះបោក្ខរណី ជិតដើមរាំងអន្ទក់នោះឯង ។*

ច្រើនបទថា **សត្តក្ខត្តុំ ភោគេហិ បរិក្ខិបិត្វា** *សេចក្តីថា កាលស្តេចនាគព័ទ្ធជុំវិញព្រះកាយ ដោយរង្វេល ๗ ជុំ បើកពពារធំខាងលើព្រះសីសៈយ៉ាងនោះ ខាងក្នុងនៃរង្វេលរបស់ស្តេចនាគនោះ មានប្រមាណប៉ុនបន្ទប់ក្នុងលោហប្រាសាទ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគហាក់ដូចជាប្រថាប់គង់ក្នុងប្រាសាទដែលមិនមានខ្យល់ មានទ្វារ និងបង្អួចបិទ ។*

បទថា **មា ភគវន្តំ សីតំ** *ជាដើម សម្តែងហេតុដែលស្តេចនាគនោះធ្វើយ៉ាងនោះ ។ សេចក្តីពិត ស្តេចនាគនោះបានធ្វើយ៉ាងនោះ ដោយតាំងចិត្ត*

ថា រឯាកុំបីបៀតបៀនព្រះមានព្រះភាគឡើយ កម្ពៅកុំបីបៀតបៀនព្រះមានព្រះភាគ និងសម្ងសរ្ស មានរបាមជាដើម កុំបីបៀតបៀនព្រះមានព្រះភាគ ឯការពិត កាលមានភ្លៀងធ្លាក់ជោកជាំអស់ ៧ ថ្ងៃក្នុងទីនោះ មិនមានកម្ពៅឡើយ ។ សូម្បីយ៉ាងនោះ ក៏សមគួរដែលស្តេចនាគនោះនឹងគិតយ៉ាងនេះថា បើពពកបាត់ទៅក្នុងចន្លោះៗ ការក្តៅគង់មាន សូម្បីការក្តៅនោះ កុំបីបៀតបៀនព្រះអង្គឡើយ ។

បទថា **វិទ្ធំ** *បានដល់ វិនាសហើយ អធិប្បាយថា ជារបស់មានធ្លាយព្រោះអស់ពពក ។ បទថា* **វិគតវលាហកំ** *បានដល់ ប្រាសចាកពពក ។ បទថា* **នភំ** *បានដល់ អាកាស ។ បទថា* **សកវណ្ណំ** *បានដល់ រូបរបស់ខ្លួន ។ ពីរបទថា* **សុខោ វិវេកោ** *សេចក្តីថា ឧបធិវិវេក ពោលគឺ ព្រះ-និព្វានជាសុខ ។ បទថា* **តុដ្ឋស្ស** *សេចក្តីថា អ្នកសន្តោសដោយការត្រេកអរក្នុងចតុមគ្គញ្ញាណ ។ បទថា* **សុតធម្មស្ស** *បានដល់ បុគ្គលមានធម៌ប្រាកដហើយ ។*

បទថា **បស្សតោ** *សេចក្តីថា ជាអ្នកឃើញនូវវិវេកនោះផង ធម៌ណាមួយ ដែលគប្បីឃើញបានទាំងអស់ផង ដោយភ្នែក គឺបញ្ញា ដែលបានសម្រេចដោយកម្លាំងសេចក្តីព្យាយាមរបស់ខ្លួន ។*

ការមិនខឹងក្រោធគ្នានិងគ្នា ឈ្មោះថា ការមិនបៀតបៀន ។

ធម៌ចំណែកខាងដើមនៃមេត្តា ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទថា ការមិនបៀតបៀននោះ ។

ពីរបទថា **ចาณาภูเตสุ สญฺญโมา** *សេចក្តីថា ការសង្រួមក្នុងសត្វទាំងឡាយ អធិប្បាយថា ការមិនបៀតបៀនគ្នា ជាសេចក្តីសុខ ។*

ធម៌ជាចំណែកខាងដើមនៃកុណា ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទថា ការសង្រួមនោះ ។

បាទគាថាថា **สุขา วิราคตา โลเกេ** *សេចក្តីថា ការប្រាសចាកតម្រេក ក៏រាប់ថា ជាសេចក្តីសុខ ។*

សួរថា ការប្រាសចាកតម្រេកដូចម្តេច ឆ្លើយថា គឺការកន្ទងបង់នូវកាមទាំងឡាយ អធិប្បាយថា ការប្រាសចាកតម្រេកណា ដែលលោកហៅថា ការកន្ទងបង់នូវកាមទាំងឡាយ សូម្បីការប្រាសចាកតម្រេកនោះ ក៏ចាត់ជាសេចក្តីសុខ ។ អនាគាមិមគ្គ ព្រះមានព្រះភាគត្រាស់ដោយបទថា ការប្រាសចាកតម្រេកនោះ ។

ឯព្រះអរហត្ត ព្រះមានព្រះភាគត្រាស់ដោយពាក្យនេះថា ការកម្ចាត់បង់អស្មិមានៈ ។ ពិតហើយ ព្រះអរហត្ត លោកពោលថា ជាការកម្ចាត់ដោយរម្ងាប់អស្មិមានៈ ។ ដែលឈ្មោះថា សុខដទៃអំពីអរហត្តនេះមិនមាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា សេចក្តីនេះឯងជាសុខក្រៃលែង ។

មុខលិខនកថា ចប់

រាជាយតនកថា

[៦] លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ ព្រះដ៏មានជោគ ទ្រង់ក្រោកចេញចាកសមាធិនោះហើយ យាងចេញពីម្លប់ដើមរាំង ហើយយាងចូលទៅកាន់ដើមរាជាយតនៈ (ដើមកែស) លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្នែនតែមួយបង្គុយអស់ ៧ ថ្ងៃក្រោមម្លប់ដើមរាជាយតនៈ ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូនទឹងគ្នាបង្កើត) ឈ្មោះតបុស្សៈ ១ ភល្លិកៈ ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញអំពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ ។ គ្រានោះ មានទេវតាជាញាតិសាលោហិតរបស់តបុស្សៈ និងភល្លិកពាណិជ បាននិយាយពាក្យនេះនឹងតបុស្សៈ ភល្លិក-ពាណិជថា ម្នាលគ្នាយើង ព្រះដ៏មានព្រះភាគអង្គនេះ ទើបនឹងបានត្រាស់ជាដំបូង ឥឡូវព្រះអង្គគង់នៅក្រោមម្លប់រាជាយតនៈ (ឯណោះ) អ្នកទាំង-ឡាយ គួរចូលទៅបូជាព្រះដ៏មានព្រះភាគអង្គនោះដោយសដូវផង់ និងសដូវដុំចុះ ការបូជានោះនឹងបានជាប្រយោជន៍ នឹងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ តបុស្សៈ និងភល្លិកពាណិជក៏នាំយកនូវសដូវផង់ និងសដូវដុំ ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងកន្លែងដ៏សមគួរ ។ លុះតបុស្សៈ និងភល្លិកពាណិជស្ថិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំរបស់យើងខ្ញុំ ព្រោះថា ការទទួលនឹងបានជាប្រយោជន៍

និងសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលយូរអង្វែង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ធម្មតាព្រះតថាគតទាំងឡាយ មិនដែលទទួល (អាមិសៈ) ផ្ទាល់នឹងដៃឡើយ បើដូច្នេះ តើតថាគតគួរទទួលនូវសដូវផង់ និងសដូវដុំដោយវត្តអ្វីហ្ន៎ ។ គ្រានោះ មហារាជ[1] ទាំង ៤ ទ្រង់ជ្រាបព្រះតម្រិះរបស់ព្រះដ៏មានព្រះភាគ (ដោយចិត្តរបស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ ៤ អំពីទិសទាំង ៤ បង្អោនចូលមកថ្វាយព្រះដ៏មានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទទួលនូវសដូវផង់ និងសដូវដុំដោយបាត្រនេះចុះ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនូវសដូវផង់ និងសដូវដុំ ដោយបាត្រថ្មកែវទាំងឡាយដ៏មានតម្លៃច្រើន លុះទទួលស្រេចហើយ ក៏ទ្រង់សោយ (ក្នុងពេលនោះ) ។ គ្រានោះឯងតបុស្សៈ និងភល្លិកពាណិជ បាននិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះសូមដល់នូវព្រះដ៏មានព្រះភាគ និងព្រះធម៌ជាទីរឭក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំទាំង-ឡាយថាជាឧបាសក បានដល់នូវទីរឭកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតរៀងទៅ ។ ក៏ឯពាណិជទាំងពីរនាក់នោះបានឈ្មោះបញ្ញត្តិថា ទ្វេវាចិក-ឧបាសក[2] ជាដំបូងក្នុងលោក ។

រាជាយតនកថា ចប់

១- លោកបាលទេវបុត្តទាំង ៤ ដែលជាស្តេចធំក្នុងស្ថានសួគ៌ឈ្មោះចាតុម្មហារាជិកៈ ។ ២- ឧបាសកបានបពោធញ្ញាចាប្តេជ្ញាខ្លួនយកព្រះពុទ្ធ និងព្រះធម៌ទាំងពីរ ជាទីពឹងទីរឭក ព្រោះក្នុងពេលនោះ មិនទាន់មានព្រះសង្ឃនៅឡើយ ។

อัฏฐกถา

ราชายตนกถา

[๖] បទថា **មុចលិន្ទមូលេ** បានដល់ ចាកគល់រាំងអន្ទក់ដែលតាំងនៅទិសខាងកើតអំពីមហាពោធិ៍ ។

បទថា **រាជាយតនំ** សេចក្តីថា ទ្រង់ចូលទៅកាន់គល់កែសដែលតាំងនៅទិសទក្សិណ ។

បទថា **តេន ខោ បន សមយេន** មានពាក្យសួរថា ដោយសម័យណា ឆ្លើយថា កាលព្រះមានព្រះភាគ ប្រថាប់ដោយការគង់ពត់ព្រះក្នែងតែម្យ៉ាង អស់ ๗ ថ្ងៃត្រង់គល់កែស សក្កទេវរាជទ្រង់ជ្រាបថា ត្រូវមានកិច្ចទាក់ទងដោយព្រះក្រយាហារ ទើបទ្រង់បង្អោនថ្វាយនូវផ្លែសម៉ ជាព្រះឱសថក្នុងវេលាអរុណរះ ក្នុងថ្ងៃដែលទ្រង់ចេញអំពីសមាធិនោះឯង ។ ព្រះមានព្រះភាគ ទ្រង់សោយផ្លែសម៉ឱសថនោះ លុះសោយស្រេចប៉ុណ្ណោះ ក៏មានកិច្ចទាក់ទងដោយព្រះសរីរៈ សក្កទេវរាជបានថ្វាយទឹកខ្ពុរព្រះឱស្ឋហើយ ។ ព្រះមានព្រះភាគទ្រង់ខ្ពុរព្រះឱស្ឋហើយ ប្រថាប់គង់ត្រង់គល់ឈើនោះឯង កាលព្រះមានព្រះភាគប្រថាប់គង់ក្នុងកាលអរុណរះហើយ ដោយប្រការយ៉ាងនោះ ដោយសម័យនោះឯង ។

ពីរបទថា **តបុស្សភល្លិកា វាណិជា** បានដល់ ពាណិជ ๒ នាក់បងប្អូន គឺតបុស្សៈ កល្លិកៈ ๑ ។ បទថា **ឧក្កលា** បានដល់ អំពីឧក្កលជនបទ ។

ពីរបទថា **តំ បទេសំ** សេចក្តីថា កាន់ប្រទេសដែលទ្រង់គង់របស់ព្រះមានព្រះភាគ ។

សួរថា ព្រះមានព្រះភាគ ទ្រង់នៅក្នុងបទេសណា ឆ្លើយថា ក្នុងមជ្ឈិមប្រទេស ។ ព្រោះដូច្នោះ ក្នុងពាក្យនេះ ទើបមានអត្ថដូចពាណិជ ២ នាក់នោះដែលជាអ្នកដើរផ្លូវឆ្ងាយ ដើម្បីទៅកាន់មជ្ឈិមប្រទេស ។

ពីរបទថា **ញាតិសាលោហិតា ទេវតា** *បានដល់ ទេវតាដែលធ្លាប់ជាញាតិរបស់ពាណិជ ២ នាក់នោះ ។*

ពីរបទថា **ឯតទវោច** *សេចក្តីថា បានឮថា ទេវតានោះបានបណ្តាលឲ្យរនេះទាំងអស់របស់ពាណិជនោះឈប់ ។ លំដាប់នោះ ពាណិជទាំង ២ មកពិចារណាមើលថា នេះជាហេតុអ្វីហ្ន៎ ទើបបានធ្វើពលិកម្មដល់ទេវតាដែលថែរក្សាផ្លូវទាំងឡាយ ។ ក្នុងវេលាធ្វើពលិកម្មនៃពាណិជនោះ ទេវតានោះសម្តែងកាយឲ្យឃើញ ហើយបានពោលពាក្យនេះ ។*

ពីរបទថា **មន្ថេន ច មធុបិណ្ឌិកាយ ច** *បានដល់ សដ្ឋូវផង់ និងសដ្ឋូវដុំ ផ្សំដោយសប្បិ ទឹកឃ្មុំ និងស្ករជាដើម ។*

បទថា **បដិមានេថ** *បានដល់ ចូរបូជា ។*

ពីរបទថា **តំ ហោ** *សេចក្តីថា ការបូជានោះនឹងមានប្រយោជន៍ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរ ។*

ពីរបទថា **យំ អម្ហាកំ** *សេចក្តីថា ការទទួលណានឹងគប្បីមានប្រយោជន៍ដើម្បីសេចក្តីសុខដល់ពួកខ្ញុំព្រះអង្គអស់កាលយូរ ។*

ពីរបទថា **ភគវតោ ឯតទហោសិ** *សេចក្តីថា បានឮថា ជាត្រណារបស់ព្រះអង្គមានក្នុងវេលាទ្រង់ប្រកបសេចក្តីព្យាយាម ជាត្រនោះបានបាត់ទៅ*

តាំងពីកាលនាងសុជាតាមកថ្វាយមធុបាយាសម្ល៉ះ ។ ព្រោះហេតុនោះ ទើប ព្រះអង្គទ្រង់មានសេចក្តីរំពឹងនេះថា ជាត្រារបស់តថាគតមិនមាន ឯព្រះតថាគត ទាំងឡាយអង្គមុនៗ ទ្រង់មិនទទួលដោយព្រះហស្តទេឡើយ តថាគតគប្បី ទទួលសដូវផង់ និងសដូវដុំ ផ្សំដោយទឹកឃ្មុំនេះដោយអ្វីហ្ន៎ ។

បទថា **បរิវิតกฺกมญฺญาย** *សេចក្តីថា ក្រយាហារដែលនាងសុជាតា ថ្វាយដល់ព្រះមានព្រះភាគក្នុងកាលមុននេះ គង់នៅដោយអំណាចដែលចិញ្ចឹម បីបាច់ឱជាទុក ការឃ្លាន ការស្រេក ភាពជាអ្នកមានការចុកពោះយស្រពន់ មិនមានអស់កាលប្រមាណប៉ុណ្ណោះ ឥឡូវនេះ ការរំពឹងដោយនយជាដើមថា* **ฉ เม ตถาคตา** *បានកើតឡើង ព្រោះព្រះអង្គប្រាថ្នាទទួលព្រះក្រយាហារ ។ ជ្រាបការរំពឹងក្នុងព្រះទ័យរបស់ព្រះមានព្រះភាគ ដែលកើតឡើងយ៉ាងនោះ ដោយចិត្តរបស់ខ្លួន ។*

បទថា **จตุទฺทิสา** *គឺអំពីទិសទាំង ៤ ។*

ពីរបទថា **เสลมเย ปตฺเต** *បានដល់ ជាត្រដែលសម្រេចដោយសិលា មានពណ៌ដូចសណ្តែកបាយ ។ ព្រះមានព្រះភាគ ទ្រង់ទទួលជាត្រនេះឯង ។ ពាក្យថា ជាត្រសម្រេចដោយសិលា លោកពោលសំដៅយកជាត្រទាំងនោះ ។ ស្តេចមហារាជទាំង ៤ បានបង្ហោនថ្វាយជាត្រសម្រេចដោយកែវឥន្ទនិលមុន ។ ព្រះមានព្រះភាគទ្រង់មិនទទួលជាត្រទាំងនោះ លំដាប់នោះ ទើបបង្ហោនថ្វាយ ជាត្រសម្រេចដោយសិលា មានពណ៌ដូចសណ្តែកបាយទាំង ៤ ជាត្រនេះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលជាត្រទាំង ៤ ដើម្បីរក្សាសេចក្តីជ្រះថ្លានៃស្តេច*

មហារាជទាំង ៤ នោះ មិនមែនព្រោះការប្រាថ្នាច្រើន ។ កាលទ្រង់ទទួលហើយ ទ្រង់បានអធិដ្ឋានបាត្រទាំង ៤ ឲ្យទៅជាបាត្រ ១ ផលបុណ្យនៃមហារាជទាំង ៤ ក៏បានដូចគ្នា ព្រះមានព្រះភាគទ្រង់ទទួលសដូវផង និងសដូវដុំផ្សំដោយទឹកឃ្មុំ ដោយបាត្រថ្មមានតម្លៃច្រើន ដែលទ្រង់អធិដ្ឋានឲ្យជាបាត្រ ១ ដោយប្រការដូច្នេះ ។

បទថា **បច្ចគ្ឃេ** *គឺមានតម្លៃច្រើន អធិប្បាយថា បាត្រនីមួយៗ មានតម្លៃច្រើន ។*

ម្យ៉ាងទៀត បទថា **បច្ចុគ្ឃេ** *បានដល់ ថ្មី គឺទើបតែអប់ស្រេច សេចក្តីថា កើតក្នុងខណៈនោះ ។ ពាណិជ ឈ្មោះថា មានវាចាពីរ ព្រោះអត្ថវិគ្គហៈថា បានជាអ្នកមានវាចាគម្រប់ ២ ។ ម្យ៉ាងទៀត សេចក្តីថា ពាណិជ ២ នាក់នោះដល់នូវភាពជាឧបាសកដោយវាចា ២ ។ ពាណិជនោះកាលប្រកាសភាពជាឧបាសកយ៉ាងនោះហើយ បានក្រាបទូលព្រះមានព្រះភាគថា អំណឹះតាំងពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គគប្បីធ្វើការអភិវាទ និងក្រោកទទួលបុគ្គលណាហ្ន៎ ព្រះអង្គ ព្រះមានព្រះភាគទ្រង់អង្អែលព្រះសីសៈ ព្រះកេសាជាប់ព្រះហស្ត បានប្រទានព្រះកេសាទាំងនោះដល់ពាណិជទាំងពីរ ដោយត្រាស់ថា អ្នកចូរក្រាសក់ទាំងនេះទុក ។ ពាណិជ ២ នាក់នោះបានព្រះកេសធាតុ ហាក់បីដូចបានអភិសេកដោយអមតធម៌ ត្រេកអរវិកវាយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយចៀសចេញទៅ ។*

រាជាយតនកថា ចប់

ព្រហ្មយាចនកថា

[๗] លុះថ្ងៃ ๗ កន្ទងទៅហើយ លំដាប់នោះ ព្រះមានជោគទ្រង់ក្រោកចាកសមាធិនោះ ហើយយាងចេញអំពីក្រោមម្លប់រាជាយតនៈហើយយាងចូលទៅកាន់ដើមអជបាលនិគ្រោធវិញ ។ បានឮថា ព្រះដ៏មានព្រះភាគក៏គង់នៅក្រោមម្លប់អជបាលនិគ្រោធនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគគង់សម្ងំនៅក្នុងទីស្ងាត់តែមួយព្រះអង្គ ទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ គឺសត្វឃើញបានដោយកម្រ ជាធម៌ គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ឧត្តម ជាធម៌ដែលសត្វមិនគប្បីសូនប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌លុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះសុទ្ធ តែនៅកំពុងរីករាយក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្តីអាល័យ (ចំពោះកាមទាំង-ឡាយនៅឡើយ) ក៏បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានិងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុនាំឲ្យពពួកសត្វនៅរីករាយក្នុងសេចក្តីអាល័យ នៅត្រេកត្រអាលក្នុងសេចក្តីអាល័យ នៅស្រើបស្រាលក្នុងសេចក្តីអាល័យ ឃើញបានដោយកម្រ ម្យ៉ាងទៀត ធម៌ណា សម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះចោលនូវឧបធិ គឺខន្ធ និងកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាកវាគៈ ជាទីរលត់នៃទុក្ខ គឺនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុដែលពពួកសត្វឃើញបានដោយកម្រក្រៃពេក បើទុកជាតថាគត

สម្តែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃ មិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្តីលំបាក សេចក្តីនឿយព្រួយ មុខជានឹងមានដល់តថាគតមិនខាន ។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយ ជាហេតុអស្ចារ្យសមគួរនេះ ព្រះដ៏មានព្រះភាគមិនដែលបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គថា ឥឡូវនេះ តថាគតគួរសម្តែងនូវធម៌ដែលតថាគតបានត្រាស់ដឹងហើយដោយកម្រ (នុ៎ះទៅចុះ) ។ ប៉ុន្តែសត្វទាំងឡាយដែលរាគៈ ទោសៈគ្របសង្កត់ ក៏មិនអាចនឹងត្រាស់ដឹងនូវធម៌នេះបានដោយងាយទេ ។ សត្វទាំងឡាយដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹត (គឺ អវិជ្ជា) កំពុងបិទបាំង (យ៉ាងនេះ) មុខជានឹងមិនឃើញនូវធម៌ដែលនាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតឆ្ងាយជ្រាលជ្រៅ សត្វឃើញបានដោយកម្រ (នុ៎ះទេ) ។

កាលដែលព្រះដ៏មានព្រះភាគពិចារណាឃើញ ដោយនយដែលត្រិះរិះដូច្នេះហើយ ព្រះហឫទ័យក៏ឱនទៅដើម្បីសេចក្តីខ្ជិលច្រអូសតិច មិនឱនទៅដើម្បីសម្តែងធម៌ឡើយ ។

[๘] លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះដ៏មានព្រះភាគ ដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងត្រិះរិះដូច្នេះថា អើហ្ន៎ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ មានព្រះហឫទ័យឱនទៅដើម្បីសេចក្តីខ្ជិលច្រអូសតិច មិនឱនទៅដើម្បីសម្តែងធម៌ (យ៉ាងនេះ) ឱ សត្វលោកវិនាសតើហ្ន៎ ឱ សត្វលោកវិនាសតើហ្ន៎ ។ គ្រានោះ សហម្បតិ-

พราหมณ์ ก็ได้สดับเรื่องราวนี้จากสำนักของพราหมณ์เหล่านั้น แล้วเข้าไปเฝ้าพระผู้มีพระภาคเจ้าถึงที่ประทับ ครั้นเข้าไปเฝ้าแล้ว ได้ถวายบังคมพระผู้มีพระภาคเจ้าแล้วนั่ง ณ ที่สมควรส่วนข้างหนึ่ง. ครั้นนั่งแล้ว ได้กราบทูลพระผู้มีพระภาคเจ้าดังนี้ว่า ข้าแต่พระโคดมผู้เจริญ ข้าพเจ้าได้สดับมาว่า พระสมณโคดมทรงปฏิญญาว่า เป็นผู้ทรงรู้ทั่วถึงธรรมทั้งปวง ดังนี้ ก็ข้าพเจ้าได้สดับมาว่า พราหมณ์ทั้งหลายผู้เฒ่าผู้แก่ ผู้เป็นอาจารย์ปาจารย์ของพราหมณ์ทั้งหลายผู้ศึกษามนต์ ย่อมกล่าวอย่างนี้ว่า ผู้ที่จะทรงรู้ทั่วถึงธรรมทั้งปวงนั้นหาได้ยาก ดังนี้ ก็

ณาหมิญ บพิตรพระองค์มาน บญาณ มานสมนฺตจกฺขุ พระองค์ชาอ្នกมานเสจกฺตีเสาก เขาปฺรสาเหาีย สูม ទ្រង់ឡើងកាន់ប្រាសាទសម្រេចដោយធម៌ ពិចារណាមើលនូវ ប្រជុំជនអ្នកច្រឡំដោយសេចក្តីសោក ដែលជាតិ ជរាកំពុង គ្របសង្កត់ មានឧបមាដូច្នោះដែរ ฯ បពិត្រព្រះអង្គអ្នកមាន ព្យាយាម អ្នកឈ្នះសង្គ្រាមហើយ ជានាយកនៃពពួកសត្វ អ្នកមិនជាប់ជំពាក់បំណុល គឺកាម សូមព្រះអង្គក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក ฯ សូមព្រះដ៏មានព្រះភាគទ្រង់ សម្តែងធម៌ សត្វទាំងឡាយ អ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ฯ

[๙] *គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនា របស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំង-ឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ฯ ព្រះដ៏មានព្រះ ភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វ ទាំងឡាយមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក (ខ្លះ) មានធូលី គឺ រាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយចាស់(ខ្លះ) មានឥន្ទ្រិយ ទន់ខ្លី(ខ្លះ) មានអាការល្អ (ខ្លះ) មានអាការអាក្រក់ (ខ្លះ) ជាសត្វ ដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយ កម្រ (ខ្លះ) ជាអ្នកឃើញបរលោក និងទោសដោយសកាពគួរខ្លាចខ្លះ ฯ*

(សេចក្តីប្រៀបថា) មានផ្កា ជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូក ក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ជុះខ្ពស់ឡើងជាងទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះដ៏មានព្រះភាគកាលទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក (ខ្លះ) មានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយរឹង (ខ្លះ) មានឥន្ទ្រិយទន់ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការមិនល្អ (ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) សត្វចំពួកខ្លះឃើញបរលោក និងទោសដោយសភាពគួរខ្លាច មានឧបមេយ្យដូច្នោះឯង លុះទ្រង់ឃើញហើយ ទើបទ្រង់សម្តែងជាបទគាថានឹងសហម្បតិព្រហ្មថា

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណាមានសោតប្បសាទ សត្វទាំងឡាយនោះចូរបពោ្ចញនូវសទ្ធាចុះ ។ ម្នាលមហាព្រហ្ម តថាគតមានសេចក្តីសម្អាល់ក្នុងការលំបាកបានជាមិនសម្តែងធម៌ដ៏ឧត្តម ដែល

ស្ងាត់ក្នុងសំណាក់មនុស្សទាំងឡាយ ។

គ្រានោះ សហម្បតិព្រហ្មគិតថា ខ្ញុំនអញជាបុគ្គល គឺព្រះដ៏មានព្រះភាគទ្រង់យល់ព្រមដើម្បីនឹងសម្តែងធម៌ហើយ (លុះគិតដូច្នេះហើយ) ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះមួយរំពេចទៅ ។

ព្រហ្មយាចនកថា ចប់

อัฏฐกถา

พุทธุปวิตักกกถา

[๗] คราวนั้น ล่วงไปได้ ๗ วัน พระมีพระภาค ทรงออกจากสมาธินั้น สำเร็จกิจทั้งปวง มีประการดังกล่าวแล้วนั้น ด้วย ออกจากความเป็นผู้ชำนาญในการเข้าอชปาลนิโครธสมาบัติ ฯ

ในบทว่า **วิวิตฺตกฺโก อุฏฺฐาสิ** ความว่า ความตรึกนี้ใด ของพระพุทธเจ้าทั้งหลายมีในก่อน ความตรึกนี้ได้เกิดขึ้นแก่พระมีพระภาคนั้น ผู้กำลังทรงสำเร็จการอยู่ในอชปาลนิโครธสมาบัตินั่นแล ฯ

ถามว่า เพราะเหตุไร ความตรึกนี้ จึงได้เกิดขึ้นแก่พระพุทธเจ้าทั้งหลาย ตอบว่า เพราะทรงพิจารณาเห็นคุณของพระธรรมอันมีคุณใหญ่ มีคุณยิ่งกว่าคุณทั้งปวง และเพราะทรงมีพระประสงค์จะทรงแสดงธรรมตามที่ทรงพิจารณาเห็นแล้วนั่นเอง ฯ

ก็ในกาลนั้น พระมีพระภาคทั้งหลายทรงดำริว่า ธรรมที่เราบรรลุแล้วนี้ ลึกซึ้งหาที่เห็นได้ยาก ฯลฯ ก็ถ้าเราจักแสดงธรรมแก่สัตว์ทั้งหลาย ผู้ไม่รู้ธรรมนั้น ความลำบากจักมีแก่เรา ดังนี้ ฯลฯ ดังนี้ ฯ

ในบทว่า **อธิคโต โข มยายํ** นี้ ท่านกล่าวไว้ด้วยอำนาจแห่งการเข้าถึงความเป็นผู้ชำนาญ ฯ

ความว่า ธรรมนี้ใด ที่เราตถาคตได้บรรลุแล้ว ฯลฯ ดังนี้ ฯ

បទថា **អាលយរាមាយ** *សេចក្តីថា សត្វទាំងឡាយរមែងជាប់ជំពាក់ក្នុងកាមគុណ ๕ យ៉ាង ព្រោះហេតុនោះ ទើបកាមគុណ ๕ នោះ លោកហៅថា អាលយ ពួកសត្វរមែងត្រេកអរដោយកាមគុណ ជាទីជាប់ជំពាក់នោះ ហេតុនោះ ទើបឈ្មោះថា ជាអ្នកត្រេកអរដោយអាលយ ។ ពួកសត្វត្រេកអរហើយ ក្នុងកាមគុណជាទីជាប់ជំពាក់ទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា ជាអ្នកត្រេកអរក្នុងអាលយ ។ ពួកសត្វត្រេកអរជ៏ក្រៃលែងក្នុងកាមគុណជាទីជាប់ជំពាក់ទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា ជាអ្នកត្រេកអរក្នុងអាលយ ។*

បទថា **យទិទំ** *ជានិបាត សេចក្តីនៃបទថា* **យទិទំ** *នោះ សំដៅយកហានៈ គប្បីឃើញយ៉ាងនេះថា* **យំ ឥទំ** *សំដៅយកបដិច្ចសមុប្បាទ គប្បីឃើញយ៉ាងនេះថា* **យោ អយំ** ។

បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នោ** *មានអត្ថវិគ្គហៈថា ធម៌ទាំងនេះ ជាបច្ច័យនៃធម៌ទាំងនេះ ឈ្មោះថា ឥទប្បច្ចយា ។ នោះ ឈ្មោះថា* **ឥទប្បច្ចយតា** *ធម៌ទាំងនេះជាបច្ច័យនៃធម៌ទាំងនេះ ទុំៈជាធម៌អាស្រ័យគ្នាកើតឡើង ព្រោះដូច្នោះ ទើបឈ្មោះថា ធម៌ទាំងនេះជាបច្ច័យនៃធម៌ទាំងនេះជាធម៌អាស្រ័យគ្នាកើតឡើង ។*

បទថា **សោ មមស្ស កិលមថោ** *សេចក្តីថា ដែលឈ្មោះថា ទេសនាដល់ពពួកជនដែលជាអ្នកមិនដឹង គប្បីជាការហត់នឿយដល់តថាគត គប្បីជាសេចក្តីលំបាកដល់តថាគត ។*

បទថា **ភគវន្តំ** *ប្រែថា ដល់ព្រះមានព្រះភាគ ។*

បទថា **អនច្ឆរិយា** *បានដល់ ជាការអស្ចារ្យពន់ពេក ។*

បទថា **បដិភំសុ** *សេចក្តីថា បានជាអារម្មណ៍នៃញាណ ពោលគឺ បដិភាណ គឺដល់នូវភាពជាគាថាដែលព្រះអង្គគប្បីបវិតក្ក ។* **ហ** *អក្ខរៈ ក្នុងបទថា* **ហលំ** *នេះ ត្រឹមតែជានិបាត សេចក្តីថា មិនគួរ ។*

បទថា **បកាសិតុំ** *បានដល់ ដើម្បីប្រកាស ។ មានពាក្យអធិប្បាយថា ឥឡូវនេះ មិនគួរសម្តែងធម៌ដែលតថាគតសម្រេចបានដោយលំបាកនេះ ។*

បានគាថាថា **ឆាយំ ធម្មោ សុសម្ពុទ្ធោ** *សេចក្តីថា ធម៌នេះធ្វើបានងាយៗ ដើម្បីនឹងត្រាស់ដឹងក៏ទេ អធិប្បាយថា ការដែលនឹងដឹងមិនមែនធ្វើបានងាយៗ ឡើយ ។*

បទថា **បដិសោតគាមឹ** *សេចក្តីថា ឲ្យដល់និព្វានដែលលោកហៅថា ធម៌បញ្ជោសក្រៃសែ ។ បទថា* **រាគរត្តា** *សេចក្តីថា សត្វទាំងឡាយដែលត្រឿងជ្រលក់ គឺកាម ត្រឿងជ្រលក់ គឺភព និងត្រឿងជ្រលក់ គឺទិដ្ឋិ ជ្រលក់ចិត្តហើយ ។ បទថា* **ន ឧក្ខន្តិ** *បានដល់ រមែងមិនឃើញ ។*

ពីរបទថា **តមោក្ខន្ធេន អាវុដា** *សេចក្តីថា បុគ្គលដែលគំនរនៃអវិជ្ជាបិទបាំងទុកហើយ ។*

បទថា **អប្បោស្សុក្កតាយ** *សេចក្តីថា ដើម្បីភាពជាអ្នកមិនបំណងនឹងសម្តែង ព្រោះភាពជាអ្នកប្រាសចាកសេចក្តីឧស្សាហ៍ ។*

ពុទ្ធបវិតក្កកថា ចប់

ព្រហ្មាយាចនកថា

[៨] បទថា **យត្រហិ នាម** សេចក្តីថា ក្នុងលោកឈ្មោះណា ។

បទថា **ភគវតោ បុរតោ ចាតុរហោសិ** សេចក្តីថា ស្តេចសហម្បតី-ព្រហ្ម នាំមហាព្រហ្មទាំងឡាយ ក្នុងមុនចក្កវាឡមកប្រាកដចំពោះមុខព្រះមានព្រះភាគ ដើម្បីទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ។

បទថា **អប្បរជក្ខជាតិកា** សេចក្តីថា ធូលី គឺរាគៈ ទោសៈ មោហៈ តិចក្នុងភ្នែក ដែលសម្រេចដោយបញ្ញា ជាប្រក្រតីនៃខ្លួនរបស់សត្វទាំងនេះ ហេតុនោះ សត្វទាំងនេះ ឈ្មោះថា ជាអ្នកមានជាតិនៃសត្វដែលមានធូលីតិចក្នុងភ្នែក ។

បទថា **ភវិស្សន្តិ ធម្មស្ស** បានដល់ ធម៌ គឺសច្ចៈ ៤ ។

បទថា **អញ្ញាតារោ** បានដល់ ដែលត្រាស់ដឹង ។

បទថា **ចាតុរហោសិ** បានដល់ មានប្រាកដ ។

ពីរបទថា **ស មលេហិ ចិន្តិតោ** សេចក្តីថា ដែលគ្រូទាំង ៦ ជាអ្នកមានមន្ទិល មានរាគៈជាដើមគិតហើយ ។

បទថា **អថាបុរេតំ** សេចក្តីថា សូមបើកទ្វារនោះ ។

ពីរបទថា **អមតស្ស ទ្វារំ** សេចក្តីថា អរិយមគ្គជាទ្វារនៃព្រះនិព្វាន ដែលជាធម៌មិនស្លាប់ ។

បាទព្រះគាថាថា **សុណន្តុ ធម្មំ វិនលេនានុពុទ្ធំ** សេចក្តីថា សត្វទាំងនេះចូរស្តាប់ធម៌ គឺអរិសច្ច ៤ ដែលព្រះសម្ពុទ្ធ ជ៏ជាអ្នកប្រាសចាកមន្ទិល ព្រោះមិនមានមន្ទិល មានរាគៈជាដើម ត្រាស់ដឹងសមគួរហើយ ។

បានព្រះគាថាថា **សេលេ យថា បព្ភតមុទ្ធនិដ្ឋិតោ** *សេចក្តីថា ឧបមាដូចបុរសមានភ្នែកល្អឈរលើកំពូលភ្នំថ្ម គប្បីឃើញមហាជនបានគ្រប់ទិសយ៉ាងណា បពិត្រព្រះមានព្រះភាគជ៏ាមេធា គឺជាអ្នកមានបញ្ញាល្អ ទ្រង់មានចក្ខុដែលអភិសេកដោយសព្វញ្ញុតញ្ញាណ សូមព្រះអង្គឡើងកាន់ប្រាសាទ ដ៏សម្រេចហើយដោយធម៌ គឺបរិសុទ្ធដោយបញ្ញា ព្រះអង្គប្រាសចាកសេចក្តីសោកហើយ សូមទ្រង់សម្លឹងមើល គឺទ្រង់ពិចារណាមហាជន ដែលចង្អៀតចង្អល់ដោយសេចក្តីសោក ត្រូវការកើត និងការចាស់គ្របសង្កត់ហើយយ៉ាងនោះចុះ សហម្បតីព្រហ្មកាលអារាធនាឲ្យព្រះមានព្រះភាគទ្រង់ចារិកទៅដើម្បីសម្តែងធម៌ ទើបទូលថា សូមទ្រង់ក្រោកឡើងចុះ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វីរ** *ជាដើមដូច្នេះ ព្រះមានព្រះភាគ មានព្រះនាមថា* **វីរ** *ព្រោះទ្រង់មានសេចក្តីព្យាយាម ទ្រង់ព្រះនាមថា* **វិឥត-សង្គាម** *ព្រោះទ្រង់ឈ្នះទេវបុត្តមារ មច្ចុមារ កិលេសមារ និងអភិសង្ខារមារ ទ្រង់ព្រះនាមថា* **សត្ថវាហ** *ព្រោះទ្រង់អាចជួយពួកសត្វឲ្យផុតចាកកន្តារ មានជាតិកន្តារជាដើម ទ្រង់ព្រះនាមថា ជាអ្នកមិនមានបំណុល ព្រោះមិនមានបំណុល គឺកាមច្ឆន្ទៈ ។*

[๙] បទថា **អជ្ឈេសនំ** *បានដល់ ពាក្យអារាធនា ។*

បទថា **ពុទ្ធចក្ខុនា** *គឺដោយឥន្ទ្រិយប្បរោបរិយត្តិញ្ញាណ និងអាសយានុសយញ្ញាណ ។ ពិតហើយ ពុទ្ធចក្ខុ ជាឈ្មោះនៃព្រះញាណ ๒ យ៉ាងនេះ ។*

បទថា **អប្បរជក្ខេ** *ជាដើម សេចក្តីថា ធូលី មានរាគៈជាដើម ក្នុងបញ្ញាចក្ខុរបស់សត្វពួកណាមានតិច សត្វទាំងនោះ ឈ្មោះថា ជាអ្នកមានធូលីក្នុងភ្នែកតិច ។ របស់សត្វពួកណាមានច្រើន សត្វទាំងនោះ ឈ្មោះថា ជាអ្នកមានធូលីក្នុងភ្នែកច្រើន ឥន្ទ្រិយ មានសទ្ធាជាដើមរបស់សត្វពួកណាចាស់ក្លា សត្វទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានឥន្ទ្រិយចាស់ក្លា របស់សត្វពួកណាទន់ខ្សោយ សត្វទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានឥន្ទ្រិយទន់ខ្សោយ ។ អាការ មានសទ្ធាជាដើម របស់សត្វពួកណាល្អ សត្វទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានអាការល្អ របស់សត្វពួកណាមិនល្អ សត្វទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានអាការមិនល្អ ។ សត្វពួកណាកំណត់ហេតុដែលទ្រង់ពោលបាន គឺជាអ្នកអាចនឹងឲ្យដឹងបានងាយ សត្វទាំងនោះ ឈ្មោះថា ជាអ្នកគប្បីប្រៀនប្រដៅឲ្យដឹងបានដោយងាយ ។ សត្វពួកណាមិនដូច្នោះ សត្វទាំងនោះ ឈ្មោះថា ជាអ្នកគប្បីប្រៀនប្រដៅឲ្យដឹងដោយលំបាក ។ សត្វពួកណាឃើញបរលោក និងទោសដោយភាពជាភ័យ សត្វទាំងនោះ ឈ្មោះថា ជាអ្នកមានប្រក្រតីឃើញបរលោក និងទោស ដោយភាពជាភ័យ ។*

បទថា **อุปฺปลินิยំ** *បានដល់ ក្នុងគុម្ពឧប្បល ។ ក្នុងបទក្រៅអំពីនេះ ក៏នយនេះដូចគ្នា ។*

បទថា **អนฺโตนิมุคฺคโปสีนิ** *បានដល់ ផ្កាឈូកដែលលិចនៅក្នុងទឹក ដែលទឹកចិញ្ចឹម ។*

បទថា **สโมทกฏฺฐานิ** *បានដល់ ផ្កាឈូកដែលតាំងនៅស្មើទឹក ។*

ច្រើនបទថា **ឧទកា អក្ខុគ្គម្ម តិដ្ឋន្តិ** *បានដល់ តាំងនៅផុតអំពីទឹក ។ បទថា* **អចារុតា** *បានដល់ រីកហើយ ។*

ពីរបទថា **អមតស្ស ទ្វារា** *បានដល់ អរិយមគ្គ ។ ពិតហើយ អរិយ-មគ្គនោះ ជាទ្វារនៃព្រះនិព្វាន ពោល គឺអមតធម៌ ។*

ពីរបទថា **បមុញ្ចន្តុ សទ្ធំ** *សេចក្តីថា ជនទាំងពួងចូរលែង គឺចូរលះការជឿរបស់ខ្លួន ។ ពីរក្នុងបទខាងចុង មានអត្ថដូច្នេះឯង ព្រោះថា តថាគតជាអ្នកមានសេចក្តីសម្គាល់ថា នឹងត្រូវលំបាកកាយវាចា ទើបមិនបានសម្តែងធម៌ដ៏ឧត្តមប្រណីតនេះ សូម្បីដែលប្រព្រឹត្តទៅល្អ ស្អាត់ជំនាញសម្រាប់ខ្លួនក្នុងពពួកមនុស្ស គឺក្នុងទេវតា និងមនុស្សទាំងឡាយ ។*

ព្រហ្មយាចនកថា ចប់

បឋមភាណវារ

[๑๐] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា តថាគត គួរសម្តែងធម៌ជល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះយ៉ាងនេះទៀតថា អាឡារ-តាបសកាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរមកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ជល់អាឡារតាបសកាលាមគោត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនច្បាកដ ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមគោត្រ ធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា អាឡារតាបសកាលាមគោត្រ (នុ៎ះ) មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះបានស្តាប់ធម៌នេះ ក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា តថាគតសម្តែងធម៌ជល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា ឧទ្ទកតាបសរាមបុត្រនេះឯងជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរណាស់មកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ជល់ឧទ្ទក-

តាបសរាមបុត្រនេះជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នេះឆាប់រហ័ស បាន ។ គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទកតាបសរាម-បុត្រធ្វើកាលកិរិយា ស្ងាប់អំពីពេលព្រលប់ទៅហើយ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបថា ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយា ស្ងាប់អំពីពេលព្រលប់ទៅហើយដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា ឧទ្ទក-តាបសរាមបុត្រមានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះបានស្តាប់ធម៌នេះ គប្បីត្រាស់ដឹងធម៌បានមួយរំពេច ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះតម្រិះដូច្នេះក្នុងលំដាប់នោះថា បញ្ចវគ្គិយ[1]ភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះថា បានបម្រើតថាគត កាលដែលកំពុងបញ្ជូនចិត្តទៅក្នុងព្យាយាម[2] បើដូច្នោះ គួរតថាគតសម្តែងដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធ ស្អាតកន្លងលើសចក្ខុរបស់មនុស្ស ។ គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យ

๑- ភិក្ខុមានគ្នា ๕ រូប ។ ๒- កំពុងខំប្រឹងបំពេញព្យាយាមឲ្យបានត្រាស់ជាព្រះពុទ្ធ ។

ទើបទ្រង់យាងទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី ។

[๑๑] *មានអាជីវកម្នាក់ ឈ្មោះឧបកៈ បានឃើញព្រះដ៏មានព្រះភាគស្តេចទៅកាន់ផ្លូវឆ្ងាញ ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង លុះឃើញហើយក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវីវណ្ណ[1] របស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។ កាលឧបកាជីវកសួរយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា*

> *តថាគត ជាអ្នកគ្របសង្កត់នូវតេកូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុកូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេកូមិកធម៌ទាំងអស់ បានលះចោលនូវតេកូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុកូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា ។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយ ក្នុងលោកនេះ ព្រមទាំងទេវលោកមិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ។ ព្រោះថា តថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត*

๑-សម្បុរស្បែក ឬសម្បុរថ្លៃ ។

ជាអ្នកត្រាស់ដឹងដោយប្រពៃ ចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ។ ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជន អ្នកកាសីដើម្បីទីងសម្តែងធម្មចក្ក (ដោយបំណងថា) តថាគតនឹងទូន្មនូវស្តារ គឺអមតនិព្វានចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកថាយ៉ាងណា អ្នក (គួរដើម្បីបាននូវឈ្មោះ) ថា អនន្តជិនៈ (យ៉ាងនោះឯង) ។ ព្រះ-សម្មាសម្ពុទ្ធ ទ្រង់មានព្រះពុទ្ធដីកាទៀតថា

ជនទាំងឡាយណា បានដល់នូវធម៌ សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ ជនទាំងឡាយនោះឈ្មោះថា ជិនៈ (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ ។ តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតបាននូវឈ្មោះថា ជិនៈ (ជាអ្នកឈ្នះបាបធម៌) ។

កាលព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកា-ជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹង ពិតមែនហើយ (ថាហើយ) ក៏ងក់ក្បាលហើយកាន់យកផ្លូវខុស (គឺដើរបែកផ្លូវគ្នា) ចៀសចេញទៅ ។

[๑๒] *ครานោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាម លំដាប់ហើយក៏យាងចូលទៅក្រុងពារាណសី រួចហើយទ្រង់យាងទៅឯឥសិបតនមិគទាយវន សំដៅទៅរកកន្លែងដែលបញ្ចវគ្គិយភិក្ខុនៅ ។ បញ្ចវគ្គិយភិក្ខុ បានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏ធ្វើប្តេជ្ញា គ្នាថា ម្នាលអាវុសោ សមណគោតមនេះជាអ្នកប្រតិបត្តិដើម្បីល្មោភឃ្លាតចាក ព្យាយាមហើយ វិលត្រឡប់ដើម្បីការៈល្មោក ឥឡូវនេះ លោកនិមន្តមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួល យកបាត្រចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើ លោកនឹងចង់គង់ក៏គង់ចុះ ។ ព្រះដ៏មានព្រះភាគយាងចូលទៅរកបញ្ចវគ្គិយភិក្ខុ ដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះក៏មិនអាចដើម្បីឋិតនៅ ក្នុងពាក្យ ប្តេជ្ញារបស់ខ្លួនដោយប្រការនោះៗ បានឡើយ ក៏ស្រាប់តែក្រោកទទួលព្រះ ដ៏មានព្រះភាគ ខ្លះទទួលយកបាត្រចីវររបស់ព្រះអង្គ ខ្លះក្រាលអាសនៈថ្វាយ ខ្លះតម្កល់ទឹកលាងព្រះបាទ យកតាំងសម្រាប់រងព្រះបាទ និងឈ្នាន់រងព្រះបាទ មកថ្វាយ ។ ព្រះដ៏មានព្រះភាគគង់លើអាសនៈដែលបញ្ចវគ្គិយភិក្ខុទាំងឡាយ រៀបចំទុកហើយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយក៏ទ្រង់លាងព្រះបាទទាំង ពីរ ។ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះដ៏មានព្រះភាគដោយចំព្រះនាមផង ដោយ ពាក្យថា អាវុសោផង ។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យហៅយ៉ាង នេះហើយ ព្រះភគវន្តមុនីទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាកុំហៅតថាគតដោយចំឈ្មោះ*

សារីបុត្រ និងមោគ្គល្លានក៏ចូលទៅរកបរិព្វាជកឈ្មោះសញ្ជ័យ លុះចូលទៅជល់ហើយ ក៏បានពោលនូវពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជ័យថា ម្នាលលោកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគៗ នោះជាគ្រូរបស់យើងទាំងឡាយ ។ បរិព្វាជកឈ្មោះសញ្ជ័យឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ ពួកយើងទាំងបីនាក់នឹងគ្រប់គ្រងរក្សាគណៈនេះ ។ សារីបុត្រ និងមោគ្គល្លានបានពោលពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជ័យអស់វារៈជាគម្រប់ពីរដងផង ។បេ។ អស់វារៈគម្រប់បីដងផងថា ម្នាលអ្នកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគៗ នោះជាគ្រូរបស់យើងទាំងឡាយ ។ បរិព្វាជកឈ្មោះសញ្ជ័យឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ ពួកយើងទាំងបីនាក់នឹងគ្រប់គ្រងរក្សាគណៈនេះ ។ គ្រានោះ សារីបុត្រ និងមោគ្គល្លានក៏នាំបរិព្វាជកចំនួន ២៥០ រូបនោះចូលទៅកាន់វត្តវេឡុវ័ន ។ ចំណែកខាងបរិព្វាជកឈ្មោះសញ្ជ័យ ក៏ (មានសេចក្តីទោមនស្សជូតឡើង) បណ្តាលឲ្យក្តៅក្រហាយរហូតដល់ក្អួតឈាមចេញអំពីមាត់ក្នុងទីនោះ ។

[๗๑] *ព្រះដ៏មានព្រះភាគបានទតឃើញសារីបុត្រនឹងមោគ្គល្លានកំពុងដើរមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជនជាសម្ងាញ់នឹងគ្នាទាំងពីរនាក់នុ៎ះឈ្មោះកោលិតៈ ๑ ឈ្មោះឧបតិស្សៈ ๑ នឹងមកជល់ឥឡូវហើយ ហ្នឹងហើយជាគូនៃសាវកបស់តថាគតដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ។*

พระสาสดาทรงพยากรณ์ชนทั้งสองพวกนั้น ผู้มีจิตน้อมไปในธรรมอันยิ่ง ในญาณวิสัย ในธรรมเป็นเครื่องสิ้นไปแห่งอุปธิอันประเสริฐ (พระนิพพาน) ด้วยประการฉะนี้ว่า ชนทั้งสองพวกนี้ ชื่อว่าโกลิตะ ๑ ชื่ออุปติสสะ ๑ จักมาถึงความเป็นคู่กันในภายหลัง จักเป็นอัครสาวกของพระตถาคต ผู้เป็นคู่อันประเสริฐ เป็นคู่อันสมควร ดังนี้ ฯ

[๗๒] ครั้งนั้น พระสารีบุตรและพระโมคคัลลานะได้เข้าไปเฝ้าพระผู้มีพระภาค ถวายบังคมพระยุคลบาทของพระผู้มีพระภาค แล้วได้กราบทูลพระผู้มีพระภาคดังนี้ว่า ข้าแต่พระองค์ผู้เจริญ ขอพระองค์ทรงโปรดให้ข้าพระองค์ทั้งสองได้บรรพชา ได้อุปสมบทในสำนักพระผู้มีพระภาคเถิด ฯ พระผู้มีพระภาคได้ตรัสว่า มาเถิด ภิกษุทั้งหลาย จงประพฤติพรหมจรรย์เพื่อทำที่สุดทุกข์โดยชอบเถิด ฯ พระพุทธดำรัสนั้นแล ได้เป็นอุปสมบทของท่านผู้มีอายุทั้งสองนั้น ฯ

[๗๓] สมัยนั้น กุลบุตรทั้งหลายอยู่ในมคธชนบท ต่างก็ทราบข่าวกันว่า ได้ยินว่า พระสมณโคดมทรงประกาศพรหมจรรย์ มีสาวกชื่อสารีบุตรและโมคคัลลานะ ผู้เป็นคู่อันประเสริฐ เป็นคู่อันสมควร ดังนี้ ฯ

ព្រះដ៏មានព្រះភាគ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្អាប់ ថា សមណគោតមប្រតិបត្តិដើម្បីធ្វើមនុស្សមិនឲ្យមានកូន សមណគោតម ប្រតិបត្តិ ដើម្បីធ្វើឲ្យស្រីទៅជាមេម៉ាយ សមណគោតមប្រតិបត្តិដើម្បីផ្តាច់ បង់ត្រកូល ឥឡូវគាត់បំបួសជដិលចំនួន ๑๐๐๐ នាក់ហើយបំបួសទាំង បរិព្វាជកចំនួន ๒๕๐ នាក់ជាពួកសញ្ជ័យនេះទៀត ទាំងកុលបុត្រទាំងឡាយ ដែលនៅក្នុងដែនមគធៈដែលមានកេរ្តិ៍ឈ្មោះ គេជឿងឮគ្រប់គ្នានេះទៀត ក៏ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតមដែរ ។ ឯមនុស្សទាំង-ឡាយឃើញពួកភិក្ខុហើយ ក៏នាំគ្នាចោទដោយគាថានេះថា

មហាសមណៈ យាងមកហើយកាន់ក្រុងគិរិព្វជៈ (ភ្នំ មានសណ្ឋានដូចជាក្រោល) របស់ពួកជននៅក្នុងដែន មគធៈ ព្រះអង្គនាំអស់ពួកបរិវាររបស់សញ្ជ័យទៅហើយ ឥឡូវ នឹងនាំយកអ្នកណាទៅទៀតអេះ ។

[๗๔] *ពួកភិក្ខុបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ទើបពួកភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មាន ព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំឡេងនោះនឹងមិនមាន នៅអស់កាលជ័យូរទេ សំឡេងនោះនឹងមាននៅត្រឹមតែ ๗ ថ្ងៃ លុះកន្លង ๗ ថ្ងៃទៅនឹងអន្តរធានបាត់ទៅឯង ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ចោទអ្នកទាំងឡាយដោយគាថានេះថា*

មហាសមណៈយាងមកហើយ កាន់ក្រុងគិរិព្វជៈ របស់

พวกชนกุฉ่ไนมคธ: เลากนำไปนูวพวกสญ្ជัยทำង
អស់ហើយ ឥឡូវនេះ នឹងនាំអ្នកណាទៅទៀតអេះ ។
(បើដូច្នោះ) អ្នកទាំងឡាយ ចូរចោទជនទាំងនោះ
ដោយគថានេះវិញថា

ព្រះតថាគតទាំងឡាយមានសេចក្តីព្យាយាមដ៏មាំ
ណែនាំសត្វ ដោយព្រះសម្មទ្ធដ៏ប្រពៃពិត ហេតុដូចម្តេច
ក៏មានសេចក្តីច្រណែនឹងពួកអ្នកប្រាជ្ញ ដែលជាអ្នក
ណែនាំសត្វដោយធម៌ (នោះឯង) ។

[๗๕] សម័យនោះឯង ពួកមនុស្សឃើញភិក្ខុទាំងឡាយ ហើយចោទ
ដោយគាថានេះថា

មហាសមណ:យាងមកហើយកាន់ក្រុងគិរិព្វជ: របស់
ពួកជនមគធ: នាំយកពួកបរិវាររបស់សញ្ជ័យទាំងពួងទៅ
ហើយ ឥឡូវនេះនឹងនាំយកអ្នកណាទៅទៀតហ្ន៎ ។
ភិក្ខុទាំងឡាយចោទតបនឹងមនុស្សទាំងនោះដោយ គាថា
នេះថា ព្រះតថាគតទាំងឡាយមានសេចក្តីព្យាយាមដ៏មាំ
ណែនាំសត្វដោយព្រះសទ្ធម្មដ៏ប្រពៃពិត ហេតុដូចម្តេចក៏
មានសេចក្តីច្រណែនពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំ
សត្វដោយធម៌ (នោះឯង) ។

[๗๖] ពួកមនុស្សពោលពាក្យយ៉ាងនេះថា បានឮថា សមណ:ទាំង-

ឡាយជាសក្យបុត្រ ណែនាំសត្វដោយធម៌ មិនមែនណែនាំដោយសការៈមិនមែនធម៌ទេ ។ សំឡេងនោះ ក៏មានត្រឹមតែ ๗ ថ្ងៃ លុះកន្លង ๗ ថ្ងៃ ក៏អន្តរធានបាត់ទៅឯង ។

បព្វជ្ជារបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ចប់

ភាណវារជាគម្រប់ ๔ ចប់

อัฏฐกถา

สารีบุตรโมคคัลลานปัญหา

[๖๔] บทว่า **สารีปุตฺตโมคฺคลฺลานา** ได้แก่ พระสารีบุตร ๑ พระโมคคัลลาน ๑ โลกทั้ง ๒ ได้ทำกติกากันว่า ผู้ใดได้บรรลุอมตธรรมก่อน ผู้นั้นจงบอกแก่ผู้นี้ ดังนี้ ฯ

ได้ยินว่า ผู้ทั้ง ๒ นั้น ได้เป็นคหบดีมีชื่อเสียงโด่งดังอย่างนี้ว่า อุปติสสะ โกลิตะ มีบริวารคนละ ๒๕๐ คน ได้ไปยังมหรสพบนยอดเขา ฯ ครั้งนั้น ท่านทั้ง ๒ เห็นมหาชนในที่นั้นแล้ว มีความคิดอย่างนี้ว่า ชื่อว่าหมู่มหาชนที่มีสภาพอย่างนี้ ไม่ล่วงพ้นไปได้ถึง ๑๐๐ ปี ก็จักตกไปในอำนาจแห่งมัจจุ ฯ

ครั้นนั้น ท่านทั้ง ๒ ได้ไปยังที่สงัดแล้ว ได้ปรึกษากันและกัน มีความเห็นร่วมกัน มีความรู้ร่วมกันว่า ความสิ้นไปเป็นธรรมดาของสัตว์ทั้งหลาย ดังนี้ ฯ

เพื่อแสวงหาอมตธรรม ได้ไปยังสำนักของสัญชัยปริพาชก ผู้อยู่ในกรุงราชคฤห์ ไม่นานนักก็ได้บรรลุถึงที่สุดแห่งวิชาของสัญชัยนั้น ฯ

កាលមើលមិនឃើញអមតធម៌ ទើបពោលថា លោកអាចារ្យ ខ្ញុំសូមសួរខ្ចីមសារជនៃក្នុងបព្វជ្ជានេះ នៅមានឬ ។

បានស្តាប់ចម្លើយរបស់លោកថា មិនមានទេ អ្នកមានអាយុ លទ្ធិនេះមានប៉ុណ្ណោះឯង ។

ទើបបានធ្វើកតិកាទុកថា អាវុសោ លទ្ធិនេះទេ មិនមានខ្ចីមសារឥឡូវនេះ ក្នុងពួកយើង បុគ្គលណាជួបអមតធម៌មុន បុគ្គលនោះ ចូរជ្រាប់ដល់ភាគីម្ខាងទៀត ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យ ពោលពាក្យជាដើមថា អ្នកទាំង ២ បានធ្វើកតិកាគ្នា ។

តតិយាវិភត្តិ ក្នុងលក្ខណៈនៃឥត្ថម្ភូត អ្នកសិក្សាគប្បីជ្រាបក្នុងបទទាំង-ទ្បាយថា **ថាសาธิเกน อภิกฺกนฺเตน** *ជាដើម ។ បទនេះថា* **อตฺเถหิ ฯเปฯ มคฺโค** *ជាបទសម្តែងហេតុនៃការជាប់តាម ។ ពិតហើយ មានពាក្យដែលអធិប្បាយទុកដូច្នេះថា កុំយ៉ាងនោះទ្បើយ អាត្មាអញ នឹងដើរតាមភិក្ខុនេះទៅខាងក្រោយ ។ ព្រោះហេតុអ្វី ព្រោះថា ការដើរតាមទៅខាងក្រោយនេះ ជាផ្លូវដែលអ្នកមានសេចក្តីត្រូវការទាំងទ្បាយស្គាល់ ស្វែងរកហើយ អធិប្បាយថា មាគ៌ាដែលជនទាំងទ្បាយ មានសេចក្តីត្រូវការដឹងហើយ នឹងដំណើរទៅស្វែងរកហើយ ។*

ម្យ៉ាងទៀត គប្បីឃើញក្នុងពាក្យនេះ យ៉ាងនេះថា ឈ្មោះថា និព្វាន ក៏យើងទាំងទ្បាយ ជាអ្នកត្រូវការដឹងច្បាស់ហើយថា មានពិតប្រាកដ

ដោយសន្និដ្ឋានយ៉ាងនេះថា កាលសេចក្តីស្លាប់មាន ធម៌ដែលមិនស្លាប់ ក៏ត្រូវមានដែរ កុំជួបច្នោះទ្បើយ អញនឹងស្វែងរក គឺកាលស្វែងរកនិព្វាននោះ គប្បីជាប់តាមភិក្ខុនេះទៅអំពីខាងក្រោយ ។

ច្រើនបទថា **បិណ្ឌាចារំ អាទាយ បដិក្កមិ** សេចក្តីថា ព្រះអស្សជិ ដ៏មានអាយុ ចូលទៅអង្គុយជិតសំយាបជញ្ជាំងមួយកន្លែង ដែលមានប្រការជួចពោលហើយ ក្នុងសុទិន្នកណ្ឌ ។ ឯសារីបុត្រមាណពឈរចាំវេលាថា មិនទាន់ដល់វេលាដែលត្រូវសួរបញ្ហា ដើម្បីនឹងបំពេញវត្តបដិបត្តិ ក៏ប្រគេនទឹកអំពីឃ្លាកបស់ខ្លួនដល់ព្រះថេរៈ ដែលសម្រេចកត្តកិច្ច ហើយធ្វើបដិ-សណ្ឋារៈជាមួយព្រះថេរៈដែលលាងដៃ និងជើង ហើយសួរបញ្ហា ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា **អថ ខោ សារី-បុត្តោ បរិព្វាជកោ** ជាដើម ។

ពីរបទថា **ន តាហំ សក្ខោមិ** កាត់បទជា **ន តេ អហំ សក្ខោមិ** ប្រែថា សម្រាប់លោក យើងមិនអាច ។

តែព្រះថេរៈដល់នូវបដិសម្ភិទាញាណក្នុងព្រះធម្មវិនយនេះ មិនមែនមិនអាចដើម្បីសម្តែងធម៌មានប្រមាណប៉ុណ្ណោះបាននោះទេ ដោយពិត លោកគិតថា អាត្មាអញនឹងបណ្តុះសេចក្តីគោរពក្នុងធម៌ដល់សត្វនេះ បានកាន់យកការសម្តែងធម៌ក្នុងពុទ្ធវិស័យដោយអាការទាំងពួង មិនមែនវិស័យរបស់លោក ទើបពោលយ៉ាងនោះ ។

[๖๕] បាទគាថាថា **យេ ធម្មា ហេតុប្បភវា** សេចក្តីថា បញ្ចក្ខន្ធ

ឈ្មោះថា ធម៌មានហេតុជាដែនកើត ។ ព្រះថេរៈសម្តែងទុក្ខសច្ចដល់សារីបុត្រ នោះដោយពាក្យនោះ ។

បាទគាថាថា **តេសំ ហេតុំ តថាគតោ អាហ** សេចក្តីថា សមុទយ-សច្ច ឈ្មោះថា ហេតុនៃបញ្ចក្ខន្ធនោះ ព្រះថេរៈសម្តែងថា ព្រះតថាគតត្រាស់សមុទយសច្ចនោះផងដែរ ។

បាទគាថាថា **តេសញ្ច យោ និរោធោ ច** សេចក្តីថា ព្រះតថាគតត្រាស់ការរលត់ គឺការមិនប្រព្រឹត្តទៅនៃសច្ចៈទាំង ២ នោះផង ព្រះថេរៈសម្តែងនិរោធសច្ចដល់សារីបុត្រនោះដោយពាក្យនោះ ។ ឯមគ្គសច្ច លោកមិនបានសម្តែងទុកក្នុងគាថានេះ ក៏ឈ្មោះថាសម្តែងហើយដោយន័យ ។ ព្រោះថា កាលពោលនិរោធ មគ្គដែលជាហេតុឲ្យដល់និរោធនោះ ក៏ឈ្មោះថា ពោលផងដែរ ។

ម្យ៉ាងទៀត ក្នុងបាទគាថាថា **តេសញ្ច យោ និរោធោ** នេះ សច្ចៈ ២ ឈ្មោះថា ព្រះថេរៈសម្តែងហើយយ៉ាងនេះថា ការរំលត់នៃសច្ចៈទាំង ២ នោះ និងឧបាយនៃការរលត់នៃសច្ចៈទាំង ២ នោះដូច្នេះឯង ។ ឥឡូវនេះ ព្រះថេរៈកាលនឹងញុំាងអត្តនោះឯងឲ្យស៊ីគ្នា ទើបពោលថា ព្រះមហាសមណៈមានប្រក្រតីត្រាស់យ៉ាងនេះ ។

[๖๖-๖๙] បាទគាថាថា **ឯសោ ធម្មោ យទិ តាវនេវ** សេចក្តីថា បើធម៌ដែលក្រៃលែងជាងនេះមិនមានសោត ធម៌ប៉ុណ្ណេះប៉ុណ្ណោះ គឺគុណត្រឹមតែសោតាបត្តិផលប៉ុណ្ណោះ ខ្ញុំនឹងគប្បីសម្រេចដល់យ៉ាងនោះនូវធម៌នោះឯង

ខ្ញុំស្វែងរកហើយ ។

បាទគាថាថា **បច្ចព្យថា បឋមសោកំ** *សេចក្តីថា ពួកខ្ញុំត្រាច់ស្វែងរកផ្លូវដែលមិនមានសេចក្តីសោកណា លោកម្ចាស់ទាំងឡាយនោះឯង រមែងត្រាស់ដឹងផ្លូវដែលមិនមានសេចក្តីសោកនោះ អធិប្បាយថា ផ្លូវនោះ គឺលោកម្ចាស់ទាំងឡាយសម្រេចហើយ ។*

កន្លះគាថាថា **អនិដ្ឋំ អព្ភុតិតំ ពហុកេហិ កប្បនេហុតេហិ** *សេចក្តីថា ផ្លូវដែលមិនមានសេចក្តីសោកនេះ ឈ្មោះថា ខ្ញុំទាំងឡាយមិនឃើញហើយនោះឯង អស់កាលកន្លងមកច្រើននហុតនៃកប្ប សារីបុត្តបរិព្វាជកសម្តែងសេចក្តីដែលខ្លួនមានការវិនាសធំអស់កាលជ័យូរ ព្រោះហេតុដែលមិនបានឃើញផ្លូវនោះដោយប្រការដូច្នេះ ។*

[๗๑] *បាទគាថាថា* **គម្ភីរេ ញាណវិសយេ** *សេចក្តីថា ជាធម៌ដ៏ជ្រាលជ្រៅផង ជាវិស័យនៃញាណដ៏ពន្ធឹកផង ។*

បាទគាថាថា **អនុត្តរេ ឧបធិសង្ខយេ** *បានដល់ ព្រះនិព្វាន ។*

បទថា **វិមុត្តេ** *សេចក្តីថា បុគ្គលនោះផុតហើយដោយវិមុត្តិ មាននិព្វាននោះជាអារម្មណ៍ ។*

បទថា **ព្យាកាសិ** *សេចក្តីថា ព្រះសាស្តាកាលត្រាស់ថា គូនៃសម្ងាញ់នោះ នឹងជាគូអគ្គសាវក ជាគូដ៏ចម្រើនរបស់តថាគត ដូច្នេះ ឈ្មោះថា ទ្រង់ព្យាករហើយនូវគូនៃសម្ងាញ់ ក្នុងសាវកបារមីញាណ ។*

[๗๒] *បទថា* **សា វ តេសំ អាយស្មន្តានំ ឧបសម្បទា អហោសិ**

สេចក្តីថា ឯហិភិក្ខុឧបសម្បទានោះឯង បានជាឧបសម្បទារបស់លោកទាំង ๒ មួយអន្លើដោយបរិសុទ្ធ ។

ឯក្នុងព្រះថេរៈទាំង ๒ ដែលឧបសម្បទាហើយយ៉ាងនោះ ព្រះមហាមោគ្គល្លានត្ថេរបានសម្រេចព្រះអរហត្ត ក្នុងរយៈពេល ๗ ថ្ងៃ ព្រះសារីបុត្រកន្លះខែ ទើបបានសម្រេចព្រះអរហត្ត ។

បានឮថា ក្នុងអតីតកាល ព្រះពុទ្ធព្រះនាមថា អនោមទស្សីកើតឡើងក្នុងលោក ។ តាបសឈ្មោះសរទៈ បានធ្វើមណ្ឌបដោយផ្ការីឈើផ្សេងៗ ត្រង់អាស្រមរបស់ខ្លួន ដើម្បីព្រះសម្ពុទ្ធអង្គនោះ យាងព្រះមានព្រះភាគប្រថាប់លើអាសនៈផ្កានោះឯង ធ្វើមណ្ឌបយ៉ាងនោះឯង រៀបចំអាសនៈផ្កាសម្រាប់កិក្ខុសង្ឃផងដែរ ហើយប្រថ្នាជាអគ្គសាវក កាលប្រថ្នាហើយ ទើបឲ្យដំណឹងទៅដល់សេដ្ឋី ឈ្មោះសិរិវឌ្ឍនៈថា ខ្ញុំបានប្រថ្នាតំណែងអគ្គសាវកហើយ សូម្បីឯង ក៏ចូរមកប្រថ្នាតំណែងមួយ ។ សេដ្ឋីធ្វើមណ្ឌបអំពីផ្កាឧប្បលខៀវ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឆាន់ក្នុងមណ្ឌបនោះ កាលឆាន់ស្រេចហើយ បានប្រថ្នាជាទុតិយសាវក ក្នុងជនទាំង ๒ នោះ សរទតាបសបានមកជាព្រះសារីបុត្រ សិរិវឌ្ឍនសេដ្ឋី បានជាព្រះមហាមោគ្គល្លាន ដូច្នេះឯងបុព្វកម្មរបស់អគ្គសាវកទាំង ๒ នោះ មានប្រមាណប៉ុណ្ណេះ[๑] ។

[๗๓] *វិនិច្ឆ័យក្នុងបទថា* **អបុត្តកតាយ** *ជាដើម ដូចតទៅនេះថា ព្រះសមណគោតមបដិបត្តិដើម្បីភាពដែលជនទាំងឡាយ ដែលមានបុត្របួសត្រូវជាអ្នកគ្មានបុត្រ ដើម្បីភាពដែលស្រីទាំងឡាយ ដែលមានប្តីបួសត្រូវជា*

មេម៉ាយ គឺត្រូវជាអ្នកឥតប្តី ។ ដើម្បីចូលទៅកាត់បង់នូវត្រកូលដោយអាការ ២ យ៉ាង ។

បទថា **សញ្ញយានិ** *គឺ បុគ្គលដែលជាអន្តេវាសិករបស់សញ្ជ័យ ។*

ពីរបទថា **មាគធានំ គិរិព្វជំ** *សេចក្តីថា កាន់គិរិព្វជនគររបស់អ្នកមគធៈទាំងឡាយ ។*

[๗๔] បទថា **មហាវីរា** *បានដល់ អ្នកមានសេចក្តីព្យាយាមធំ ។*

បទថា **ឥយមានានំ** *សេចក្តីថា គ្រាកុលបុត្រទាំងឡាយដែលព្រះអង្គទូន្មាន ។*

បទថា **ឥយមានានំ** *នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ម្យ៉ាងទៀត ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។*

បាទគាថាថា **កា ឧសុយ្យា វិជានតំ** *សេចក្តីថា នឹងត្រូវប្រណែនអ្វីកាលដឹងយ៉ាងនេះថា ព្រះតថាគតទាំងឡាយ ទ្រង់ដឹកនាំដោយធម៌ ។*

សារីបុត្តមោគ្គល្លានបព្វជ្ជា ចប់

๑- សេចក្តីនេះ មានក្នុងធម្មបទ តែក្នុងអបទានលោករចនាថា សារីបុត្រឈ្មោះសុរុចិតាបស ព្រះមហាមោគ្គល្លាន ជាស្តេចនាគឈ្មោះអរុណ ។

อุปชฌายวัตรกถา

[๗๗] สมัยนั้นแล ภิกษุทั้งหลายมิได้มีอุปัชฌาย์ ไม่มีผู้ให้นิสัย ไม่มีผู้ให้ศึกษา ความเป็นอยู่ก็มิได้เป็นไปตามควร ความประพฤติก็มิได้เป็นไปตามควร ทั้งบาตรและจีวรก็มิได้ปรารถนาให้ถึงพร้อม ได้พากันเที่ยวไปบิณฑบาตในเวลาวิกาล มนุษย์ทั้งหลายเห็นแล้วพากันติเตียนว่า ไฉนพวกสมณะสากยบุตรจึงมิได้มีอุปัชฌาย์ ... ฯลฯ ... ได้พากันเที่ยวไปบิณฑบาตในเวลาวิกาลเล่า ความเป็นอยู่ของพวกสมณะสากยบุตรเหล่านี้ ก็มิได้เป็นไปตามควร ความประพฤติก็มิได้เป็นไปตามควร ทั้งบาตรและจีวรก็มิได้ปรารถนาให้ถึงพร้อม ได้พากันเที่ยวไปบิณฑบาตในเวลาวิกาลเล่า ภิกษุทั้งหลายได้ยินมนุษย์เหล่านั้นพากันติเตียนอยู่ ... ฯลฯ ... ได้กราบทูลเรื่องนั้นแด่พระผู้มีพระภาค ฯ

[๗๘] ภิกษุทั้งหลาย ได้ยินพวกมนุษย์เหล่านั้นพากันติเตียนอยู่ ... ฯลฯ ... ได้กราบทูลเรื่องนั้นแด่พระผู้มีพระภาคแล้ว ฯ ภิกษุใดมีความละอาย

สนฺตาส มานสเจตฺตีฆาส ជាអ្នករង្កៀស ប្រាថ្នាក្នុងការរៀនសូត្រ ពួកភិក្ខុ នោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរបើស្បៀក ពាក់ក៏មិនត្រឹមត្រូវ មានឫកមារយាទមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រសម្រាប់សុំ ទៅលើកោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅលើខាទនីយខ្លះ បង្អោនបាត្រ សម្រាប់សុំទៅលើវត្តុសម្រាប់ភ្ងក្សខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើទឹក សម្រាប់ផឹកខ្លះ សូមសម្លខ្លះ បាយខ្លះ ដោយខ្លួនឯងហើយបរិភោគ មាន សំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្ទាំងនៅក្នុងរោងបាយខ្លះ (ជូចេ្នះ) ឡើយ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

[๗๙] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំ ភិក្ខុសង្ឃហើយទ្រង់សួរបញ្ជក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុ ស្បៀកជណ្តប់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ ត្រាច់ទៅដើម្បី បិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រ សម្រាប់សុំទៅលើកោជនខ្លះ បង្អោនបាត្រសម្រាប់សុំ ទៅខាងលើខាទនីយខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើវត្តុសម្រាប់ភ្ងក្សខ្លះ បង្អោនបាត្រសម្រាប់ សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសម្លខ្លះ បាយខ្លះ ដោយខ្លួនឯងហើយ បរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្ទាំងនៅក្នុងរោងបាយខ្លះ ពិត មែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះដ៏ មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ (អំពើនោះ) មិនសមគួរ

มิនត្រូវទំនង៑ មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគួរ មិនត្រូវធ្វើ ទ្បើយ ម្នាលភិក្ខុទាំងឡាយ ចុះហេតុអ្វី បានជាមោយបុរសទាំងនោះស្បៃក ជណ្តប់ក៏មិនឲ្យត្រឹមត្រូវ មានអាកប្បរិយាមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលមនុស្សទាំងឡាយកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រ សម្រាប់សុំទៅខាងលើកោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើ ខាទនីយខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើវត្ថុសម្រាប់ភ្លក្សខ្លះ បង្អោន បាត្រសម្រាប់សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសម្លខ្លះ បាយខ្លះ ដោយ ខ្លួនឯងហើយបរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវសំឡេងខ្ទាំងក្នុងរោងបាយខ្លះ ម្នាលភិក្ខុទាំងឡាយ ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ ជ្រះថ្លាផង មិននាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតផង ម្នាលភិក្ខុទាំងឡាយ ការនេះ នាំឲ្យពួកជនដែលមិនទាន់ជ្រះថ្លាឲ្យខានជ្រះថ្លា ទៅវិញផង នាំពួកជនខ្លះដែលជ្រះថ្លាស្រាប់ហើយឲ្យប្រែប្រួលផ្តេសផ្តាសទៅ វិញផង ។

[៨០] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលភិក្ខុទាំងនោះ ដោយអនេកបរិយាយ ហើយទ្រង់សម្តែងនូវទោសនៃសភាពជាបុគ្គលដែល គេចិញ្ចឹមបានដោយលំបាក គេរក្សាបានដោយលំបាក សេចក្តីប្រាថ្នាធំ មិន សន្តោស សេចក្តីច្រឡូកច្រឡំដោយពួកគណៈ សេចក្តីខ្ជិល ទើបទ្រង់ពោល សរសើរគុណនៃសភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយងាយ គេរក្សាបាន ដោយងាយ សេចក្តីប្រាថ្នាតិច សេចក្តីសន្តោស កម្ចាត់បង់នូវកិលេស ដុស

ฆาต์จิตฺต สេចក្តីជ្រះថ្លា មិនសន្សំនូវកិលេសវដ្តៈ និងសេចក្តីប្រារព្ធព្យាយាម ដោយព្រះពុទ្ធជីកាជាអនេកបរិយាយ រួចទ្រង់ធ្វើធម្មីកថាដ៏ល្មមសមគួរដល់ហេតុនោះៗ ចំពោះភិក្ខុទាំងឡាយ ទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបជ្ឈាយ៍ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវយកចិត្តទុកជាក់ក្នុងសទ្ធិវិហារិកឲ្យដូចជាកូន សទ្ធិវិហារិកត្រូវយកចិត្តទុកជាក់ក្នុងឧបជ្ឈាយ៍ឲ្យដូចជាបិតា ឧបជ្ឈាយ៍ និងសទ្ធិវិហារិកនោះប្រកបដោយសេចក្តីគោរពកោតក្រែងដល់គ្នានិងគ្នា មានការចិញ្ចឹមជីវិតស្មើគ្នាយ៉ាងនេះ នឹងដល់នូវសេចក្តីចម្រើន សេចក្តីលូតលាស់ សេចក្តីទូលំទូលាយក្នុងធម្មវិនัยនេះ ฯ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកគប្បីកាន់យកឧបជ្ឈាយ៍ដោយទំនងយ៉ាងនេះ ฯ សទ្ធិវិហារិកត្រូវគ្រងចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងទាំងឡាយ រួចហើយអង្គុយច្រហោងផ្គងឡើងនូវអញ្ជលី រួចពោលយ៉ាងនេះនឹងឧបជ្ឈាយ៍ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជាឧបជ្ឈាយ៍របស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ចូរជាឧបជ្ឈាយ៍របស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ចូរជាឧបជ្ឈាយ៍របស់ខ្ញុំ ฯ ឧបជ្ឈាយ៍ត្រូវពន្យល់សទ្ធិវិហារិកឲ្យដឹងដោយកាយ (ឬ) ឲ្យដឹងដោយវាចា (ឬ) ឲ្យដឹងទាំងកាយទាំងវាចា ដោយពាក្យថា សាហុ (កម្មនេះប្រពៃហើយក្តី) លហុ (ពាក្យនេះមិនជាការធ្ងន់អ្វីទេក្តី) ឱបាយិកំ (កម្មនេះជាឧបាយជាទីរំខ្ជិនចេញក្តី) បដិរូបំ (កម្មនេះសមគួរហើយក្តី) បាសាទិកេន សម្បាទេហិ (អ្នកចូរញុាំងកម្មឲ្យបរិបូណ៌ដោយកាយ និងវាចា គួរជាទីនាំមកនូវ

สเจ ปกฺกมิตุกาโม โหติ ฯเปฯ อาปตฺติ ทุกฺกฏสฺสา (อย่างนี้) เรียกว่า สัทธิวิหาริกกำลังจะหลีกไปแล้ว (แต่ยังไม่ได้หลีกไป) ไม่บอกอุปัชฌาย์ (ก็ดี) ไม่ลาอุปัชฌาย์ (ก็ดี) ไม่ขับสัทธิวิหาริกให้ไปด้วยกาย หรือด้วยวาจา หรือด้วยกายและวาจา (อย่างนี้) เรียกว่า สัทธิวิหาริกไม่กำลังจะหลีกไปแล้ว ฯ

[๘๑] ดูก่อนภิกษุทั้งหลาย สัทธิวิหาริกควรประพฤติชอบในอุปัชฌาย์ ฯ การประพฤติชอบในอุปัชฌาย์นั้น (เป็นอย่างนี้) ฯ สัทธิวิหาริกควรลุกขึ้นแต่เช้าตรู่ ถือรองเท้าและร่มแล้วไปสู่ที่ใกล้ ๆ อุปัชฌาย์ (ก็ดี) ควรถือไม้ชำระฟันและน้ำล้างหน้าไปด้วย ครั้นถึงแล้วควรวางไว้ในที่สมควร ควรเข้าไปหาอุปัชฌาย์ (ก็ดี) ถ้าอุปัชฌาย์มีบาตรและจีวร สัทธิวิหาริกควรถือบาตรและจีวรของอุปัชฌาย์ (ไว้) ในมือข้างหนึ่ง ควรถือไม้ชำระฟันและน้ำล้างหน้าของอุปัชฌาย์ (ไว้) ในมือข้างหนึ่ง ควรให้น้ำล้างหน้าแก่อุปัชฌาย์ ควรเช็ดหน้าด้วยผ้าเช็ดหน้า

ឲ្យជ្រះហើយសឹមប្រគេន ថាបើឧបជ្ឈាយ៍ប្រាថ្នានឹងយកខ្លួនទៅជាមួយជាបច្ចាសមណៈផង សទ្ធិវិហារិកនោះត្រូវស្បៃកជណ្តប់ឲ្យមានបរិមណ្ឌល ៣ ស្បៃកស្បង់ឲ្យជាបរិមណ្ឌល ចងវត្តពន្ធចង្កេះហើយឃ្ពុំសង្ឃាដិទាំងឡាយ ដែលបានត្រួតគ្នាហើយ រួចពាក់ឡើវក្នុំ លាងជាត្រ ហើយកាន់ធ្វើជាបច្ចាសមណៈ (ដើរទៅតាមខាងក្រោយឧបជ្ឈាយ៍) សទ្ធិវិហារិកមិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក សទ្ធិវិហារិកគប្បីទទួលយកវត្តុដែលគេជាក់ចុះក្នុងជាត្រ ឧបជ្ឈាយ៍កំពុងពោល សទ្ធិវិហារិកមិនត្រូវនិយាយស្តាត់ពាក្យនោះឡើយ ឧបជ្ឈាយ៍កំពុងពោលនូវពាក្យជាទំនងនឹងត្រូវអាបត្តិ សទ្ធិវិហារិកត្រូវឃាត់ សទ្ធិវិហារិកត្រូវត្រឡប់មកមុនឧបជ្ឈាយ៍ហើយក្រាលអាសនៈចាំ ត្រូវរៀបចំទុកទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ ក្បឿងសម្រាប់ជូតជើងដែលមិនបានលាង ហើយក្រោកឡើងទទួលយកជាត្រ ចីវរប្រគេនសំពត់ផ្ទាស់ ទទួលយកស្បង់ ។ ថាបើចីវរសើមដោយញើសក្អែលសទ្ធិវិហារិកត្រូវសំដិលក្នុងទីមានកម្តៅបន្តិចសិន មិនត្រូវទុកដាក់ចីវរក្នុងទីមានកម្តៅយូរទេ ត្រូវតែបត់ចីវរទុកដោយល្អ កាលដែលនឹងបត់ចីវរ ត្រូវបំផ្លើសជាយម្ខាងឲ្យលើសប្រមាណ ៤ ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យចីវរបាក់ផ្តត់ពាក់កណ្តាលឡើយ ហើយគប្បីដាក់វត្តពន្ធចង្កេះក្នុងផ្តត់ចីវរចុះ ។ ថាបើបិណ្ឌបាតមាន ឧប្បាយ៍ត្រូវការនឹងធាន់ សទ្ធិវិហារិកត្រូវប្រគេនទឹក ហើយសឹមបង្អោនបិណ្ឌបាតប្រគេន សទ្ធិវិហារិកត្រូវសួរឧបជ្ឈាយ៍អំពីទឹកធាន់ហើយប្រគេនទឹកដល់ឧបជ្ឈាយ៍ដែលធាន់រួចហើយ រួចទទួលជាត្រ

យកមកដោយសេចក្តីខ្មិនលំទោន ហើយលាងដោយប្រពៃកុំឲ្យទង្គិច ហើយ
ធ្វើឲ្យស្ងួតទឹករួចហាលថ្មត្រមួយស្រេបក់ក្នុងទីមានកម្តៅ តែមិនត្រូវទុកថ្មត្រ
ក្នុងទីមានកម្តៅយូរពេកទេ ត្រូវតម្កល់ទុកនូវថ្មត្រ និងចីវរឲ្យល្អ កាលតម្កល់
ទុកនូវថ្មត្រ ត្រូវកាន់យកនូវថ្មត្រដោយដៃម្ខាង ហើយយកដៃម្ខាងស្ទាបមើល
ទីជាខាងក្រោមនៃគ្រែក្តី នូវទីជាខាងក្រោមនៃតាំងក្តី ហើយសឹមទុកជាក់ថ្មត្រ
(នោះ) ចុះ តែមិនត្រូវតម្កល់ទុកថ្មត្រលើទីដែលមិនសមគួរ កាលតម្កល់
ទុកនូវចីវរសោត ត្រូវកាន់ចីវរដោយដៃម្ខាង ហើយយកដៃម្ខាងជូតស្បៃង
ចីវរក្តី ខ្សែសម្រាប់ពាក់ចីវរក្តី ហើយធ្វើនូវជាយនៃចីវរខាងនាយ ឲ្យជាផ្នត់
ខាងអាយ គឺបត់ចីពរជាពីរ ហើយតម្កល់ចីពរនោះទុក កាលបើឧបជ្ឈាយ៍
ក្រោកឡើងហើយ សទ្ធិវិហារិកត្រូវរើអាសនៈចេញ ហើយសឹមរៀបចំទឹក
សម្រាប់លាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង ថាបើទី
នោះមានសំរាម សទ្ធិវិហារិកត្រូវបោសទីនោះចេញ ។ បើឧបជ្ឈាយ៍ត្រូវការ
ស្រង់ទឹក គប្បីចាត់ចែងទឹកសម្រាប់ស្រង់ បើឧបជ្ឈាយ៍ត្រូវការដោយទឹក
ត្រជាក់ សទ្ធិវិហារិកគប្បីចាត់ចែងទឹកត្រជាក់ប្រគេន បើឧបជ្ឈាយ៍ត្រូវការ
ដោយទឹកក្តៅ សទ្ធិវិហារិកគប្បីចាត់ចែងទឹកក្តៅប្រគេន ។ បើឧបជ្ឈាយ៍មាន
សេចក្តីប្រាថ្នាចូលទៅកាន់រោងភ្លើង សទ្ធិវិហារិកត្រូវលាយគ្រឿងលម្អិត
សម្រាប់ងូត ត្រូវផ្សែមដីស្អិតទុក ត្រូវកាន់យកតាំងសម្រាប់តម្កល់ក្នុងរោង
ភ្លើង ហើយដើរទៅអំពីខាងក្រោយៗ នៃឧបជ្ឈាយ៍ ហើយប្រគេនតាំង
សម្រាប់រោងភ្លើង រួចត្រូវទទួលយកចីវរមកតម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវ

ប្រគេនគ្រឿងលម្អិតសម្រាប់ងូត ត្រូវប្រគេនដីស្អិតផង បើសទ្ធិវិហារិកអាច ត្រូវចូលទៅកាន់រោងភ្លើង កាលចូលទៅកាន់រោងភ្លើងត្រូវលាបមុខដោយ ដីស្អិត ហើយបិទបាំង (កាយ) អំពីខាងមុនផង អំពីខាងក្រោយផង ហើយចូលទៅកាន់រោងភ្លើងចុះ សទ្ធិវិហារិកមិនគប្បីអង្គុយច្រៀតបៀតកិកុ្ខទាំងឡាយជាថេរៈ មិនគប្បីហាមឃាត់កិកុ្ខថ្មីទាំងឡាយដោយអាសនៈឡើយ ត្រូវធ្វើបរិកម្ម (គឺកិច្ចទាំងពួងមានឲ្យនូវដីស្អិត និងទឹកក្តៅជាដើម) ដល់ឧបជ្ឈាយ៍ក្នុងរោងភ្លើង កាលចេញអំពីរោងភ្លើង ត្រូវនាំយកតាំងសម្រាប់រោងភ្លើងហើយបិទបាំង (កាយ) អំពីខាងមុខផង អំពីខាងក្រោយផង ហើយសឹមចេញអំពីរោងភ្លើងចុះ ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ក្នុងទឹកផង បើសទ្ធិវិហារិកងូតទឹករួចហើយ ត្រូវឡើងមុនឧបជ្ឈាយ៍ ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹក រួចសឹមស្លៀក ហើយទើបជូតទឹកអំពីកាយរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនសំពត់ស្លៀក ប្រគេនសង្ឃាដិ ហើយត្រូវកាន់យកតាំងសម្រាប់រោងភ្លើងមកជាមុន ហើយក្រាលអាសនៈ រៀបចំទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង កៀរជើងសម្រាប់ជូតជើង ត្រូវសួរឧបជ្ឈាយ៍អំពីទឹកឆាន់ ។ បើសទ្ធិវិហារិកមានសេចក្តីប្រាថ្នាដើម្បីរៀនបាលី គប្បីរៀនបាលីចុះ បើមានសេចក្តីប្រាថ្នាដើម្បីរៀនអដ្ឋកថា គប្បីរៀនអដ្ឋកថាចុះ ។ ឧបជ្ឈាយ៍នៅក្នុងវិហារណា បើវិហារនោះមានសំរាម បើសទ្ធិវិហារិកអាចធ្វើបាន វិហារនោះ សទ្ធិវិហារិកត្រូវជម្រះសម្អាត កាលដែលជម្រះសម្អាតវិហារ ត្រូវយកបាត្រ និងចីវរទៅតម្កល់ទុកក្នុងទីដ៏សមគួរជាមុនសិន ត្រូវនាំយកកម្រាលអង្គុយ

ទៅតម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូក និងខ្នើយទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកដែលនឹងនាំគ្រែចេញ ត្រូវធ្វើឲ្យទាបស្រួលកុំឲ្យទង្គិចទង្កៀតផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកដែលនឹងនាំតាំងចេញ ត្រូវធ្វើឲ្យទាបស្រួលកុំឲ្យទង្គិចទង្កៀតផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកដែលនឹងនាំតាំងចេញ ត្រូវធ្វើឲ្យទាបស្រួលកុំឲ្យទង្គិចទង្កៀតផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកត្រូវនាំយកទ្រនាប់គ្រែទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកត្រូវនាំកន្ទោរទៅតម្កល់ទុកក្នុងទីដ៏សមគួរ សន្ធិវិហារិកត្រូវនាំយកផែនក្តារសម្រាប់ផ្អែកទៅតម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវចំណាំឲ្យច្បាស់នូវគ្រឿងកម្រាលផែនដីដែលគេក្រាលយ៉ាងណា ហើយនាំទៅតម្កល់ទុកក្នុងទីដ៏សមគួរ បើគ្រឿងស្មុគស្មាញ (សំវាមមានសម្បុកកន្ទាត និងសរសៃពីងពាងជាដើម) មានក្នុងវិហារ សន្ធិវិហារិកត្រូវបោស តាំងអំពីពិតានជាមុនកន្ទៀតជ្រុងសន្ទះបង្អួច សន្ធិវិហារិកត្រូវជូតសម្អាត បើជញ្ជាំងដែលគេលាបដោយរងំមានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់សំពត់ ហើយពូត រួចសឹមជូតបើផ្ទៃដែលគេលាបដោយពណ៌ខ្មៅ មានពណ៌សៅហ្មង ត្រូវជ្រលក់សំពត់ហើយពូត រួចសឹមជូត បើផ្ទៃគេមិនបានលាបអ្វីទេ ត្រូវប្រោសទឹក ហើយសឹមជូត សន្ធិវិហារិកត្រូវប្រមែប្រមូលសំវាមយកទៅចោលក្នុងទីដ៏សមគួរ ដោយគិតថា វិហារកុំប្រឡាក់ប្រឡូសដោយធូលីឡើយ គ្រឿងកម្រាលផែនដី

ដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមកក្រាលដូចដើមវិញ ទ្រនាប់គ្រែដែលសទ្ធិវិហារិកយកទៅហាលថ្ងៃហើយ ជូតរួច ត្រូវយកមកតម្កល់ទុកក្នុងទីដដែល គ្រែដែលសទ្ធិវិហារិកហាលថ្ងៃ ជម្រះគោះរួច ត្រូវធ្វើឲ្យទាបស្រួលកុំឲ្យទង្គិចទង្គិកផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកមកជាក់រៀបចំទុកឲ្យល្អដូចពីដើមវិញ តាំងដែលសទ្ធិវិហារិកហាលថ្ងៃហើយជម្រះគោះហើយ ត្រូវធ្វើឲ្យទាបស្រួលកុំឲ្យទង្គិចទង្គិកនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅជាក់រៀបចំឲ្យល្អដូចពីដើមវិញ ពូក និងខ្នើយដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមករៀបចំឲ្យដូចពីដើមវិញ កម្រាលសម្រាប់អង្គុយដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមកក្រាលឲ្យដូចពីដើមវិញ កន្ទារដែលសទ្ធិវិហារិកហាលថ្ងៃហើយ ជូតហើយនាំយកមកតម្កល់ទុកដូចដែលវិញ ផែនក្តារសម្រាប់ផ្អែកដែលសទ្ធិវិហារិកហាលថ្ងៃហើយ និងជូតហើយ ត្រូវនាំមកតម្កល់ទុកដូចដែលវិញ ជាត្រ និងចីវរសទ្ធិវិហារិកត្រូវតម្កល់ទុក កាលយកជាត្រទៅទុកជាក់ត្រូវកាន់ជាត្រដោយដៃម្ខាង ហើយយកដៃម្ខាងស្ទាបមើលទីខាងក្រោមនៃគ្រែក្តី ទីខាងក្រោមនៃតាំងក្តី ហើយសឹមទុកជាត្រចុះ មិនត្រូវទុកជាត្រលើទីមិនសមគួរឡើយ កាលយកចីវរទៅទុក ត្រូវកាន់ចីវរដោយដៃម្ខាង យកដៃម្ខាងជូតស្បៀងចីវរក្តី ខ្សែចីវរក្តី ហើយបត់ជាយខាងណោះ ឲ្យជាផ្នត់ចូលមកខាងណោះ (គឺបត់ចីវរជាពីរ) ហើយតម្កល់ទុកនូវចីវរចុះ ។ បើខ្សល់បក់ទាំងធូលីមកអំពីទិសខាងកើត សទ្ធិវិហារិកត្រូវបិទបង្អួចទិសខាង

เกิด *บ่อยๆ* *ทั้งกลางวันและกลางคืน* *ภิกษุนั้นพึงทำอย่างไร* *ภิกษุนั้นพึงทำอย่างนี้* *คือ* *ภิกษุนั้นพึงเข้าไปหาภิกษุรูปหนึ่ง* *ผู้เป็นพหูสูต* *ผู้ทรงธรรม* *ผู้ทรงวินัย* *ผู้ทรงมาติกา* *ผู้ทรงปริยัติ* *ผู้ฉลาด* *ผู้สามารถ* *ผู้ไม่ขลาด* *ผู้ไม่เกียจคร้าน* *ผู้ปรารภความเพียร* *ผู้ปรารภความเพียรมั่นคง* *ผู้ไม่ทอดทิ้งความเพียร* *ผู้ปรารภความเพียรมั่นคงเป็นนิตย์* *ผู้ไม่ทอดทิ้งความเพียรเป็นนิตย์* *ผู้ประกอบด้วย

ដោយខ្លួនឯង ឬឲ្យភិក្ខុដទៃដោះស្រាយសេចក្តីយល់ខុសនោះចេញក៏បាន ឬត្រូវធ្វើធម្មកថាជល់ឧបជ្ឈាយ៍នោះ ។ បើឧបជ្ឈាយ៍ត្រូវគុកាបត្តិ គួរជល់បរិវាស សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយ ដោយគិតថា សង្ឃគប្បីឲ្យបរិវាសជល់ឧបជ្ឈាយ៍ (របស់អញ) ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរជល់កិរិយាទាញអន្តរាបត្តិ[1] មកជាក់ក្នុងមូលាបត្តិ[2] សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយ ដោយគិតថា សង្ឃនឹងទាញអន្តរាបត្តិមកជាក់ក្នុងមូលាបត្តិចំពោះឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរជល់មានត្តសទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃគប្បីឲ្យមានត្តជល់ឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរជល់អព្ភានកម្ម សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃនឹងឲ្យអព្ភានកម្មចំពោះឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ ។ បើសង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្ពាជនីយកម្មក្តី បដិសារណីយកម្មក្តី ខក្ខបនីយកម្មក្តី[3] ជល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃកុំគប្បីធ្វើកម្មជល់ឧបជ្ឈាយ៍ ឬសង្ឃគប្បីបង្អោនទៅដើម្បីកម្មស្រាលដោយឧបាយដូចម្តេចហ្ន៎ ម៉្យាងទៀត តជ្ជនីយកម្មក្តី និយស្សកម្មក្តី

๑- អន្តរាបត្តិ សំដៅយកគុកាបត្តិដែលភិក្ខុត្រូវក្នុងវេលាកំពុងប្រព្រឹត្តវត្តបរិវាស ។ ๒- មូលាបត្តិ សំដៅយកគុកាបត្តិដែលភិក្ខុត្រូវមកពីខាងដើម សេចក្តីថា ភិក្ខុកំពុងប្រព្រឹត្តបរិវាសមកច្រើនថ្ងៃហើយៗ ត្រូវគុកាបត្តិណាមួយទៀត ដោយបិទបាំងទុកនោះ សង្ឃត្រូវលុបថ្ងៃដែលបានប្រព្រឹត្តវត្តមកហើយនោះចេញ តាំងឲ្យប្រព្រឹត្តវត្តរាប់ថ្ងៃជាថ្មីទៅទៀត ។ ๓- កម្មទាំង ๕ យ៉ាងនេះនឹងមានសម្តែងដោយពិស្តារក្នុងកម្មក្ខន្ធកៈតទៅខាងមុខ ។

ปព្យាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដែលសង្ឃបាន ធ្វើដល់ឧបជ្ឈាយ៍ហើយ សទ្ធិវិហារិកត្រូវធ្វើសេចក្តីទ្រលំទ្វាយ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យឧបជ្ឈាយ៍របស់អញលោកប្រព្រឹត្តល្អទៅ គប្បីសម្អបរោម (កុំប្រកៃប្រកាន់) គប្បីប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម សង្ឃ គប្បីរម្ងាប់កម្មនោះចេញ (ដោយស្រួល) បើចីវររបស់ឧបជ្ឈាយ៍គួរនឹងលាង សទ្ធិវិហារិកត្រូវលាង ឬត្រូវធ្វើនូវសេចក្តីទ្រលំទ្វាយដោយគិតថា ធ្វើដូចម្តេច នឹងឲ្យគេលាងចីវររបស់ឧបជ្ឈាយ៍ បើចីវររបស់ឧបជ្ឈាយ៍គួរធ្វើ (មានប៉ះជេរជាដើម) សទ្ធិវិហារិកគប្បីធ្វើប្រគេន ឬត្រូវធ្វើសេចក្តីទ្រលំទ្វាយ ដោយគិតថា ធ្វើម្តេចហ្ន៎ នឹងឲ្យគេធ្វើចីវរប្រគេនឧបជ្ឈាយ៍ (របស់អញ) បើគ្រឿងជ្រលក់របស់ឧបជ្ឈាយ៍គួរចម្អិន សទ្ធិវិហារិកគប្បីចម្អិនប្រគេន ឬត្រូវ ធ្វើសេចក្តីទ្រលំទ្វាយថា ធ្វើម្តេចហ្ន៎ ជនណាមួយគេនឹងចម្អិនទឹកជ្រលក់ប្រគេន ឧបជ្ឈាយ៍ បើចីវររបស់ឧបជ្ឈាយ៍គួរជ្រលក់ សទ្ធិវិហារិកគប្បីជ្រលក់ ឬត្រូវ ធ្វើសេចក្តីទ្រលំទ្វាយថា ធ្វើម្តេចហ្ន៎ ជនណាមួយ គប្បីជ្រលក់ចីវររបស់ ឧបជ្ឈាយ៍ កាលនឹងជ្រលក់ចីវរត្រូវប្រែត្រឡប់ជ្រលក់ឲ្យសព្វល្អ បើតំណក់ ទឹកមិនទាន់ដាច់ទេ សទ្ធិវិហារិកមិនត្រូវចៀសចេញទៅឡើយ ។ សទ្ធិវិហារិក មិនបានប្រាប់ឧបជ្ឈាយ៍ មិនត្រូវឲ្យបាត្រដល់ភិក្ខុពួកខ្លះ (ភិក្ខុដែលមិនត្រូវ នឹងឧបជ្ឈាយ៍) ទេ មិនត្រូវទទួលយកបាត្ររបស់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យ ចីវរដល់ភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកចីវរភិក្ខុពួកខ្លះទេ មិនត្រូវឲ្យគ្រឿង បរិក្ខារដល់ភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកគ្រឿងបរិក្ខាររបស់ភិក្ខុពួកខ្លះទេ

មិនត្រូវកោរសក់ដល់កិកុពួកខ្លះទេ មិនត្រូវឲ្យកិកុពួកខ្លះកោរសក់ឲ្យទេ មិនត្រូវធ្វើបរិកម្មដល់កិកុពួកខ្លះទេ មិនត្រូវញុាំងកិកុពួកខ្លះឲ្យធ្វើបរិកម្មទេ មិនត្រូវធ្វើសេចក្តីខ្វល់ខ្វាយបម្រើដល់កិកុពួកខ្លះទេ មិនត្រូវញុាំងកិកុពួកខ្លះឲ្យធ្វើសេចក្តីខ្វល់ខ្វាយបម្រើខ្លួនទេ មិនត្រូវធ្វើជាបច្ឆាសមណៈនៃកិកុពួកខ្លះទេ មិនត្រូវយកកិកុពួកខ្លះជាបច្ឆាសមណៈទេ មិនត្រូវនាំយកបិណ្ឌបាតឲ្យដល់កិកុពួកខ្លះទេ មិនត្រូវញុាំងកិកុពួកខ្លះ ឲ្យនាំយកបិណ្ឌបាតមកឲ្យទេ ។ សទ្ធិវិហារិកមិនបានលាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុកទេ មិនត្រូវទៅកាន់ព្រៃស្មសានទេ មិនត្រូវចៀសចេញទៅកាន់ទិសឡើយ ។ បើឧបជ្ឈាយ៍មានជំងឺ សទ្ធិវិហារិកត្រូវបម្រើអស់មួយជីវិត ត្រូវរង់ចាំតែឧបជ្ឈាយ៍ចេញចាកអាពាធ (គឺត្រូវទ្រាំជំងឺជរាបទាល់ជា) ។

ឧបជ្ឈាយវត្ត ចប់

อัฏฐกถา

อุปัชฌายวัตรกถา

[๗๗] บทว่า **อนุปัชฌายกา** เสจกฺดีว่า เวียรจากครูอันเลสมีน โทสตูจ และโทสธัง ฯ

บทว่า **อนาคปฺปสมฺปนฺนา** ได้แก่ บุคคลอันเลมิได้แก่ถึงพร้อมด้วยมารยาท อธิบายว่า ประกอบด้วยมารยาทอันเลสมควรแก่สมณะ ฯ

[๗๙] บทว่า **อุปริโภชเน** ได้แก่ ข้างเลือแห่งโภชน ฯ

บทว่า **อุตฺติฏฺฐปตฺตํ** ได้แก่ บาตรสำหรับถ่ายเทเพื่อบิณฑ์ บิต เหือย มนุสฺสทั้งหลาย มีการสังเกตในบาตรนั้นว่า ชื่อสมณะ เพราะเหตุนั้น จึงเรียกว่า **อุตฺติฏฺฐปตฺตํ** ฯ อีกอย่างหนึ่ง ท่านพระสาริบุตรเถระ ประสงค์เอาเนื้อความในบทว่า **อุตฺติฏฺฐปตฺตํ** นี้ นั่นแหละ จึงกล่าวว่า ภิกฺขูนํ ปตฺตา ดังนี้ ฯ

[๘๐] บทว่า **อนุชานามิ ภิกฺขเว อุปชฺฌายํ** เสจกฺดีว่า ตถาคตอนุญาต ในกาลนี้ เพื่อให้ภิกษุทั้งหลายถือเอาอุปัชฌาย์ ฯ

บทว่า **ปุตฺตจิตฺตํ อุปฏฺฐเปสฺสติ** เสจกฺดีว่า พระอุปัชฌาย์จักตั้งจิตไว้ในบุตรด้วยอำนาจแห่งความรัก เหมือนบิดาและบุตรนี้ว่า บุคคลนี้เป็นบุตรของเรา ในบทนี้ ฯ

บทว่า **สคารวา สปฺปติสฺสา** เสจกฺดีว่า อุปัชฌาย์และสัทธิวิหาริก จักตั้งอยู่ในฐานะเป็นผู้เคารพและยำเกรงกันและกัน ฯ

បទថា **សភាគវុត្តិកោ** *បានដល់ មានភាពជាអ្នកនៅត្រូវចំណែកគ្នា ។*

ច្រាំបទ មានបទថា **សាហ្វាតិ វា** *ជាដើម ជាវេវចនៈនៃពាក្យទទួលជាឧបជ្ឈាយ៍ ។*

ពីរបទថា **ការយេន វិញ្ញាបេតិ** *សេចក្តីថា កាលសទ្ធិវិហារិកពោល ៣ ដងថា សូមលោកម្ចាស់ជាឧបជ្ឈាយ៍របស់ខ្ញុំចុះ ។ យ៉ាងនោះហើយ បើព្រះឧបជ្ឈាយ៍ទទួលការកាន់យកនូវឧបជ្ឈាយ៍ថា ឧបជ្ឈាយ៍ក៏អ្នកកាន់យកហើយ ដូច្នេះ ដោយកាយក្តី វាចាក្តី កាយវាចាក្តី ដោយអំណាចបទនីមួយៗ មាន* **សាហុ** *ជាដើម ឧបជ្ឈាយ៍ឈ្មោះថា សទ្ធិវិហារិកកាន់យកហើយ ។*

ពិតហើយ ការប្រើវាចាប្រកាសក្តី ការប្រើកាយកម្រើកឲ្យជ្រាបអត្ថក្តី នៃបទណាមួយ ក្នុងបទទាំង ៥ នេះ របស់ឧបជ្ឈាយ៍ នេះឯងជាការកាន់យកឧបជ្ឈាយ៍ ក្នុងពាក្យថា គប្បីកាន់យកឧបជ្ឈាយ៍នេះ ។ ឯកេចិអាចារ្យពោលសំដៅយកពាក្យទទួលថា **សាធុ** *ពាក្យរបស់កេចិអាចារ្យនោះ មិនជាប្រមាណ ។ ព្រោះថា ឧបជ្ឈាយ៍ រមែងឈ្មោះថា សទ្ធិវិហារិកកាន់យកហើយ ដោយហេតុត្រឹមតែពាក្យសូម និងពាក្យឲ្យ ពាក្យទទួល មិនរាប់ថាជាអង្គនៃការកាន់យកឧបជ្ឈាយ៍នេះ ។ ឯសទ្ធិវិហារិកគួរជ្រាបត្រឹមតែឧបជ្ឈាយ៍ ក៏អាត្មាអញកាន់យកហើយ ដោយបទនេះក៏ទេ គួរជ្រាបអត្ថនេះ ដោយពាក្យថា ឥឡូវនេះ មានថ្ងៃនេះជាដើម ព្រះថេរៈជាការៈអាត្មាអញ សូម្បីអាត្មាអញ ក៏ជាការៈរបស់ព្រះថេរៈ ។*

[๘๑] *បទថា* **តត្រាយំ សម្មាវត្តនា** *សេចក្តីថា ពាក្យណា ដែល*

តថាគតសម្តែងហើយថា គប្បីប្រព្រឹត្តប្រពៃ ការប្រព្រឹត្តប្រពៃក្នុងពាក្យនោះ ជួរច្នេះ ។

ច្រើនបទថា **กาลเสฺวว อุฏฺฐาย อุปชฺฌาโย ฉมฺภาเปตพฺโพ** *សេចក្តីថា បើស្បែកជើងរបស់សទ្ធិវិហារិកនោះ ដែលលោកពាក់ គឺជារបស់ដែលនៅក្នុងជើងដើម្បីប្រយោជន៍ដល់ការចង្រ្កមក្នុងពេលជិតភ្លឺ ឬដើម្បីប្រយោជន៍ដល់ការរក្សាជើងដែលលាងហើយ ។ គប្បីក្រោកឡើងអំពីព្រលឹម ដោះស្បែកជើងទាំងនោះចេញ ។*

បទថា **ขณฺฑกฏฺฐ ขาตพฺพ** *សេចក្តីថា គប្បីប្រគេនឈើសូន់ ๓ ខ្នាត គឺខ្នាតធំ ខ្នាតកណ្តាល ខ្នាតតូច អំពី ๓ ខ្នាតនោះ លោកកាន់យកខ្នាតណាគ្រប់ ๓ ថ្ងៃ តាំងអំពីថ្ងៃទី ๔ ទៅ គប្បីប្រគេនខ្នាតនោះប៉ុណ្ណោះ បើលោកកាន់យកតាមមានតាមបាន មិនមានកំណត់តទៅ បានប្រភេទណាមួយ គប្បីប្រគេនប្រភេទនោះ ។*

បទថា **มุโขทกํ ขาตพฺพ** *សេចក្តីថា គប្បីនាំចូលទៅ ទាំងទឹកត្រជាក់ និងទឹកក្តៅ លោកប្រើបែបណា អំពីទឹក ๒ យ៉ាងនោះគ្រប់ ๓ ថ្ងៃ តាំងអំពីថ្ងៃទី ๔ ទៅ គប្បីប្រគេនទឹកលាងមុខប្រភេទនោះប៉ុណ្ណោះ បើលោកប្រើតាមមានតាមបាន មិនកំណត់តទៅ បានប្រភេទណា គប្បីប្រគេនប្រភេទនោះ ។ បើលោកប្រើទាំង ๒ យ៉ាង គប្បីនាំយកទៅប្រគេនទាំង ๒ យ៉ាង គប្បីតម្កល់ទឹកទុកក្នុងទីលុបមុខហើយ គប្បីបោសប្រាសតាំងអំពីវច្ចកុដីមក ។ កាលព្រះថេរៈទៅវច្ចកុដិ គប្បីបោសបរិវេណ ដោយប្រការយ៉ាងនេះ*

បរិវេណឈ្មោះថា មិនទំនេរ ។ គប្បីរៀបចំអាសនៈទុក តែកាលព្រះថេរៈមិនទាន់ចេញអំពីវច្ចកុដិនោះឯង កាលលោកធ្វើសរីរកិច្ចស្រេច ហើយមកអង្គុយលើអាសនៈនោះ គប្បីធ្វើវត្តតាមដែលពោលហើយ ដោយន័យជាដើមថា បើបបរមាន គប្បីប្រគេន ។

បទថា **ឧក្កលាភោ** *សេចក្តីថា ដេរដាសដោយកាកសំណល់ឯណាមួយ តែបើមិនមានកាកសំណល់ដទៃ មានតែតំណក់ទឹក បទេសនោះ គួរជូតដោយដៃ ។*

ពីរបទថា **សគុណំ កត្វា** *សេចក្តីថា គប្បីត្រួតចីវរ ២ ផ្ទាំងចូលជាមួយគ្នាហើយ ប្រគេនសង្ឃាដីទាំង ២ ផ្ទាំងដែលត្រួតហើយនោះ ។ ពិតហើយ ចីវរទាំងអស់ ហៅថា សង្ឃាដី ព្រោះត្រួតគ្នា ។*

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គប្បីប្រគេនសង្ឃាដីទាំងឡាយ ។

ក្នុងបទថា **ឆាតិទ្ធរេ គន្តព្វំ ឆាទ្ធាសង្ខេ** *នេះ មានវិនិច្ឆ័យថា បើដោយជំហានត្រឹម ១ ជំហាន ឬ ២ ជំហាន នឹងទៅដល់ឧបជ្ឈាយ៍ដែលកំពុងសម្ងឹង ដោយរយៈមានប្រមាណប៉ុណ្ណេះ គប្បីជ្រាបថា ជាអ្នកដើរមិនឆ្ងាយពេក មិនជិតពេក ។*

បទថា **បត្តចរិយាបទំ បដិគ្គហេតព្វំ** *សេចក្តីថា បើឧបជ្ឈាយ៍បានបបរក្តី បាយក្តី ក្នុងទីកិក្ខាចារហើយ បាត្រក្តៅ ឬធ្ងន់ គប្បីឲ្យបាត្រខ្លួនដល់លោក ទទួលបាត្រនោះមក ។*

បទថា **ន ឧបជ្ឈាយស្ស អាណាមានស្ស អន្តរន្តរាកថា ឯថាតេតព្វោ** *សេចក្តីថា កាលឧបជ្ឈាយ៍កំពុងអង្គុយនិយាយក្នុងចន្លោះស្រុកក្តី ក្នុងទីដទៃក្តី កាលពាក្យរបស់លោកមិនទាន់ចប់ មិនគួរពោលកាត់រឿងដទៃឡើយ ។*

តាំងអំពីនេះទៅ ក្នុងទីណាមួយលោកធ្វើការហាម ដោយ **ន** *អក្សរៈ ដែលប្រែថា* **មិន** *ឬ* **កុំ** *ក្នុងទីនោះគ្រប់អន្លើ គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដ ។ ពិតហើយ សេចក្តីនេះ ជាធម្មតាក្នុងខន្ធកៈ ។*

បទថា **អាបត្តិសាមន្តា អាណាមាតោ** *សេចក្តីថា កាលឧបជ្ឈាយ៍ពោលវាចាជិតចំពោះអាបត្តិ ដោយអំណាចបទសោធម្មសិក្ខាបទ និងទុដ្ឋុល្ល-វាចាសិក្ខាបទជាដើម ។*

បទថា **និវារេតព្វោ** *សេចក្តីថា គប្បីហាមនូវការសាកសួរយ៉ាងនេះថា និយាយដូច្នេះ គួរឬ មិនត្រូវអាបត្តិឬ តែតាំងចិត្តថា នឹងហាមហើយ ក៏មិនគួរពោលនឹងលោកថា លោកធំ កុំពោលយ៉ាងនោះ ។*

បទថា **បឋមតរំ អាគន្ត្វា** *សេចក្តីថា បើស្រុកនៅជិតក្តី ក្នុងវិហារមានកិកូឈីក្តី គប្បីត្រឡប់អំពីស្រុកជាមុន ។ បើស្រុកនៅឆ្ងាយ មិនមានបុគ្គលណាមកជាមួយឧបជ្ឈាយ៍ គួរចេញអំពីស្រុក ព្រមគ្នាជាមួយលោកនោះឯង ហើយយកចីវរខូបច់បាត្រ ស្តាយប្រញាប់មកមុន អំពីកណ្តាលផ្លូវ កាលត្រឡប់យ៉ាងនេះ មកដល់មុនហើយ គប្បីធ្វើវត្តគ្រប់យ៉ាង មានក្រាលអាសនៈជាដើម ។*

ពីរបទថា **សិន្ធំ ហោតិ** *សេចក្តីថា ជារបស់ជប់ទឹក គឺសើមដោយ*

ញើស ។

បទថា **ចតុរង្គុលំ កណ្ណំ ឧស្សាទេត្វា** *សេចក្តីថា គប្បីធ្វើជ្រុងឲ្យលើសពីគ្នាប្រមាណ ៤ ធ្នាប់ ត្រូវបត់ចីវរយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះតាំងចិត្តមិនឲ្យបាក់ត្រង់កណ្តាល ។ ពិតហើយ ចីវរដែលបត់ឲ្យជ្រុងស្មើគ្នារមែងបាក់ត្រង់កណ្តាល ។ ចីវរដែលបត់ចំកន្លែងជដែលជានិច្ច ព្រោះបត់ជូច្នោះ រមែងគ្រាំគ្រា ។ ព្រះមានព្រះភាគត្រាស់សេចក្តីនេះ ដើម្បីការពារការខូចខាតនោះ ។ ព្រោះហេតុនោះ ក្នុងថ្ងៃស្អែក ចីវរនឹងមិនបត់ចំត្រង់ទីដែលបាក់ក្នុងថ្ងៃនេះ ដោយវិធីណា គប្បីបត់ឲ្យហួសគ្នា មួយថ្ងៃ ៤ ធ្នាប់ ដោយវិធីនោះ ។*

បទថា **ឯកោគេ កាយពន្ធនំ កាតព្ពំ** *សេចក្តីថា គប្បីក្រវាត់វត្តពន្ធចង្កេះ ស៊ីកទុកក្នុងផ្នត់ចីវរ ។*

បទថា **សចេ បិណ្ឌចារោ ហោតិ** *នេះ មានវិនិច្ឆ័យថា ឧបជ្ឈាយ៍ធាន់ក្នុងស្រុកនោះឯងក្តី ក្នុងចន្លោះស្រុកក្តី ក្នុងរោងធាន់ក្តី ហើយទើបមក ឬមិនបានបិណ្ឌ ។ បិណ្ឌបាតរបស់ឧបជ្ឈាយ៍នោះ ឈ្មោះថា មិនមាន តែរបស់ឧបជ្ឈាយ៍ដែលមិនបានធាន់ក្នុងស្រុក ឬដែលបានកិក្ខា ឈ្មោះថា មាន ។*

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា បើបិណ្ឌបាតមាន បើបិណ្ឌបាតរបស់លោកមិនមាន ហើយលោកប្រាថ្នានឹងធាន់ គប្បីប្រគេនទឹក ហើយបង្អោនប្រគេនបិណ្ឌបាតដែលខ្លួនបានហើយ ។

បទថា **ចានីយេន បុច្ឆិតព្ពោ** *សេចក្តីថា គប្បីសួរឧបជ្ឈាយ៍ដែល*

កំពុងធាន់ដល់ទឹកធាន់ ៣ ដងថា ខ្ញុំនាំទឹកធាន់មកបានឬទេ បើវេលាល្ងាម កាលឧបជ្ឈាយ៍ធាន់ស្រេចហើយ ខ្លួនឯងសឹមធាន់ ។ បើពេលជិតអស់ គប្បីតាំងទឹកធាន់ទុកក្នុងទីជិតឧបជ្ឈាយ៍ ហើយខ្លួនឯង គប្បីធាន់ដែរ ។

បទថា **អនន្តរហិតាយ** *សេចក្តីថា មិនគួរដាក់ជាត្រលើដី ដែលប្រឡាក់ដោយធូលី និងក្រួស មិនបានក្រាលដោយបណ្តាកម្រាល មានកន្ទេលទន់ និងកំណាត់ស្បែកជាដើមប្រភេទណាមួយ ។ បើទីដែលគេលាបម្រក់ក្បណ៌ ឬបូកជាយ-អ ឬមិនមានលម្អងធូលីដី ទោះដាក់លើផ្ទៃបៃបនោះ គួរ ។ បើដាក់លើខ្នាច់ដែលស្អាត ក៏គួរ ។ បើដាក់លើដីស្រួយ ធូលី និងក្រួសជាដើម មិនគួរ ។ តែគប្បីដាក់ស្វឹកឈើ ឬជើងជាត្រ លើវត្ថុទាំងនោះហើយ ទុកជាត្រលើស្វឹកឈើ ឬជើងជាត្រនោះចុះ ។*

ពាក្យថា ធ្វើនូវជាយនៃចីវរខាងនាយ ឲ្យជាផ្នត់ខាងអាយនេះ ព្រះមានព្រះភាគត្រាស់ដើម្បីស៊កដៃទៅខាងក្រោមស្នូចីវរជាដើមហើយ ពាក់សន្សឹមៗ ដោយដៃដែលនៅត្រង់មុខ ។ កាលចាប់ជាយទាំង ២ យកផ្នត់វាត់ឡើងទៅលើស្នូចីវរជាដើម ចុងផ្នត់រមែងប៉ះជញ្ជាំង ព្រោះហេតុនោះ ទើបមិនគួរធ្វើយ៉ាងនោះ ។

បទថា **ចុណ្ណំ សន្ថេតព្វំ** *សេចក្តីថា លម្អិតសម្រាប់ងូតទឹក គប្បីផ្សឹមដោយទឹកហើយ ពូតជាដុំ ។*

បទថា **ឯកមន្តំ និក្ខិបិតព្វំ** *សេចក្តីថា ចីវរគប្បីទុកចំពោះក្នុងទីដែលមិនមានផ្សែងភ្លើងទីណាមួយ ។ កិច្ចទាំងពួង មានឲ្យរងើកភ្លើង ដី និងទឹក*

ក្តៅជាដើម ឈ្មោះថា បរិកម្មក្នុងរោងភ្លើង ។

បទថា **ឧទកេបិបរិកម្មំ** *បានដល់ កិច្ចគ្រប់យ៉ាង មានដុសខ្លួនជាដើម ។*

បទថា **ចានីយេន បុច្ឆិតព្ពោ** *សេចក្តីថា ការស្រែក រមែងមានព្រោះការក្តៅស្អុះ ក្នុងរោងភ្លើង ព្រោះដូច្នោះ ទើបគួរសួរលោកអំពីទឹកធាន់ ។*

បទថា **សចេ ឧសុម្ភហាតិ** *សេចក្តីថា បើសទ្ធិវិហារិកអាច គឺជាអ្នកមិនត្រូវជំងឺតម្កាត់ឯណាមួយគ្របសង្កត់ ។ ពិតហើយ សទ្ធិវិហារិកអ្នកមិនមានជំងឺតម្កាត់ សូម្បីមានវស្សា ៦០ ក៏គួរធ្វើឧបជ្ឈាយវត្តគ្រប់យ៉ាង បើមិនធ្វើដោយមិនអើពើ ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ (ទម្ងាយវត្ត) កាលសទ្ធិវិហារិកជាអ្នកមានជំងឺ ទៅធ្វើការដែលទ្រង់ហាម ក្នុងបទទាំងឡាយដែលមានអក្ខរៈថា* **ន** *(មិន) ជាប់តាម ក៏ត្រូវទុក្កដដូចគ្នា ។*

បទថា **អបរិឃំសន្តេន** *សេចក្តីថា កុំអូសទៅលើផែនដី ។*

បទថា **ករាជបិដ្ឋំ** *សេចក្តីថា កុំឲ្យប៉ះទង្គិចសន្ទះទ្វារ និងក្របបង្អួច ។*

បទថា **សន្តានកំ** *បានដល់ សម្បកកណ្តូប និងសរសៃពីងពាងជាដើមណាមួយ ។*

បទថា **ឧល្លោកា បឋមំ ឱការេតព្វំ** *សេចក្តីថា គប្បីបោសអំពីពិតានចុះមកមុន គឺចាប់ផ្តើមបោសពិតានចុះមក ។*

បទថា **អាលោកសន្ធិកណ្ណភាគា** *បានដល់ ចំណែកបង្អួច ទ្វារ និងចំណែកជ្រុងបន្ទប់ ។ អធិប្បាយថា គប្បីជូតសន្ទឹកបង្អួច និងសន្ទឹកទ្វារ ទាំងខាងក្នុង និងខាងក្រៅ និងជ្រុងទាំង ៤ នៃបន្ទប់ ។*

បទថា **យថាបញ្ញត្តំ បញ្ញាបេតព្វំ** *សេចក្តីថា កម្រាលផែនដីដើមគេក្រាលទុកយ៉ាងណា គប្បីក្រាលទុកឲ្យដូចយ៉ាងនោះ ។ ពិតហើយ ដើម្បីប្រយោជន៍នេះឯង ទើបទ្រង់បញ្ញត្តវត្តទី ១ ទុកថា គប្បីសង្កេតកម្រាលដើមទុក ហើយជញ្ជូនចេញទៅទុកត្រង់ចំណែកម្ខាង ។ បើគ្រឿងកម្រាលផែនដីនោះ ជារបស់បុគ្គលខ្លះដែលមិនយល់ បានក្រាលទុកមុន គប្បីក្រាលឲ្យឆ្ងាយជញ្ជាំងជុំវិញប្រមាណ ២-៣ ធ្នាប់ ។*

ឯទំនៀមនៃការក្រាលមានដូច្នេះថា បើមានកន្ទេលផែង តែធំពេក គប្បីកាត់ជាយបត់ដេរចងហើយ សឹមក្រាល បើមិនចេះបត់ជាយដេរចង កុំគប្បីកាត់ ។

បទថា **បុរត្ថិមា វាតថាលា ឋកេតព្វា** *សេចក្តីថា គប្បីបិទបង្អួចខាងកើត ។ បង្អួចដ៏សេសក៏គប្បីបិទយ៉ាងនោះ ។*

បទថា **វូបកាសេតព្វោ** *សេចក្តីថា ខ្លួនឯងគប្បីនាំទៅទីដទៃ ។*

បទថា **វូបកាសាបេតព្វោ** *សេចក្តីថា គប្បីពឹងពាក់ភិក្ខុដទៃថា សូមលោកជួយនាំព្រះថេរៈទៅទីដទៃចុះ បទថា* **វិវេចេតព្វំ** *សេចក្តីថា ខ្លួនឯងគប្បីពោលឲ្យលោកលះបង់ចេញ ។*

បទថា **វិវេចាបេតព្វំ** *សេចក្តីថា គប្បីពឹងអ្នកដទៃថា សូមលោកជួយនិយាយឲ្យព្រះថេរៈលះបង់ទិដ្ឋិផងចុះ ។*

បទថា **ឧស្សុក្កំ កាតព្វំ** *សេចក្តីថា ភិក្ខុនោះដែលសទ្ធិវិហារិកគប្បីចូលទៅរកសង្ឃ សូមដើម្បីឲ្យបរិវាស បើសទ្ធិវិហារិកជាអ្នកអាចដោយខ្លួន*

ឯង គប្បីឲ្យបរិវាសដោយខ្លួនឯង បើមិនប្រតិពល គប្បីពឹងភិក្ខុដទៃឲ្យជួយ ។

បទថា **កិន្តិ នុ ខោ** សេចក្តីថា ដោយឧបាយដូចម្តេចហ្ន៎ ។ មានន័យដូចគ្នាគ្រប់អន្លើ ។

បទថា **លហុកាយ វា បរិណាមេយ្យ** សេចក្តីថា សង្ឃមិនគប្បីធ្វើឧក្ខេបនីយកម្មឡើយ គប្បីធ្វើតជ្ជនីយកម្ម ឬនិយស្សកម្មជំនួស ។

ពិតហើយ សទ្ធិវិហារិកនោះបានជ្រាបថា សង្ឃប្រុងនឹងធ្វើឧក្ខេបនីយកម្មដល់ឧបជ្ឈាយ៍របស់ខ្លួន គប្បីចូលទៅរកភិក្ខុមួយរូប អង្វរថា សូមលោកម្ចាស់កុំធ្វើកម្មដល់ឧបជ្ឈាយ៍របស់ខ្ញុំឡើយ ។

បើភិក្ខុទាំងឡាយនឹងធ្វើតជ្ជនីយកម្ម ឬនិយស្សកម្មឲ្យបាន ។ គប្បីអង្វរលោកទាំងឡាយថា សូមកុំធ្វើឡើយ ។

បើភិក្ខុទាំងឡាយ នឹងធ្វើដោយខានមិនបាន ពេលនោះ គប្បីអង្វរឧបជ្ឈាយ៍ថា សូមលោកម្ចាស់ត្រឡប់ប្រព្រឹត្តតាមធម៌ចុះ ។

កាលអង្វរឲ្យលោកត្រឡប់ប្រព្រឹត្តប្រពៃបានយ៉ាងនេះហើយ គប្បីអង្វរភិក្ខុទាំងឡាយថា សូមរម្ងាប់កម្មចុះ ។ ពីរបទថា **សម្បរិវត្តកំ សម្បរិវត្តកំ** បានដល់ ប្រែត្រឡប់ទៅដោយជុំវិញ ។

បទថា **ន ច អច្ចិន្នេ ថេវេ បក្ខមិតព្ពំ** សេចក្តីថា បើទឹកជ្រលក់មានបន្តិចបន្តួច នៅតក់នៅឡើយ កុំគប្បីចៀសចេញទៅ ។

វត្តគ្រប់អន្លើ មានជាដើមថា មិនទាន់បានជ្រាប់ឧបជ្ឈាយ៍ កុំឲ្យបាត្រដល់ភិក្ខុពួកខ្លះ ដូច្នេះ ព្រះមានព្រះភាគត្រាស់សម្រាប់បុគ្គលដែលជាវិសភាគ

របស់ឧបជ្ឈាយ៍ ។

បទថា **ន อุปชฺฌายํ อนาปุจฺฉา คาเมา ปวิสิตพฺพา** *សេចក្តីថា សទ្ធិវិហារិកប្រាថ្នានឹងចូលទៅដោយបិណ្ឌបាត ឬដោយកវណីជនៃ គប្បីលាជាមុន សឹមចូលទៅ ។*

បើឧបជ្ឈាយ៍ បំណងនឹងក្រោកឡើងអំពីព្រលឹម ទៅបិណ្ឌបាតឆ្ងាយ គប្បីប្រាប់ថា ពួកភិក្ខុកំលោះ គប្បីចូលទៅបិណ្ឌបាតចុះ ហើយសឹមទៅ ។

បើឧបជ្ឈាយ៍មិនបានប្រាប់ ចេញទៅ សទ្ធិវិហារិកទៅដល់បរិវេណ មិនឃើញឧបជ្ឈាយ៍ ទោះចូលស្រុកក៏គួរ ។

បើកំពុងចូលទៅក្នុងស្រុក ហើយជួបឧបជ្ឈាយ៍ គួរពោលលាតាំងពីទីដែលជួបនោះឯង ។

បទថា **ន สุสานํ คนฺตพฺพํ** *សេចក្តីថា មិនទៅដើម្បីការនៅ ឬដើម្បីការមើល ។*

ក្នុងបទថា **ន ทิสา ปกฺกมิตพฺพา** *នេះ មានវិនិច្ឆ័យថា សទ្ធិវិហារិកដែលបំណងនឹងទៅ គប្បីប្រាប់ដល់កិច្ចការ ហើយអង្វរត្រឹមគ្រាទី ៣ ។ បើលោកអនុញ្ញាតជាការប្រពៃ បើមិនអនុញ្ញាត កាលឧបជ្ឈាយ៍អាស្រ័យភិក្ខុនោះ ឧទ្ទេសក្តី បរិបុច្ឆាក្តី កម្មដ្ឋានក្តី មិនសម្រេច (ព្រោះ) ឧបជ្ឈាយ៍ជាអ្នកល្ងង់ខ្លៅ មិនឈ្លាស មិនព្រមឲ្យទៅយ៉ាងនោះ ព្រោះប្រាថ្នានឹងឲ្យនៅក្នុងសម្នាក់របស់ខ្លួនតែម្យ៉ាង កាលឧបជ្ឈាយ៍មានសភាពដូច្នេះ សូម្បីឃាត់លើសអំពី ៣ ដងទៅ ក៏គួរ ។*

បទថា **វុដ្ឋានសប្ប អាគមេតព្ពំ** *សេចក្តីថា គប្បីរង់ចាំរហូតជាសះស្បើយអំពីជំងឺ មិនគួរទៅណាឡើយ បើមានភិក្ខុដទៃជាអ្នកព្យាបាល គប្បីរកថ្នាំមកប្រគល់ទុកក្នុងដៃរបស់លោក ហើយប្រាប់លោកថា ភិក្ខុនេះនឹងព្យាបាលលោកម្ចាស់ ហើយសឹមទៅ ។*

ឧបជ្ឈាយវត្តកថា ចប់

សទ្ធិវិហារិកវត្តកថា

[៨២] ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តឲ្យស្រួលល្អនឹងសទ្ធិវិហារិក ។ ឯការដែលប្រព្រឹត្តឲ្យស្រួលល្អនឹងសទ្ធិវិហារិកនោះ (ដូចសេចក្តីតទៅនេះ) ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវសង្រ្គោះ (ត្រូវទំនុកបម្រុង) ត្រូវអនុគ្រោះ (អាណិតអាសូរ) សទ្ធិវិហារិកដោយការបង្រៀនបាលីដោយអដ្ឋកថា (ពន្យល់នូវសេចក្តីនៃបាលី) ដោយឲ្យដំបូន្មាន (ដោយសេចក្តីពន្យល់ការខុសត្រូវជាមុន) ដោយពាក្យប្រៀនប្រដៅ (ដោយពាក្យរំលឹកជាស់តឿនរឿយៗ) ។ បើឧបជ្ឈាយ៍មានបាត្រ សទ្ធិ-វិហារិកគ្មានបាត្រត្រូវឧបជ្ឈាយ៍ឲ្យបាត្រទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្រលំ់ទ្រាយថា ធ្វើម្តេចហ្ន៎ សទ្ធិវិហារិកនឹងបានបាត្រ បើឧបជ្ឈាយ៍មានចីវរ សទ្ធិវិហារិកគ្មានចីវរ ត្រូវឧបជ្ឈាយ៍ឲ្យចីវរទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្រលំ់ទ្រាយ៉ាថា ចីវរបស់សទ្ធិវិហារិកគប្បីកើតឡើងដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍មានគ្រឿងបរិក្ខារ សទ្ធិវិហារិកគ្មានគ្រឿងបរិក្ខារ ត្រូវឧបជ្ឈាយ៍ឲ្យគ្រឿងបរិក្ខារទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្រលំ់ទ្រាយថា គ្រឿងបរិក្ខាររបស់សទ្ធិវិហារិក គប្បីកើតឡើងដោយឧបាយដូចម្តេចហ្ន៎ ។ បើសទ្ធិវិហារិកឈឺ ឧបជ្ឈាយ៍ត្រូវក្រោកពីព្រឹកឲ្យឈើសូន ឲ្យទឹកលុបមុខ ក្រាលអាសនៈបើមានបបរត្រូវឧបជ្ឈាយ៍លាងកាជន៍ ហើយដាក់បបរឲ្យទៅ កាលសទ្ធិវិហារិកដែលឈឺនោះហុតទឹកបបររួចហើយ ឧបជ្ឈាយ៍ត្រូវហុចទឹកឲ្យ រួចទទួលយកកាជន៍មកវិញដោយស្រួល

ប្រុលកុំឲ្យ ទង្គិចទង្គុកឡើយរួចលាងរៀបទុកជាក់ឲ្យល្អ កាលបើសទ្ធិវិហារិក ក្រោកចេញហើយ ឧបជ្ឈាយ៍ត្រូវរើអាសនៈចេញ បើកន្លែងនោះស្មោកគ្រោក ឧបជ្ឈាយ៍ត្រូវបោសកន្លែងនោះចេញ ។ បើសទ្ធិវិហារិកមានប្រាថ្នានឹងចូលទៅកាន់ស្រុក ឧបជ្ឈាយ៍ត្រូវឲ្យស្បង់សម្រាប់ស្លៀកទៅ ទទួលយកស្បង់បន្ទាស់នោះមកវិញ ត្រូវឲ្យកាយពន្ធគឺវត្តពន្ធចង្កេះ ត្រូវតម្រួតសង្ឃាដិជាពីរជាន់ហើយ សឹមឲ្យ ត្រូវលាងបាត្រដែលមានទឹកចេញហើយ សឹមឲ្យ ឧបជ្ឈាយ៍ត្រូវគិតថា សទ្ធិវិហារិកមុខជានឹងត្រឡប់មកវិញនៅពេលស្អែកនេះ ហើយក្រោលអាសនៈបម្រុងទុកឲ្យ ត្រូវតម្កល់ទឹកលាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង[1] ត្រូវក្រោកឡើងទៅទទួលបាត្រ និងចីវរ ត្រូវឲ្យស្បង់សម្រាប់ផ្ងាស់ ហើយទទួលយកស្បង់ដែលស្លៀកមកវិញ ។ បើចីវរសើមដោយញើស ឧបជ្ឈាយ៍ត្រូវសំដិលចីវរក្នុងកម្តៅថ្ងៃមួយស្របក់ម្យ៉ាងទៀត កុំទុកចីវរក្នុងកម្តៅថ្ងៃយូរពេក ត្រូវបត់ចីវរ (យកមកទុក) កាលបើឧបជ្ឈាយ៍បត់ចីវរ ត្រូវបំផ្លើសជាយចីវរឲ្យលើសពីគ្នាប្រមាណ ៤ ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យជាក់ផ្តត់ចីវរពាក់កណ្តាលឡើយ ហើយជាក់វត្តពន្ធចង្កេះ ក្នុងផ្តត់ចីវរចុះ ។ បើអាហារបិណ្ឌបាតមានហើយ សទ្ធិវិហារិកត្រូវការនឹងឆាន់ ឧបជ្ឈាយ៍ត្រូវឲ្យទឹកហើយហុចអាហារបិណ្ឌបាតទៅឲ្យ ឧបជ្ឈាយ៍ត្រូវសួរសទ្ធិវិហារិកអំពីទឹកឆាន់ សទ្ធិវិហារិកឆាន់ រួច

๑- បានដល់ តាំងសម្រាប់រងជើងដែលលាងរួចហើយ គឺតាំងថ្នាក់ខាងលើ ឯក្បឿងសម្រាប់ជូតជើងនោះ បានដល់ វត្ថុសម្រាប់ជូតជើង ដែលគេមិនត្រូវការលាង គឺរបស់អ្វីដែលគេសម្រាប់ជូត ។

ហើយ ឧបជ្ឈាយ៍ត្រូវហុចទឹកឲ្យ ហើយទទួលយកបាត្រមកវិញដោយស្រួល បួលកុំឲ្យទង្គិចទង្គឹកឡើយ ហើយលាងឲ្យស្អាត រួចជូតទឹកឲ្យស្ងួត ហើយត្រូវហាលថ្ងៃបានមួយស្របក់ ម្យ៉ាងទៀត មិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃយូរពេកទេ រួចត្រូវទុកជាក់បាត្រ និងចីវរ កាលដែលរៀបចំទុកជាក់បាត្រដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបមើលក្រោមគ្រែ ឬក្រោមតាំងហើយ សឹមទុកជាក់បាត្រ ម្យ៉ាងទៀត មិនត្រូវទុកជាក់បាត្រលើទីដែលមិនសមគួរឡើយ កាលដែលរៀបចំទុកជាក់ចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្បៀងចីវរ ឬខ្សែចីវរ ហើយបត់ជាយខាងណោះឲ្យជាផ្នត់មកខាងណោះ (គឺបត់ចីវរជាពីរ) ហើយសឹមទុកជាក់ចីវរ កាលសន្ធិវិហារិកក្រោកឡើងហើយ ឧបជ្ឈាយ៍ត្រូវរើអាសនៈចេញ រៀបចំទុកជាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ក្បឿងសម្រាប់ជូតជើង ប្រសិនបើកន្លែងនោះ ស្មោកគ្រោកដោយសំរាម ឧបជ្ឈាយ៍ត្រូវបោសកន្លែងនោះចេញ ។ បើសន្ធិវិហារិកចង់ងូតទឹក ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកសម្រាប់ងូតឲ្យ បើសន្ធិវិហារិកត្រូវការទឹកត្រជាក់ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកត្រជាក់ឲ្យ បើសន្ធិវិហារិកត្រូវការទឹកក្តៅ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកក្តៅឲ្យ ។ បើសន្ធិវិហារិកចង់ចូលទៅកាន់រោងភ្លើង ឧបជ្ឈាយ៍ត្រូវសូន្យលម្អិតសម្រាប់ងូតទឹកទុក ត្រូវផ្សែមដីស្អិតទុក រួចនាំយកតាំងសម្រាប់រោងភ្លើង ហើយប្រគល់តាំងសម្រាប់រោងភ្លើងទៅសន្ធិវិហារិក ស្រេចហើយ ទទួលយកចីវរមកទុកជាក់ដោយឡែក ហើយត្រូវឲ្យគ្រឿងលម្អិត ត្រូវឲ្យដីស្អិតទៅសន្ធិវិហារិក បើឧបជ្ឈាយ៍អាចនឹងចូលទៅកាន់រោងភ្លើង (ផង

*ปาน) คปฺปีจูลเทวกาน่เวนกฺเฬงจุ: กาลนีงจูลเทวกาน่เวนกฺเฬง ตฺรเว ยกฺกชีสฺนิตลาปมุข รูปจินฑุาีงพีขาีงมุขขาีงกฺรายย เหียยสีมจูลเทว กาน่เวนกฺเฬง มินตฺรเวหนฺคุยปฺรเตปฺรเตพูกกิกฺขุจาส่ มินตฺรเวหามพูกกิกฺขุ ขฺเชยหาสน: ขปชฺฌาย์ตฺรเวชฺเปกมฺมชล่สทฺธิวิหาริกกฺนีงเวนกฺเฬง กาล นีงจេញពីវេងក្លែងទៅ ត្រូវនាំយកតាំងសម្រាប់វេងក្លែងចេញហើយបិទបាំង ពីខាងមុខខាងក្រោយ រួចសឹមចេញពីវេងក្លែង សូម្បីក្នុងទឹកក៏ឧបជ្ឈាយ៍ត្រូវ តែធ្វើបរិកម្មជល់សទ្ធិវិហារិកដែរ កាលឧបជ្ឈាយ៍ងូតរួច ត្រូវឡើងមកមុន ហើយជូតកាយនៃខ្លួនឲ្យស្ងួតទឹក ហើយសឹមស្បៃកស្បង់ រួចត្រូវជូតទឹកអំពី កាយរបស់សទ្ធិវិហារិកទៀត ហើយហុចស្បង់សម្រាប់ស្បៃក ហុចសង្ឃាដិ ទៅឲ្យសទ្ធិវិហារិក រួចហើយ ត្រូវនាំយកតាំងសម្រាប់វេងក្លែងចេញមក ហើយក្រាលអាសន:ចាំជាមុន ឧបជ្ឈាយ៍ត្រូវតម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង ត្រូវសួរសទ្ធិវិហារិកអំពីទឹក ធាន់ ។ សទ្ធិវិហារិកនៅក្នុងវិហារណា បើវិហារនោះស្មោកគ្រោក បើឧបជ្ឈាយ៍ អាចនឹងសម្អាតបាន គប្បីសម្អាតវិហារនោះចេញ កាលនឹងសម្អាតវិហារ ត្រូវនាំយកជាត្រ និងចីវរចេញ ជាមុនទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយក កម្រាលសម្រាប់អង្គុយទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូក និងខ្នើយទៅ ទុកក្នុងទីដ៏សមគួរ ត្រូវបន្ទាបគ្រែឲ្យទាប កុំឲ្យត្រជុសនឹងផែនដី កុំឲ្យទង្គិច នឹងសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកចេញ ឲ្យស្រួលទៅទុកក្នុងទីដ៏សម គួរ ត្រូវបន្ទាបតាំងឲ្យទាប កុំឲ្យត្រជុសនឹងផែនដី កុំឲ្យទង្គិចទង្គុកសន្ទះទ្វារ

និងប្រកទ្វារ ហើយនាំយកចេញឲ្យស្រួលទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់គ្រែទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ទោរទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដ៏សមគួរ គ្រឿងកម្រាលផែនដី ត្រូវឧបជ្ឈាយ៍កំណត់ឲ្យចាំកន្លែងដែលគេក្រាលយ៉ាងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើក្នុងវិហារមានគ្រឿងស្មុគស្មាញ (មានសរសៃពីងពាងជាដើម) ត្រូវបោសអំពីពិតានចេញជាមុន ហើយត្រូវជូតសម្អាតកន្ទៀតជ្រុងសន្ទឹកបង្អួច បើជញ្ជាំងគេលាបដោយរង់ មានមន្ទិលសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ (ក្នុងទឹក) រួចពួតចេញហើយ សឹមជូត បើទីដែលគេលាបដោយពណ៌ខ្មៅមានមន្ទិលសៅហ្មង ត្រូវផ្សែមកំណាត់សំពត់ រួចពួតចេញ ហើយសឹមជូត បើទីដែលមិនបានលាបអ្វីទេ ត្រូវយកទឹកទៅប្រោសសិន ហើយសឹមបោសចេញ ត្រូវកំណត់ទុកក្នុងចិត្តថា វិហារមិនត្រូវឲ្យស្មោកគ្រោកដោយធូលីឡើយ ហើយប្រមូលសំរាមយកទៅចាក់ចោលដោយឡែក គ្រឿងកម្រាលផែនដីដែលហាលរួចហើយ ត្រូវគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលដូចដែលវិញ ទ្រនាប់គ្រែដែលហាលរួចត្រូវជូត (ឲ្យស្អាត) ហើយនាំយកទៅទុកនៅទីដដែលវិញ គ្រែដែលហាលរួចហើយ ដុសលាងគោះរួចហើយ ធ្វើឲ្យទាបស្រួល កុំឲ្យត្រជុសនឹងផែនដី កុំឲ្យទង្គិចទង្គឹកសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅរៀបទុកជាក់ដូចដែលវិញ តាំងដែលហាលរួចហើយ ត្រូវគោះ ហើយធ្វើឲ្យទាបស្រួលកុំឲ្យត្រជុសនឹងផែនដី កុំឲ្យទង្គិចទង្គឹកសន្ទះទ្វារ និងក្របទ្វារហើយនាំយកទៅរៀបទុកជាក់ដូចដែល

វិញ ពូក និងខ្នើយដែលហាលរួចហើយ ត្រូវគោះ រួចនាំយកទៅក្រោលដូច ដែលវិញ កម្រាលសម្រាប់អង្គុយដែលហាលរួចហើយ ត្រូវគោះ រួចនាំយក ទៅក្រោលទុកដូចដែលវិញ កន្ទោរដែលហាលរួចហើយ ត្រូវជូត រួចនាំយក ទៅទុកនៅទីដដែលវិញ ក្តារសម្រាប់ផ្អែកដែលហាលរួចហើយ ត្រូវជូត ហើយនាំយកទៅទុកនៅទីដដែលវិញ ត្រូវទុកជាត្រ និងចីវរ (ឲ្យល្អ) កាល នឹងទុកជាត្រ ដៃម្ខាងចាប់ជាត្រ ដៃម្ខាងស្ទាបក្រោមត្រែ ឬក្រោមតាំងមើល ហើយ សឹមទុកជាត្រ មិនត្រូវទុកជាត្រលើទីដែលមិនសមគួរឡើយ កាល នឹងទុកចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្បៀងចីវរ ឬខ្សែចីវរ ហើយបត់ ជាយខាងណោះមកខាងណេះ ឲ្យជាផ្នត់សិន រួចសឹមទុកចីវរចុះ ។ បើខ្យល់ បក់ធូលីមកពីទិសខាងកើត ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងកើត បើខ្យល់បក់ ធូលីមកពីទិសខាងលិច ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងលិច បើខ្យល់បក់ធូលី មកពីទិសខាងជើង ត្រូវបិទបង្អួចពីខាងជើង បើខ្យល់បក់ធូលីមកពីទិសខាង ត្បូង ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីទិសខាងត្បូង បើរដូវត្រជាក់ ឧបជ្ឈាយ៍ត្រូវ បើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ ឧបជ្ឈាយ៍ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកបង្អួចក្នុងវេលាយប់វិញ ។ បើទីបរិវេណ ស្មោកគ្រោក មិនស្អាត ឧបជ្ឈាយ៍ត្រូវបោសបរិវេណចេញ បើបន្ទប់ស្មោក គ្រោក មិនស្អាត ត្រូវបោសបន្ទប់ចេញ បើរោងសម្រាប់ឆាន់មិនស្អាត ត្រូវ បោសរោងសម្រាប់ឆាន់ចេញ បើរោងភ្លើងស្មោកគ្រោក ត្រូវបោសរោងភ្លើង ចេញ បើបង្គន់ស្មោកគ្រោក ត្រូវបោសសម្អាតបង្គន់ បើគ្មានទឹកសម្រាប់ឆាន់

ត្រូវតម្កល់ទឹកសម្រាប់ឆាន់ បើគ្មានទឹកសម្រាប់ប្រើប្រាស់ ត្រូវតម្កល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងភ្នមសម្រាប់លាងអាចម៍គ្មានទេ ត្រូវចាក់ទឹកទៅក្នុងភ្នមសម្រាប់លាងអាចម៍ ។ បើសទ្ធិវិហារិកមានសេចក្តីអផ្សុក ឧបជ្ឈាយ៍ត្រូវនាំចៀសចេញទៅកម្បាន្តដោយខ្លួនឯង ឬប្រើគេឲ្យនាំចៀសចេញទៅកម្បាន្តក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសទ្ធិវិហារិកមានសេចក្តីសង្រ្ស័យកើតឡើង ឧបជ្ឈាយ៍ត្រូវបន្ទោបង់ដោយខ្លួនឯង ឬរកគេឲ្យជួយបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសេចក្តីយល់ខុសកើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវដោះស្រាយ (ពន្យល់) ដោយខ្លួនឯង ឬប្រើគេឲ្យជួយដោះស្រាយ (ពន្យល់ឲ្យលះទិដ្ឋិនោះចេញ) ក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ ។ បើសទ្ធិវិហារិកត្រូវគុកាបត្តិគួរនឹងចូលបរិវាស ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្វល់ទ្វាយថា សង្ឃគួរឲ្យបរិវាសដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់កិរិយាទាញអន្តរាបត្តិមកជាក់ក្នុងមូលាបត្តិ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្វល់ទ្វាយថា សង្ឃគប្បីទាញអន្តរាបត្តិមកជាក់ក្នុងមូលាបត្តិ ចំពោះសទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មានត្ត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្វល់ទ្វាយថា សង្ឃគប្បីឲ្យមានត្តដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិ-វិហារិកគួរដល់អព្ភានកម្ម ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីទ្វល់ទ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្មចំពោះសទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ ។ បើសង្ឃចង់ធ្វើកម្មគឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ខក្ខ-

បនីយកម្មក្តី ដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា សង្ឃកុំ គប្បីធ្វើកម្ម ឬគប្បីបង្អោនទៅដើម្បីកម្មស្រាលដល់សទ្ធិវិហារិកដោយឧបាយ ដូចម្តេចហ្ន៎ បើជាកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់សទ្ធិវិហារិកនោះរួចទៅហើយ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា ធ្វើដូចម្តេចហ្ន៎ សទ្ធិវិហារិក គប្បីប្រព្រឹត្តដោយប្រពៃគប្បីសម្ងបរោម (កុំប្រកែកប្រកាន់) គប្បីប្រព្រឹត្តវត្តគួរក្នុងការរើខ្ជិនចេញអំពីអាបត្តិ សង្ឃគប្បីរម្ងាប់នូវកម្មនោះ ។ បើចីវរបស់សទ្ធិវិហារិកគួរនឹងលាង ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងគប្បីលាងយ៉ាងនេះ ឬគប្បីធ្វើសេចក្តីឲ្យល់ឲ្យាយថា ចីវរបស់សទ្ធិវិហារិកគួរនឹងលាងដូចម្តេចហ្ន៎ បើចីវរបស់សទ្ធិវិហារិកគួរនឹងធ្វើ (មានដេរប៉ះជាដើម) ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីធ្វើយ៉ាងនេះ ឬត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា ចីវរបស់សទ្ធិវិហារិកគួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់សទ្ធិវិហារិកគួរនឹងចម្ងិន ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងត្រូវចម្ងិនគ្រឿងជ្រលក់យ៉ាងនេះ ឬត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា គ្រឿងជ្រលក់របស់សទ្ធិ-វិហារិកគួរនឹងចម្ងិនដោយឧបាយដូចម្តេចហ្ន៎ បើចីវរបស់សទ្ធិវិហារិកគួរនឹងជ្រលក់ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីជ្រលក់ចីវរបែបនេះ ឬត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា ចីវរបស់សទ្ធិវិហារិកគួរនឹងជ្រលក់ដោយឧបាយដូចម្តេចហ្ន៎ កាលបើជ្រលក់ចីវរត្រូវជ្រលក់ដោយប្រែត្រឡប់ឲ្យសព្វស្មើល្អ ប្រសិនបើ

តំណក់ទឹកស្រក់មិនទាន់អស់ ឧបជ្ឈាយ៍កុំអាលដើរចេញ ។ បើសទ្ធិវិហារិក
មានជំងឺ ឧបជ្ឈាយ៍ត្រូវថែទាំអស់មួយជីវិត ត្រូវរង់ចាំលុះតែជាជំងឺ ។

សទ្ធិវិហារិកវត្ត ចប់

อัฏฐกถา

สทฺธิวิหาริกวตฺตกถา

[๘๒] *คប្បីជ្រាបវិនិច្ឆ័យក្នុងការដែលឧបជ្ឈាយ៍ប្រព្រឹត្តប្រពៃក្នុងសទ្ធិវិហារិកតទៅ បទថា* **សង្គហោតព្ពោ អនុគ្គហោតព្ពោ** *សេចក្តីថា ឧបជ្ឈាយ៍គប្បីធ្វើការជួយសង្គ្រោះ និងអនុគ្រោះសទ្ធិវិហារិកដោយកិច្ច មានឧទ្ទេសជាដើម ។ ក្នុងកិច្ច មានឧទ្ទេសជាដើមនោះ ឧទ្ទេសនោះ បានដល់ ការជ្រាប់បាលី ។ បរិបុច្ឆានោះ បានដល់ អត្ថនៃបាលី ។ ឱវាទនោះ បានដល់ ការពោលថា ចូរធ្វើយ៉ាងនេះ ចូរកុំធ្វើយ៉ាងនេះ ក្នុងកាលរឿងមិនទាន់កើត ។ អនុសាសនីនោះ បានដល់ ការពោលយ៉ាងនោះ ក្នុងកាលរឿងកើតហើយ ។ ប្រការមួយទៀត រឿង ទោះកើតក្តី មិនកើតក្តី ការពោលដំបូង ឈ្មោះថា ឱវាទ ការទូន្មានរឿយៗ ឈ្មោះអនុសាសនី ។*

បទថា **សចេ ឧបជ្ឈាយស្ស បត្តោ ហោតិ** *សេចក្តីថា បើអតិរេកបាត្រមាន មានន័យដូចគ្នាគ្រប់អន្លើ សមណបរិក្ខារដទៃ ឈ្មោះថា បរិក្ខារ ។ ការស្រាវជ្រាវរកឧបាយដែលកើតឡើង ដោយន័យដែលប្រកបដោយធម៌ ឈ្មោះថា ការខ្នះខ្នែងក្នុងសទ្ធិវិហារិកវត្តនេះ ។ បន្ទាប់ពីនេះទៅ វត្តចាប់តាំងពីឲ្យឈើសូនដល់ទីបំផុត បន្ថែមទឹកក្នុងឆ្នាំងជម្រះ ឧបជ្ឈាយ៍គួរធ្វើដល់សទ្ធិវិហារិកក្នុងកាលដែលមានជំងឺ ម្យ៉ាងទៀត កិច្ច មានការនាំត្រាច់ទៅដើម្បីរម្ងាប់ការអផ្សុកជាដើម សូម្បីសទ្ធិវិហារិកមិនឈឺ ឧបជ្ឈាយ៍គួរធ្វើពិត ។*

បទថា **ចីវរំ រជនេន** *សេចក្តីថា កាលបានស្តាប់ឧបាយអំពីឧបជ្ឈាយ៍ ថា គប្បីជ្រលក់យ៉ាងនេះ ហើយសឹមជ្រលក់ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។*

សទ្ធិវិហារិកវត្តកថា ចប់

សម្ភារវត្ថុជាធិកថា

[๘๓] សម័យនោះឯង ពួកសទ្ធិវិហារិកមិនបានប្រព្រឹត្តល្អ (គឺមិនបានយកចិត្តទុកជាក់) នឹងឧបជ្ឈាយ៍ទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសទ្ធិវិហារិកមិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍សោះ ។ គ្រានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកសទ្ធិ-វិហារិកមិនបានប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកសទ្ធិវិហារិកមិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ ។ ព្រះដ៏មានបុណ្យទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកមិនគួរនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ ភិក្ខុណាដែលមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ ត្រូវអាបត្តិទុក្កដ ។ ពួកសទ្ធិវិហារិកទាំងនោះក៏នៅតែមិនប្រព្រឹត្តល្អក្នុងឧបជ្ឈាយ៍ដដែល។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ទើបព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍ បណ្តេញសទ្ធិវិហារិក ដែលមិនបានប្រព្រឹត្តល្អចេញ ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវបណ្តេញសទ្ធិវិហារិកយ៉ាងនេះ គឺឧបជ្ឈាយ៍បញ្ជាក់ឲ្យដឹងដោយកាយ បញ្ជាក់ឲ្យដឹងដោយវាចា ឬទាំងកាយ ទាំងវាចាថា អញបណ្តេញអ្នកឯង ឥឡូវនេះក្តី ថាអ្នកឯងកុំចូលមកក្នុងទីនេះក្តី ថាអ្នកឯងចូរ

នាំយកជាត្រ និងចីវរ របស់អ្នកទៅក្តី ខ្លួនអញអ្នកឯងមិនត្រូវមកបម្រើទេក្តី (យ៉ាងនេះហៅថា) ឧបជ្ឈាយ៍បណ្តេញសទ្ធិវិហារិក (បើ) ឧបជ្ឈាយ៍មិនបានបញ្ជាក់ឲ្យដឹងដោយកាយ ឬដោយវាចា ឬទាំងកាយ ទាំងវាចា(យ៉ាងនេះហៅថា) ឧបជ្ឈាយ៍មិនបានបណ្តេញសទ្ធិវិហារិកទេ ។ សម័យនោះ ពួកសទ្ធិវិហារិកដែលឧបជ្ឈាយ៍បានបណ្តេញចេញ ហើយក៏មិនបានឲ្យឧបជ្ឈាយ៍អត់ទោសឲ្យវិញ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកសទ្ធិវិហារិក សូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យបាន ។ ពួកសទ្ធិវិហារិក នៅតែមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យឡើយ ។ ភិក្ខុទាំង-ឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលឧបជ្ឈាយ៍បណ្តេញចេញទៅហើយមិនគួរនឹងមិនសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យទេ សទ្ធិវិហារិកណាមួយមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យ ត្រូវអាបត្តិទុក្កដ។ គ្រានោះឯង ពួកឧបជ្ឈាយ៍កាលបើសទ្ធិវិហារិកទៅសូមខមាទោសវិញ ក៏មិនព្រមអត់ទោសឲ្យឡើយ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍អត់ទោសដល់សទ្ធិវិហារិក ។ ឧបជ្ឈាយ៍ទាំងនោះក៏មិនព្រមអត់ទោសឲ្យឡើយ ។ ឯពួកសទ្ធិវិហារិករត់ចេញទៅខ្លះ សឹកចេញទៅខ្លះ រត់ចូលពួកតិរ្ថិយខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់

លុះគង់ក្នុងទីដ៏សមគួរហើយ ព្រះបាទសុទ្ធោទនសក្យរាជ ក៏ទ្រង់មានព្រះរាជឱង្ការយ៉ាងនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណាសូមពរម្យ៉ាងអំពីព្រះដ៏មានព្រះភាគ ។ ព្រះសម្ពុទ្ធទ្រង់ ត្រាស់ថា បពិត្រព្រះគោតម[1] ព្រះតថាគតទាំងឡាយមានពរកន្ធងហើយ ។ ព្រះបាទសុទ្ធោទនសក្យរាជក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពរណាដែលគួរ ពរណាដែលមិនមានទោស (ខ្ញុំសូមពរនោះ) ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បពិត្រព្រះគោតម សូមព្រះអង្គមានព្រះបន្ទូលចំពោះពរនោះចុះ ។ ព្រះបាទសុទ្ធោទនសក្យរាជក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអង្គមកទ្រង់ព្រះផ្នួសហើយ ខ្ញុំព្រះករុណាកើតទុក្ខមិនមែនតិចទេ កាលដែលនន្ទ និងរាហុលមកបួស ក៏ខ្ញុំព្រះករុណាកើតទុក្ខខ្លាំងណាស់ដូច្នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីស្រឡាញ់រាហុលកុមារដូចជាកូនលើសពន់ប្រមាណ (ហាក់ដូចជា) កាត់នូវសម្បុរស្បែកក្រៅ លុះកាត់សម្បុរស្បែកក្រៅហើយ ក៏កាត់នូវស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ ក៏កាត់នូវសាច់ លុះកាត់សាច់ហើយ ក៏កាត់នូវសរសៃ លុះកាត់សរសៃហើយ ក៏កាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ ក៏ចុចរហូតដល់ខួរក្នុងឆ្អឹង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំសូមអង្វរថា លោកម្ចាស់ទាំងឡាយ កុំបំបួសកូនដែលមាតាបិតាមិនបានអនុញ្ញាតឡើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទសុទ្ធោទនសក្យរាជ ឲ្យឃើញ

១- ទ្រង់ហៅព្រះពុទ្ធបិតា តាមនាមគោត្រ គឺនាមត្រកូលរបស់ព្រះអង្គដែលហៅថា គោតម-គោត្រ ។

ច្បាស់ ឲ្យសមាទានទូវកុសលធម៌ដោយប្រពៃ ឲ្យក្លៀវក្លាឡើងដោយល្អ និង ឲ្យមានព្រះហឫទ័យរីករាយដោយធម្មីកថា ។ ឯព្រះបាទសុទ្ធោទនសក្យរាជ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទានទូវកុសលធម៌ ដោយប្រពៃ ឲ្យក្លៀវក្លាឡើងដោយល្អ និងឲ្យរីករាយដោយ ធម្មីកថាហើយ ក៏ក្រោកអំពីអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ (យាងវិលខាងស្តាំ) ហើយ ស្តេចចៀសចេញទៅ ។ ព្រោះនិទាននេះ ជំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយ មកទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ បុត្រដែលមាតានិងបិតាមិនបានអនុញ្ញាត ភិក្ខុមិនគប្បីបំបួសឡើយ បើភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ ។ លំដាប់ពីនោះមក ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងក្រុងកបិលវត្ថុតាមសមគួរ ដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិកឯក្រុងសាវត្ថី ទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ៗ ហើយ ទ្រង់បានដល់ទៅក្រុងសាវត្ថីនោះ ។ តាមតំណាលក្នុងនិទានថា ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងជេតវនារាមរបស់ អនាថបិណ្ឌិកសេដ្ឋីក្បែរក្រុងសាវត្ថី ។

[១១៩] សម័យនោះឯង ត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្រដ៏មានអាយុបញ្ជូនទារកទៅក្នុងសំណាក់ព្រះសារីបុត្រដ៏មានអាយុ ហើយនិយាយថា សូមព្រះថេរៈបំបួសទារកនេះឲ្យទាន ។ គ្រានោះ ព្រះសារីបុត្រដ៏មានអាយុត្រិះរិះគិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា ភិក្ខុមួយរូបមិនត្រូវឲ្យសាមណេរពីររូបបម្រើខ្លួន ឥឡូវភណ្ឌសាមណេរនេះ ជាសាមណេររបស់

อญฺ តើអញនឹងត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ព្រះសារីបុត្រក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមួយរូបដែលឈ្វាសប្រតិពល ឲ្យសាមណេរពីររូបបម្រើបាន ម៉្យាងវិញទៀត បើភិក្ខុនោះអាចទូន្មានប្រៀនប្រដៅសាមណេរប៉ុន្មានរូបបាន ឲ្យសាមណេរមានទាំងប៉ុណ្ណោះបម្រើក៏បានដែរ ។

[๑๒๐] គ្រាតពីនោះមក សាមណេរទាំងឡាយបានត្រិះរិះសេចក្តីនេះនឹងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្ន៎ ម៉្យាងទៀត យើងទាំងឡាយគួរសិក្សាក្នុងវិនយដូចម្តេចខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំងឡាយ ๑๐ ដល់សាមណេរទាំងឡាយ ម៉្យាងទៀត អនុញ្ញាតឲ្យសាមណេរទាំងឡាយសិក្សាក្នុងសិក្ខាបទទាំងឡាយជប់នោះ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ๑ ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ๑ ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ ๑ ចេតនាហេតុជាវៀរចាកកិរិយាពោលនូវពាក្យកុហក ๑ ចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ๑ ចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ๑ ចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ๑ ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់

តែងស្ថិតស្ថានឯរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ១ ចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ១ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់ ១ ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតនូវសិក្ខាបទទាំង ១០ នេះដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឲ្យពួកសាមណេរសិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នេះ ។

អដ្ឋកថា

រាហុលវត្ថុ

[១១៨] ក្នុងបទថា **យេន កបិលវត្ថុ តេន ចារិកំ បក្កាមិ** នេះ គប្បីជ្រាបអនុបុព្វីកថាដូចតទៅនេះ ៖ បានឮថា ចាប់តាំងពីថ្ងៃដែលព្រះពោធិ-សត្វយាងចេញអភិនេស្ក្រមណ៍ ព្រះបាទសុទ្ធោទនមហារាជទ្រង់ផ្ទៀងសោតៈទន្ទឹងចាំស្តាប់ដំណឹងនោះឯងថា កូនអញចេញទៅដោយបំណងថា នឹងត្រាស់ជាព្រះពុទ្ធ បានជាព្រះពុទ្ធហើយឬហ្ន៎ ព្រះរាជាទ្រង់ស្តាប់ការបំពេញព្យាយាមការត្រាស់ដឹងឯង និងពុទ្ធកិច្ចទាំងឡាយ មានញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅជាដើមរបស់ព្រះមានព្រះភាគ ទ្រង់បានឮថា ឥឡូវនេះ កូនរបស់អញអាស្រ័យក្រុងរាជគ្រឹះ ទើបត្រាស់ប្រាប់អមាត្យម្នាក់ថា ឯងចាស់ជរាហើយណាបា ឯងចូរបង្ហាញបុត្រដល់យើង ទាន់នៅរស់ អមាត្យទទួលថា សាធុ ហើយមានបុរស ១០០០ នាក់ជាបរិវារទៅកាន់ក្រុងរាជគ្រឹះ ថ្វាយបង្គំបាទាព្រះមានព្រះភាគ ហើយអង្គុយ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ធម្មកថាដល់អមាត្យនោះជ្រះថ្លា ទូលសូមបព្វជ្ជា និងឧបសម្បទាទីនោះ ព្រះមានព្រះភាគឲ្យអមាត្យនោះ ឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា ភិក្ខុនោះ មួយអន្ទឹដោយបរិស័ទសម្រេចអរហត្តហើយ បាននៅសោយសុខ ដែលកើតអំពីផលសមាបត្តិ ក្នុងទីនោះឯង ។ ព្រះរាជាទ្រង់បញ្ជូនទូតជនៃទៅ ៨ នាក់ទៀតដោយឧបាយនោះឯង ។ សូម្បីទូតទាំងអស់នោះ មួយអន្ទឹដោយបរិស័ទបានសម្រេចអរហត្តហើយ នៅក្នុងទីនោះឯង យ៉ាងនោះដូចគ្នា ។ មិនមាន

អ្នកណាក្រាបទូល សូម្បីត្រឹមតែដំណឹងដល់ព្រះរាជាថា ទូតទាំងនោះ មិនត្រឡប់មកវិញទេ ព្រោះហេតុនេះមួយៗ ។

គ្រានោះ ព្រះរាជា មានបំណងបញ្ជូនអមាត្យឈ្មោះកាឡុទាយីដែលកើតក្នុងថ្ងៃជាមួយនឹងព្រះពោធិសត្វ ទើបទ្រង់បញ្ជាតាមន័យមុននោះឯង ។ កាឡុទាយីក្រាបទូលថា បើទូលបង្គំទៅ ហើយបានបួស ទូលបង្គំនឹងបង្ហាញគឺនាំមក ព្រះរាជាបញ្ជូនកាឡុទាយីទៅថា សូម្បីបាឯងបួសហើយ ចូរបង្ហាញបុត្រដល់យើង កាឡុទាយីក៏មានបរិវារ ១០០០ ទៅហើយ មួយអន្ទឹងដោយបរិស័ទបានសម្រេចអរហត្តនោះដែរ ។ ថ្ងៃមួយ កាឡុទាយិភិក្ខុនោះកាលស្រូវទាំងពួង សម្រេចរៀបរយល្អហើយ មនុស្សក្នុងជនបទទាំងឡាយបញ្ឈប់ការងារអស់ហើយ ផ្កាឈើដែលកើតលើគោក កើតក្នុងទឹក រីកស្គុសស្គាយហើយ ក៏បានថ្វាយបង្គំព្រះមានព្រះភាគ ហើយពណ៌នាគុណនៃការយាងក្នុងផ្លូវដ៏សមគួរ ដែលទ្រង់នឹងត្រូវធ្វើដំណើរ ដោយគាថាប្រមាណ ៦០ គាថា ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា អ្នកពោលអ្វីហ្ន៎ ទើបកាឡុទាយិភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជជាព្រះបិតារបស់ព្រះអង្គ បានបញ្ជូនខ្ញុំព្រះអង្គមកថា យើងចាស់ជរាហើយ បាឯងចូរបង្ហាញបុត្រដល់យើង ទាន់យើងនៅរស់ ដូច្នេះ ជាការល្អណាស់ព្រះអង្គ សូមព្រះអង្គធ្វើនូវសេចក្តីអនុគ្រោះព្រះញាតិទាំងឡាយផងចុះ ឥឡូវនេះ ជាកាលដែលទ្រង់យាងទៅបាន ព្រះមានព្រះភាគត្រាស់ថា បើដូច្នោះអ្នកចូរប្រាប់សង្ឃ ភិក្ខុទាំងឡាយនឹងញុំាងគមិកវត្តឲ្យបរិបូណ៌ ។ ព្រះថេរៈ

ទូលថា **សាធុ ភនฺเต** ហើយធ្វើតាមព្រះតម្រាស់ ។ ព្រះមានព្រះភាគ ទ្រង់ហែហមហើយដោយព្រះខីណាស្រពទាំងអស់ ២ ម៉ឺនអង្គ គឺកុលបុត្រក្នុងអង្គ: និងមគធ: ១ ម៉ឺនរូប កុលបុត្រក្នុងក្រុងកបិលពស្តុ ១ ម៉ឺនរូប ។ ស្តេចចេញពីក្រុងរាជគ្រឹះ ចារិកទៅដោយមិនប្រញាប់ប្រញាល់ ដោយទ្រង់ធ្វើក្នុងព្រះទ័យថា តថាគតកាលដើរមួយថ្ងៃ ១ យោជន៍ ២ ខែ នឹងដល់ក្រុងកបិលពស្តុ ដែលមានរយៈផ្លូវ ៦០ យោជន៍ អំពីក្រុងរាជគ្រឹះ ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា **យេន กបิล-วตฺถุ เตน จาริกำ បกฺกามิ** ដូច្នេះ កាលព្រះមានព្រះភាគទ្រង់ចៀសចារិកទៅហើយយ៉ាងនោះ ព្រះឧទាយិត្ថេរធ្វើកត្តកិច្ចក្នុងនិវេសន៍របស់ព្រះបាទសុទ្ធោទនមហារាជ ចាប់តាំងអំពីថ្ងៃដែលព្រះមានព្រះភាគយាងចេញ ។ ព្រះរាជាទ្រង់អង្គាសព្រះថេរ: ហើយទ្រង់អប់បាត្រដោយខ្ជីមចន្ទន៍ និងដាក់ព្រះក្រយាហារដ៏ឧត្តមរហូតពេញ បង្អោនប្រគេនក្នុងដៃព្រះថេរ:ថា លោកម្ចាស់នឹងប្រគេនដល់ព្រះមានព្រះភាគ សូម្បីព្រះថេរ:រមែងធ្វើតាមពាក្យប្រាប់ទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់សោយបិណ្ឌបាតរបស់ព្រះរាជាប៉ុណ្ណោះ ក្នុងរវាងផ្លូវដោយប្រការដូច្នេះ ។

ឯព្រះថេរ: ក្នុងវេលាស្រេចកត្តកិច្ចរាល់ថ្ងៃ បានទូលព្រះរាជាថា ថ្ងៃនេះ ព្រះមានព្រះភាគយាងមកបានប៉ុណ្ណោះ និងបានបណ្តុះសទ្ធាក្នុងព្រះមានព្រះភាគឲ្យកើតឡើងដល់ស្តេចសក្យ:ទាំងឡាយ ដោយកថាបដិសំយុត្តដោយពុទ្ធគុណ ។

ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងឯតទគ្គ-ស្ថានថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងឡាយដែលញុំាងត្រកូលឲ្យជ្រះថ្លា ជាសាវ័ករបស់តថាគត កាឡុទាយី ជាឯតទគ្គៈ ដូច្នេះ ។

ឯសក្យរាជវិញ កាលព្រះមានព្រះភាគមិនទាន់យាងមកដល់ ទើបមានព្រះបំណងថា យើងទាំងឡាយ នឹងគាល់ព្រះញាតិដ៏ប្រសើររបស់ពួកយើង ទើបប្រជុំគ្នា កាលជ្រើសរើសទីប្រថាប់សម្រាប់ព្រះមានព្រះភាគ ទ្រង់កំណត់ថា អារាមរបស់សក្កៈ ឈ្មោះនិគ្រោធ គួរជាទីរីករាយ ទើបឲ្យធ្វើបជិជគ្គ-នវិធីទាំងពួង ក្នុងអារាមនោះ មានគ្រឿងក្រអូប និងផ្កាក្នុងដៃ ដើម្បីធ្វើការទទួល តែបញ្ជូនរាជកុមារ និងរាជកុមារី អ្នកនគរស្រែករក្រោយ ប្រជាប់ដោយអលង្ការទៅមុន បន្ទាប់អំពីនោះ បញ្ជូនពួកយុវរាជ និងយុវរាជនីទៅ ហើយទៅឯងក្នុងលំដាប់នៃពួកយុវរាជ និងយុវរាជនីទាំងនោះ បូជាដោយសក្ការៈ មានផ្កា និងលម្អិតជាដើម បានយាងព្រះមានព្រះភាគចូលកាន់និគ្រោធារាមនោះឯង ។

ព្រះមានព្រះភាគ មានព្រះខីណាស្រព ២ ម៉ឺនចោមរោម ប្រថាប់លើបវរពុទ្ធាសនៈដែលគេរៀបចំទុកក្នុងនិគ្រោធារាមនោះ ។ ពួកសក្យរាជ ជាមនុស្សមានៈ ប្រកាន់ខ្លួនពន់ពេក ។ ពួកសក្យរាជទាំងនោះ ត្រិះរិះថា សិទ្ធត្ថកុមារនៅក្មេងជាងពួកយើង ជាព្រះកនិដ្ឋា ជាព្រះភាគិនេយ្យ ជាព្រះឱរស ជាព្រះនត្តានៃពួកយើង ទើបបញ្ជាព្រះកុមារកំលោះៗ ថា ពួកអ្នកចូរថ្វាយបង្គំ ពួកខ្ញុំនឹងអង្គុយខាងក្រោយពួកអ្នក ។ កាលសក្យរាជទាំងនោះ

ប្រថាប់គង់យ៉ាងនោះហើយ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលនិស្ស័យ
របស់ពួកព្រះរាជាទាំងនោះ ហើយទ្រង់ពិចារណាថា ពួកព្រះញាតិមិនព្រម
ថ្វាយបង្គំតថាគត ណ្ហ៎ីយចុះ ឥឡូវនេះ តថាគតនឹងឲ្យព្រះញាតិទាំងនោះ
ថ្វាយបង្គំ ដូច្នេះហើយ ទ្រង់ចូលចតុត្ថជ្ឈានជាបាទនៃអភិញ្ញា ចេញហើយ
ហោះទៅឯកាន់អាកាសដោយឫទ្ធិ ទ្រង់បានធ្វើបាដិហារិយ៍ ដូចគ្នានឹងយមក-
ប្បាដិហារិយ៍ ត្រង់គល់នៃគណ្ឌម្ពព្រឹក្ស ហាក់បីដូចទ្រង់រោយធូលីដែលជាប់
ត្រង់ព្រះបាទ ចុះលើសីសៈនៃព្រះញាតិទាំងនោះ ។

ព្រះរាជាទ្រង់ឃើញអស្ចារ្យនោះ ទើបត្រាស់ថា បពិត្រព្រះមានព្រះភាគ
កាលព្រះអង្គ ដែលកីលៀងនាំចូលទៅដើម្បីថ្វាយបង្គំព្រាហ្មណ៍ក្នុងថ្ងៃមង្គល
ខ្ញុំព្រះអង្គ បានឃើញព្រះបាទរបស់ទ្រង់អណ្តែតទៅប្រតិស្ឋានលើសីសៈរបស់
ព្រាហ្មណ៍ ទើបថ្វាយបង្គំព្រះអង្គ នោះជាបឋមវន្ទនារបស់ខ្ញុំព្រះអង្គ ។ ក្នុង
ថ្ងៃវប្បមង្គល កាលព្រះអង្គផ្ទំលើព្រះទែនមានសិរី ត្រង់ម្ជុំព្រឹង ខ្ញុំព្រះអង្គ
ឃើញស្រមោលដើមព្រឹងមិនបានជ្រេរៅ ទើបថ្វាយបង្គំព្រះបាទ ន៎ុះជាទុតិយ
វន្ទនារបស់ខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញបាដិហារិយ៍ដែលមិនធ្លាប់
ឃើញនេះ សូមថ្វាយបង្គំបាទារបស់ព្រះអង្គ នេះជាតតិយវន្ទនារបស់ខ្ញុំ
ព្រះអង្គ ។

កាលព្រះមានព្រះភាគ ដែលព្រះបាទសុទ្ធោទនមហារាជថ្វាយបង្គំហើយ
សក្យៈសូម្បីមួយអង្គ ដែលឈ្មោះថា មិនថ្វាយបង្គំមិនមាន បានថ្វាយបង្គំ
ទាំងអស់អង្គនោះឯង ។

ព្រះមានព្រះភាគ ទ្រង់ញុាំងព្រះញាតិទាំងឡាយឲ្យថ្វាយបង្គំហើយ ទ្រង់ចុះអំពីអាកាស ប្រថាប់លើអាសនៈដ៏ប្រសើរដែលគេរៀបចំទុក ។ កាលព្រះមានព្រះភាគប្រថាប់គង់ហើយ ញាតិសមាគមបានជាអ្នកដល់នូវទីបំផុត គឺអស់នូវមានះ ព្រះញាតិទាំងពួង មានព្រះរាជហឫទ័យទន់ភ្លន់ អង្គុយប្រជុំគ្នាហើយ ។

លំដាប់នោះ មហាមេឃបង្អុរជោកក្នុរពស៌ពណ៌ក្រហមស្រែកចុះមកខាងក្រោម ទឹកសូម្បីមួយតំណក់ ធ្លាក់ចុះលើសរីរៈរបស់បុគ្គលណាមួយក៏មិនមាន ។ ព្រះញាតិទាំងពួងឃើញហេតុនោះហើយ បានជាអ្នកកើតអស្ចារ្យចម្លែកក្នុងចិត្ត ។

ព្រះមានព្រះភាគត្រាស់ថា ភ្លៀងជោកក្នុរពស៌ធ្លាក់ក្នុងញាតិសមាគមរបស់តថាគតក្នុងកាលនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងអតីតកាល ក៏ធ្លាក់បានហើយដូចគ្នា ហើយត្រាស់វេស្សន្តរជាតក ព្រោះឧបទ្ទវហេតុនេះ ។

ព្រះញាតិទាំងពួង ស្តាប់ធម្មទេសនាហើយ ក្រោកឡើងថ្វាយបង្គំ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ បុគ្គលសូម្បីតែម្នាក់ គឺព្រះរាជាក្តី មហាមាត្យក្តីដែលទូលថា ស្អែកនេះ សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំហើយទើបទៅក៏មិនមាន ។

ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគ មានភិក្ខុ ២ ម៉ឺនជាបរិវារស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងកបិលពស្តុ ។ បុគ្គលណាមួយ ក្រោកទទួល ហើយនិមន្តឬបានទទួលបាត្រក៏មិនមាន ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ឈរត្រង់សសរ

ឥន្ទ្រសាល[๑] ទ្រង់នឹកថា ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ទ្រង់ចារិកបិណ្ឌបាតក្នុងនគរនៃត្រកូលដូចម្តេចហ្ន៎ ទ្រង់បានយាងទៅកាន់ផ្ទះរបស់ពួកឥស្សរជនដោយខុសលំដាប់ឬ ឬក៏ស្តេចចារិកទៅដោយលំដាប់ច្រក ។

លំដាប់នោះ ទ្រង់មិនបានឃើញការទៅខុសលំដាប់នៃព្រះពុទ្ធ សូម្បីមួយអង្គ ទើបទ្រង់រំពឹងថា ឥឡូវនេះ វង្សនេះ ប្រពៃណីនេះ សូម្បីតថាគតក៏គួរលើកតម្កើង ហើយតទៅ សូម្បីសាវកទាំងឡាយរបស់តថាគត កាលយកលំអានតាមតថាគត នឹងញុំាងបិណ្ឌបាតចារិកវត្តឲ្យពេញបាន ហើយទ្រង់ត្រាច់បិណ្ឌបាតតាមលំដាប់ច្រក ចាប់ផ្តើមពីផ្ទះដែលទ្រង់ចូលទៅគ្រាចុងក្រោយ ។

មហាជនបានជំណឹងថា ព្រះបាទសិទ្ធត្ថកុមារ ទ្រង់ត្រាច់បិណ្ឌបាត ទើបបើកបង្អួចក្នុងប្រាសាទ ๔ ជាន់ជាដើម បានជាអ្នកភ្លាក់ផ្អើលដើម្បីនឹងឃើញ ។

ឯព្រះទេវីភហុលមាតា ទ្រង់ចិន្តាថា បានឮថា ព្រះអយ្យបុត្រ ស្តេចត្រាច់ទៅដោយព្រះយាន មានសុវណ្ណសិវិកាជាដើម ដោយព្រះរាជានុភាពធំក្នុងព្រះនគរនេះឯង ឥឡូវនេះ ទ្រង់កាត់ព្រះកេសា និងព្រះមស្សុ ទ្រទ្រង់សំពត់កាសាវពស្ត្រ មានអំបែងក្នុងដៃ ត្រាច់បិណ្ឌបាត ។ ព្រះអង្គទ្រង់ល្អឬទេហ្ន៎ ឬទ្រង់មិនល្អទេ ។ ទើបព្រះនាងបើកព្រះសីហបញ្ជរទត ព្រះនាងឃើញព្រះមានព្រះភាគ មានលម្អរុងរឿងដោយព្រះពុទ្ធសិរី ទ្រង់ញុំាងនគរវិថីទាំងឡាយឲ្យភ្លឺដោយព្រះរស្មីជ័រុងរឿង ដោយរស្មីនានា ទើបព្រះនាងសរសើរ

๑- សសរបោះត្រង់កណ្តាលទ្វារ សម្រាប់ទប់សន្ទះទ្វារទាំង ๒ ដែលបិទ ។

ព្រះលម្អ ចាប់តាំងអំពីថ្ងាស រហូតដល់បាតជើង ដោយគាថា ៨ គាថា ដែលមានឈ្មោះថា នរសីហគាថា ហើយព្រះនាងទៅគាល់ព្រះរាជា ក្រាបបង្គំទូលដល់ព្រះរាជាថា ព្រះអយ្យបុត្ររបស់ព្រះអង្គទ្រង់យាងបិណ្ឌបាត ។ ព្រះរាជាទ្រង់ឮដំណឹងនោះ ទ្រង់ស្ទុតព្រះទ័យ ទ្រង់ស្ទៀកពាក់ព្រះភូសាបណ្តើរ ឲ្យរៀបរយដោយព្រះហស្ត ទើបទ្រង់ប្រញាប់យាងចេញទៅដោយរហ័ស ប្រថាប់ខាងមុខព្រះមានព្រះភាគទូលថា បពិត្រអយ្យបុត្រ ហេតុអ្វី ទើបទ្រង់ធ្វើខ្ញុំឲ្យបានទូវសេចក្តីខ្មាស ព្រះអង្គយាងបិណ្ឌបាតដើម្បីប្រយោជន៍អ្វី ព្រះអង្គបានជាអ្នកមានសេចក្តីសម្គាល់យ៉ាងនេះថា ភិក្ខុមានប្រមាណប៉ុណ្ណេះ មិនអាចបានភត្តឬ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ការត្រាច់បិណ្ឌបាតនេះ ជាចារិកសម្រាប់វង្សរបស់តថាគត ។

ព្រះរាជាសួរថា បពិត្រអយ្យបុត្រ ដែលឈ្មោះថា មហាសម្មតិខត្តិយ-វង្ស ជាវង្សរបស់ពួកយើងមិនមែនឬ ឯក្នុងខត្តិយវង្សនោះ ក្សត្រសូម្បីតែមួយអង្គ ឈ្មោះថា ជាអ្នកត្រាច់ភិក្ខា រមែងមិនមាន ។

ព្រះមានព្រះភាគត្រាស់ស្នងព្រះរាជឱង្ការថា បពិត្រមហារាជ ឈ្មោះថា រាជវង្ស ជាវង្សរបស់មហាបពិត្រ តែឈ្មោះថា ពុទ្ធវង្ស ជាវង្សរបស់តថាគត ព្រះពុទ្ធគ្រប់ព្រះអង្គបានជាអ្នកយាងបិណ្ឌបាតដូច្នេះ គង់ប្រថាប់ឈរក្នុងផ្លូវនោះឯង បានត្រាស់គាថានេះថា

បុគ្គលមិនគប្បីប្រមាទក្នុងដំបាយ ដែលខ្ជូនគប្បីក្រោកទៀន ទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជា

ประกฺรติ วเมติ ชเคกชาสุข กฺนฺติ โลเกนเมติ กฺนฺติ โลเกนาติ มุขเมติ ฯ

พระราชาทรงได้ทรงกระทำให้แจ้งซึ่งโสดาปัตติผล ในกาลเมื่อจบพระคาถา และได้ตรัสพระคาถานี้ว่า

บุคคลพึงประพฤติสุจริต ไม่พึงประพฤติทุจริตนั่น ให้เป็นสุขในโลกนี้ บุคคลประพฤติทุจริตเป็นประกติ ย่อมเกิดเป็นสุขในโลกนี้ และในโลกหน้าด้วย ฯ

ครั้นจบพระคาถาแล้ว ทรงดำรงอยู่ในสกทาคามิผล ทรงได้สดับพระธรรมบทแล้วทรงดำรงอยู่ในอนาคามิผล ในขณะแห่งมรณสมัย ทรงนั่งขัดสมาธิเหนือราชบัลลังก์ อันประเสริฐ ใต้ร่มเศวตฉัตร ได้ทรงทำให้แจ้งซึ่งพระอรหัตผล ก็กิจที่ควรทำด้วยความพยายามด้วยประการใดๆ ความพยายามในอนาคตไม่มีแก่พระราชาเลย ฯ ส่วนพระราชาทรงได้ทำให้แจ้งซึ่งโสดาปัตติผลนั้นแล้ว ได้ทรงถวายบังคมพระผู้มีพระภาคเจ้าแล้ว ได้เสด็จไปยังพระราชนิเวศน์ ทรงให้มหาทานแก่พระผู้มีพระภาคเจ้าพร้อมด้วยภิกษุสงฆ์ ๗ วัน ทรงอังคาสด้วยขาทนียะ และโภชนียะอันประณีต ฯ

ในเวลาที่ทรงกระทำกิจนั้นเสร็จ พวกสตรีในพระราชวัง มีพระนางวาสุลทัตตาเทวีเป็นประมุข ได้มาแล้วถวายบังคมพระผู้มีพระภาคเจ้า ทูลขอพระนางนั้นกับพระผู้มีพระภาคเจ้าว่า ขอพระผู้มีพระภาคเจ้าโปรดทรงรับถวายบังคมพระนางนั้นเถิด พระเจ้าข้า ได้ทรงสดับว่า ดูก่อนพระอานนท์ ถ้าเช่นนั้นเธอจงไปนำพระนางนั้นมาเถิด ดังนี้ ฯ

ដែលយាងមកហើយ ដូច្នេះ មិនបានយាងទៅ ។

ព្រះមានព្រះភាគ ទ្រង់ញុាំងព្រះរាជាឲ្យកាន់ចាត្រហើយ មួយអន្ទើដោយគួសាវ័ក យាងទៅបន្ទប់ដ៏មានសិរីរបស់ព្រះរាជធីតា ត្រាស់ថា ព្រះរាជធីតា ចូរថ្វាយបង្គំតាមពេញចិត្ត កុំគប្បីពោលស្តីថា ដោយប្រការណាឡើយ ហើយប្រថាប់គង់លើសេនាសនៈដែលគេរៀបចំទុក ។ ព្រះនាងយាងមកដោយរហ័ស ចាប់ត្រង់កព្រះបាទ ជាក់សីសៈលើខ្នងព្រះបាទ ថ្វាយបង្គំតាមព្រះអធ្យាស្រ័យ ។

ព្រះរាជាទូលជល់គុណសម្បត្តិ មានព្រះសិនេហៈ និងការរាប់អានច្រើនក្នុងព្រះមានព្រះភាគរបស់ព្រះរាជធីតា ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ មិនទាន់អស្ចារ្យទេ ការដែលព្រះរាជធីតាដែលព្រះបរមបពិត្រទ្រង់គ្រប់គ្រង ទើបរក្សាខ្លួនទុកបានក្នុងកាលព្រះញាណចាស់ក្លាហើយក្នុងឥឡូវនេះ ក្នុងកាលមុន នាងមិនមានគ្រប់គ្រង ត្រាច់ទៅទៀបជើងភ្នំ រក្សាខ្លួនទុកបាន ក្នុងកាលព្រះញាណមិនទាន់ចាស់ក្លា ដូច្នេះហើយ ត្រាស់ចន្ទកិន្នរីជាតក ។

ថ្ងៃនោះឯង ព្រះនន្ទរាជកុមារ មានមហាមង្គល ៥ យ៉ាង គឺស្រោយព្រះកេសា ចងព្រះសុវណ្ណបដ្ដ ឃរមង្គល អាវាហមង្គល និងឆត្តមង្គល ។

ព្រះមានព្រះភាគ ទ្រង់ញុាំងព្រះនន្ទកុមារឲ្យកាន់ចាត្រ ហើយត្រាស់មង្គល ទ្រង់ក្រោកចាកព្រះទីនិងចៀសចេញទៅ ។ គ្រានោះ នាងជនបទកល្យាណីឃើញព្រះកុមារកំពុងយាងទៅ ទើបទូលថា បពិត្រអយ្យបុត្រ សូម

ព្រះអង្គប្រញាប់យាងត្រឡប់មក ហើយអើតកសម្ងឹងមើល ។ សូម្បីនន្ទ-កុមារនោះ កាលមិនអាចប្រាប់ព្រះមានព្រះភាគថា សូមព្រះអង្គទ្រង់ទទួលបាត្រចុះ ទើបត្រូវយាងទៅដល់វត្តនោះឯង ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងនន្ទកុមារនោះ ដែលទ្រង់មិនប្រាថ្នាឡើយ ឲ្យបួស ។ ព្រះមានព្រះភាគ យាងមកកាន់កបិលបុរី ញ៉ាំងនន្ទកុមារឲ្យបួសក្នុងថ្ងៃទី ២ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ រាហុលមាតា ព្រះនាងតាក់តែងព្រះរាជកុមារ បញ្ជូនទៅកាន់សម្នាក់ព្រះមានព្រះភាគ ដោយប្រាប់ថា នែបា បាចូរឃើញសមណៈនោះ ដែលមានពណ៌ដូចមាស មានព្រះរូបវណ្ណៈរូបព្រហ្ម មានសមណៈ ២ ម៉ឺន ហែហមព្រះសមណៈនោះ ជាបិតារបស់បា ព្រះសមណៈនោះ មានរណ្តៅទ្រព្យធំ តាំងអំពីកាលដែលទ្រង់យាងចេញទៅ មាតាមិនបានឃើញទៅចុះបា ចូរទូលសូមជាទាយាទនឹងទ្រង់ថា បពិត្របិតា ខ្ញុំជាកុមារ នឹងលើកឆត្រ ហើយជាស្តេចចក្រពត្តិ ខ្ញុំត្រូវការទ្រព្យ សូមព្រះរាជទានទ្រព្យដល់ខ្ញុំចុះ ព្រោះថា កូន រមែងជាម្ចាស់ទ្រព្យរបស់បិតា ។

ព្រះរាជកុមារ លុះយាងទៅកាន់សម្នាក់ព្រះមានព្រះភាគ ក៏បែរជាបានសេចក្តីស្រឡាញ់ព្រះបិតា មានព្រះទ័យត្រេកអរវិកវាយ ទូលថា បពិត្រសមណៈ ម្ចប់របស់ព្រះអង្គនាំមកនូវសុខ ហើយបានឈរចរចាពាក្យដែលសមគួរដល់ខ្លួនជាច្រើនដងទៀតៗ ទៀត ។

ព្រះមានព្រះភាគ ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ធ្វើអនុមោទនា ស្តេច

ក្រោកចាកទីសេនាសនៈ ចៀសចេញទៅ ។

ឯព្រះកុមារបានយាងតាមព្រះអង្គ ទូលព្រះមានព្រះភាគថា បពិត្រសមណៈ សូមព្រះអង្គប្រទានទ្រព្យមត៌កដល់ខ្ញុំចុះ សូមព្រះអង្គប្រទានទ្រព្យមត៌កដល់ខ្ញុំចុះ ។

ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យពោលថា **អនុបុព្ពេន ចារិ-កញ្ចមានោ យេន กปิลวตฺถุ ฯเปฯ ตายฉฺ เม สมณา តេហิ** ដូច្នេះ ។

បទថា **អថ ខោ ภคฺคา អายสฺมนฺตំ สารีปุตฺตំ อามนฺเตสิ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់មិនញុំាងព្រះរាជកុមារឲ្យត្រឡប់ហើយ មួយអន្ទឹដោយបរិវារ ក៏មិនអាចញុំាងព្រះកុមារ ដែលយាងទៅជាមួយព្រះមានព្រះភាគ ឲ្យយាងត្រឡប់បាន ។

គ្រានោះ ព្រះមានព្រះភាគយាងទៅកាន់អារាម ហើយទ្រង់ត្រិះរិះថា រាហុលនេះ ប្រាថ្នាទ្រព្យរបស់បិតាណា ទ្រព្យនោះទាក់ទងដោយវដ្តៈ ប្រព្រឹត្តទៅដោយការចង្អៀតចង្អល់ ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ๗ ប្រការ ដែលតថាគតបានហើយ ត្រង់ពោធិមណ្ឌលដល់គេ និងធ្វើគេឲ្យជាម្ចាស់របស់មត៌កដែលជាលោកុត្តរ ដូច្នេះហើយ ហៅព្រះសារីបុត្រ ។

កាលត្រាស់ហៅមកហើយ ទ្រង់ត្រាស់ថា សារីបុត្រ បើដូច្នោះ អ្នកចូរញុំាងរាហុលកុមារឲ្យបួសចុះ អធិប្បាយថា រាហុលកុមារនេះ សូមទ្រព្យមត៌ក ព្រោះហេតុនោះ អ្នកចូរញុំាងរាហុលកុមារឲ្យបួស ដើម្បីបានចំពោះនូវទ្រព្យមត៌កដែលជាលោកុត្តរ ។ បព្វជ្ជា និងឧបសម្បទាដោយត្រៃសរណៈ-

គមន៍ណា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតឯក្រុងពារាណសី បណ្តាបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណាគមន៍នោះ ទ្រង់ហាមឧបសម្បទា ទ្រង់លើកទុកក្នុងភាពជារបស់ធ្ងន់ គឺជាកិច្ចសំខាន់ហើយ ទើបទ្រង់អនុញ្ញាតឧបសម្បទាដោយញត្តិចតុត្ថកម្ម ។ ឯបព្វជ្ជាទ្រង់មិនបានហាមទ្បើយ តែក៏មិនបានអនុញ្ញាតទៀត ព្រោះហេតុនោះ សេចក្តីសង្ស័យនឹងកើតឡើងដល់កិក្ខុទាំងឡាយ ក្នុងអនាគតថា ឈ្មោះថា បព្វជ្ជានេះ ដូចគ្នានឹងឧបសម្បទាក្នុងកាលមុន ។ ទោះក្នុងឥឡូវនេះ បព្វជ្ជាដែលយើងទាំងឡាយគប្បីធ្វើដោយកម្មវាចានោះឯង ដូចឧបសម្បទាឬហ្ន៎ ឬថា គប្បីធ្វើដោយត្រៃសរណាគមន៍ ដូច្នេះ ឯព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនេះហើយ ប្រោថ្នានឹងអនុញ្ញាតសាមណេរបព្វជ្ជា ដោយត្រៃសរណាគមន៍ទៀត ព្រោះហេតុនោះ ព្រះធម្មសេនាបតីជ្រាបអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ប្រោថ្នានឹងញុំងព្រះមានព្រះភាគឲ្យទ្រង់អនុញ្ញាតបព្វជ្ជាទៀត ទើបទូលថា ខ្ញុំព្រះអង្គញុំងរាហុលកុមារឲ្យបួសដូចម្តេច ព្រះអង្គ ។

បទថា **អថ ខោ អាយស្មា សារីបុត្តោ រាហុលកុមารំ បព្ពาเชสิ** សេចក្តីថា ព្រះមហាមោគ្គល្លានត្តេរកោរព្រះកេសារបស់កុមារហើយ ឲ្យសំពត់កាសាយៈ ព្រះសារីបុត្របានឲ្យសរណៈ ព្រះមហាកស្សបត្តេរបានជាឧវាទាចារ្យ ។ បព្វជ្ជា និងឧបសម្បទា មានឧបជ្ឈាយ៍ជាមូល ឧបជ្ឈាយ៍ប៉ុណ្ណោះជាធំ ក្នុងបព្វជ្ជា និងឧបសម្បទានោះ អាចារ្យមិនជាធំ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យពោលថា គ្រានោះឯង ព្រះសារីបុត្រដ៏មានអាយុញុំងរាហុលកុមារឲ្យបួសហើយ ដូច្នេះ ។ ដោយប្រការយ៉ាងនេះ ពាក្យទាំងពួង

ដែលអ្នកសិក្សាគប្បីពោលថា គ្រានោះឯង ព្រះបាទសុទ្ធោទនៈដ៏ជាសក្យរាជ ទ្រង់កើតការស្ទុតព្រះហប្ញទ័យ ព្រោះឮថា ព្រះកុមារបួសហើយ ក្នុងកាល ព្រះរាជាពោលថា ខ្ញុំសូមពរ ដូច្នេះ ដោយមិនប្រារព្ធបែបផែន ពាក្យថា ចូរ សូម ជាពាក្យមិនគួរដល់បព្វជិត ដែលចិញ្ចឹមជីវិតដោយឧញ្ឆាចរិយា (សូម ទានចិញ្ចឹមជីវិត) ទាំងព្រះពុទ្ធទាំងឡាយ ក៏ទ្រង់មិនប្រព្រឹត្ត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ទុកក្នុងព្រះបាលីនោះថា បពិត្រគោតម ព្រះ-តថាគតទាំងឡាយ ទ្រង់លះបង់ពរចោលហើយ ដូច្នេះ ។

បទថា **យញ្ហ ភន្តេ កប្បតិ យញ្ហ អនវជ្ជំ** *សេចក្តីថា ពរណាសមគួរ ដែលព្រះអង្គអាចប្រទានបានផង ជាពរមិនមានទោសផង គឺជាពរដែលវិញ្ញូជន ទាំងឡាយ មិនគប្បីនិន្ទា ព្រោះកិរិយាដែលទទួលរបស់ខ្ញុំជាបច្ច័យផង ខ្ញុំ សូមពរនោះ ។*

បទថា **តថា ឆន្ទេ អធិមត្តំ ភាហុលេ** *សេចក្តីថា បានឮថា ហោរា ទាំងឡាយបានទាយព្រះពោធិសត្វក្នុងថ្ងៃមង្គលថា នឹងបានជាស្តេចចក្រពត្តិ យ៉ាងណា បានទំនាយ ទាំងនន្ទកុមារ ទាំងរាហុលកុមារ ក្នុងថ្ងៃមង្គលថា នឹង បានជាស្តេចចក្រពត្តិដូច្នោះដែរ ។ គ្រានោះ ព្រះរាជាទ្រង់កើតព្រះឧស្សាហ៍ថា អញនឹងឃើញចក្រពត្តិសិរីរបស់បុត្រ តែទ្រង់អស់សង្ឃឹមយ៉ាងខ្លាំង ព្រោះ ព្រះមានព្រះភាគទ្រង់បួសហើយ ។ ទើបទ្រង់ញុាំងព្រះឧស្សាហ៍ឲ្យកើតថា អញ នឹងឃើញចក្រពត្តិសិរីរបស់បាននន្ទ ព្រះមានព្រះភាគ ទ្រង់ញុាំងនន្ទ-កុមារនោះឲ្យបួសហើយ ។ ព្រះរាជាទ្រង់អត់សង្កត់នូវសេចក្តីទុក្ខទៀត បាន*

ទ្រង់ញុាំងព្រះឧស្សាហ៍ឲ្យកើតថា ឥឡូវនេះ អញនឹងបានឃើញចក្រពត្តិសិរី របស់បាភហុល ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ញុាំងភហុល-កុមារនោះឲ្យបួសទៀត ។ ព្រោះហេតុនោះ ទើបសេចក្តីទុក្ខកើតដល់ព្រះរាជា ក្រៃលែងពន់ពេកថា ឥឡូវនេះ កុលវង្សជាច់សូន្យហើយ ចក្រពត្តិសិរីនឹងមានមកអំពីទីណាហ្ន៎ ។ ព្រោះហេតុនោះ ទើបព្រះបាទសុទ្ធោទន: ជ័ជាសក្យរាជទូលថា **តថា ឯតេ អធិមត្តំ ภาหุเล** *ដូច្នេះ ។ ឯការសម្រេចអនាគាមិផលរបស់ព្រះរាជា អ្នកសិក្សាគប្បីជ្រាបថា ខាងក្រោយអំពីកាលដែលភហុលបួសនេះ ។ ហេតុអ្វី ទើបព្រះរាជាត្រាស់ពាក្យនេះថា* **សาธุ ภนฺเต អยฺยา** *ជាដើម ។ បានឮថា ព្រះរាជាទ្រង់ត្រិះរិះថា សូម្បីយើងជាពុទ្ធមាមក: ធម្មមាមក: សង្ឃមាមក:ក៏ពិត តែកាលបុត្រដែលបិតារបស់ខ្លួនឲ្យបួស ក៏មិនអាចនឹងអត់ធន់ក្នុងញាតិវិយោគទុក្ខបាន ។ អម្បាលជនដទៃ នឹងអត់ធន់បានដូចម្តេច ក្នុងកាលកូន និងចៅទាំងឡាយរបស់ខ្លួនបួស ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ពាក្យនេះ ដោយទ្រង់គិតក្នុងព្រះទ័យថា ទុក្ខដែលមានសភាពបែបនេះ កុំបីមានដល់ជនដទៃឡើយ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មកថាថា ព្រះរាជាត្រាស់ហេតុជាគ្រឿងនាំចេញក្នុងសាសនាហើយ ទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រដែលឪពុកម្តាយមិនអនុញ្ញាត មិនគួរឲ្យបួសទេ ដូច្នេះ ។*

បណ្តាបទទាំងនោះបទថា **มาตาปิตูหิ** *ព្រះមានព្រះភាគត្រាស់សំដៅយកជននី និងជនក (អ្នកឲ្យកំណើត) ។ បើមានទាំងពីរ ត្រូវលាទាំងពីរ*

បើបិតា ឬមាតាស្លាប់ហើយ បុគ្គលណានៅរស់ ត្រូវលាបុគ្គលនោះ ។ មាតា បិតា សូម្បីបួសហើយ ក៏គួរលាពិត ។ ភិក្ខុកាលលា ខ្លួនគប្បីទៅលាឯងក៏ បាន បញ្ជូនអ្នកដទៃទៅជំនួសក៏បាន បញ្ជូនកុលបុត្រនោះឯងទៅថា អ្នកចូរ ទៅលាមាតាបិតា ហើយចូរមក ដូច្នេះក៏បាន ។ បើកុលបុត្រនោះជ្រាប់ថា ខ្ញុំ ជាអ្នកដែលមាតាបិតាអនុញ្ញាតហើយ កាលជឿបាន គប្បីឲ្យបួស បិតាបួស ឯងហើយ ជាអ្នកជ្រាបថ្នាឲ្យបុត្របួសផង ចូរលាមាតា ហើយសឹមឲ្យបួស ។ ឬថា មាតាជ្រាបថ្នាឲ្យធីតាបួស ចូរលាបិតាមុន ហើយសឹមឲ្យបួស ។ បិតា មិនមានការត្រេកអរដោយបុត្រកវិយាគេចចេញទៅ មាតាប្រគល់បុត្រដល់ ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយ ឲ្យបុរសនេះបួសចុះ កាលភិក្ខុ ពោលថា បិតារបស់កុលបុត្រនេះទៅណា មាតានោះជ្រាប់ថា គេចទៅដើម្បី លេងក្នុងចិត្តកេលី (ល្បែងរបាំផ្សេងៗ ដែលនាំឲ្យចិត្តរីករាយ) ហើយ សមគួរឲ្យបុរសនោះបួសបាន បើមាតាគេចទៅជាមួយប្រុសណាមួយ បិតា ប្រគល់ឲ្យថា សូមលោកម្ចាស់ទាំងឡាយ ឲ្យកុមារនេះបួសចុះ សូម្បីក្នុង បុត្រនេះក៏មាននយ័នេះ ។ ក្នុងអដ្ឋកថាឈ្មោះកុរុន្ទីវចនាទុកថា បិតាលែងលះ គ្នាទៅហើយ មាតាអនុញ្ញាតថា សូមលោកម្ចាស់បំបួសកូនខ្ញុំចុះ កាលភិក្ខុ ពោលថា បិតារបស់ក្មេងនេះទៅណា ស្ត្រីនោះពោលថា លោកម្ចាស់ ចាំបាច់ ត្រូវការអ្វីដោយបិតានោះ ខ្ញុំទើបជ្រាបដូច្នេះ គួរឲ្យបួសបាន ។ មាតាបិតា ស្លាប់ ទារកចម្រើនក្នុងសម្ពាក់ញាតិទាំងឡាយ មានម្ដាយមីងជាដើម កាល ទារកនោះ ភិក្ខុឲ្យបួស ញាតិទាំងឡាយអាស្រ័យទារកនោះហើយ នឹងញុំាង

ការឈ្លោះទាស់ទែង ឬនាំគ្នាតិះដៀល ព្រោះហេតុនោះ ដើម្បីកាត់ការវិវាទ នោះចេញ ភិក្ខុគប្បីជ្រាប់ជាមុន សឹមឲ្យបួស ។ តែកាលមិនជ្រាប់ជាមុនឲ្យ បួស ក៏មិនមានអាបត្តិ ។ ជនដែលទទួលមកចិញ្ចឹម ក្នុងវេលាដែលនៅជា ទារក ក៏រាប់ថាជាមាតាបិតាបាន ។ សូម្បីក្នុងមាតាបិតានោះ ក៏មានន័យដូច គ្នា ។ បុត្រអាស្រ័យខ្លួន គឺភិក្ខុរស់នៅ មិនបានអាស្រ័យមាតាបិតា ។ បើ បុត្រនោះជាព្រះរាជា ភិក្ខុក៏ត្រូវជ្រាប់មាតាបិតាជាមុន សឹមឲ្យបួស ។ បុត្រ ដែលមាតាបិតាអនុញ្ញាតឲ្យបួសហើយ ត្រឡប់ជាសឹក ។ បើកុលបុត្រនោះ បួសហើយសឹកអស់វារៈ ៧ ដង ភិក្ខុគួរសួរម្តងហើយ ម្តងទៀត ក្នុងវេលា ដែលកុលបុត្រនោះមកហើយ ឲ្យបានរាល់លើក សឹមឲ្យបួស ។ បើមាតា បិតាពោលយ៉ាងនេះថា កូននេះ សឹកហើយមកផ្ទះ មិនធ្វើការងាររបស់ខ្ញុំ បើ គេបួសហើយ នឹងមិនញុំាងវត្តរបស់លោកម្ចាស់ទាំងឡាយឲ្យបរិបូណ៌ កិច្ច ដែលនឹងត្រូវលាសម្រាប់កុលបុត្រនេះ មិនមាន ភិក្ខុទាំងឡាយគប្បីញុំាង កុលបុត្រនោះដែលមកហើយឲ្យបួសចុះ ដូច្នេះ សូម្បីមិនលាទៀត ញុំាង កុលបុត្រដែលមាតាបិតាបោះបង់ហើយយ៉ាងនេះឲ្យបួស ក៏គួរ ។ សូម្បីកូន ណាប្រគល់ឲ្យក្នុងវេលាដែលនៅជាកូនក្មេងយ៉ាងនេះថា ក្មេងនេះខ្ញុំឲ្យលោក ម្ចាស់ ភិក្ខុគប្បីឲ្យបួសក្នុងវេលាដែលលោកជ្រាថ្នាចុះ ដូច្នេះ សូម្បីបុត្រនោះ មកហើយមកទៀត ភិក្ខុគប្បីជ្រាប់ទៀតនោះឯង សឹមឲ្យបួស ។ ឯបុត្រណា ដែលមាតាបិតាអនុញ្ញាត ក្នុងវេលាដែលខ្លួននៅជាកុមារនោះឯងថា បពិត្រ លោកម្ចាស់ លោកម្ចាស់គប្បីញុំាងកុមារនេះឲ្យបួសចុះ ខាងក្រោយក្នុងវេលា

ដែលកុមារដល់នូវការចម្រើន ត្រឡប់មិនអនុញ្ញាត ។ បុត្រនេះ បើភិក្ខុមិនទាន់បានប្រាប់មាតាបិតា មិនគប្បីឲ្យបួស ។ បុត្រទោលដែលត្រាច់ទៅជាមួយមាតាបិតា ពោលថា សូមលោកម្ចាស់ឲ្យខ្ញុំបួសចុះ ហើយកុមារនោះ ដែលភិក្ខុពោលថា អ្នកចូរលាហើយសឹមមក ទើបពោលថា ខ្ញុំមិនទៅ បើលោកម្ចាស់មិនឲ្យខ្ញុំបួស ខ្ញុំនឹងដុតវិហារចោលក្តី ប្រហារពួកលោកម្ចាស់ដោយសស្ត្រាក្តី បង្កវិនាសកម្ម ដោយបំផ្លាញសួនជាដើមក្តី របស់ញាតិ និងឧបដ្ឋាកទាំងឡាយរបស់ពួកលោកម្ចាស់ ឬថា ខ្ញុំនឹងលោតទម្លាក់ពីលើដើមឈើឲ្យស្លាប់ក្តី នឹងចូលទៅកាន់ចំណោមចោរក្តី ឬនឹងទៅប្រទេសដទៃដូច្នេះ សមគួរឲ្យបុគ្គលនោះបួស ដើម្បីការរក្សាជីវិតទុកប៉ុណ្ណោះ ។ បើមាតាបិតារបស់គេមកនិយាយថា ហេតុអ្វី ទើបឲ្យកូនរបស់ខ្ញុំបួស ភិក្ខុគប្បីប្រាប់សេចក្តីនោះដល់ជនទាំងពីរ ហើយគប្បីពោលថា អាត្មាឲ្យកុលបុត្រនេះបួស ក៏ដើម្បីការពារទុក អ្នកទាំងឡាយចូរសាកសួរបុត្រមើលចុះ ។ ម៉្យាងទៀត សមគួរពិតដែលបំបួសឲ្យបុគ្គលដែលគិតថា អញនឹងលោតទម្លាក់ពីលើដើមឈើហើយឡើងទៅលែងដៃ និងជើង ។ កូនតែមួយដែលទៅប្រទេសផ្សេង ហើយសូមបួស បើកុលបុត្រនោះលាហើយ ទើបមក គប្បីឲ្យបួសបាន ។ បើមិនបានលាគប្បីបញ្ជូនភិក្ខុកំលោះទៅឲ្យប្រាប់ហើយ សឹមឲ្យបួស ។ បើប្រទេសដទៃនោះជាទីឆ្ងាយពន់ពេក សូម្បីឲ្យបួសហើយ បញ្ជូនទៅបង្ហាញ មួយអន្ទឹដោយភិក្ខុទាំងឡាយ ក៏គួរ ។ តែក្នុងអដ្ឋកថាកុរុន្ទីខៃសេចក្តីថា បើប្រទេសផ្សេង ជាកន្លែងឆ្ងាយផង ជាផ្លូវកន្តារច្រើនផង ទោះឲ្យបួសដោយតាំងចិត្តថា

ពួកយើងនឹងទៅប្រាប់ដូច្នេះ ក៏គួរ ។ បើមាតាបិតាមានបុត្រច្រើន ពួកគាត់ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ បណ្តាក្មេងទាំងនេះ លោកម្ចាស់ប្រាថ្នាឲ្យក្មេងមួយណាបួស គប្បីឲ្យក្មេងនោះបួសចុះ ភិក្ខុគប្បីពិនិត្យមើលក្មេងទាំងឡាយ ហើយប្រាថ្នាកុលបុត្រណា គប្បីឲ្យកុលបុត្រនោះបួស សូម្បីត្រកូល ឬស្រុកទាំងមូលអនុញ្ញាតទុកថា បពិត្រលោកម្ចាស់ ក្នុងត្រកូលឬក្នុងស្រុកនេះ លោកម្ចាស់ប្រាថ្នានឹងឲ្យអ្នកណាបួស គប្បីឲ្យអ្នកនោះបួសចុះ ដូច្នេះ ។ ភិក្ខុប្រាថ្នាបុគ្គលណា គប្បីឲ្យបុគ្គលនោះបួសបាន ។

ភហុលវត្ថុកថា ចប់

ជាសនង្គ្គហណ្ឌកម្ម

[១២១] *សម័យនោះឯង សាមណេរទាំងឡាយមិនគោរព មិនកោតក្រែង មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នាក្នុងភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសាមណេរមិនសមបើមិនគោរព មិនកោតក្រែង មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នាក្នុងភិក្ខុទាំងឡាយ (ដូច្នេះ) សោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទណ្ឌកម្មដល់សាមណេរ ដែលប្រកបដោយអង្គទាំងឡាយ ៥ គឺ សាមណេរព្យាយាម ដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ១ សាមណេរព្យាយាមដើម្បីមិនឲ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ ១ សាមណេរព្យាយាមដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបាននូវលំនៅ ១ សាមណេរជេរគំរាមនូវភិក្ខុទាំងឡាយ ១ សាមណេរញុះញង់ភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំង-ឡាយ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទណ្ឌកម្មដល់សាមណេរដែលប្រកបដោយអង្គទាំងឡាយ ៥ នេះ ។ លំដាប់តពីនោះមក ភិក្ខុទាំងឡាយបានត្រិះរិះនូវសេចក្តីនេះថា យើងទាំងឡាយគប្បីធ្វើទណ្ឌកម្មដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាម (ថា អ្នកកុំចូលមកក្នុងទីនេះ) ។ ក៏សម័យនោះឯង ពួកភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមដល់សាមណេរទាំងឡាយ អស់ទាំងអាវាសរបស់សង្ឃទាំងមូល ។ សាមណេរទាំងឡាយ*

กาลបើចូលទៅកាន់អារាមមិនបានក៏ចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ចូលទៅក្នុងពួកតិរ្ថិយខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អារាមរបស់សង្ឃទាំងមូល ភិក្ខុមិនគប្បីធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ សាមណេរធ្លាប់នៅក្នុងទីណា ឬធ្លាប់ចូលទៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមតែក្នុងទីនោះ ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមចំពោះអាហារ ដែលបរិភោគតាមទ្វារមាត់ ដល់សាមណេរទាំងឡាយ ។ មនុស្សទាំងឡាយកាលធ្វើទឹកបបរខ្លះ សង្ឃភត្តខ្លះ ក៏និយាយពាក្យយ៉ាងនេះនឹងសាមណេរទាំងឡាយថា បពិត្រលោកដ៏ចម្រើន លោកទាំងឡាយចូរមកឆាន់បបរចុះ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកទាំងឡាយចូរមកឆាន់ចង្ហាន់ចុះ ។ សាមណេរទាំងឡាយ ក៏និយាយពាក្យយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយឆាន់មិនបានទេ (ព្រោះ) ភិក្ខុទាំងឡាយ លោកធ្វើអាវរណកម្មហើយ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនសមបើធ្វើអាវរណកម្មហាមប្រាមចំពោះអាហារ ដែលបរិភោគតាមមុខទ្វារដល់សាមណេរ (ដូច្នេះ) សោះ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើអាវរណកម្មហាមប្រាមចំពោះអាហារដែល បរិភោគតាមមុខទ្វារឡើយ ភិក្ខុណាធ្វើត្រូវអាបត្តិទុក្កដ ។

រឿង ទណ្ឌកម្ម ចប់

[១២២] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនបានប្រាប់ភិក្ខុទាំង-ឡាយជាឧបជ្ឈាយ៍ ក៏ធ្វើអាវរណកម្មដល់សាមណេរទាំងឡាយ ។ ឧបជ្ឈាយ៍ទាំងឡាយស្វែងរកដោយគិតថា ពួកសាមណេររបស់យើងទាំងឡាយម្តេចក៏មិនឃើញដូច្នេះ ។ ភិក្ខុទាំងឡាយនិយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុធ្វើអាវរណកម្មហើយ ។ ឧបជ្ឈាយ៍ទាំងឡាយក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើ មិនប្រាប់យើងហើយធ្វើអាវរណកម្មដល់ពួកសាមណេររបស់យើង (ដូច្នេះ) សោះ ។ ភិក្ខុទាំង-ឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) អ្នកទាំងឡាយមិនទាន់ប្រាប់ ពួកឧបជ្ឈាយ៍ (ឲ្យដឹងជាមុនទេ) មិនត្រូវធ្វើអាវរណកម្មឡើយ ។ ភិក្ខុណាធ្វើត្រូវអាបត្តិទុក្កដ ។

[១២៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រលោមយកពួកសាម-ណេររបស់ពួកភិក្ខុជាថេរៈ ព្រះថេរៈទាំងឡាយក៏បានសេចក្តីលំបាកដោយកាន់យកឈើសូន់ និងទឹកលុបមុខដោយខ្លួនឯង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីប្រលោមយកបរិសទ្យរបស់ភិក្ខុដទៃឡើយ ។ ភិក្ខុណាប្រលោមយក ត្រូវអាបត្តិទុក្កដ ។

[១២៤] សម័យនោះឯង សាមណេរឈ្មោះកណ្ហកៈ (ជាសិស្ស) របស់ព្រះឧបនន្ទសក្យដ៏មានអាយុ ប្រទូស្ត (សេពមេថុនធម្ម) នឹងភិក្ខុនី

ឈ្មោះកណ្ដកី ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបើសាមណេរមកប្រព្រឹត្តអនាចារមានសភាពដូច្នេះសោះ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុញុំងសាមណេរដែលប្រកបដោយអង្គទាំងឡាយ ១០ ឲ្យវិនាស គឺសាមណេរធ្វើសត្វមានជីវិតឲ្យធ្លាក់កន្ទង (គឺសម្លាប់សត្វ) ១ សាមណេរកាន់យកវត្ថុដែលគេមិនបានឲ្យ (ដោយកាយឬវាចា) ១ សាមណេរប្រព្រឹត្តនូវធម៌មិនប្រសើរ (គឺសេពមេថុនធម្ម) ១ សាមណេរពោលពាក្យកុហក ๑ សាមណេរផឹកទឹកស្រវឹង (គឺសុរា និងមេរ័យ) ๑ សាមណេរពោលតិះដៀលព្រះពុទ្ធ ๑ សាមណេរពោលតិះដៀលព្រះធម៌ ๑ សាមណេរពោលតិះដៀលព្រះសង្ឃ ๑ សាមណេរមានទិដ្ឋិខុស ๑ សាមណេរប្រទូស្តភិក្ខុនី ๑ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុញុំងសាមណេរដែលប្រកបដោយអង្គទាំងឡាយ ๑๐ នេះឲ្យវិនាស ។

อัฏฐกถา

ฉาสนฉัฏฐณฆกัมมวัตถุ

[๑๑๙] ใจ็นบทว่า **ยาวตเกหิ วา ปน อุสฺสหาติ** สจกัต่ว่า รมังอาจฉาสเ่ตืนทูฐานสามณารมานปรมาณปุ๋นณา ฯ

[๑๒๐] กุฐงสิกขาบท ๑๐ การเลืส ๕ สิกขาบทขางเดืม ฉา วัตถุนาสนงค์: การปรพฤัตถกนทง ๕ สิกขาบทขางจุงฉาวัตถุนทณกัม ฯ

[๑๒๑] บทว่า **อปฺปฏิสฺสา** สจกัต่ว่า มินตางกิกขุทุกกุฐงหาน: อุกจเมืน คืกุฐงตำณางนบุคคลฉาธ ฯ

บทว่า **อสภาควุตฺติกา** สจกัต่ว่า มินฉาบุคคลรเส่นสเ่ตืคูา อธิบคายว่า ฉาบุคคลรเส่นมินสเ่ตืจำณกคูา ฯ

บทว่า **อลาภาย ปริสกฺกติ** สจกัต่ว่า กิกขุทำงคายนีงมิน ถานลากโดยปรการณา โลกรมังพยายามโดยปรการนาะ ฯ

บทว่า **อนตฺถาย** ถานฉล่ เดืมปีขบคู ฯ

บทว่า **อนาวาสาย** สจกัต่ว่า โลกรมังพยายามว่า เกืมัดขบ ฮุ๋ กิกขุนาะ มินคบปีนุกุฐงอาวาสนาะ ฯ

พีรบทว่า **อกฺโกสติ ปริภาสติ** สจกัต่ว่า โลกรมังเชร นิง รมังคำม โดยรสมัดงกัย ฯ

บทว่า **ภេเทติ** สจกัต่ว่า โลกรมังรกเรืองญุะญงช้รบกคูา ฯ

บทว่า **อาวาฬำ กาตุ** สจกัต่ว่า เดืมปีเกืการหามว่า โลกกุ๋ขูล มกกุฐงทีนาะ ฯ

ច្រើនបទថា **យត្ថ វា វសតិ យត្ថ វា បដិក្កមតិ** *សេចក្តីថា លោកនៅក្តី ចូលទៅក្តី ក្នុងទីណា ។ បរិវេណរបស់ខ្លួន និងសេនាសនៈដែលដល់តាមលំដាប់វស្សា ព្រះមានព្រះភាគត្រាស់ហើយ ដោយបទទាំងពីរ ។*

ច្រើនបទថា **មុខទ្វារិកំ អាហារំ អាវរណំ ករោន្តិ** *សេចក្តីថា ភិក្ខុទាំងឡាយ រមែងហាមយ៉ាងនេះថា ថ្ងៃនេះ លោកទាំងឡាយ ចូរកុំទំពា កុំឆាន់ ។*

គប្បីជ្រាបវិនិច្ឆ័យសេចក្តីនេះថា **ន ភិក្ខវេ មុខទ្វារិកោ អាហារោ អាវរណំ ករោតព្ពោ** *នេះ ដូច្នេះ ។ កាលភិក្ខុពោលថា លោកកុំទំពា កុំឆាន់ដូច្នេះក្តី ទុកជាក់ជាត្រចីវរខាងក្នុង ដោយតាំងចិត្តថា អញនឹងហាមអាហារដូច្នេះក្តី ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ តែបើធ្វើទណ្ឌកម្មដល់សាមណេរដែលជាអ្នកប្រជៀក្រ មិនមានអាចារៈ ទោះបង្ហាញយាគូ ឬភត្ត ឬជាត្រ និងចីវរ ពោលថា កាលបើទណ្ឌកម្មឈ្មោះមានប្រមាណប៉ុណ្ណេះ លោកត្រូវទទួល លោកនឹងបានវត្ថុនេះ ដូច្នេះ សមគួរ ។*

ពិតហើយ ទណ្ឌកម្ម គឺការហាមដែលព្រះមានព្រះភាគត្រាស់ហើយ ឯព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា សូម្បីការឲ្យជញ្ជូនមកនូវទឹកឬឧស ឬខ្សាច់ជាដើម ល្មមសមគួរដល់កំហុស ភិក្ខុក៏គួរធ្វើបាន ។ ព្រោះហេតុនោះ សូម្បី ការឲ្យជញ្ជូននូវទឹកជាដើមនោះ ដែលភិក្ខុគប្បីធ្វើ ។ ទណ្ឌកម្មនោះឯងដែលភិក្ខុគប្បីដាក់ ដោយមេត្តាថា លោកនឹងមិនធ្វើ នឹងវៀរ មិនគប្បីដាក់ដោយអធ្យាស្រ័យដ៏លាមក ដែលប្រព្រឹត្តទៅដោយនយជាដើមថា លោកនឹង

สาปสูนฺย លោកនឹងសឹកចេញទៅ ។ *ដោយគិតថា អញនឹងជាក់ទណ្ឌកម្ម ឲ្យ* លោកដេកលើថ្កៅ *ឬនឹងឲ្យលោកទូលជុំថ្ន* និងឥដ្ឋជាដើមលើក្បាល *ឬនឹង* ឲ្យលោកចុះត្រាំទឹក *រមែងមិនគួរ* ។

[๑๒๒] *គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* **ฉ ภิกฺขเว อุปชฺฌาเย อนา-ปุจฺฉา** *នេះ ដូច្នេះថា កាលបើខ្លួនប្រាប់គ្រប់ ๓ ដងថា សាមណេររបស់លោកមានកំហុសដូច្នេះ លោកចូរជាក់ទណ្ឌកម្មដល់សាមណេរ បើឧបជ្ឈាយ៍មិនជាក់ទណ្ឌកម្ម ទោះជាក់ខ្លួនឯង ក៏គួរ បើឧបជ្ឈាយ៍ប្រាប់អំពីខាងដើមថា បើពួកសាមណេររបស់ខ្ញុំមានទោស លោកទាំងឡាយនោះឯង ចូរជាក់ទណ្ឌកម្ម ដូច្នេះ សមគួរជាក់ ។ និងចូរជាក់ទណ្ឌកម្មដល់សទ្ធិវិហារិក និងអន្តេវាសិកទាំងឡាយ ដូចសាមណេរទាំងឡាយក៏គួរ* ។

[๑๒๓] *បទថា* **อปลาเปฺนฺติ** *សេចក្តីថា រមែងប្រលោមដើម្បីធ្វើឧបជ្ឈាកដល់ខ្លួនថា ពួកខ្ញុំនឹងឲ្យបាត្រ នឹងឲ្យចីវរដល់ពួកលោក* ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ฉ ภิกฺขเว อญฺญสฺส ปริสา อปลา-เปฺตพฺพา** *នេះ ដូច្នេះថា ទោះជាសាមណេរក្តី ឧបសម្បន្នក្តី ដែលភិក្ខុញុះញង់ទទួលយកជនដែលជាបរិស័ទរបស់អ្នកដទៃ ដោយហោចសូម្បីជាភិក្ខុទ្រុស្ត-សីលរមែងមិនគួរ តែសមគួរក្នុងការសម្តែងទោសថា ការដែលលោកអាស្រ័យបុគ្គលទ្រុស្តសីល ប្រព្រឹត្តទៅហើយ ក៏ដូចជាការដែលជនមកដើម្បីនឹងងូតទឹក តែបែរទៅជាងូតលាមក ដូច្នេះ* ។ *បើលោកជ្រាបឯងនោះឯង ទើបសូមឧបជ្ឈាយ៍ ឬនិស្សយ ភិក្ខុឲ្យ ក៏គួរ* ។

[๑๒๔] *บณฺฑิตาสนา ๓ ដែលពោលក្នុងវណ្ណនានៃកណ្តកសិក្ខាបទ លិង្គនាសនាប៉ុណ្ណោះ ដែលសំដៅយកក្នុងបទថា* **អនุชานามิ ภิกฺขเว ฉสหาเคหิ สมฺมนฺนาคตํ สามเณรึ นาเสตุ๎** *នេះ ព្រោះហេតុនោះ ក្នុងកម្មទាំងឡាយ មានបាណាតិបាតជាដើម សាមណេរណា រមែងធ្វើកម្មតែមួយ សាមណេរនោះ ក៏ភិក្ខុគប្បីឲ្យវិនាសដោយលិង្គនាសនា ដូចភិក្ខុទាំងឡាយ រមែងត្រូវអាបត្តិផ្សេងៗ គ្នា ព្រោះកម្មទាំងឡាយ មានបាណាតិបាតជាដើម យ៉ាងណា សាមណេរទាំងឡាយ មិនដូច្នោះទេ ព្រោះថា សាមណេរញុាំងស្រមោចខ្មៅ ស្រមោចក្រហមឲ្យស្លាប់ក្តី ញុាំងពងសង្កើចក្តី រមែងដល់នូវភាពជាអ្នកគួរឲ្យវិនាសនោះឯង ។ សរណគមន៍ មានការកាន់យកនូវឧបជ្ឈាយ៍ និងការកាន់យកសេនាសនៈរបស់លោក រមែងរម្ងាប់ភ្លាមៗ ។ លោករមែងមិនបានលាភសង្ឃ នៅសល់ត្រឹមតែវត្ថុ ๑ គឺភេទប៉ុណ្ណោះ បើលោកជាអ្នកមានទោសជដែលហើយជដែលទៀត នឹងមិនតាំងនៅក្នុងសំវរៈតទៅ គប្បីកម្ចាត់បង់ចេញ បើលោកខុសភ្លាំងភ្លាត់ទៅហើយ ព្រមទទួលថា អំពើអាក្រក់ ខ្ញុំបានធ្វើហើយ ដូច្នេះ ជាអ្នកប្រាថ្នានឹងតាំងនៅក្នុងសំវរៈទៀតកិច្ច គឺលិង្គនាសនា រមែងមិនមាន គប្បីឲ្យសរណៈទាំងឡាយ គប្បីឲ្យឧបជ្ឈាយ៍ដល់លោក ដែលគង់នៅក្នុងការស្មៀកជណ្តប់ដូចដើមនោះឯង ឯសិក្ខាបទទាំងឡាយ រមែងសម្រេចដោយសរណគមន៍នោះឯង ពិតហើយ សរណគមន៍របស់សាមណេរទាំងឡាយ ដូចគ្នានឹងកម្មវាចាក្នុងឧបសម្បទារបស់ភិក្ខុទាំងឡាយ ព្រោះហេតុនោះ សីល ๑๐ ឈ្មោះថា សាមណេរនេះ*

សមាទានហើយពិត ដូចចតុប្បារិសុទ្ធិសីល ដែលភិក្ខុសមាទានហើយដូច្នោះ សូម្បីដូច្នោះ សីល ១០ ក៏គួរឲ្យទៀត ដើម្បីធ្វើឲ្យមាំ គឺដើម្បីញុំាងលោកឲ្យតាំងនៅក្នុងសំវរៈតទៅ បើសរណៈទាំងឡាយលោកទទួលទៀត ក្នុងវស្សូបនាយិកាដើម លោកនឹងបានសំពត់ចំណាំវស្សា ក្នុងវស្សូបនាយិកក្រោយ បើលោកទទួលសរណៈក្នុងថ្ងៃវស្សូបនាយិកាក្រោយ លាភក៏សង្ឃគប្បីអបលោកឲ្យ ។

សាមណេរ រមែងជាអ្នកមិនមែនសមណៈ គឺរមែងដល់នូវភាពជាអ្នកគួរនាសនាចោល ព្រោះអទិន្នាទាន ដោយវត្ថុត្រឹមតែស្មៅមួយសរសៃ ព្រោះអព្រហ្មចរិយៈ ដោយបដិបត្តិខុសក្នុងទ្វារមគ្គណាមួយ បណ្តាមគ្គ ៣ ព្រោះមុសាវាទ កាលខ្លួនពោលកុហក សូម្បីដោយភាពជាអ្នកបំណងនឹងសើចលេងចំណែកក្នុងការផឹកទឹកស្រវឹង ត្រូវបាចិត្តិយៈ ដល់ភិក្ខុដែលមិនដឹង ផឹកទឹកស្រវឹង ចាប់ផ្តើមតាំងអំពីជាក់ពូជសុរា ឯសាមណេរដឹងហើយផឹក ទើបត្រូវសីលភេទ គឺបែកធ្លាយនូវសីល បើមិនដឹងមិនត្រូវ ។ ឯសិក្ខាបទ ៥ ក្រៅអំពីនេះរបស់សាមណេរនោះ កាលសិក្ខាបទទាំងនោះបែកធ្លាយហើយ ឈ្មោះថា ភិក្ខុមិនគប្បីនាសនា គប្បីជាក់ទណ្ឌកម្ម ។ កាលសិក្ខាបទដែលភិក្ខុបានឲ្យទៀតក្តី មិនទាន់បានឲ្យក្តី ទោះជាក់ទណ្ឌកម្ម រមែងគួរ ។ តែគប្បីជ្រាបដោយទណ្ឌកម្ម ហើយគប្បីឲ្យសិក្ខាបទ ដើម្បីប្រយោជន៍ដល់ការតាំងនៅក្នុងសំវរៈតទៅ ។ ការផឹកទឹកស្រវឹងរបស់ពួកសាមណេរ ជាសចិត្តកៈ ទើបជាវត្ថុនៃបារាជិក ។ ការប្លែកគ្នាមានប្រមាណប៉ុណ្ណោះ ។

ឯវិនិច្ឆយក្នុងអវណ្ណភាសនៈ គប្បីជ្រាបដូច្នេះថា ក្នុងអដ្ឋកថាឈ្មោះកុរុន្ទីពោលថា សាមណេរដែលពោលទោសនៃព្រះពុទ្ធ ដោយអំណាចនៃពាក្យដែលជាសឹកសត្រូវដល់ពុទ្ធគុណជាដើមថា **អរហំ សម្មាសម្ពុទ្ធោ** ក្តី នៃព្រះធម៌ ដោយអំណាចជាសត្រូវដល់ធម្មគុណជាដើមថា **স্বাক্খাតো** ក្តី នៃព្រះសង្ឃ ដោយអំណាចនៃពាក្យជាសត្រូវដល់សង្ឃគុណជាដើមថា **សុប-ដិបន្នោ** ក្តី បានដល់និន្ទា គឺ តិះដៀលព្រះរតនត្រ័យ ដែលភិក្ខុទាំងឡាយមានអាចារ្យ និងឧបជ្ឈាយ៍ជាដើម គប្បីសម្តែងទោសក្នុងការពោលទោសដោយហាមប្រាមថា អ្នកកុំពោលយ៉ាងនោះទ្បើយ បើលោកត្រូវភិក្ខុទាំងឡាយប្រដៅដល់លើកទី ៣ នៅតែមិនវៀរចាក ភិក្ខុទាំងឡាយគប្បីឲ្យវិនាស ដោយកណ្តកនាសនា ។

ឯក្នុងមហាអដ្ឋកថាវៃសេចក្តីថា បើសាមណេរត្រូវភិក្ខុទាំងឡាយប្រៀនប្រដៅយ៉ាងនោះ លះបង់នូវលទ្ធិនោះ គប្បីឲ្យធ្វើទណ្ឌកម្ម ហើយសម្តែងទោសដែលប្រព្រឹត្តកន្លង ។ បើមិនព្រមលះបង់ នៅតែពោលយ៉ាងនោះឯង គប្បីឲ្យវិនាសដោយលិង្គនាសនា ។

ពាក្យនៃមហាអដ្ឋកថានោះប្រពៃ ព្រោះថា នាសនានេះប៉ុណ្ណោះ ដែលព្រះមានព្រះភាគ ទ្រង់បំណងក្នុងអធិប្បាយនេះ ។ សូម្បីក្នុងសាមណេរជាមិច្ឆាទិដ្ឋិក៏នយនេះឯង បើសាមណេរជាអ្នកមានបណ្តាសសុត្តទិដ្ឋិ និងឧច្ឆេទ-ទិដ្ឋិណាមួយ បើលោកត្រូវភិក្ខុទាំងឡាយ មានអាចារ្យជាដើមជាសំតៀនលះបង់បាន គប្បីឲ្យធ្វើទណ្ឌកម្ម ហើយឲ្យសម្តែងទោសដែលប្រព្រឹត្តល្មើស

បើមិនព្រមលះនោះឯង គប្បីឲ្យវិនាសចេញដូច្នេះឯង ។

អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានថា អង្គ ១០ គឺភិក្ខុនីទូសកោនេះ ដែលព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្តែងតែអត្ថនេះថា ពិតហើយ បណ្តានាសនង្គៈ ១០ នេះ សាមណេរប្រទូស្តភិក្ខុនី គឺព្រះអង្គទ្រង់កាន់យកដោយ **ព្រហ្មចារី** *សព្វដោយពិត ។ ទោះយ៉ាងនោះ ក៏សមគួរឲ្យសរណៈ ហើយឧបសម្បទា អព្រហ្មចារីសាមណេរដែលប្រាថ្នានឹងតាំងនៅក្នុងសំវរៈតទៅ ។ សាមណេរដែលប្រទូស្តភិក្ខុនី សូម្បីប្រាថ្នានឹងតាំងនៅក្នុងសំវរៈតទៅ រមែងមិនបានសូម្បីតែបព្វជ្ជា (បួសជាសាមណេរ) ចាំបាច់ពោលទៅថ្វីដល់ឧបសម្បទា (បួសជាភិក្ខុ) ។*

នាសនង្គ៏ទណ្ឌកម្មវត្ថុ ចប់

បណ្ឌកកថា

[១២៥] *សម័យនោះឯង មានមនុស្សខ្ទើយម្នាក់បួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ មនុស្សខ្ទើយនោះចូលទៅរកពួកភិក្ខុជាកំលោះៗ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយចូលមកប្រទូស្ត (សេពមេថុនធម្ម) នឹងខ្ញុំចុះ ។ ភិក្ខុទាំងឡាយក៏បណ្តេញដោយពាក្យថា នែអ្នកខ្ទើយ អ្នកឯងចូរអន្តរធានទៅ នែអ្នកខ្ទើយ អ្នកឯងចូរវិនាសទៅ យើងមិនត្រូវការនឹងអ្នកឯងទេ ។ មនុស្សខ្ទើយនោះ លុះដល់ភិក្ខុទាំងឡាយបណ្តេញចេញហើយ ក៏ចូលទៅរកពួកសាមណេរធំៗ ដែលមានសរីរៈធាត់ៗ ទៀតហើយនិយាយយ៉ាងនេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយមកប្រទូស្តនឹងខ្ញុំចុះ ។ ពួកសាមណេរក៏បណ្តេញដោយពាក្យថា នែអ្នកខ្ទើយ អ្នកឯង ចូរអន្តរធានទៅ នែអ្នកខ្ទើយ អ្នកឯងចូរវិនាសទៅ យើងមិនត្រូវការនឹងអ្នកឯងទេ ។ មនុស្សខ្ទើយនោះ លុះសាមណេរទាំងឡាយបណ្តេញហើយ ក៏ចូលទៅរកពួកគង្វាលដំរី និងពួកគង្វាលសេះ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកចូរមកប្រទូស្តនឹងខ្ញុំចុះ ។ ពួកគង្វាលដំរី និងពួកគង្វាលសេះក៏ប្រទូស្តទៅ ។ គង្វាលដំរី និងគង្វាលសេះទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រទាំងនេះជាមនុស្សខ្ទើយ បណ្តាសមណៈទាំងនេះ ប្រហែលជាសមណៈណា ដែលមិនខ្ទើយមុខជាប្រទូស្តពួកខ្ទើយមិនលែងឡើយ បើដូច្នេះពួកសមណៈទាំងនេះ សុទ្ធតែប្រព្រឹត្តអព្រហ្មចរិយធម៌ (មេថុនធម្ម) គ្រប់*

គ្នាទាំងអស់មិនខាន ។ ភិក្ខុទាំងឡាយកាលបើបានឮពួកគង្វាលជីរី និងពួកគង្វាលសេះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ទើបពួកភិក្ខុនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ខ្ញុំយជាអនុបសម្បន្ន សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បទាហើយ ត្រូវឲ្យវិនាសចេញ ។

อัฏฐกถา

ปณฺฑกวัตถุ

[๑๒๕] ពីរបទថា **ឧហារេ ឧហារេ** បានដល់ កំលោះៗ ។

បទថា **មោលិគល្លេ** បានដល់ អ្នកមានរាងកាយធាត់ ។

ពីរបទថា **ហត្ថិកណ្ហេ អស្សកណ្ហេ** បានដល់ អ្នកចិញ្ចឹមដំរី និងអ្នកចិញ្ចឹមសេះ ។

ក្នុងបទថា **បណ្ឌកោ ភិក្ខវេ** ជាដើមនេះ មានវិនិច្ឆ័យថា ខ្ទើយមាន ៥ ប្រភេទ គឺអាសិត្តបណ្ឌក ១ ឧសុយ្យបណ្ឌក ១ ឱបក្កមិយបណ្ឌក ១ បក្ខបណ្ឌក ១ នបុំសកបណ្ឌក ១ ។

ក្នុងខ្ទើយ ៥ ប្រភេទនោះ ខ្ទើយណាយកមាត់បៀមអង្គជាតរបស់បុរសពួកជំទៃ ត្រូវទឹកអសុចិស្រោចហើយ ការក្តៅក្រហាយ ទើបស្ងប់ទៅ ខ្ទើយនេះ ឈ្មោះអាសិត្តបណ្ឌក ។ ឯបណ្ឌកណា ឃើញអជ្ឈាចាររបស់ជនពួកជំទៃ កាលការច្រណែនកើតឡើងហើយ ទើបសេចក្តីក្តៅក្រហាយស្ងប់ទៅ ខ្ទើយនេះឈ្មោះឧសុយ្យបណ្ឌក ។ ខ្ទើយណា មានអវយវៈដូចពូជទាំងឡាយ ត្រូវនាំទៅប្រាស់ហើយ គឺត្រូវគេក្រៀវចេញហើយដោយសេចក្តីព្យាយាម ខ្ទើយនេះឈ្មោះឱបក្កមិយបណ្ឌក ឯបុគ្គលពួកខ្លះខាងរនោចជាខ្ទើយ ដោយអានុភាពនៃអកុសលវិបាក តែខាងខ្នើតសេចក្តីក្តៅក្រហាយរបស់បុគ្គលនោះរមែងស្ងប់ទៅ នេះឈ្មោះថា បក្ខបណ្ឌក ។

ចំណែកបណ្ឌកណា កើតមិនមានភេទ មិនមានការរូប ក្នុងបដិសន្ធិ

នោះឯង គឺមិនជ្រាកដថា បុរស ឬស្ត្រីពីកំណើតមក ខ្ទើយនេះ ឈ្មោះថា នបុំសកបណ្ឌក ។

ក្នុងអដ្ឋកថា ឈ្មោះកុរុន្ទីខៃសេចក្តីថា ក្នុងបណ្ឌក ៥ ប្រភេទនេះ អាសិត្តបណ្ឌក និងឧសុយ្យបណ្ឌក មិនមានហាមបព្វជ្ជា ៣ ប្រភេទក្រៅពីនេះ ហាមសូម្បីក្នុងបណ្ឌក ៣ ប្រភេទ សម្រាប់បក្ខបណ្ឌកហាមបព្វជ្ជាដល់គេចំពោះបក្ខដែលជាខ្ទើយប៉ុណ្ណោះ ។ ក្នុងបណ្ឌក ៣ ប្រភេទនេះ បណ្ឌកណាទ្រង់ហាមបព្វជ្ជា ព្រះមានព្រះភាគ ទ្រង់សំដៅយកបណ្ឌកនោះ ត្រាស់ពាក្យនេះថា **អនុបសម្បន្នោ ឆាសេតព្ពោ ។** *ខ្ទើយនោះ ភិក្ខុគប្បីឲ្យវិនាសដោយលិង្គនាសនានោះឯង ។ ខាងមុខអំពីនេះ សូម្បីក្នុងពាក្យដែលពោលថា គប្បីឲ្យវិនាស ក៏មានន័យនេះដូចគ្នា ។*

បណ្ឌកវត្ថុ ចប់

ជេយ្យសំវាសកកថា

[១២៦] *សម័យនោះឯង មានកុលបុត្រចាស់ម្នាក់ជាបុគ្គលគ្មានញាតិសាលោហិត តែធ្លាប់ជាអ្នកមានសេចក្តីសុខដ៏ល្អិតល្អ ។ ឯកុលបុត្រចាស់នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អញឯងជាសុខមាលជាតិ តែមិនអាចនឹងបានកោគសម្បត្តិដែលខ្លួនមិនទាន់បានផង មិនអាចនឹងធ្វើកោគសម្បត្តិដែលខ្លួនបានហើយឲ្យតែតែចម្រើនផង បើដូច្នេះ អញនឹងគប្បីចិញ្ចឹមជីវិតដោយឧបាយយ៉ាងណាអេះ ទើបបានស្រួល មិនបាច់លំបាកផង ។ លំដាប់តពីនោះមក កុលបុត្រចាស់ដែលគ្មានញាតិសាលោហិតនោះ បានរំពឹងសេចក្តីនេះតទៅទៀតថា ពួកសមណៈជាសក្យបុត្រទាំងនេះមានសីល ជាសុខ មានសមាចារជាសុខ បានធាន់នូវភោជនដ៏ល្អ ដេកលើដំណេកទាំងឡាយដែលហាប់មិនមានខ្យល់ បើដូច្នោះ មានតែអញត្រូវតាក់តែងជាត្រ និងចីវរ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់នូវសំពត់កាសាយៈទាំងឡាយខ្លួនឯង ទៅកាន់អារាមហើយ នៅអាស្រ័យជាមួយនឹងភិក្ខុទាំងឡាយចុះ ។ ទើបកុលបុត្រចាស់គ្មានញាតិសាលោហិតនោះ ក៏តាក់តែងជាត្រ និងចីវរ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់នូវសំពត់កាសាយៈទាំងឡាយខ្លួនឯងទៅកាន់អារាមហើយ ថ្វាយបង្គំភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ លោកបួសបានប៉ុន្មានវស្សាហើយ ។ កុលបុត្រនោះត្រឡប់សួរថា ម្នាលអាវុសោ ពាក្យដែលថាបួសបានប៉ុន្មានវស្សានុ៎ះតើដូចម្តេច ។ ភិក្ខុទាំងឡាយសួរតទៅទៀតថា ម្នាលអាវុសោ ចុះលោកណាជាឧបជ្ឈាយ៍របស់លោក ។ កុលបុត្រនោះក៏ត្រឡប់សួរបកមកទៀតថា ម្នាលអាវុសោ ពាក្យដែលហៅថា*

ឧបជ្ឈាយ៍នោះតើដូចម្តេច ។ ភិក្ខុទាំងឡាយនិយាយពាក្យនេះនឹងព្រះឧបាលិដ៏មានអាយុថា ម្នាលអាវុសោឧបាលិ សូមនិមន្តលោកជម្រះសួរបព្វជិតនេះមើល ។ ឯកុលបុត្រចាស់ដែលគ្មានញាតិសាលោហិតនោះ កាលបើត្រូវព្រះឧបាលិដ៏មានអាយុជម្រះសួរហើយក៏ប្រាប់នូវសេចក្តីនុ៎ះតាមត្រង់ ។ ព្រះឧបាលិដ៏មានអាយុតំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដែលជាថេយ្យសំវាស (លួចសំវាស) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយគប្បីឲ្យវិនាសចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាតិត្ថិយបក្កន្តកៈ (ចូលពួកតិរ្ថិយ) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ ។

อัฏฐกถา

เชยยสังวาสกกถา

[๑๒๖] บทว่า **ปุราณกุลปุตฺโต** ได้แก่ กุลบุตรเก่า ท่านกล่าวหมายเอาผู้ถึงความแก่เฒ่าชรา ๆ

บทว่า **ญาติกุลูปโก** มีอรรถวิเคราะห์ว่า ญาติทั้งหลายย่อมรู้จักกันในตระกูลฝ่ายมารดา และฝ่ายบิดาของบุคคลนั้นอย่างนี้ว่า สาบสูญไปแล้ว ตายไปแล้ว ดับไปแล้ว เพราะเหตุนั้น บุคคลนั้นจึงชื่อว่า **ญาติกุลูปโก** ได้แก่ ผู้มีญาติรู้จักกันในตระกูลอย่างนี้ ๆ

บทว่า **อนธิคตํ** ได้แก่ ไม่ได้ ไม่ถึง ๆ

บทว่า **ชาตึ กาตุํ** ความว่า ได้แก่ เพื่อให้เกิดขึ้น ๆ ส่วนบทว่า **สงฺฆ** เป็นคำแสดงชาติแห่งบุคคล ๆ

บทว่า **อนุยุญฺชิยมาโน** ความว่า กุลบุตรนั้น ที่พระอุปัชฌาย์ตักเตือนอยู่ในที่ลับ และที่แจ้ง ในการเคารพนับถือ และการประพฤติอ่อนน้อม การรับบาตรจีวร การรับของเคี้ยว ของฉัน การรับยาคือน้ำปานะ การรับผ้าสาฎก การรับผ้าอาบน้ำฝน การรับผ้าจำนำพรรษา การรับผ้าสังฆาฏิ การรับผ้าอุตตราสงค์ การรับผ้าอันตรวาสก การรับบาตร การรับผ้ากรองน้ำ การรับมีดโกน การรับกายพันธน์ ชื่อว่าย่อมถูกตักเตือน ๆ

บทว่า **ฉตฺตมตฺตํ อาโรเจสิ** ความว่า ได้แก่ ประกาศการที่ล่วงไปแล้วสองสามวันนั้น ๆ ตั้งแต่วันบวชมา ๆ

ในบทว่า **เชยยสังวาสโก ภิกฺขเว** นี้ มีวินิจฉัยว่า บุคคลที่ชื่อว่าเชยยสังวาสกมี ๓ ประเภท คือบุคคลลบเกษ ๑ บุคคลลบ

สังวาส ๑ บุคคลลบทั้งพวก ๑ ฯ

ในบุคคลทั้ง ๓ ประเภทนั้น บุคคลณาบวชแล้ว ไปวัดอยู่ ไม่รับวัสสาของภิกษุ ไม่ตรึกในการถือนอนเป็นวัตรตามลำดับพรรษา ไม่ทำอุโบสถ ไม่ทำสังฆกรรม มีอุโบสถ และปวารณาเป็นต้น บุคคลนี้เรียกว่า บุคคลลบเทศ เพราะลบเฉพาะเทศเท่านั้น ฯ

ส่วนบุคคลณา เป็นสามเณรที่บวชอุปสมบทแล้วหลีกไปแล้ว ไปยังชนบทอื่น เมื่อกุลบุตร รับวัสสาของภิกษุว่า ๑๐ พรรษาก็ดี หรือว่า ๒๐ พรรษาก็ดี ตรึกในการถือนอนเป็นวัตรตามลำดับพรรษา ทำอุโบสถ มีอุโบสถ และปวารณาเป็นต้น ฯ บุคคลนี้เรียกว่า เป็นผู้ลบสังวาส เพราะเฉพาะแต่ลบสังวาสเท่านั้น ฯ

ส่วนการแยกกันแห่งกิริยาทั้งปวง มีรับวัสสาของภิกษุเป็นต้น ผู้ศึกษาพึงทราบว่า สังวาสในอรรถนี้ ฯ แต่ในบุคคลที่ลาสิกขา แล้วบัญญัติอย่างนั้นว่า ผู้นี้ลาสิกขาของเรา ดังนี้ ฯ

ส่วนบุคคลณาบวช แล้วไปวัดที่อยู่ รับวัสสาของภิกษุ ตรึกในการถือนอนเป็นวัตรตามลำดับผู้เข้าก่อน มีอุโบสถ และปวารณาเป็นต้น บุคคลนี้เรียกว่า เป็นผู้ลบทั้งพวก เพราะเหตุที่ตนลบทั้งเทศ ทั้งสังวาส ฯ

ថេយ្យសំវាសកទាំង ៣ ប្រភេទនេះ ជាអនុសម្បន្ន មិនគួរឲ្យឧប-សម្បទា ជាឧបសម្បន្ន គួរឲ្យវិនាសចេញ សូម្បីសូមបួសទៀត ក៏មិនគួរឲ្យបួស ។ ដើម្បីកុំឲ្យវង្វេងក្នុងថេយ្យសំវាសកាធិការនេះ គប្បីជ្រាបបកិណ្ណកៈដូច្នេះថា ជនណា កាន់យកភេទក្នុងសាសនានេះ ព្រោះរាជភ័យ ទុព្ភិក្ខភ័យ កន្តារភ័យ រោគភ័យ និងវេរីភ័យក្តី ដើម្បីនឹងនាំចីវរមកក្តី ជននោះមានចិត្តបរិសុទ្ធ មិនព្រមទទួលសង្វាសជរាបណា ជននោះ បណ្ឌិតមិនទាន់ពោលថាជាថេយ្យសំវាសបុគ្គលជរាបនោះ ។

គប្បីជ្រាបនយពិស្តារក្នុងគាថានោះ ដូច្នេះថា ព្រះរាជាក្នុងលោកនេះរមែងជាអ្នកក្រោធចំពោះបុរសខ្លះ បុរសនោះគិតថា សេចក្តីសួស្តីនឹងមានដល់អញដោយឧបាយយ៉ាងនេះ ហើយកាន់យកភេទឯងនោះឯងគេចទៅ ។ ជនទាំងឡាយជួបបុគ្គលនោះហើយ ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បន្ទោបង់សេចក្តីក្រោធក្នុងបុគ្គលនោះ ដោយទ្រង់ត្រិះរិះថា បើបួសហើយយើងមិនធ្វើអ្វីបុគ្គលនោះទេ្បីយ តែបុគ្គលនោះមិនបានចូលកាន់ជំនុំសង្ឃ តែកាន់យកភេទគ្រហស្ថហើយ ទើបមក ដោយគិតថា រាជភ័យរបស់អញស្ងប់ហើយ ភិក្ខុទាំងឡាយគួរឲ្យបួស ។ បើបុគ្គលនោះកើតសេចក្តីសង្វេគថា អញអាស្រ័យព្រះសាសនា ទើបរក្សាជីវិតទុកបាន ល្អីយចុះ ឥឡូវនេះអញនឹងបួសដូច្នេះ មកដោយភេទនោះឯង តែមិនត្រេកអរក្នុងអាគន្តុកវត្តដែលភិក្ខុទាំងឡាយសួរហើយក្តី មិនសួរក្តី បានចង្អុលបង្ហាញតាមសេចក្តីពិតហើយសូមបព្វជ្ជា ភិក្ខុទាំងឡាយគប្បីដោះភេទហើយ សឹមឲ្យបួស ។ តែបើ

បុគ្គលនោះត្រេកអរចំពោះវត្ត សម្តែងអាកប្បកិរិយាដូចបព្វជិត បដិបត្តិវិធីផ្សេងៗ ដោយរាប់រាសព្វជាដើមដែលពោលហើយក្នុងខាងដើមទាំងអស់ អ្នកនេះមិនគួរឲ្យបួស ។

ម៉្យាងទៀត បុគ្គលខ្លះក្នុងលោកនេះ មិនអាចរស់នៅបានក្នុងគ្រាទុព្ភិក្ខភ័យ ទើបកាន់យកភេទឯង បរិភោគអាហារដែលគេរៀបចំទុកដើម្បីអ្នកបួស ក្នុងលទ្ធិទាំងពួង កាលទុព្ភិក្ខភ័យកន្លងទៅហើយ មិនទាន់បានចូលជំនុំសង្ឃ កាន់យកភេទគ្រហស្ថហើយ ទើបមក ពាក្យពោលដូច្នេះទាំងអស់ ដូចគ្នានឹងពាក្យដែលពោលមកហើយនោះឯង ។

បុគ្គលមួយទៀត ជាអ្នកជ្រាបថ្នានឹងឆ្លងមហាកន្តារ ជាមួយអ្នកឈ្មួញរនេះ រមែងនាំបព្វជិតទាំងឡាយទៅ ។ បុរសនោះគិតថា ដោយឧបាយយ៉ាងនេះ ឈ្មួញរនេះនឹងនាំអញទៅ ទើបកាន់យកភេទឯង រួមជាមួយឈ្មួញរនេះ ឆ្លងផ្លូវកន្តារដល់នូវចំណែកដ៏ក្សេម តែមិនបានចូលកាន់ជំនុំសង្ឃ លុះកាន់យកភេទគ្រហស្ថហើយ ទើបមក ពាក្យពោលដូច្នេះទាំងពួងដូចគ្នានឹងពាក្យដែលពោលមកអំពីមុននោះឯង ។

បុគ្គលមួយទៀត កាលភ័យ គឺរោគកើតឡើង មិនអាចនឹងរស់នៅបាន ទើបកាន់យកភេទឯង បរិភោគអាហារដែលគេរៀបចំទុក ដើម្បីអ្នកបួសក្នុងលទ្ធិទាំងពួង ។ កាលភ័យ គឺរោគស្ងប់ហើយ មិនទាន់បានចូលជំនុំសង្ឃ លុះកាន់យកភេទគ្រហស្ថហើយ ទើបមក ពាក្យដ៏សេសទាំងអស់ ដូចគ្នានឹងពាក្យដែលពោលមកពីមុននោះឯង ។

បុគ្គលមានពៀរនឹងបុរសម្នាក់ទៀត ដែលខឹងក្រោធគ្នា ប៉ុនប៉ងនឹងសម្លាប់ បុគ្គលនោះត្រាច់ទៅ ដោយគិតថា ដោយឧបាយយ៉ាងនេះ សួស្តីនឹងមានដល់អញ ទើបកាន់យកភេទឯង ហើយគេចទៅ បុគ្គលដែលជាអ្នកមានពៀរ ស៊ើបសួរថា បុគ្គលនោះទៅណា បានឮថា បុគ្គលនោះបួសហើយគេចទៅ ទើបបន្ធូបង់សេចក្តីក្រោធក្នុងបុគ្គលនោះចោល ដោយគិតថា អ្នកនោះបួសហើយ អញក៏ធ្វើអ្វីគេមិនបាន បុគ្គលនោះមិនបានចូលកាន់ជំនុំសង្ឃ កាន់យកភេទជាគ្រហស្ថហើយ ទើបមក ដោយគិតថា ពៀរវេរារបស់អញស្ងប់ហើយ ពាក្យដែលត្រូវពោលទាំងអស់ ដូចពាក្យដែលពោលពីមុននោះឯង ។

បុគ្គលម្នាក់ទៀត ទៅកាន់ត្រកូលញាតិ លាសិក្ខាជាគ្រហស្ថហើយ ធ្វើទុកក្នុងចិត្តថា ចីវរនេះនឹងវិនាសក្នុងទីនេះ បើអញកាន់យកទៅឯវិហារដោយភេទជាគ្រហស្ថនេះ ក្នុងចន្លោះផ្លូវ ជនទាំងឡាយនឹងចាប់អញថា ជាចោរណ្ហើយចុះ អញគប្បីធ្វើឲ្យជារបស់ដែលកាយគប្បីរក្សាទុក សឹមទៅ ដូច្នេះដើម្បីនឹងនាំចីវរមក ទើបស្លៀក និងដណ្តប់ ហើយទៅវត្តដែលជាលំនៅ ពួកសាមណេរ និងភិក្ខុកំលោះទាំងឡាយ ឃើញលោកមកអំពីចម្ងាយហើយ នាំគ្នាចូលទៅទទួលសម្តែងវត្ត ។ បុគ្គលនោះមិនត្រេកអរ ប្រកាសខ្លួនតាមសេចក្តីពិត បើភិក្ខុទាំងឡាយពោលថា ពួកអាត្មាមិនបណ្តាយឲ្យអ្នកទៅទេ ជាអ្នកជ្រុថ្នានឹងឲ្យបួសដោយកម្លាំង បុគ្គលនោះ កាលភិក្ខុទាំងឡាយគប្បីដោះសំពត់កាសាយៈហើយ ទើបឲ្យបួសទៀត តែបើបុគ្គលនោះគិតថា ភិក្ខុ

ทำงนี้มิได้งการที่เขามาหาตน ได้ชื่อว่าเป็นผู้ลักทรัพย์แล้วอย่างนี้ ด้วยประการฉะนี้ ภิกษุนั้นแสดงตนเป็นภิกษุ ประพฤติวิธีต่างๆ ด้วยอาศัยเพศที่ตนกล่าวแล้วทั้งหมด ชื่อว่าเป็นเถยยสังวาสก ไม่ควรให้อุปสมบท ฯ

สามเณรเดินทางไกลคนหนึ่ง ไปสู่ตระกูลญาติ สึกแล้ว เป็นผู้เกียจคร้านในการงาน จึงคิดว่า บัดนี้ เราเป็นสามเณรอีก ไม่ได้งการที่เราสึกแล้ว จึงให้นำบาตรจีวรของตนไปสู่วิหาร ไม่บอกเรื่องนั้นแก่ภิกษุทั้งหลาย แสดงตนเป็นสามเณร ชื่อว่าเป็นเถยยสังวาสก ไม่ควรให้อุปสมบท ฯ

ในขณะนำไปให้ ภิกษุนั้นมีความคิดอย่างนี้ว่า เราไม่ได้งบอกแก่ใครๆ ดังนี้ ก็แต่ว่าภิกษุนั้นไปสู่วิหารแล้ว ชื่อว่าบอกแล้ว ฯ การนำไป (ให้) นั่นเอง ชื่อว่าเป็นเถยยสังวาสก ฯ

ในขณะนำไปให้ ภิกษุนั้นมีความคิดอย่างนี้ว่า เราไม่ได้งบอก แต่ไปสู่วิหารแล้ว ภิกษุใดถามว่า ท่านมีอายุ ท่านมาแต่ที่ไหน ดังนี้ ก็ตอบว่า บัดนี้ ชนเหล่านี้ไม่ได้งเรา ดังนี้ ชื่อว่าไม่บอก ภิกษุนี้ชื่อว่าเป็นเถยยสังวาสกโดยแท้ ด้วยเข้าใจกันว่าเราบอกแล้ว ฯ

ในขณะนำไปให้ ภิกษุมีความคิดเกี่ยวเนื่องกันว่า เราไม่ได้งบอก ก็แต่ว่าไปสู่วิหารแล้ว ภิกษุนี้ชื่อว่าบอกแล้วเหมือนกัน ฯ

បើសាមណេរកំលោះដទៃទៀត ជាមនុស្សធំ តែល្ងង់មិនឈ្លាស លោកសឹកហើយដោយនព្វយមុននោះឯង មិនចង់ធ្វើកិច្ច មានឃ្លាលគោជាដើម ក្នុងផ្ទះញាតិទាំងឡាយឲ្យបុគ្គលនោះ ស្លៀកដណ្តប់សំពត់កាសាយៈទាំងនោះឯង ហើយឲ្យកាជនៈ ឬបាត្រក្នុងដៃ បណ្តេញពីផ្ទះថា ឯងចូរទៅជាសមណៈចុះ ។ ចូលទៅកាន់វិហារ ភិក្ខុទាំងឡាយមិនដឹងសោះថា បុគ្គលនេះសឹកហើយបួសឯងទៀត ទាំងខ្លួនឯងក៏មិនដឹងថា បុគ្គលណាបួសយ៉ាងនោះ បុគ្គលនោះរមែងជាអ្នកមានឈ្មោះថេយ្យសំវាសក ។ បើភិក្ខុទាំងឡាយឲ្យឧបសម្បទាបុគ្គលនោះក្នុងកាលមានអាយុគ្រប់ ២០ ក៏ជាការឧបសម្បទាល្អហើយ ។ តែបើក្នុងវេលាដែលខ្លួននៅជាអនុបសម្បន្ននោះឯង កាលការវិនិច្ឆ័យវិនយប្រព្រឹត្តទៅ បុគ្គលនោះបានស្តាប់ថា បុគ្គលណាបួសយ៉ាងនោះ បុគ្គលនោះឈ្មោះថា ថេយ្យសំវាសក បុគ្គលនោះ ប្រាប់ដល់ភិក្ខុទាំងឡាយថា ខ្ញុំបានធ្វើយ៉ាងនេះ ដោយប្រការយ៉ាងនោះ បុគ្គលនោះរមែងបានបព្វជ្ជាទៀត ។ បើមិនប្រាប់ដោយគិតថា ឥឡូវនេះ បុគ្គលណាមួយមិនដឹងឡើយ គ្រាន់តែដាក់ធុរៈ បុគ្គលនោះរមែងជាថេយ្យសំវាសក ។

ភិក្ខុលាសិក្ខា លះកេទហើយ ធ្វើទុសីលកម្មក៏ដោយ មិនធ្វើក៏ដោយ បដិបត្តិវិធីផ្សេងៗ ដោយវាប់វស្សាជាដើម ដែលពោលហើយខាងដើមទាំងអស់ រមែងជាថេយ្យសំវាសកបុគ្គល ។

មិនបានលាសិក្ខា តាំងនៅក្នុងកេទរបស់ខ្លួន សេពមេថុនធម្ម ប្រើវិធីផ្សេងៗ ដោយវាប់វស្សាជាដើម មិនជាថេយ្យសំវាសកបុគ្គលឡើយ ។ រមែង

ปานตฺรึมតែបព្វជ្ជា ។ តែក្នុងអន្ធកអដ្ឋកថាឲ្យសេចក្តីថា បុគ្គលនេះជាថេយ្យ-សំវាសក ពាក្យនោះមិនគួរកាន់យក ។

ភិក្ខុមួយរូបនៅមានឧស្សាហ៍ ក្នុងសំពត់កាសាយៈ ស្លៀកសំពត់ស ហើយសេពមេថុន ហើយត្រឡប់ស្លៀកសំពត់កាសាយៈវិញ ប្រើប្រាស់វិធីទាំងពួង មានរាប់វស្សាជាដើម សូម្បីភិក្ខុនេះ រមែងមិនជាថេយ្យសំវាសក បុគ្គលទេ រមែងបានត្រឹមតែបព្វជ្ជា (បួសជាសាមណេរ) ។

តែបើជាក់ធុរៈក្នុងសំពត់កាសាយៈ ហើយស្លៀកសំពត់ស សេពមេថុនធម្ម ត្រឡប់ស្លៀកសំពត់កាសាយៈវិញ ប្រើវិធីទាំងពួង មានរាប់វស្សាជាដើម បុគ្គលនោះរមែងជាថេយ្យសំវាសក ។

សាមណេរតាំងនៅក្នុងភេទរបស់ខ្លួន សូម្បីកន្ធងធម៌ ធ្វើឲ្យជាអ្នកមិនមែនជាសមណៈ មានមេថុនជាដើមហើយ រមែងមិនជាថេយ្យសំវាសកទេ សូម្បីនៅមានឧស្សាហ៍ ក្នុងសំពត់កាសាយៈ តែដោះចេញ សេពមេថុនហើយ ត្រឡប់ស្លៀកសំពត់កាសាយៈវិញ មិនជាថេយ្យសំវាសកដូចគ្នា ។

តែបើជាក់ធុរៈក្នុងកាសាយៈហើយ ជាបុគ្គលអាក្រាតក្តី ស្លៀកសក្តីជាអ្នកមិនមែនសមណៈ ដោយការសេពមេថុនជាដើម ហើយត្រឡប់ស្លៀកសំពត់កាសាយៈ បុគ្គលនោះជាថេយ្យសំវាសកពិត ។

បើសាមណេរប្រាថ្នាភាពជាគ្រហស្ថ ទើបស្លៀកសំពត់ដូចគ្រហស្ថ ធ្វើសំពត់កាសាយៈ ចង្កៀនក្តី ដោយអាការដទៃក្តី ដើម្បីសាកមើលថា ភេទគ្រហស្ថរបស់អញស្អាត ឬមិនស្អាត នៅរក្សានៅឡើយ តែត្រមទទួលថា

ស្អាតហើយ (អញសមជាគ្រហស្ថហើយ) ត្រឡប់ត្រេកអរក្នុងបព្វជិតភេទ ទៀត រមែងជាថេយ្យសំវាសក ។ សូម្បីក្នុងការស្បែកសំពត់សសាកមើល និងព្រមទទួល ក៏មានន័យដូចគ្នានោះឯង ។

បើសំពត់សទ្រាប់សំពត់កាសាយៈ ដែលស្បែកហើយ សាកមើលក្តី រមែងទទួលក្តី នៅរក្សាពិត ។ សូម្បីភិក្ខុនីក៏នយនេះឯង ។

បើភិក្ខុនីនោះប្រាថ្នាជាគ្រហស្ថ ស្បែកសំពត់កាសាយៈដូចគ្រហស្ថដើម្បី សាកមើលថា ភេទគ្រហស្ថរបស់អញស្អាត ឬមិនស្អាតហ្ន៎ នៅរក្សានៅឡើយ បើព្រមទទួលថា ស្អាត (អញសមជាគ្រហស្ថ) រក្សាមិនបានឡើយ។ ក្នុងការស្បែក សំពត់សសាកមើល និងព្រមទទួលក៏នយនេះឯង ។

ចំណែកបុគ្គលស្បែកសំពត់សជាន់ពីលើសំពត់កាសាយៈ ដែលស្បែក ហើយ ទោះសាកមើលក្តី រមែងទទួលក្តី នៅរក្សានៅឡើយ ។ បើសាមណេរ អង្គខ្ទះ បួសឯចាស់មិនរាប់វស្សា មិននៅក្នុងជួរ មកផ្លូវម្ខាង កាលដុំបាយ ក្នុងភាជនៈ ធំជាដើមដែលគេយកវែកដួសឡើង ជាក់បាត្រចូលទៅទទួលយក ដូចក្លែងធាបដុំសាច់ទៅដូច្នោះ មិនទាន់ជាថេយ្យសំវាសក តែកាលរាប់ វស្សាភិក្ខុ រាប់ថា ជាថេយ្យសំវាសក ។

សាមណេរ កាលរាប់វស្សាកោង ដោយលំដាប់របស់សាមណេរ មិនរាប់ថា ជាថេយ្យសំវាសក ។

ភិក្ខុកាលរាប់វស្សាកោង ដោយលំដាប់របស់ភិក្ខុ គប្បីទទួលតាមតម្លៃ នៃភណ្ឌៈ ។

ថេយ្យសំវាសកកថា ចប់

តិត្ថិយបក្កន្តកកថា

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **តិត្ថិយបក្កន្តោ ភិក្ខុ** *ជាដើមនេះ ដូច្នេះ កុលបុត្រដែលឈ្មោះថា ចូលតិរ្ថិយ ព្រោះអត្តវិគ្គហៈថា គេចទៅ គឺទៅចូលពួកតិរ្ថិយ ។ កុលបុត្រនោះ មិនគួរឲ្យឧបសម្បទាតែម្យ៉ាង តែដែលពិត មិនគួរឲ្យបព្វជ្ជាផងដែរដូច្នេះ ។*

វិនិច្ឆ័យក្នុងពាក្យនោះ គប្បីជ្រាបដូចតទៅនេះថា ឧបសម្បន្នភិក្ខុគិតថា អញនឹងជាតិរ្ថិយ ហើយទៅកាន់សម្នាក់នៃតិរ្ថិយទាំងនោះ ទាំងកេទនោះឯង ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន កាលកេទនៃតិរ្ថិយនោះ គ្រាន់តែខ្លួនកាន់ហើយ រមែងរាប់ថា ជាអ្នកចូលតិរ្ថិយ ។

បើភិក្ខុណាគិតថា អញនឹងជាតិរ្ថិយខ្លួនឯង ទើបស្បៃកសំពត់ស្បូវភ្ជាំង ជាដើម ភិក្ខុនោះ រមែងជាអ្នកចូលតិរ្ថិយដូចគ្នា ។

ឯភិក្ខុណា កាលអាក្រាតកាយងូតទឹក សម្លឹងមើលខ្លួនថា ការដែលអញជាអាជីវកសមឬ អញនឹងជាអាជីវក ដូច្នេះហើយ មិនកាន់យកសំពត់កាសាយៈ អាក្រាតកាយទៅក្នុងសម្នាក់ពួកអាជីវក ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន តែបើក្នុងរវាងផ្លូវ ហិរិឱត្តប្បៈកើតឡើងដល់លោកៗ សម្តែងអាបត្តិទុក្កដហើយ រមែងរួចផុត ។

សូម្បីទៅដល់សម្នាក់ពួកអាជីវកទាំងនោះហើយ ត្រូវពួកអាជីវកជាស់តឿនក្តី ឬឃើញថា បព្វជ្ជារបស់ជនពួកនេះ ជាទុក្ខក្រៃលែង ហើយត្រឡប់ខ្លួនឯង រមែងរួចផុតបានដូចគ្នា ។

ម្យ៉ាងទៀត បើលោកសួរថា អ្វីប្រសើរបំផុតនៃបព្វជ្ជារបស់ពួកលោក

ត្រូវអាបត្តិទុក្កដ ។ ក៏សម័យនោះឯង ក្នុងអាវាសមួយ ក្នុងកោសលជនបទ មានសញ្ជ្ញវភ័យ[1] ក្នុងឧបោសថថ្ងៃនោះ ។ ភិក្ខុទាំងឡាយមិនអាចនឹងសម្តែងបាតិមោក្ខដោយពិស្តារបាន ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីអន្តរាយ តថាគតអនុញ្ញាតឲ្យសម្តែងនូវបាតិមោក្ខដោយសង្ខេបបាន ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសូម្បីមិនមានសេចក្តីអន្តរាយ ក៏សម្តែងនូវបាតិមោក្ខដោយសង្ខេប ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កាលបើគ្មានសេចក្តីអន្តរាយ ភិក្ខុមិនត្រូវសម្តែងបាតិមោក្ខដោយសង្ខេបទេ ភិក្ខុណាសម្តែងត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសម្តែងនូវបាតិមោក្ខដោយសង្ខេបបាន ក្នុងពេលដែលមានសេចក្តីអន្តរាយ ។ ឯអន្តរាយក្នុងពេលដែលសម្តែងបាតិមោក្ខនោះ (មាន ១០ យ៉ាងគឺ) អន្តរាយអំពីស្តេច (គឺមានស្តេចយាងចូលមក) អន្តរាយអំពីចោរ (គឺមានចោរចូលមកលុកលុយ) អន្តរាយអំពីភ្លើង (គឺមានភ្លើងព្រៃឆេះរាលមកឬភ្លើងរន្ទះកើតឡើង) អន្តរាយអំពីទឹក (គឺមានភ្លៀងខ្លាំងឬជន់ហូរមក) អន្តរាយអំពីមនុស្ស (គឺមានមនុស្សច្រើន ចូលមក) អន្តរាយអំពីអមនុស្ស (គឺខ្មោចចូលភិក្ខុ) អន្តរាយអំពីសត្វសាហាវ អំពីសត្វទីឃជាត (ពួកសត្វលូនវារ) អន្តរាយដល់ជីវិត (គឺមានភិក្ខុកើតជំងឺ

๑- សូមមើលអដ្ឋកថាខាងក្រោម ។

ស្ងាប់ឬមានមនុស្សមានពៀរប៉ងសម្លាប់ភិក្ខុ) អន្តរាយដល់ ព្រហ្មចារ្យ (គឺ មានមនុស្សមកចាប់ភិក្ខុផ្សឹក) ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តី អន្តរាយទាំងឡាយបែបយ៉ាងនេះ តថាគតអនុញ្ញាតឲ្យ ភិក្ខុសម្តែងនូវ ជាតិមោក្ខដោយសង្ខេបបាន កាលបើមិនមានសេចក្តីអន្តរាយទេ ឲ្យភិក្ខុ សម្តែងដោយពិស្តារ ។

อัฏฐกถา

ชาติมหากุเรุสชาดก

[๑๖๗] บทว่า **ฉินฺนาสึ ขุฏฺฐิสิกฺขา อาสเยสึ สุเตน สาเวตุ** เพื่อจะแสดงเนื้อความแห่งคำว่า กาลสมัยนั้นอย่างนี้ว่า **สุณาตุ เม ภนฺเต สงฺฆา ฯเปฯ อาวิกตา หิสฺส ชาสุ เหนติ** แล้วกล่าวว่า **ขุฏฺฐิฏฺฐ เหา อายสฺมนฺโต ฉินฺนาสึ ตตฺถายสฺมนฺเต ปุจฺฉามิ ฯ กจฺจิตฺถ ชานาสุหา ทุติยมฺปิ ปุจฺฉามิ ฯเปฯ ฬหเมตฺ ธารยามิ** แล้วกล่าวขุเรุสชาดก ๔ ด้วยสูตรอย่างนี้ว่า **สุตา เหา ภนายสฺมนฺโตหิ จตฺตาโร ชานาสิกา ธมฺมา ฯเปฯ อาวิรหมาเนหิ สกฺกิตพฺพ ฯ** ชาตกมหากุเรุสชาดก ๔ ด้วยประการฉะนี้ ฯ

สัตว์เหล่านั้น ได้ถึง ความเกิดเป็นมนุษย์ในหมู่ชนผู้ตั้งอยู่ในธรรม ฯ

วินิจฉัยในอนันตรชาดก ๑๐ ชื่อว่าชนันตรชาดกก่อน ฯ ได้ยินว่าพวกโจรเหล่านั้นคิดกันว่า พวกเราจักทำสัตย์สาบานกันแล้วจึงมาประชุมกันแล้วจึงมา นี้ชื่อว่า ชนันตรชาดก ฯ พวกโจรเหล่านั้นมาแล้วๆ นี้ชื่อว่า โจรันตรชาดก ฯ ภิกษุในพระศาสนานี้ ถึงความเป็นผู้ชำนาญในอาสวะทั้งหลาย นี้ชื่อว่า อัคคันตรชาดก ฯ ภิกษุเหล่านั้นเข้าไปหาพระศาสดาแล้วๆ นี้ชื่อว่า ทุกันตรชาดก ฯ มนุษย์เหล่านั้นมาแล้วๆ นี้ชื่อว่า มนุสสันตรชาดก ฯ ภิกษุเข้าไปสู่ป่า นี้ชื่อว่า อมนุสสันตรชาดก ฯ สัตว์สาหัสมีกำลังเข้าไปสู่ป่า นี้ชื่อว่า ปาฬันตรชาดก ฯ สัตว์มีกำลัง

ពិស មានពស់ជាដើមចឹកកិក្ខុ នេះឈ្មោះថា សិរីសបន្តរាយ ។ កិក្ខុអាពាធក្តី ធ្វើកាលកិរិយាក្តី ពួកបុគ្គលមានពៀរប៉ុនប៉ងនឹងសម្លាប់ក្តី ចាប់កិក្ខុនោះក្តី នេះឈ្មោះថា ជីវិតន្តរាយ ។ មនុស្សបំណងឲ្យកិក្ខុមួយរូប ឬច្រើនឃ្លាតអំពីព្រហ្មចរិយៈ ចាប់យកទៅ នេះឈ្មោះថា ព្រហ្មចរិយន្តរាយ ។

ក្នុងអន្តរាយដែលមានសភាពបែបនេះ គប្បីសូធ្យបាតិមោក្ខសង្វរបាន គប្បីសូធ្យខន្ធកទី ១ ឬសូធ្យ ២ ខន្ធក ។ ៣ ខន្ធក ៤ ខន្ធកខាងដើមក្តី ។ ក្នុងខន្ធកទាំងនេះ ខន្ធកទី ២ ជាដើម កាលខន្ធកណាសូធ្យមិនទាន់ចប់ មានអន្តរាយ ខន្ធកនោះ គប្បីសូធ្យដោយសុតបទនោះចុះ ។

បាតិមោក្ខុទ្ទេស ចប់

អញ្ញតត្តិយភាណវារៈ ៧៧

[១៦៨] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនមានគេអារាធនាក៏សម្តែងធម៌ក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេមិនអារាធនាមិនត្រូវសម្តែងធម៌ក្នុងកណ្តាលសង្ឃទេ ភិក្ខុណាសម្តែងត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈសម្តែងធម៌ខ្លួនឯង ឬអារាធនាភិក្ខុដទៃបាន ។

[១៦៩] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយមិនទាន់បានការសន្មតិក៏សួរវិនិច្ឆយក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគ្មានការសន្មតិមិនត្រូវសួរវិនិច្ឆយក្នុងកណ្តាលសង្ឃទេ ភិក្ខុណាសួរត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានការសន្មតិសួរវិនិច្ឆយក្នុងកណ្តាលសង្ឃបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ ។ ត្រូវសន្មតខ្លួនដោយខ្លួនឯងក៏បាន ត្រូវភិក្ខុដទៃសន្មតភិក្ខុដទៃក៏បាន ។ ក៏ឯសន្មតខ្លួនដោយខ្លួនឯងនោះដូចម្តេច ។ ភិក្ខុដែលឆ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំសូមសួរវិនិច្ឆយនឹងភិក្ខុឈ្មោះនេះ ។ ភិក្ខុត្រូវសន្មតខ្លួនដោយខ្លួនឯងយ៉ាងនេះ ។ ក៏ឯភិក្ខុដទៃត្រូវសន្មតភិក្ខុដទៃដូចម្តេច ។ ត្រូវភិក្ខុដែលឆ្លាសប្រតិពលឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃ

ហើយ កិក្ខុឈ្មោះនេះគួរសួរវិនិច្ឆយនឹងកិក្ខុឈ្មោះនេះ ។ ត្រូវកិក្ខុដទៃសន្ទុះ កិក្ខុដទៃយ៉ាងនេះ ។ ក៏សម័យនោះឯង កិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់មានការសន្មតិហើយ ក៏សួរវិនិច្ឆយក្នុងកណ្តាលសង្ឃ ។ ពួកឆព្វគ្គិយកិក្ខុបានសេចក្តីគំនុំ បានសេចក្តីមិនពេញចិត្ត ក៏គំរាមដោយប្រុងនឹងសម្លាប់ ។ កិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលកិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកិក្ខុដែលទុកជាមានការសន្មតិហើយមែន ត្រូវតែរមិលមើលបរិសទ្យ ពិចារណាបុគ្គលហើយសិន សឹមសួរវិនិច្ឆយក្នុងកណ្តាលសង្ឃ ។ ក៏សម័យនោះឯង ឆព្វគ្គិយកិក្ខុទាំងឡាយគ្មានការសន្មតិ ក៏ដោះស្រាយវិនិច្ឆយក្នុងកណ្តាលសង្ឃ ។ កិក្ខុទាំង-ឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលកិក្ខុទាំងឡាយ កិក្ខុដែលគ្មានការសន្មតិ មិនត្រូវដោះស្រាយវិនិច្ឆយក្នុងកណ្តាលសង្ឃទេ កិក្ខុណាដោះស្រាយ ត្រូវអាបត្តិទុក្កដ ។ ម្នាលកិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យកិក្ខុដែលមានការសន្មតិហើយដោះស្រាយវិនិច្ឆយក្នុងកណ្តាលសង្ឃបាន ។ ម្នាលកិក្ខុទាំងឡាយ កិក្ខុត្រូវសន្មតយ៉ាងនេះ ។ ត្រូវខ្លួនឯងសន្មតខ្លួនក៏បាន កិក្ខុដទៃសន្មតកិក្ខុដទៃក៏បាន ។ ក៏ឯខ្លួនឯងសន្មតខ្លួនឯងតើដូចម្តេច ។ ត្រូវកិក្ខុដែលឆ្លាសប្រតិពលឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ កិក្ខុឈ្មោះនេះសួរវិនិច្ឆយនឹងខ្ញុំហើយ ខ្ញុំត្រូវតែដោះស្រាយ ។ ត្រូវខ្លួនឯងសន្មតខ្លួនឯងយ៉ាងនេះ ។ ក៏ឯកិក្ខុដទៃសន្មតកិក្ខុដទៃ តើដូចម្តេច ។

ត្រូវភិក្ខុដែលធ្វាសប្រតិពលឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុឈ្មោះនេះត្រូវដោះស្រាយវិន័យដែលភិក្ខុឈ្មោះនេះសួរ ។ ត្រូវភិក្ខុដទៃសន្មតភិក្ខុដទៃយ៉ាងនេះ ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់បានការសន្មតិហើយក៏ដោះស្រាយវិន័យក្នុងកណ្តាលសង្ឃ ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយបានសេចក្តីគំនុំ បានសេចក្តីមិនគាប់ចិត្ត ក៏គំរាមប្រុងនឹងសម្លាប់ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញត្តឲ្យភិក្ខុដែលទុកជាមានការសន្មតិហើយមែនត្រូវតែរមិលមើលបរិសទ្យពិនិត្យបុគ្គលហើយសិន សឹមដោះស្រាយវិន័យក្នុងកណ្តាលសង្ឃ ។

[១៧០] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុចោទអាបត្តិចំពោះភិក្ខុដែលខ្លួនមិនទាន់បានសូមឱកាស (ជាមុន) ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចោទអាបត្តិចំពោះភិក្ខុដែលខ្លួនមិនបានសូមឱកាស (ជាមុន) ទេ ភិក្ខុណាចោទ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសូមឱកាសថា សូមលោកដ៏មានអាយុបើកឱកាស (ឲ្យខ្ញុំ) ខ្ញុំចង់និយាយនឹងលោក ដូច្នេះហើយសិន សឹមចោទអាបត្តិ ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ឲ្យពួកឆព្វគ្គិយភិក្ខុបើកឱកាសហើយចោទអាបត្តិ ។ ពួកឆព្វគ្គិយភិក្ខុបានសេចក្តីគំនុំ បាន

សេចក្តីមិនត្រេកអរ ក៏គំរាមដោយប្រាថ្នានឹងសម្លាប់ ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដទៃបើកឱកាសឲ្យហើយមែន តថាគត អនុញ្ញាតឲ្យពិនិត្យមើលបុគ្គលហើយសិន សឹមចោទអាបត្តិ ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ គង់តែឲ្យយើងបើកឱកាសជាមុន (មិនខាន) ហើយក៏ឲ្យភិក្ខុទាំងឡាយ ដែលបរិសុទ្ធ មិនមានអាបត្តិបើកឱកាសជាមុនក្នុងការមិនមែនជារឿង មិនមែនជាហេតុ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យភិក្ខុទាំងឡាយដែលបរិសុទ្ធមិនមានអាបត្តិបើកឱកាសក្នុងការមិនមែនជារឿង មិនមែនជាហេតុទេ ភិក្ខុណាឲ្យបើក (ឱកាស) ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពិនិត្យមើលបុគ្គលហើយសិនសឹមឲ្យគេបើកឱកាស ។

[១៧១] *ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មមិនមែនជាធម៌ក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកម្មមិនមែនជាធម៌កណ្តាលសង្ឃ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។ ពួកឆព្វគ្គិយ-ភិក្ខុទាំងនោះនៅតែធ្វើកម្មមិនមែនជាធម៌ដដែល ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុណាមួយធ្វើកម្មមិនប្រកបដោយធម៌ តថាគតអនុញ្ញាត*

ឲ្យភិក្ខុហាមឃាត់បាន ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ កាលបើពួកឆព្វគ្គិយភិក្ខុធ្វើកម្មមិនមែនជាធម៌ ក៏ហាមឃាត់ ។ ពួកឆព្វគ្គិយភិក្ខុបានសេចក្តីគំនុំ បានសេចក្តីមិនសប្បាយចិត្ត ក៏គំរាមដោយប្រុងសម្ងាប់ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រកាសសេចក្តីយល់ឃើញក៏បាន ។ ភិក្ខុទាំងឡាយប្រកាសសេចក្តីយល់ឃើញក្នុងសំណាក់ឆព្វគ្គិយភិក្ខុទាំងឡាយនោះឯង ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បានសេចក្តីគំនុំ បានសេចក្តីមិនសប្បាយចិត្ត ក៏គំរាមដោយប្រុងនឹងសម្ងាប់ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ៤ ឬ ៥ រូបហាមឃាត់ ឲ្យភិក្ខុ ២ ឬ ៣ រូបប្រកាសសេចក្តីយល់ឃើញ ឲ្យភិក្ខុមួយរូបអធិដ្ឋាន (តាំងចិត្ត) ថា កម្មនោះមិនគាប់ចិត្តដល់អញទេ ។

[១៧២] ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយកាលសម្តែងនូវបាតិមោក្ខក្នុងកណ្តាលសង្ឃ ក៏ក្អែងធ្វើមិនឲ្យឮច្បាស់ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសម្តែងនូវបាតិមោក្ខ មិនត្រូវក្អែងមិនឲ្យឮច្បាស់ទេ ភិក្ខុណាមិនឲ្យឮច្បាស់ ត្រូវអាបត្តិទុក្កដ ។ ក៏សម័យនោះឯង ឧទាយិដ៏មានអាយុជាអ្នកសម្តែងបាតិមោក្ខដល់សង្ឃ មានសំឡេងដូចក្អែក ។ ទើបឧទាយិដ៏មានអាយុមានសេចក្តីគិតដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា

ภิกฺขุអ្នកសម្តែងនូវជាតិមោក្ខធ្វើសំឡេងឲ្យព្រួចច្បាស់ ឯអាត្មាអញមានសំឡេងដូចក្អែក គួរអញប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកសម្តែងនូវជាតិមោក្ខទំប្រើងគិតថា អញត្រូវធ្វើសំឡេងឲ្យព្រួចច្បាស់ដោយប្រការដូចម្តេច កាលបើភិក្ខុទំប្រើង(ដូច្នេះ) ទើបមិនត្រូវអាបត្តិ ។

[๑๗๓] ក៏សម័យនោះឯង ទេវទត្តសម្តែងនូវជាតិមោក្ខក្នុងបរិសទ្យព្រមជាមួយនឹងគ្រហស្ថ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុសម្តែងនូវជាតិមោក្ខក្នុងបរិសទ្យជាមួយនឹងគ្រហស្ថទេ ភិក្ខុណាសម្តែងត្រូវអាបត្តិទុក្កដ ។

[๑๗๔] ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ មិនមានភិក្ខុអាវាធនាក៏សម្តែងនូវជាតិមោក្ខក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលមិនមានគេអាវាធនាមិនត្រូវសម្តែងនូវជាតិមោក្ខក្នុងកណ្តាលសង្ឃទេ ភិក្ខុណាសម្តែង ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជាតិមោក្ខ មានព្រះថេរៈជាធំ ។

អញ្ញតិត្ថិយភាណវារទី ๑๑ ចប់

អដ្ឋកថា

អជ្ឈេសនា

[១៦៨] បទថា **អនជ្ឈិដ្ឋោ** បានដល់ មិនបានទទួលបញ្ជា ឬមិនបានទទួលនិមន្ត ។ ក្នុងអជ្ឈេសនាទិកានេះ ការនិមន្តន៍ ទាក់ទងដោយភិក្ខុដែលនិមន្តសម្តែងធម៌ដែលសង្ឃសន្មតក៏មាន ទាក់ទងដោយព្រះសង្ឃត្តេរក៏មាន ។ កាលភិក្ខុ ដែលនិមន្តសម្តែងធម៌នោះ មិនមាន ភិក្ខុប្រាប់ព្រះសង្ឃត្តេរហើយ ឬព្រះសង្ឃត្តេរនិមន្តហើយ រមែងបានដើម្បីពោលធម៌ ។

ព្រះសង្ឃត្តេរសោត បើក្នុងវិហារ មានធម្មកថិកច្រើន គប្បីប្រើតាមលំដាប់វារៈ ។ ភិក្ខុដែលលោកប្រើថា លោកចូរសូត្រធម៌ក្តី ប្រើថា លោកចូរសម្តែងធម៌ក្តី ប្រើថា លោកចូរឲ្យធម្មទានក្តី គប្បីពោលធម៌បានទាំង ៣ វិធី តែភិក្ខុដែលបានទទួលពាក្យប្រើថា ចូរសូត្រ រមែងបានដើម្បីសូត្រប៉ុណ្ណោះ ដែលបានទទួលពាក្យប្រើថា ចូរសម្តែង រមែងបានដើម្បីសម្តែងប៉ុណ្ណោះ ដែលបានទទួលពាក្យប្រើថា ចូរសូត្រសរភញ្ញ រមែងបានដើម្បីសូត្រសរភញ្ញប៉ុណ្ណោះ ។ ឯព្រះថេរៈសោត ដែលអង្គុយលើអាសនៈខ្ពស់ជាង រមែងមិនបាននឹងនិមន្ត ។ បើព្រះសង្ឃត្តេរជាឧបជ្ឈាយ៍ ឯព្រះធម្មកថិកជាសទ្ធិវិហារិក ហើយព្រះឧបជ្ឈាយ៍អង្គុយលើអាសនៈខ្ពស់ ប្រាប់សទ្ធិវិហារិកនោះថា លោកចូរសូត្រ ។ គប្បីតាំងចិត្តស្វាធ្យាយ ហើយសូត្រចុះ ។ តែបើក្នុងសម្នាក់ឧបជ្ឈាយ៍នេះ មានភិក្ខុកំលោះច្រើន គប្បីតាំងចិត្តថា អាត្មាអញសូត្រដល់ភិក្ខុទាំងនោះ ហើយសូត្រចុះ ។

បើព្រះសង្ឃត្តេរក្នុងវិហារឲ្យសូធ្យដល់និស្សិតរបស់ខ្លួនប៉ុណ្ណោះ មិនមែនភិក្ខុទាំងឡាយដទៃដែលសូធ្យពីរោះខ្លះ ភិក្ខុទាំងឡាយដទៃគប្បីសួរលោកថា បពិត្រលោកម្ចាស់ ពួកខ្ញុំសូមឲ្យភិក្ខុឈ្មោះនោះសូធ្យ ។ បើលោកឆ្លើយថា សូធ្យចុះ ឬលោកនៅស្ងៀម សមគួរឲ្យសូធ្យបាន ។ តែបើលោកហាមមិនគួរឲ្យសូធ្យ ។

បើផ្តើមធម្មស្សវនៈ តែកាលព្រះសង្ឃត្តេរមិនទាន់មក កាលលោកមកកណ្តាលចន្លោះ កិច្ចដែលត្រូវឈប់សូមឱកាសមិនមាន ។

ម្យ៉ាងទៀត កាលសូធ្យហើយ ទោះអធិប្បាយអត្ថ គប្បីសុំឱកាសលោក ហើយសឹមអធិប្បាយក៏បាន ។ មិនឈប់ ហើយអធិប្បាយតែម្តងក៏បាន សូម្បីក្នុងព្រះសង្ឃត្តេរដែលមកត្រង់ចន្លោះ កាលកំពុងអធិប្បាយ ក៏មានន័យដូចគ្នា ។ សូម្បីក្នុងឧបនិសិន្នកថា ព្រះសង្ឃត្តេរជាប្រធាន ព្រោះដូច្នោះ ព្រះសង្ឃត្តេរនោះ គប្បីពោលឯង ឬប្រាប់ភិក្ខុដទៃថា លោកចូរពោលឯព្រះថេរៈអង្គុយខ្ពស់ជាង មិនគួរប្រាប់ ។ តែបើប្រាប់ដល់មនុស្សទាំងឡាយថា អ្នកចូរពោល គួរ ជនទាំងឡាយសួរភិក្ខុដែលស្គាល់ខ្លួន ភិក្ខុនោះគប្បីសូមឱកាសព្រះថេរៈជាមុន សឹមឆ្លើយតប ។ បើព្រះថេរៈបានទទួលចម្លើយថា លោកដ៏ចម្រើន ជនទាំងនេះសួរបញ្ហាជាមួយខ្ញុំ ដូច្នេះហើយ ប្រាប់ថាឆ្លើយចុះក្តី ស្ងៀមក្តី ទោះឆ្លើយក៏គួរ ។

ក្នុងការអនុមោទនាជាដើម ក្នុងចន្លោះស្រុក ក៏មាននន័យនេះឯង ។ បើព្រះសង្ឃត្តេរអនុញ្ញាតថា លោកគប្បីពោលក្នុងវិហារ ឬក្នុងចន្លោះស្រុកចុះ

មិនចាំបាច់ប្រាប់ខ្ញុំទេ ជាការបាននូវការអាង សមគួរពោលបានក្នុងទីទាំងពួង ។ កាលធ្វើការស្វាធ្យាយសោត ក៏ត្រូវសូមឱកាសព្រះថេរៈជួចគ្នា ។ កាលសូមឱកាសមួយអង្គហើយ កំពុងស្វាធ្យាយ អង្គដទៃទៀតមក កិច្ចដែលត្រូវសូមឱកាសទៀត មិនមាន ។ បើចង់ចិត្តថា អញនឹងផ្អាក ហើយឈប់ ព្រះថេរៈមក កាលផ្តើមទៀត ត្រូវសូមឱកាស បើកំពុងស្វាធ្យាយធម៌ដែលផ្តើមទុកហើយ តែកាលព្រះសង្ឃត្តេរមិនទាន់បានមក ក៏មានន័យដូច្នេះ ។ ព្រះសង្ឃត្តេរមួយអង្គ អនុញ្ញាតហើយថា មិនបាច់សូមឱកាសខ្ញុំទេ ស្វាធ្យាយតាមសប្បាយចុះ ដូច្នេះ សមគួរស្វាធ្យាយតាមសប្បាយ តែបើព្រះសង្ឃត្តេរដទៃមក ត្រូវសូមឱកាសលោកជាមុន សឹមស្វាធ្យាយ ។

[๑๖๙] *បទថា* **អត្តនា វា អត្តានំ សម្មជ្ជិតព្ពំ** *សេចក្តីថា គប្បីសន្មតខ្លួនដោយខ្លួនឯងក៏បាន ។ តែកាលនឹងសួរត្រូវក្រឡេកមើលបរិស័ទ បើឧបទ្វៅមិនមានដល់ខ្លួន គប្បីសួរវិន័យ ។*

[๑๗๐] *បទថា* **កតេបិ ឱកាសេ បុគ្គលំ តុលយិត្វា** *សេចក្តីថា តថាគត អនុញ្ញាតឲ្យភិក្ខុដែលខ្លួនសូមឱកាសហើយ ត្រូវពិចារណាយ៉ាងនេះថា ឧបទ្វៅអំពីបុគ្គលនេះនឹងមានដល់អញ ឬ មិនមានហ្ន៎ ដូច្នេះ ហើយសឹមចោទដោយអាបត្តិ ។*

បទថា **បុរេភត្តំ** *បានដល់ យើងទាំងឡាយ ... មុន ។*

បទថា **បដិកច្ចេវ** *បានដល់ មុនអំពីនោះ ។ កម្មមិនត្រូវតាមធម៌ មានន័យដូចពោលហើយនោះឯង ។*

บทว่า **บุคฺคลํ ตุลยิตฺวา ฐิกาสํ กาตุ** *สมควรแก่คำว่า ตถาคตอนุญาตให้ภิกษุพิจารณาอย่างนี้ว่า บุคคลนี้ควรเพื่อจะสนทนาในเรื่องจริงหรือไม่จริงหนอ ดังนี้แล้วจึงให้โอกาส ฯ*

[๑๗๑] บทว่า **ปฏิกฺโกสิตุ** *ได้แก่ เพื่อห้าม ฯ*

บทว่า **ธิฏฺฐิมฺปิ อาวิกาตุ** *สมควรแก่คำว่า ตถาคตอนุญาตให้ภิกษุประกาศความเห็นผิดของตนในสัมภาระของภิกษุอย่างนี้ว่า กรรมนี้ไม่ควรเพื่อทำ กรรมนั้นไม่ควรเพื่อทำ ฯ*

คำว่า ๔ หรือ ๕ รูปขึ้นไป พระผู้มีพระภาคตรัสไว้เพื่อไม่ให้มีอันตรายแก่ภิกษุทั้งหลาย ฯ

[๑๗๒] บทว่า **สญฺจิจฺจ น สาเวนฺติ** *สมควรแก่คำว่า ภิกษุทั้งหลายย่อมสวดซ้ำๆ ด้วยตั้งใจว่า ภิกษุพวกอื่นยังไม่ได้ฟังด้วยประการใดๆ เราจักให้ฟังด้วยประการนั้นๆ ฯ*

[๑๗๔] บทว่า **เถราธิกํ** *สมควรแก่คำว่า ตถาคตอนุญาตให้ภิกษุณีมีพระเถระเป็นใหญ่ อธิบายว่า เพื่อให้ขึ้นอยู่กับพระเถระ ฯ*

ในบาลีว่า **เถราเธยฺยา** *ก็มี แปลว่า ให้มีพระเถระเป็นประธาน เพราะเหตุนั้น พระเถระจึงสวดก็ได้ ภิกษุณีจึงอาราธนาภิกษุก็ได้ ฯ*

ในอธิการที่กล่าวด้วยการอาราธนาภิกษุณีนี้ วิธีอาราธนา มีนัยดังกล่าวแล้วนั่นแล ในการอาราธนาธรรมนั่นเทียว ฯ

អាឡ្លសនា

[១៧៥] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចោទនាវត្ថុនគរ ទ្រង់គ្រាច់ទៅដោយលំដាប់ ទើបបានទៅដល់ចោទនាវត្ថុនគរនោះ ។ សម័យនោះឯង ភិក្ខុច្រើនអង្គនៅក្នុងអាវាសមួយ ។ ភិក្ខុជាថេរៈក្នុងអាវាសនោះល្ងង់មិនឆ្លាស ។ ភិក្ខុជាថេរៈនោះ មិនដឹងឧបោសថ ឬឧបោសថកម្ម ជាតិមោក្ខ ឬជាតិមោក្ខទូសៈ ។ ទើបភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា ជាតិមោក្ខមានព្រះថេរៈជាធំ ក៏ព្រះថេរៈរបស់យើងនេះល្ងង់ មិនឆ្លាស មិនដឹងឧបោសថ ឬឧបោសថកម្មជាតិមោក្ខឬជាតិមោក្ខទូសៈ ត្រូវយើងប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវជាតិមោក្ខសម្រេចលើភិក្ខុ ដែលភិក្ខុឆ្លាសប្រតិពលក្នុងអាវាសនោះ ។

[១៧៦] ក៏សម័យនោះឯង ឧបោសថថ្ងៃនោះមានភិក្ខុច្រើនរូបនៅក្នុងអាវាសមួយ សុទ្ធតែល្ងង់មិនឆ្លាស ។ ភិក្ខុទាំងនោះមិនដឹងឧបោសថ ឬឧបោសថកម្ម ជាតិមោក្ខ ឬជាតិមោក្ខទូសៈ ។ ភិក្ខុទាំងនោះអាវាធនាព្រះថេរៈថា បពិត្រព្រះថេរៈដ៏ចម្រើន សូមព្រះថេរៈសម្តែងនូវជាតិមោក្ខ ។ ព្រះថេរៈនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសម្តែងជាតិមោក្ខមិនកើតទេ ។ ភិក្ខុទាំងនោះអាវាធនាព្រះថេរៈទី ២ ថា បពិត្រព្រះថេរៈដ៏ចម្រើន សូមព្រះថេរៈ

សម្តែងនូវបាតិមោក្ខ ។ ព្រះថេរៈទី ២ នោះក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសម្តែងមិនកើតទេ ។ ភិក្ខុទាំងនោះអាចនាព្រះថេរៈទី ៣ ថា បពិត្រថេរៈដ៏ចម្រើន សូមព្រះថេរៈសម្តែងនូវបាតិមោក្ខ ។ ព្រះថេរៈទី ៣ នោះក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសម្តែងមិនកើតទេ ។ ភិក្ខុទាំងនោះអាចនាដរាបដល់ភិក្ខុថ្មីក្នុងសង្ឃ ដោយឧបាយនេះឯងថា ចូរលោកដ៏មានអាយុសម្តែងនូវបាតិមោក្ខ ។ ភិក្ខុនោះក៏និយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំសម្តែងមិនកើតទេ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះឧបោសថថ្ងៃនោះមានភិក្ខុច្រើនរូបជាភិក្ខុល្ងង់ មិនឆ្លាសនៅក្នុងអាវាសមួយ ។ ភិក្ខុទាំងឡាយនោះមិនដឹងឧបោសថឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស ។ ភិក្ខុទាំងនោះអាចនាព្រះថេរៈថា បពិត្រព្រះថេរៈដ៏ចម្រើន សូមព្រះថេរៈសម្តែងនូវបាតិមោក្ខ ។ ព្រះថេរៈនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសូត្រមិនកើតទេ ។ ភិក្ខុទាំងនោះអាចនាព្រះថេរៈទី ២ ថា បពិត្រព្រះថេរៈដ៏ចម្រើន សូមព្រះថេរៈសម្តែងនូវបាតិមោក្ខ ។ ព្រះថេរៈទី ២ នោះក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសម្តែងមិនកើតទេ ។ ភិក្ខុទាំងនោះអាចនាព្រះថេរៈទី ៣ ថា បពិត្រថេរៈដ៏ចម្រើន សូមព្រះថេរៈសម្តែងនូវបាតិមោក្ខ ។ ព្រះថេរៈទី ៣ នោះក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសូត្រមិនកើតទេ ។ ភិក្ខុទាំងនោះអាចនាដរាបដល់ភិក្ខុថ្មីក្នុងសង្ឃដោយឧបាយនេះឯងថា លោកដ៏មានអាយុចូរសម្តែងនូវបាតិមោក្ខ ។ ភិក្ខុនោះ ក៏

นิยายយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំសូត្រមិនកើតទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបញ្ជូនភិក្ខុមួយរូបទៅកាន់អាវាសដែលមាននៅជិតខាង ក្នុងថ្ងៃនោះឯងថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ឃបឬដោយពិស្តារមក ។ លំដាប់នោះឯង ភិក្ខុទាំងឡាយ មានសេចក្តីគិតដូច្នេះថា យើងត្រូវបញ្ជូនលោកណាទៅហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុថ្មីបាន ។ ភិក្ខុថ្មីទាំងឡាយដែលព្រះថេរៈបង្គាប់ហើយ មិនទៅ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្មានជំងឺបើព្រះថេរៈបង្គាប់ហើយត្រូវតែទៅ ភិក្ខុណាមិនទៅ ត្រូវអាបត្តិទុក្កដ ។

[๑๗๗] លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងចោទនាវត្ថុនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញទៀត ។ ក៏សម័យនោះឯង មនុស្សទាំងឡាយសួរពួកភិក្ខុដែលកំពុងត្រាច់ទៅបិណ្ឌបាតថា បពិត្រលោកដ៏ចម្រើន តិថីនៃបក្ខបានប៉ុន្មានហើយ (គឺប៉ុន្មានកើត ប៉ុន្មានរោចហើយ) ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ យើងមិនដឹងទេ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀលបន្ទុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យៈទាំងនេះ ត្រឹមតែវិជ្ជារាប់បក្ខ (ប៉ុណ្ណោះ) មិនដឹងទៅហើយ ចំណង់បើការល្អណាមួយដទៃទៀត

ធ្វើម្តេចពួកសមណៈទាំងនេះនឹងដឹងបាន ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរៀនរាប់បក្ខ[1]។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណារៀនរាប់បក្ខហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងអស់គ្នារៀនរាប់បក្ខ ។ សម័យនោះឯង ពួកមនុស្សសួរភិក្ខុទាំងឡាយដែលកំពុងត្រាច់ទៅបិណ្ឌបាតថា បពិត្រលោកដ៏ចម្រើន ភិក្ខុទាំងឡាយមានប៉ុន្មានអង្គ ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ យើងមិនដឹងទេ ។ មនុស្សទាំងឡាយ ក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យៈទាំងនេះ ត្រឹមតែគ្នីគ្នាមានប៉ុន្មានក៏មិនដឹង (ទៅហើយ) ធ្វើម្តេចទៀបពួកសមណៈទាំងនេះ នឹងដឹងការល្អតិចតួចដទៃបាន ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរាប់ពួកភិក្ខុ ។ ទើបភិក្ខុទាំងឡាយមានការត្រិះរិះដូច្នេះថា យើងគួររាប់ភិក្ខុទាំងឡាយក្នុងកាលណាហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរាប់ត្រឹមតែឈ្មោះ ឬឲ្យកាន់យកស្លាកក្នុងឧបោសថថ្ងៃនោះ ។

๑- ក្នុងវិនយមួយៗ ហៅថា បក្ខមួយៗ ។

[๑๗๘] ก็สมัยนោះឯង ភិក្ខុទាំងឡាយមិនដឹងថាថ្ងៃនេះជាថ្ងៃឧបោសថ ក៏នាំគ្នាដើរទៅកាន់ស្រុកឆ្ងាយដើម្បីបិណ្ឌបាត ។ ភិក្ខុទាំងនោះមកដល់ក្នុងពេលដែលភិក្ខុកំពុងសម្តែងនូវបាតិមោក្ខក៏មាន មកដល់ក្នុងពេលដែលភិក្ខុសម្តែងនូវបាតិមោក្ខចប់ហើយក៏មាន ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ថា ថ្ងៃនេះជាថ្ងៃឧបោសថ ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវភិក្ខុណាប្រាប់ថ្ងៃឧបោសថហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈប្រាប់អំពីព្រឹក ។ ក៏សម័យនោះឯង ព្រះថេរៈមួយអង្គភ្លេច (មិនបានប្រាប់) អំពីព្រឹក ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ក្នុងពេលឆាន់ក៏បាន ។ ភិក្ខុក៏ភ្លេចក្នុងពេលឆាន់ទៀត ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរលឹកឃើញកាលណា ប្រាប់កាលនោះចុះ ។

[๑๗๙] ក៏សម័យនោះឯង ភេងឧបោសថក្នុងអាវាសមួយស្មុកគ្រោក ។ ភិក្ខុជាអាគន្តុកៈទាំងឡាយពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងមិនបោសភេងឧបោសថសោះ ។ ភិក្ខុទាំងឡាយ

ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចោសរោងឧបោសថ ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាចោសរោងឧបោសថហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុ ។ ពួកភិក្ខុដែលព្រះថេរៈបង្គាប់ហើយក៏នៅតែមិនចោស ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានជំងឺ (បើ) ព្រះថេរៈបង្គាប់ហើយ មិនត្រូវមិនចោសទេ (ត្រូវតែចោស) ភិក្ខុណាមិនចោស ត្រូវអាបត្តិទុក្កដ ។ ក៏សម័យនោះឯង ភិក្ខុមិនបានក្រាលអាសនៈក្នុងរោងឧបោសថ ។ ភិក្ខុទាំងឡាយអង្គុយផ្ទាល់ផែនដី កាយភិក្ខុក្តី ចីវរទាំងឡាយក្តីប្រឡាក់ដោយដី ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឲ្យភិក្ខុក្រាលអាសនៈ ក្នុងរោងឧបោសថ ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាក្រាលអាសនៈក្នុងរោងឧបោសថហ្ន៎ ។ ភិក្ខុទាំង-ឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុ ។ ពួកភិក្ខុដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនក្រាលអាសនៈ ។ ភិក្ខុទាំង-ឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈឺ (បើ) ភិក្ខុជាថេរៈបង្គាប់ហើយមិនត្រូវមិនក្រាលអាសនៈទេ ភិក្ខុណាមិនក្រាល ត្រូវអាបត្តិទុក្កដ ។ ក៏សម័យនោះឯង ក្នុងភេងខុបោសថគ្មានប្រទីប ។ ភិក្ខុទាំងឡាយជាន់កាយគ្នាខ្លះ ជាន់ចីវរគ្នាខ្លះក្នុងទីងងឹត ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអុជប្រទីបក្នុងភេងខុបោសថ ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាអុជប្រទីបក្នុងភេងខុបោសថហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុ ។ ពួកភិក្ខុដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនអុជប្រទីប ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមិនឈឺ (បើ) ព្រះថេរៈបង្គាប់ហើយ មិនត្រូវមិនអុជប្រទីបទេ ភិក្ខុណាមិនអុជប្រទីប ត្រូវអាបត្តិទុក្កដ[1] ។

๑- រឿងតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ប្រាកដក្នុងច្បាប់ឱរុបទាំងឡាយ តពីបាលីនេះយ៉ាងនេះថា ក៏សម័យនោះឯង ពួកភិក្ខុអ្នកនៅចាំអារាមក្នុងអារាមកន្លែងមួយ មិនចូលទៅតម្កល់ទឹកឆាន់ មិនចូលទៅតម្កល់ទឹកប្រើប្រាស់ ។ ភិក្ខុជាអាគន្តុកៈទាំងឡាយពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងឡាយអ្នកនៅចាំអារាម មិនសមបើនីងមិនតម្កល់ទឹកឆាន់ មិនតម្កល់ទឹកប្រើប្រាស់សោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ ។ ទើបភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូល

[๑๘๐] ก็สมัยนั้นแล ภิกษุทั้งหลายเป็นจำนวนมากสุดที่จะนับได้ มิได้ฉันสำรับ มีความเดือดร้อนเพราะไม่ได้อาจารย์ และอุปัชฌาย์ ฯ ภิกษุทั้งหลายกราบทูลความข้อนั้นแด่พระผู้มีพระภาค ฯ พระองค์ทรงตรัสว่า ดูก่อนภิกษุทั้งหลาย ภิกษุเป็นจำนวนมากสุดที่จะนับได้ในศาสนานี้ มิได้ฉันสำรับ มีความเดือดร้อนเพราะไม่ได้อาจารย์ และอุปัชฌาย์ ฯ ดูก่อนภิกษุทั้งหลาย ภิกษุทั้งหลายพึงขอร้องอาจารย์และอุปัชฌาย์ว่า ท่านทั้งหลายจงให้ในที่ไหน ให้กับใคร ฯ ดูก่อนภิกษุทั้งหลาย ถ้าภิกษุนั้นมิได้ให้ในที่ใดที่หนึ่งแก่ภิกษุอื่นเลย (ทั้งสิ้น) ดูก่อนภิกษุทั้งหลาย ภิกษุทั้งหลายไม่พึงขอร้องอาจารย์และอุปัชฌาย์ ถ้าขอร้องต้องอาบัติทุกกฏ ฯ ดูก่อนภิกษุทั้งหลาย ถ้าภิกษุมิได้ฉันสำรับนั้นแม้แก่อาจารย์และอุปัชฌาย์ ถ้าแม้นกระนั้นก็ต้องอาบัติทุกกฏ ฯ ดูก่อนภิกษุทั้งหลาย ภิกษุอื่นอีกในศาสนานี้ ภิกษุเป็นจำนวนมากสุดที่จะนับได

*มานชฺฌา มานสเจตฺตีขาสา มานสเจตฺตีรเฆฺมสา สฺเรฬฺหาญฺจการสิกฺขา กึ มหกฺกฺขมาวาสนาโร ฯ ภิกฺขเวติกฺขเวติกฺขเวติ

បញ្ជូនភិក្ខុមួយរូបទៅកាន់អាវាសជិតខាងក្នុងថ្ងៃនោះថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារហើយមក ។ បើភិក្ខុនោះបានបាតិមោក្ខនុ៎ះ មកយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយបញ្ជូនភិក្ខុមួយរូបក្នុងវេលា ៧ ថ្ងៃថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារមក ។ បើភិក្ខុនោះបានបាតិមោក្ខនុ៎ះយ៉ាងនេះ ការបាននុ៎ះជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុទាំងនោះនៅចាំវស្សាក្នុងអាវាសនោះទេ បើនៅ ត្រូវអាបត្តិទុក្កដ ។

อัฏฐกถา

อาปัตติสังสัคคสิกขาบท

[๑๗๕] วินิจฉัยในบทว่า **โย ปน ภิกฺขุ** ชื่อว่า ภิกษุ ในบทว่า **ภิกฺขุ** นี้ ดังนี้ ก่อน ;

ก็ภิกษุนั้น ไม่รู้จักอุโบสถ ๓ อย่าง ที่แสดงไว้ด้วยจาตุทสิกอุโบสถ ปัณณรสิกอุโบสถ และสามัคคีอุโบสถ และไม่รู้จักอุโบสถ ๙ อย่าง มีสังฆอุโบสถเป็นต้น ไม่รู้จักอุโบสถกรรม ๔ อย่าง ไม่รู้จักปาติโมกข์ ๒ อย่าง ไม่รู้จักปาติโมกข์อุเทส ๙ อย่าง ;

ในบทว่า **ยาว ตติยา กมฺมวาจา อนุสฺสาวิตา โหติ** นี้ มีวินิจฉัยว่า ปาติโมกข์ พระผู้มีพระภาคทรงอนุญาตแก่ภิกษุผู้อาพาธ สวดในเวลาเช้าก็ได้

[๑๗๗] *បទថា* **กตมี ภนฺเต** *នេះ មានអធិប្បាយថា តិថីដែលពេញនៃតិថីទាំងឡាយប៉ុនណា ឈ្មោះថា តិថីប៉ុនណា គឺប៉ុន្មានកើត ប៉ុន្មានរោច ។ មនុស្សទាំងឡាយសំដៅយកកុសលកម្ម ដែលទាក់ទងដោយភិក្ខុ សួរថា ភិក្ខុមានប្រមាណប៉ុនណា ។*

បទថា **สลากํ วา คาเหตุ** *សេចក្តីថា តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យក គឺរួមស្លាក ហើយរាប់ ។*

[๑๗๘] *បទថា* **กาลวาโร** *បានដល់ ចំពោះកាលនោះឯង សេចក្តីថា អំពីព្រលឹមនោះឯង ។*

ក្នុងបទថា **ยํ กาลํ สรติ** *នេះ មានសេចក្តីថា សូម្បីក្នុងវេលាល្ងាច ទោះជ្រាប់ថា ថ្ងៃនេះឧបោសថ លោកទាំងឡាយចូរមកប្រជុំ ក៏គួរ ។*

[๑๗๙] *សូម្បីក្នុងបទថា* **เถเรน ภิกฺขุนา ฆรํ ภิกฺขุ อาคนฺตเพฺพ** *នេះ មានវិនិច្ឆ័យថា ភិក្ខុដែលធ្វើកម្មណាមួយក្តី ភិក្ខុដែលជួយការៈណាមួយអស់កាល គ្រប់កាលនោះឯងក្តី ភិក្ខុជាសរភាណក: និងធម្មកថិកជាដើម អង្គណាមួយក្តី ព្រះថេរៈមិនគួរប្រើ ដើម្បីបោសរោងឧបោសថ ឯភិក្ខុដ៏សេសគប្បីប្រើតាមវារៈ គឺផ្ចាស់ប្តូរគ្នា បើភិក្ខុដែលបានទទួលពាក្យប្រើហើយ ទោះមិនបានបោស សូម្បីជារបស់ខ្ចីសោត គប្បីពីងគប្បិយការកឲ្យកាច់មែកឈើធ្វើឲ្យគួរ ហើយបោស កាលលោកមិនបានទូវគប្បិយការកនោះ ជាការបានទូវគោលអាង ។ សូម្បីក្នុងការជ្រាប់ឲ្យក្រាលអាសនៈ ក៏គប្បីជ្រាប់តាមន័យ*

ដែលពោលហើយនោះឯង ។

ចំណែកភិក្ខុដែលទទួលពាក្យប្រើហើយ បើអាសនៈក្នុងវេលាឧបោសថមិនមាន គប្បីជញ្ជូនមកអំពីសង្ឃិកាវាស ក្រោលហើយ ត្រូវជញ្ជូនទៅទុកវិញ កាលអាសនៈមិនមាន ទោះក្រោលកន្ទេលផែនក្តី កន្ទេលទន់ក្តី រមែងគួរ បើកន្ទេលទន់មិនមាន ក៏គប្បីពីងពាក់កប្បិយការកឲ្យជួយកាច់មែកឈើ ធ្វើឲ្យគួរ ហើយក្រោលចុះ កាលលោកមិនបានកប្បិយការក ជាការបានគោលអាង ។

ក្នុងការអុជប្រទីបសោត ព្រះថេរៈគប្បីប្រើតាមន័យដែលពោលហើយនោះឯង ។ កាលនឹងប្រើ ត្រូវប្រាប់ថា ប្រេងក្តី ប្រេះក្តី ចង្កៀងក្តី មាននៅក្នុងឱកាសឈ្មោះនោះ លោកចូរកាន់យកវត្ថុនោះៗ មកធ្វើជាប្រទីប ។ បើប្រេងជាដើមមិនមាន ភិក្ខុអ្នកទទួលប្រើ ត្រូវស្វែងរកមក កាលស្វែងរកមកហើយមិនបាន ឈ្មោះថា បានគោលអាង ។ ម្យ៉ាងទៀត គប្បីជុតភ្លើងឲ្យរេះលើអំបែងក៏បាន ។

[๑๘๐] *បទថា* **สงฺฆเภทาย** *សេចក្តីថា ភិក្ខុដែលជាពហូសូតនោះ ក៏ភិក្ខុទាំងឡាយគប្បីសង្គ្រោះដោយពាក្យសម្តីដ៏ពីរោះយ៉ាងនេះថា លោកមកហើយក្តី ទីនេះភិក្ខារកបានងាយ សម្ប និងម្ហូបក៏មាន កុំចាំបាច់កង្វល់ឡើយ និមន្តនៅចុះ គប្បីអនុគ្រោះ ទាក់ទងដោយការពោលចរចាគ្នារឿយៗ គប្បីលួងលោម ដោយឲ្យលោកឲ្យចម្ងើយថា ខ្ញុំនឹងនៅ ។*

ប្រការមួយទៀត គប្បីសង្គ្រោះ និងអនុគ្រោះដោយបច្ច័យ ๔ គប្បី

លួងលោមដោយពាក្យសម្តីដ៏ពីរោះ អធិប្បាយថា គប្បីចរចាឲ្យពីរោះត្រចៀក គប្បីទំនុកបម្រុងដោយរបស់ផ្សេងៗ មានលម្អិតសម្រាប់ងូតទឹកជាដើម ។

បទថា **អាបត្តិ ទុក្កដស្ស** *សេចក្តីថា បើសង្ឃទាំងមូលមិនធ្វើសោត ត្រូវអាបត្តិទុក្កដទាំងអស់ ។ ក្នុងអធិការនេះ ព្រះថេរៈទាំងឡាយក៏មិនផុត ពួកភិក្ខុកំលោះក៏មិនផុត ។ ភិក្ខុទាំងពួងគប្បីឲ្យផ្ងាស់វារៈគ្នាទំនុកបម្រុង ជាអាបត្តិដល់ភិក្ខុ ដែលមិនទំនុកបម្រុងក្នុងវារៈរបស់ខ្លួន ។ តែភិក្ខុដែលជាពហូសូតនោះកុំគប្បីត្រេកអរក្នុងវត្ត មានការបោសបរិវេណ និងឲ្យឈើសូនជាដើមរបស់ព្រះមហាថេរៈទាំងឡាយ ។ កាលកាពដែលលោកបានត្រេកអរ មាន ព្រះមហាថេរៈទាំងឡាយ ក៏គួរមកកាន់ទីទំនុកបម្រុងទាំងព្រឹកល្ងាច ។ តែភិក្ខុដែលជាពហូសូតនោះ ដឹងការមករបស់ពួកលោកហើយ គប្បីទៅកាន់ទីទំនុកបម្រុងរបស់ព្រះមហាថេរៈទាំងឡាយជាមុន ។ បើភិក្ខុជាសហចរ ជាឧបដ្ឋាករបស់លោកមាន លោកគប្បីហាមថា ឧបដ្ឋាករបស់ខ្ញុំមាន លោកទាំងឡាយ ចូរជាអ្នកឲ្យល់ខ្យាយតិចចុះ បើភិក្ខុដែលជាសហចររបស់លោកមិនមាន តែភិក្ខុមួយរូប ឬពីររូប ដែលដល់ព្រមដោយវត្ត ក្នុងវិហារនោះឯង ពោលថា ខ្ញុំនឹងធ្វើកិច្ចដែលគួរធ្វើដល់ព្រះថេរៈឯង ភិក្ខុដ៏សេសចូរនៅជាសុខចុះ មិនជាអាបត្តិដល់ភិក្ខុទាំងពួង ។*

បទថា **សោ អាวาសោ គนฺตพฺโพ** *សេចក្តីថា អាវាសនោះដែលភិក្ខុទាំងឡាយជាអ្នកល្ងង់ខ្លៅ មិនឈ្លាស គប្បីទៅរៀងរាល់កន្លះខែ ដើម្បីប្រយោជន៍ដល់ការធ្វើឧបោសថ ឯអាវាសនោះឯង គួរទៅទាំងហេមន្តរដូវ*

นิฬคิมฺพรุกฺขนฺติ ต้นมะรุมนั่นเอง แต่ทรงมีพระภาคตรัสพระวจนะว่า *ปุคฺคลสงฺขาย* ดังนี้ เพื่อแสดงกิจที่ควรทำในต้นมะรุมนั้น ฯ

ในพระบาลี ว่า **น ภิกฺขเว เตหิ ภิกฺขูหิ ตสฺมึ อาวาเส วสฺสูปนายิกา** เป็นต้น ความว่า ภิกษุทั้งหลายเหล่านั้น ไม่พึงเข้าจำพรรษาในอาวาสนั้น ฯ

วสิตพฺพนฺ ความว่า ในการเข้าจำพรรษาต้น ไม่พึงเข้าจำพรรษาในอาวาสที่ภิกษุผู้สูตรปาติโมกข์ ซึ่งภิกษุผู้สูตรปาติโมกข์นั้นจำพรรษาแล้วไปเสีย ด้วยกิจมีการไปเป็นต้น ในเวลาภิกษุทั้งปวงจำพรรษาแล้ว ภิกษุรูปใดรูปหนึ่งที่สูตรปาติโมกข์ได้ ควรจำพรรษาในอาวาสนั้น ถ้าภิกษุผู้สูตรปาติโมกข์ไม่มี ต้องไปในที่ที่มีภิกษุผู้สูตรปาติโมกข์ ถ้าไม่ไป ต้องอาบัติทุกกฏ ฯ แต่ภิกษุผู้สูตรปาติโมกข์ใด จำพรรษาแล้วไปเสีย ด้วยกิจมีการไปเป็นต้น ในการเข้าจำพรรษาหลัง ภิกษุผู้สูตรปาติโมกข์นั้น ควรอยู่ในที่นั้นตลอด ๒ เดือน ฯ

อาวาสปฺปฏิสงฺขรณกถา จบ

ចារិសុទ្ធិ និងឆន្ទៈ

[១៨១] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គ្រាស់ហៅភិក្ខុទាំងឡាយ ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា សង្ឃនឹងធ្វើឧបោសថ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលយ៉ាងនេះ ភិក្ខុមួយរូបបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន នៅមានភិក្ខុឈឺ ភិក្ខុនោះមិនទាន់មក ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺឲ្យបារិសុទ្ធិបាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុឈឺនោះឲ្យបារិសុទ្ធិយ៉ាងនេះ ។ ត្រូវភិក្ខុឈឺនោះចូលទៅ រកភិក្ខុមួយរូបហើយ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង រួចអង្គុយច្រហោង ផ្គងអញ្ជលី ហើយនិយាយ យ៉ាងនេះថា ខ្ញុំឲ្យបារិសុទ្ធិ លោកចូរនាំបារិសុទ្ធិរបស់ខ្ញុំទៅ លោកចូរប្រាប់បារិសុទ្ធិរបស់ខ្ញុំ ។ ភិក្ខុឈឺនោះបញ្ជាក់ដោយកាយ (ក្តី) បញ្ជាក់ដោយវាចា (ក្តី) បញ្ជាក់ដោយកាយវាចា (ក្តី) ឈ្មោះថា ឲ្យបារិសុទ្ធិហើយ ភិក្ខុនោះមិនបញ្ជាក់ដោយកាយ មិនបញ្ជាក់ដោយវាចា មិនបញ្ជាក់ដោយកាយវាចាទេ មិនឈ្មោះថា ឲ្យបារិសុទ្ធិទេ ។ បើភិក្ខុនោះ បានបារិសុទ្ធិនុ៎ះយ៉ាងនេះ ការបានបារិសុទ្ធិនុ៎ះជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនាំភិក្ខុឈឺដោយគ្រែ ឬតាំងមកក្នុងកណ្តាលសង្ឃហើយ ធ្វើឧបោសថ ។ ម្នាលភិក្ខុទាំងឡាយ បើគំនិតយ៉ាងនេះមានដល់ភិក្ខុអ្នកបម្រើភិក្ខុឈឺថា បើយើងទាំងឡាយឲ្យភិក្ខុឈឺឃ្លាតចាកទី អាពាធនឹងរឹតតែចម្រើន ឬនឹងស្លាប់ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅធ្វើឧបោសថក្នុងទីនោះ ។ មិនត្រូវសង្ឃធ្វើឧបោសថដោយពួកឡើយ បើធ្វើត្រូវ

អាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុឈឺឲ្យបាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំបាវិសុទ្ធិចៀសចេញចាកទីនោះទៅ ត្រូវឲ្យបាវិសុទ្ធិដល់ភិក្ខុជំងឺ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំបាវិសុទ្ធិទៅសឹកក្នុងទីនោះឯង (ក្តី) ស្លាប់ទៅ (ក្តី) ប្តេជ្ញាខ្លួនជាសាមណេរ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកលាសិក្ខា (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត (ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសម្តែងអាបត្តិ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សខ្ទើយ (ក្តី) ប្តេជ្ញាខ្លួនជាថេយ្យសំវាសកៈ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកទៅចូលពួកតិរ្ថិយ (ក្តី) ប្តេជ្ញាខ្លួនជាតិរច្ឆាន (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតា (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតា (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្ត (ក្តី) ប្តេជ្ញាខ្លួនជាអ្នកទ្រុស្តភិក្ខុនី (ក្តី) ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកញ៉ាំងព្រះលោហិតឲ្យព្រុះពងឡើង (ក្តី) ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកៈ (មានកេទពីរក្តី) ត្រូវឲ្យបាវិសុទ្ធិទៅភិក្ខុជំងឺ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំបាវិសុទ្ធិ ចៀសចេញទៅក្នុងពាក់កណ្តាលផ្លូវ មិនឈ្មោះថា ភិក្ខុនោះបាននាំបាវិសុទ្ធិមកដល់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំបាវិសុទ្ធិសឹក (ក្តី) ស្លាប់

(ក្តី) ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកៈ (ក្តី) ក្នុងពាក់កណ្តាលផ្លូវ ជាវិសុទ្ធិក៏មិនឈ្មោះថា ភិក្ខុនោះបាននាំមកដល់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យជាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំជាវិសុទ្ធិដល់ទៅសង្ឃហើយ ទើបចៀសចេញទៅ ជាវិសុទ្ធិក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យជាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំជាវិសុទ្ធិដល់ទៅសង្ឃហើយ ទើបសឹក (ក្តី) ស្លាប់ (ក្តី) ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យ-ញ្ជនកៈ (ក្តី) ជាវិសុទ្ធិក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យជាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំជាវិសុទ្ធិដល់ទៅសង្ឃ ហើយដេកលក់ មិនបានច្រាប់ ឬភ្លាំងភ្លេចមិនបានច្រាប់ ឬចូលឈានហើយមិនបានច្រាប់ ជាវិសុទ្ធិក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ ។ អាបត្តិមិនមានដល់ភិក្ខុអ្នកនាំជាវិសុទ្ធិទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យជាវិសុទ្ធិហើយ បើភិក្ខុអ្នកនាំជាវិសុទ្ធិទៅដល់សង្ឃហើយ ភ្លែងមិនច្រាប់ជាវិសុទ្ធិឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ តែភិក្ខុអ្នកនាំជាវិសុទ្ធិត្រូវអាបត្តិទុក្កដ ។

[១៨២] លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា សង្ឃនឹងធ្វើកម្ម ។ កាលបើព្រះដ៏មានព្រះភាគមានបន្ទូលយ៉ាងនេះ ភិក្ខុមួយរូបបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុឈឺ ភិក្ខុនោះមិនទាន់មក ។ ព្រះអង្គមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាតឲ្យភិក្ខុឈឺឲ្យឆន្នៈបាន ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឆន្នៈនោះត្រូវភិក្ខុឈឺនោះឲ្យយ៉ាងនេះ ។ ត្រូវភិក្ខុឈឺនោះចូលទៅរកភិក្ខុ ១ រូប ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះថា ខ្ញុំឲ្យឆន្នៈ លោកចូរនាំឆន្នៈរបស់ខ្ញុំទៅចុះ ចូរជ្រាប់ឆន្នៈរបស់ខ្ញុំ (ផង) ។ ភិក្ខុឈឺនោះបញ្ជាក់ដោយកាយ (ក៏បាន) បញ្ជាក់ដោយវាចា (ក៏បាន) បញ្ជាក់ដោយកាយវាចា (ក៏បាន) ឆន្នៈ ឈ្មោះថាភិក្ខុឈឺនោះបានឲ្យហើយ ។ ភិក្ខុឈឺមិនបានបញ្ជាក់ដោយកាយ (ក្តី) មិនបានបញ្ជាក់ដោយវាចា (ក្តី) មិនបានបញ្ជាក់ដោយកាយវាចា (ក្តី) មិនឈ្មោះថាភិក្ខុនោះបានឲ្យឆន្នៈទេ ។ បើបានឆន្នៈនោះយ៉ាងនេះ ការបាននុ៎ះជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវនាំភិក្ខុឈឺនោះមកក្នុងកណ្តាលសង្ឃដោយគ្រែ ឬតាំងមក ហើយត្រូវធ្វើសង្ឃកម្មចុះ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកបម្រើជំងឺមានគំនិតយ៉ាងនេះថា បើយើងនឹងឲ្យភិក្ខុឈឺឃ្លាតចាកទីអាពាធនឹងរឹតតែចម្រើនឡើង ឬនឹងស្លាប់ដូច្នេះ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅធ្វើកម្មក្នុងទីនោះ មិនត្រូវសង្ឃធ្វើកម្មជាពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្នៈហើយ បើភិក្ខុអ្នកនាំឆន្នៈគេចចៀសចេញអំពីទីនោះត្រូវឲ្យឆន្នៈដល់ភិក្ខុជនៃ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្នៈហើយ បើភិក្ខុអ្នកនាំឆន្នៈសឹកក្នុងទីនោះឯង (ក្តី) ស្លាប់ទៅ (ក្តី) ប្តេជ្ញាខ្លួនជាសាមណេរ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកពោលលាសិក្ខា (ក្តី) ប្តេជ្ញាខ្លួនជាអ្នក

ត្រូវអន្តិមវត្ថុ (បារាជិកក្តី) ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត (ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្តព្រោះមិនសម្តែងអាបត្តិ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សខ្ទើយ (ក្តី) ប្តេជ្ញាខ្លួនជាថេយ្យសំវាសកៈ (អ្នកលួចសំវាសក្តី) ប្តេជ្ញាខ្លួនជាអ្នកបូលពួកតិរ្ថិយ (ក្តី) ប្តេជ្ញាខ្លួនជាសត្វតិរច្ឆាន (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតា (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតា (ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្ត (ក្តី) ប្តេជ្ញាខ្លួនជាអ្នកទ្រុស្តកិក្ខុនី (ក្តី) ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកធ្វើព្រះលោហិតឲ្យព្រុតង៣ឡើង (ក្តី) ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកៈ (ក្តី) ត្រូវឲ្យឆន្ទៈដល់ភិក្ខុដទៃ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈគេចចៀសទៅក្នុងពាក់កណ្តាលផ្លូវ ភិក្ខុនោះឈ្មោះថា មិនបាននាំឆន្ទៈមកដល់ទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈសឹកទៅ (ក្តី) ស្លាប់ទៅ (ក្តី) ក្នុងពាក់កណ្តាលផ្លូវ ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកៈ (ក្តី) ភិក្ខុនោះឈ្មោះថាមិនបាននាំឆន្ទៈមកទេ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈទៅដល់សង្ឃហើយទើបចៀសចេញទៅ ឆន្ទៈឈ្មោះថានាំមកដល់ហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈ ដល់ទៅសង្ឃហើយសឹកទៅ (ក្តី) ស្លាប់

ទៅ (ក្តី) ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនកៈ (ក្តី) ភិក្ខុនោះឈ្មោះថា បាននាំឆន្ទៈមកហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈដល់ទៅសង្ឃ ហើយដេកលក់មិនបានជ្រាប់ (ក្តី) ភ្លេច មិនបានជ្រាប់ (ក្តី) ចូលសមាបត្តិមិនបានជ្រាប់ (ក្តី) ភិក្ខុនោះឈ្មោះ ថាបាននាំឆន្ទៈមកដល់ហើយ ។ ភិក្ខុអ្នកនាំឆន្ទៈមិនត្រូវអាបត្តិ ។ ម្នាលភិក្ខុ ទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈដល់ទៅសង្ឃហើយ ភ្លេចមិនជ្រាប់ ភិក្ខុនោះឈ្មោះថា នាំឆន្ទៈមកដល់ហើយ ។ ភិក្ខុអ្នកនាំឆន្ទៈ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានកិច្ចត្រូវធ្វើ តថាគត អនុញ្ញាតឲ្យភិក្ខុដែលឲ្យបារិសុទ្ធិក្នុងឧបោសថថ្ងៃនោះឲ្យឆន្ទៈទៀតបាន ។

[๑๘๓] ក៏សម័យនោះឯង ពួកជនជាញាតិចាប់ភិក្ខុមួយរូបក្នុងថ្ងៃ ឧបោសថនោះ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ពួកជនជា ញាតិចាប់ភិក្ខុក្នុងឧបោសថថ្ងៃនោះ ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជន ជាញាតិអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយលែងភិក្ខុនេះមួយរំពេចសិន ទម្រាំភិក្ខុនេះធ្វើឧបោសថរួច ។ បើភិក្ខុបានការលែងនោះយ៉ាងនេះ ការបាននុ៎ះជាការល្អ បើមិនបានទេ ត្រូវ ភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំង ឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយនៅចាំក្នុងទីដ៏សមគួរមួយរំពេច សិន ទម្រាំភិក្ខុនេះឲ្យបារិសុទ្ធិរួច ។ បើភិក្ខុបានការឈប់បង្ខំនុ៎ះយ៉ាងនេះ ការ

ปานฺ๎ทุ๎ชาการณ์ បើមិនបានទេ ត្រូវភិក្ខុទាំង๒ឲ្យាយនិយាយនឹងពួកជនជាញាតិ
អស់នោះយ៉ាងនេះថា ម្នាលអ្នកទាំង๒ឲ្យាយដ៏មានអាយុ ណ្ហ្លើយចុះ អ្នកទាំង๒-
ឲ្យាយចូរនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទម្រាំសង្ឃធ្វើឧបោសថ
រួច ។ បើភិក្ខុបានការនាំទៅនុ๎ះយ៉ាងនេះ ការបានន៎ុ๎ជាការណ៍ បើមិនបានទេ
មិនត្រូវសង្ឃធ្វើឧបោសថជាពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុ
ទាំង๒ឲ្យាយ ក៏ក្នុងសាសនានេះ ស្តេចទាំង๒ឲ្យាយចាប់ភិក្ខុក្នុង๒ឧបោសថថ្ងៃនោះ
។បេ។ ពួកចោរចាប់ ... ពួកអ្នកលេង๒ចាប់ ... ពួកជនជាសត្រូវនៃភិក្ខុចាប់ ។
ត្រូវភិក្ខុទាំង๒ឲ្យាយ និយាយនឹងពួកជនជាសត្រូវនៃភិក្ខុអស់នោះ យ៉ាងនេះថា
ម្នាលអ្នកទាំង๒ឲ្យាយដ៏មានអាយុ ណ្ហ្លើយចុះ អ្នកទាំង๒ឲ្យាយចូរលែងភិក្ខុនេះ
មួយរំពេចសិន ទម្រាំភិក្ខុនេះធ្វើឧបោសថរួច ។ បើភិក្ខុបានការលែងនុ๎ះ
យ៉ាងនេះ ការបានន៎ុ๎ជាការណ៍ បើមិនបានទេ ត្រូវភិក្ខុទាំង๒ឲ្យាយនិយាយនឹង
ជនជាសត្រូវនៃភិក្ខុទាំង๒នោះយ៉ាងនេះថា ម្នាលអ្នកទាំង๒ឲ្យាយដ៏មានអាយុ
ណ្ហ្លើយចុះ អ្នកទាំង๒ឲ្យាយចូរឈប់បង្អង់នៅក្នុង๒ទីដ៏សមគួរមួយរំពេចសិន
ទម្រាំភិក្ខុនេះឲ្យបារិសុទ្ធិរួច ។ បើភិក្ខុបានការឈប់បង្អង់នុ๎ះយ៉ាងនេះ ការបាន
នុ๎ះជាការណ៍ បើមិនបានទេ ត្រូវភិក្ខុទាំង๒ឲ្យាយនិយាយនឹង๒ជនជាសត្រូវនៃភិក្ខុ
ទាំង๒នោះយ៉ាងនេះថា ម្នាលអ្នកទាំង๒ឲ្យាយដ៏មានអាយុ ណ្ហ្លើយចុះ អ្នកទាំង๒-
ឲ្យាយចូរនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទម្រាំសង្ឃធ្វើឧបោសថ
រួច ។ បើភិក្ខុបានការនាំទៅនុ๎ះយ៉ាងនេះ ការបានន៎ុ๎ជាការណ៍ បើមិនបានទេ
មិនត្រូវសង្ឃធ្វើឧបោសថដោយពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ ។

[๑๘๔] លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា (ព្រោះ) សង្ឃមានកិច្ចត្រូវធ្វើ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលយ៉ាងនេះហើយ ភិក្ខុមួយរូបបានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន នៅមានភិក្ខុឈ្មោះគគ្គៈឆ្កួត ភិក្ខុនោះមិនទាន់មកដល់ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឆ្កួតទាំងឡាយនេះមានពីរយ៉ាង គឺមានភិក្ខុឆ្កួត ๑ យ៉ាង រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ រលឹកមិនបានសោះក៏មាន ភិក្ខុឆ្កួត ๑ យ៉ាង មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ មកមិនបានសោះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុឆ្កួតទាំងពីរយ៉ាងនោះ ភិក្ខុឆ្កួតណារលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យសង្ឃឲ្យឧម្មត្តកសម្មតិ[๑] ដល់ភិក្ខុឆ្កួតបែបនេះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឧម្មត្តកសម្មតិ សង្ឃត្រូវឲ្យយ៉ាងនេះ ។ ត្រូវភិក្ខុដែលធ្លាសប្រតិពលឲ្យសង្ឃដើងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះគគ្គៈជាមនុស្សឆ្កួត រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ

๑- សេចក្តីសម្មតិថា ជាមនុស្សឆ្កួត ។

មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ ។ បើសម្មតិកម្មមានការគួរដល់សង្ឃហើយ គួរសង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុ ឈ្មោះគគ្គៈជាភិក្ខុឆ្កួត ភិក្ខុឈ្មោះគគ្គៈ គប្បីរលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃគប្បីធ្វើឧបោសថ គប្បីធ្វើសង្ឃកម្មជាមួយភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះគគ្គៈ ជាភិក្ខុឆ្កួត រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ ។ ឥទ្ធូវសង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈជាភិក្ខុឆ្កួតថា ភិក្ខុឈ្មោះគគ្គៈគប្បីរលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថនឹងធ្វើសង្ឃកម្ម ជាមួយនឹងភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន ។ ការឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈជាភិក្ខុឆ្កួតថា ភិក្ខុឈ្មោះគគ្គៈរលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្មជាមួយនឹងភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន ដូច្នេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះស្ងៀម មិន

គាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះនិយាយទៅចុះ ។ សង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គ:ជាភិក្ខុឆ្កួតហើយថា ភិក្ខុឈ្មោះគគ្គ: រលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្មជាមួយនឹងភិក្ខុឈ្មោះគគ្គ:ក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គ:ក៏បាន ។ ការឲ្យឧម្មត្តកសម្មតិនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

[๑๘๕] ក៏សម័យនោះឯង មានភិក្ខុ ๔ អង្គគង់ក្នុងអាវាសមួយ ក្នុងឧបោសថថ្ងៃនោះ ។ ទើបភិក្ខុទាំងឡាយនោះមានគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ត្រូវភិក្ខុធ្វើឧបោសថ ក៏យើងទាំងឡាយជា ជន ๔ រូប ត្រូវយើងទាំងឡាយធ្វើឧបោសថដូចម្តេចទៅ ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ๔ រូបសម្តែងនូវបាតិមោក្ខបាន។ ក៏សម័យនោះឯង មានភិក្ខុបីរូបនៅក្នុងអាវាសមួយ ក្នុងឧបោសថថ្ងៃនោះ ។ ទើបភិក្ខុទាំងឡាយនោះមានគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបសម្តែងនូវបាតិមោក្ខ ក៏ឯយើងទាំងឡាយជាជនបីរូប ត្រូវយើងធ្វើឧបោសថដូចម្តេចទៅ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាតឲ្យភិក្ខុបីរូបធ្វើបាវិសុទ្ធិឧបោសថដល់គ្នានិងគ្នា ។ ម្នាលភិក្ខុទាំង-
ឡាយ ក៏ឯបាវិសុទ្ធិឧបោសថនោះត្រូវភិក្ខុធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុដែលឈ្វាស
ប្រតិពលឲ្យភិក្ខុទាំងឡាយនោះដឹងថា ចូរលោកដ៏មានអាយុទាំងឡាយស្តាប់
ខ្ញុំ ថ្ងៃទី ១៥ នេះជាថ្ងៃឧបោសថ បើកម្មមានកាលគួរដល់លោកដ៏មានអាយុ
ទាំងឡាយហើយ យើងទាំងឡាយគួរធ្វើបាវិសុទ្ធិឧបោសថដល់គ្នានិងគ្នា ។
ត្រូវភិក្ខុជាថេរៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គង
អញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំ
ជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំថាជាបុគ្គលបរិសុទ្ធ នែ
អាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំថាជាបុគ្គល
បរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំថា
ជាបុគ្គលបរិសុទ្ធ ។ ត្រូវភិក្ខុទីវិសភ្លាធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយ
អង្គុយច្រហោងផ្គងអញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះ
ថា ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំថា ជា
បុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុក
នូវខ្ញុំថា ជាបុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុក
នូវខ្ញុំថាជាបុគ្គលបរិសុទ្ធ ។ ក៏សម័យនោះឯង ភិក្ខុពីររូបនៅក្នុងអាវាសមួយ
ក្នុងឧបោសថថ្ងៃនោះ ។ ទើបភិក្ខុទាំងឡាយនោះមានគំនិតយ៉ាងនេះថា ព្រះដ៏
មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបសម្តែងនូវបាតិមោក្ខ ឲ្យភិក្ខុបីរូបធ្វើ
បាវិសុទ្ធិឧបោសថដល់គ្នានិងគ្នាបាន ក៏យើងទាំងឡាយជាជន ២ រូប ត្រូវ

យើងទាំងឡាយធ្វើឧបោសថដូចម្តេចទៅ ។ កិក្ខុទាំងឡាយក្រាបទូលដំណើរ
នុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ
តថាគតអនុញ្ញាតឲ្យភិក្ខុ ២ រូបធ្វើបារិសុទ្ធិឧបោសថបាន ។ ម្នាលភិក្ខុទាំង-
ឡាយ ក៏ឯបារិសុទ្ធិឧបោសថនោះ ត្រូវភិក្ខុទាំងឡាយធ្វើយ៉ាងនេះ ។ ត្រូវភិក្ខុ
ជាថេរៈធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើងហើយ
ពោលនឹងភិក្ខុទីយ៉ាងនេះថា នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំ
ទុកនូវខ្ញុំថាជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំ
ទុកនូវខ្ញុំថា ជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោក
ចាំទុកនូវខ្ញុំថា ជាបុគ្គលបរិសុទ្ធ ។ ត្រូវភិក្ខុទីវិស្សា ធ្វើឧត្តរាសង្គឆៀង
ស្មាម្ខាងអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយពោលនឹងភិក្ខុជាថេរៈយ៉ាង
នេះថា ទានព្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំថាជាបុគ្គល
បរិសុទ្ធ ទានព្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំថាជាបុគ្គល
បរិសុទ្ធ ទានព្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំថាជាបុគ្គល
បរិសុទ្ធ ។ ក៏សម័យនោះឯង កិក្ខុតែមួយរូបនៅក្នុងអាវាសមួយក្នុងឧបោសថ
ថ្ងៃនោះ ។ ទើបភិក្ខុនោះបានគិតដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យ
ភិក្ខុបួនរូបសម្តែងនូវបាតិមោក្ខ ឲ្យភិក្ខុបីរូបធ្វើបារិសុទ្ធិដល់គ្នានិងគ្នា ឲ្យភិក្ខុពីរ
រូបធ្វើបារិសុទ្ធិឧបោសថ ក៏អាត្មាអញនៅតែម្នាក់ឯង ត្រូវអញធ្វើឧបោសថដូច
ម្តេចទៅ ។ កិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។
ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ កិក្ខុតែមួយរូប

នៅក្នុងអាវាសមួយក្នុងឧបោសថថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុតែងត្រឡប់មកនៅក្នុងប្រទេសណា គឺក្នុងឧបដ្ឋានសាលាក្តី មណ្ឌបក្តី គល់ឈើក្តី ត្រូវភិក្ខុនោះ បោសប្រទេសនោះហើយ ចូលទៅតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ ក្រាលអាសនៈ អុជប្រទីបហើយ ត្រូវអង្គុយចាំ ។ បើភិក្ខុទាំងឡាយដទៃមក ត្រូវភិក្ខុនោះធ្វើឧបោសថជាមួយនឹងភិក្ខុទាំងឡាយនោះ បើភិក្ខុទាំង-ឡាយដទៃមិនមកទេ ត្រូវភិក្ខុនោះអធិដ្ឋានឧបោសថថា ថ្ងៃនេះជាថ្ងៃឧបោសថរបស់អញ បើមិនអធិដ្ឋានទេ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបួនរូបនៅក្នុងអាវាសណា មិនត្រូវភិក្ខុបីរូបនាំបាវិសុទ្ធិរបស់ភិក្ខុមួយរូបមកហើយសម្តែងនូវបាតិមោក្ខក្នុងអាវាសនោះទេ បើភិក្ខុទាំងឡាយនោះសម្តែងត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបីរូបនៅក្នុងអាវាសណាមិនត្រូវភិក្ខុពីររូបនាំបាវិសុទ្ធិរបស់ភិក្ខុមួយរូបមក ហើយធ្វើបាវិសុទ្ធិឧបោសថ ក្នុងអាវាសនោះទេ បើភិក្ខុទាំងនោះធ្វើ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ២ រូបនៅក្នុងអាវាសណា មិនត្រូវភិក្ខុមួយរូបនាំបាវិសុទ្ធិរបស់ភិក្ខុមួយរូបមក ហើយអធិដ្ឋានឧបោសថក្នុងអាវាសនោះទេ បើអធិដ្ឋាន ត្រូវអាបត្តិទុក្កដ ។

អដ្ឋកថា

ចារិសុទ្ធិ និងឆន្ទៈ

[១៨១] បទថា **ការយេន វិញ្ញាបេតិ** សេចក្តីថា ភិក្ខុអាពាធ រមែងឲ្យដឹង គឺរមែងឲ្យជ្រាបការឲ្យបារិសុទ្ធិ ដោយអវយវៈធំតូចណាមួយ បើអាចបន្ទឹវាចា រមែងឲ្យដឹងដោយវាចា បើអាចទាំង ២ ប្រការ រមែងឲ្យដឹងទាំងកាយវាចា ។

បទថា **សង្ឃេន តត្ត គន្ត្វា ឧចោសថោ ការេតព្ពោ** សេចក្តីថា បើភិក្ខុអាពាធដូច្នោះមានច្រើន សង្ឃគប្បីតាំងនៅតាមលំដាប់ ធ្វើភិក្ខុដែលអាពាធទាំងពួងទុកក្នុងហត្ថបាស ។ បើភិក្ខុអាពាធមានក្នុងរយៈឆ្ងាយ សង្ឃមិនគ្រប់គ្រាន់ ថ្ងៃនោះមិនត្រូវធ្វើឧបោសថ ឯសង្ឃដែលជាពួក មិនគប្បីធ្វើឧបោសថពិត ។

បទថា **តត្ថេវ បក្កមតិ** សេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិ មិនមកកាន់ជំនុំសង្ឃ នឹងទៅក្នុងទីណាមួយអំពីទីនោះៗ ឯង ។

បទថា **សាមណេរោ បដិជានាតិ** សេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិប្តេជ្ញាយ៉ាងនេះថា ខ្ញុំជាសាមណេរក្តី ប្រាប់ភាពដែលខ្លួនជាសាមណេរពិតៗក្តី តាំងនៅក្នុងភូមិនៃសាមណេរក្នុងខាងក្រោយក្តី ។ ក្នុងបទទាំងពួងក៏មានន័យដូច្នេះ ។

បទថា **សង្ឃប្បត្តោ បក្កមតិ** សេចក្តីថា ភិក្ខុដែលនាំបារិសុទ្ធិដល់ហត្ថបាសនៃភិក្ខុ ៤ រូប កំណត់យ៉ាងតិចបំផុត ដែលប្រជុំគ្នាដើម្បីប្រយោជន៍ដល់ឧបោសថ ហើយចៀសចេញទៅ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។

ឯវិនិច្ឆ័យក្នុងការនាំបាវិសុទ្ធិនេះ គប្បីជ្រាបដូច្នេះថា បាវិសុទ្ធិរបស់ភិក្ខុច្រើនរូប ដែលភិក្ខុមួយរូបនាំមកហើយ ឈ្មោះថា នាំមកហើយពិត តែបើភិក្ខុអ្នកនាំនោះជួបភិក្ខុដទៃត្រង់កណ្តាលផ្លូវ ទើបឲ្យបាវិសុទ្ធិរបស់ភិក្ខុទាំងឡាយដែលខ្លួនទទួលមកផង បាវិសុទ្ធិរបស់ខ្លួនផង បាវិសុទ្ធិរបស់ភិក្ខុដែលនាំនោះប៉ុណ្ណោះ រមែងមក ឯបាវិសុទ្ធិក្រៅអំពីនេះ ចាត់ជាបាវិសុទ្ធិដូចខ្សែលាមធ្មៅ បាវិសុទ្ធិនោះ រមែងមិនមក ។

បទថា **សុត្តោ ន អារោចេតិ** *សេចក្តីថា ភិក្ខុដែលនាំបាវិសុទ្ធិនោះមកហើយ ដេកលក់ មិនប្រាប់បាវិសុទ្ធិ ដែលភិក្ខុនោះឲ្យហើយ ។ វិនិច្ឆ័យក្នុងបទថា* **ចាវិសុទ្ធិហារកស្ស អនាបត្តិ** *នេះ គប្បីជ្រាបដូច្នេះថា បើភិក្ខុនាំបាវិសុទ្ធិក្លែងមិនប្រាប់ លោកត្រូវអាបត្តិទុក្កដ ឯបាវិសុទ្ធិ ឈ្មោះថា នាំមកហើយពិត ។ តែមិនជាអាបត្តិដល់លោក ព្រោះមិនបានក្លែងមិនប្រាប់ និងឧបោសថរបស់លោកទាំងពីររូប ឈ្មោះថា ធ្វើហើយដូចគ្នា ។*

[๑๘๒] វិនិច្ឆ័យក្នុងការឲ្យឆន្ទៈសោត ដូចគ្នានឹងវិនិច្ឆ័យដែលពោលហើយ ក្នុងការឲ្យបាវិសុទ្ធិនោះឯង ។

វិនិច្ឆ័យក្នុងបទថា **ចាវិសុទ្ធិ ទេន្តេន ឆន្ទម្បិ ទាតុំ** *នេះ គប្បីជ្រាបដូច្នេះថា បើភិក្ខុដែលអាពាធឲ្យបាវិសុទ្ធិប៉ុណ្ណោះ មិនឲ្យឆន្ទៈ ឧបោសថរមែងឈ្មោះថា សង្ឃធ្វើហើយ តែសង្ឃធ្វើកម្មណា កម្មជទៃនោះ មិនជាការដែលសង្ឃបានធ្វើ ។ ភិក្ខុដែលអាពាធឲ្យតែឆន្ទៈប៉ុណ្ណោះ មិនឲ្យបាវិសុទ្ធិ ទាំងឧបោសថ ទាំងកម្មរបស់ភិក្ខុសង្ឃ ឈ្មោះថា សង្ឃធ្វើហើយពិត តែឧបោសថ*

របស់ភិក្ខុដែលឲ្យឆន្ទៈ មិនឈ្មោះថា លោកបានធ្វើឡើយ ។ បើភិក្ខុអង្គខ្លះអធិដ្ឋានឧបោសថក្នុងសីមា ឬក្នុងសីមាហើយ ទើបមក លោកវង្វេងមិនបានដើម្បីនឹងនៅព្រងើយ ដោយគិតថា អញធ្វើឧបោសថហើយ ត្រូវឲ្យសាមគ្គី ឬឆន្ទៈ ។

[១៨៤] បទថា **សាតិបិ ឧបោសថំ ឆបិ សាតិ** សេចក្តីថា គ្រាខ្លះក៏រឭកបាន គ្រាខ្លះក៏រឭកមិនបាន ។

បទថា **អត្ថិ នោ សាតិ** សេចក្តីថា ភិក្ខុឆ្កួតរូបណារឭកមិនបានសោះ ដោយចំណែកមួយ កិច្ចដែលនឹងត្រូវឲ្យសម្មតិដល់ភិក្ខុឆ្កួតរូបនោះ រមែងមិនមាន ។

[១៨៥] ច្រើនបទថា **សោ ឧសោ សម្មដ្ឋិត្វា** បានដល់ គប្បីបោសបន្ទប់នោះ ។

ពីរបទថា **សោ ឧសោ** ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។

បទថា **ចាតីយំ បរិភោជនីយំ** ជាដើម មានន័យជាក់ច្បាស់ហើយ ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ពាក្យនោះទុក ដើម្បីសម្តែងកិច្ចមានបុព្វករណៈជាដើមនៃឧបោសថ ។ ព្រោះដូច្នោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ការបោសសម្អាត ការអុជប្រទីប តាំងទឹកឆាន់ ទឹកប្រើ ព្រមទាំងក្រាលអាសនៈ ទាំងនេះ ហៅថា បុព្វករណៈរបស់ឧបោសថ ។

កម្ម ៤ យ៉ាងនេះ លោកហៅថា បុព្វករណៈ ដោយប្រការដូច្នេះ ។

នាំឆន្ទៈ បារិសុទ្ធិ ប្រាប់រដូវ រាប់ភិក្ខុ ទូន្មានភិក្ខុនី ទាំងនេះជាបុព្វកិច្ច

នៃឧបោសថ ។

កម្ម ៥ យ៉ាងនេះ លោកពោលថា បុព្វកិច្ច ព្រោះនឹងត្រូវធ្វើខាងក្រោយបុព្វករណៈ ។ ថ្ងៃឧបោសថ ១ ភិក្ខុដែលចូលធ្វើកម្មមានចំនួនប៉ុណ្ណា ១ សភាគាបត្តិមិនមាន ១ បុគ្គលគួរវៀរមិនមានក្នុងហត្ថបាសសង្ឃនោះ ១ ហៅថា បត្តកល្ប ប្រែថា ការដល់ព្រម និងកាលគួរ ។

លក្ខណៈ ៤ ប្រការនេះ លោកហៅថា បត្តកល្ប ។

បទថា **តេហិ សទ្ធឹ** *សេចក្តីថា គប្បីធ្វើបុព្វករណៈជាដើមនេះហើយធ្វើឧបោសថជាមួយភិក្ខុទាំងឡាយដែលមកហើយទាំងនោះ ។*

វិនិច្ឆ័យក្នុងបទថា **អជ្ជ មេ ឧបោសថោ** *នេះ គប្បីជ្រាបដូច្នេះថា បើជាថ្ងៃ ១៥ កើត ទោះអធិដ្ឋានថា* **អជ្ជ មេ ឧបោសថោ បណ្ណរសោ** *ប្រែថា ថ្ងៃនេះជាថ្ងៃឧបោសថ ថ្ងៃ ១៥ កើតរបស់អញដូច្នេះក្តី ក៏គួរ ។ សូម្បីក្នុងឧបោសថថ្ងៃ ១៤ ក៏មានន័យដូច្នេះ ។*

បារិសុទ្ធិ និងឆន្ទៈ ចប់

ឧបោសថវត្ថុភាណវារៈ

[๑๘๖] ក៏សម័យនោះឯង ភិក្ខុមួយរូបត្រូវអាបត្តិក្នុងឧបោសថថ្ងៃនោះ ។ ទើបភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា មិនត្រូវភិក្ខុប្រកបដោយអាបត្តិធ្វើឧបោសថទេ ក៏អាត្មាអញត្រូវអាបត្តិហើយ ត្រូវអញប្រតិបត្តិដូចម្តេចទៅ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុត្រូវអាបត្តិក្នុងឧបោសថថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាងអង្គុយច្រហោង ផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំត្រូវអាបត្តិមានឈ្មោះនេះ ខ្ញុំសូមសម្តែងនូវអាបត្តិនោះ ។ ភិក្ខុមិនត្រូវអាបត្តិនោះគប្បីសួរភិក្ខុត្រូវអាបត្តិនោះថា លោកឃើញអាបត្តិនោះឬ ។ ភិក្ខុអ្នកត្រូវអាបត្តិគប្បីប្រាប់ថា អើ ខ្ញុំឃើញ ។ ភិក្ខុមិនត្រូវអាបត្តិគប្បីប្រាប់ថា លោកគប្បីសង្រួមតទៅ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះមានភិក្ខុមានសេចក្តីសង្ស័យក្នុងអាបត្តិក្នុងឧបោសថថ្ងៃនោះ ។ ម្នាលភិក្ខុទាំង-ឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុមួយរូប ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីឡើងហើយត្រូវនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមានសេចក្តីសង្ស័យក្នុងអាបត្តិមានឈ្មោះនេះ កាលណាខ្ញុំអស់សង្ស័យ ខ្ញុំនឹងសម្តែងអាបត្តិនោះក្នុងកាលនោះ លុះនិយាយហើយត្រូវធ្វើឧបោសថត្រូវស្តាប់បាតិមោក្ខ មិនត្រូវធ្វើសេចក្តីអន្តរាយដល់ឧបោសថព្រោះហេតុប៉ុណ្ណោះឡើយ ។

[១៨៧] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសម្តែងអាបត្តិស្មើភាគគ្នា (គឺអាបត្តិដូចគ្នា) ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសម្តែងអាបត្តិស្មើភាគគ្នាទេ ភិក្ខុណាសម្តែង ត្រូវអាបត្តិទុក្កដ ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលអាបត្តិស្មើភាគគ្នា ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុទទួលអាបត្តិស្មើភាគគ្នាទេ ភិក្ខុណាទទួលត្រូវអាបត្តិទុក្កដ ។

[๒] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងគួរចូលវស្សាក្នុងកាលណាហ្ន៎ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងវស្សានរដូវ ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ថ្ងៃចូលវស្សា តើមានប៉ុន្មានហ្ន៎ ។ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សានេះមានពីរ គឺថ្ងៃបុរិមិកា[2]វស្សា ๑ ថ្ងៃបច្ឆិមិកា[3] វស្សា ๑ ភិក្ខុគួរចូលបុរិមិកាវស្សាក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញបូណ៌មីខែអាសាធ (គឺថ្ងៃ ๑ រោច ខែអាសាធ) ភិក្ខុគួរចូលបច្ឆិមិកាវស្សាក្នុងថ្ងៃដែលកន្លងហួស ๑ ខែ អំពីថ្ងៃពេញបូណ៌មីខែអាសាធ (គឺថ្ងៃ ๑ រោច ខែស្រាពណ៌) ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សាមានតែពីរយ៉ាងនេះឯង ។

[๓] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានចូលវស្សាហើយ ក៏ចេញដើរទៅកាន់ចារិកក្នុងកណ្តាលវស្សា ។ មនុស្សទាំងឡាយពោលទោស តិះ-

---

๑- សូមមើលអដ្ឋកថាខាងក្រោម ។ ๒- ថ្ងៃចូលវស្សាមុន ។ ๓- ថ្ងៃចូលវស្សាក្រោយ ។

ដៀល បន្ទុះបង្អាប់ដូចក្នុងគ្រាមុននោះទៀតថា ពួកសមណៈជាសក្យបុត្តិយ៍ មិនសមបើនឹងដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែមួយ ញាំងពួកសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាសសោះ យ៉ាងដូចជាពួកតិរ្ថិយដទៃនេះ ដែលពោលធម៌អាក្រក់ ម្តេចគង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា អស់ទាំងពួកសត្វស្ថាបនេះទៀតសោត ក៏ធ្វើសម្បុកទាំងឡាយទុកនៅលើចុងឈើទាំងឡាយ ហើយនឹងសម្ងំនៅចាំវស្សាជួចគ្នាដែរ ចម្លែកតែពួកសមណៈជាសក្យបុត្តិយ៍នេះ ម្តេចឡើយក៏នៅតែដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែមួយ ញាំងពួកសត្វតូចៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាស ។ កាលមនុស្សទាំងនោះកំពុងពោលទោសតិះដៀល បន្ទុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុចូលវស្សាហើយ មិនសមបើនឹងចេញដើរទៅកាន់ចារិកក្នុងកណ្តាលវស្សាសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា រួចហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ខែ ៣ ឬបច្ឆិមិកាវស្សាអស់ខែ ៣ ទេ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ ភិក្ខុ

ณาเจ็ปสเจញ្ជាទៅ ត្រូវអាបត្តិទុក្កដ ។

[๔] *សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សា ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនចូលវស្សាឡើយ (គឺត្រូវតែចូលវស្សា) ភិក្ខុណាមិនចូលវស្សា ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សាក្នុងថ្ងៃចូលវស្សានោះ ក៏ក្លែងដើរចេញពីទីអាវាស ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនប្រាថ្នានឹងចូលវស្សាក៏ក្លែងដើរចេញពីអាវាសទៅក្នុងថ្ងៃចូលវស្សានោះមិនបានទេ ភិក្ខុណាចេញដើរទៅ ត្រូវអាបត្តិទុក្កដ ។*

[๕] *សម័យនោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានសេចក្តីប្រាថ្នាដើម្បីនឹងលើកខែ ក៏បញ្ជូនរាជបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយ គួរតែចូលវស្សាក្នុងខែខាងមុខ (ខែអាសាធក្រោយ) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រព្រឹត្តទៅតាមស្តេចទាំងឡាយចុះ ។*

อัฏฐกถา

วัสสูปนายิกขันธกะ

[๑] วินิจฉัยในวัสสูปนายิกขันธกะ คัมภีร์ท่านกล่าวไว้ดังนี้ บทว่า **อปฺป-ญฺญตฺโต** ได้แก่ ทรงมิได้ทรงอนุญาต หรือว่า มิได้ทรงห้าม ฯ

ในบทว่า **เตน ภิกฺขู** ได้แก่ ภิกษุทั้งปวงนั่นแล ฯ **สพฺเพ** ได้แก่ ภิกษุทั้งปวงนั่นเทียว ฯ

สัตว์ทั้งปวงที่เที่ยวไปในอากาศ ชื่อว่า ปักษี ฯ

บทว่า **สพฺพาสยิสฺสนฺติ** ความว่า ปักษีทั้งปวงก็จักมีความอาลัยในที่อยู่ของตนในที่ใดที่หนึ่ง ฯ

ในบทว่า **สพฺพาตํ อาคาเนยฺยา** ได้แก่ พึงถึงซึ่งความพินาศ ฯ

[๒] ในบทว่า **วสฺสาเน วสฺสํ อุปคนฺตุ** ความว่า เพื่อจะเข้าจำพรรษา ๓ เดือน ในเวลาต้นฤดูฝน ฯ

ในบทว่า **กติ นุ โข วสฺสูปนายิกา** ความว่า วันเข้าจำพรรษามีกี่วันหนอ ฯ

วินิจฉัยในบทว่า **อปรฉฏฺฐิยา อาสาฬฺหิยา** ดังนี้ว่า วันที่ ๑ แห่งเดือน ๑๑ ที่ล่วงไปแล้ว ในเดือนอาสาฬหะนั้น ที่ล่วงไปแล้วนั่นเทียว เพราะเหตุนั้น เดือน ๑๑ ในเดือนอาสาฬหะนั้น ชื่อว่า มีวันที่ ๑ ล่วงไปแล้ว ฯ เวลาเดือน ๑๑ ในเดือนอาสาฬหะนั้นล่วงไปแล้ว คือเป็นอันล่วงไปแล้ว ๑ วัน อธิบายว่า ในวันที่ ๑ นั่นเอง ฯ

សូម្បីក្នុងនិស្សយទី ๒ ក៏មានសេចក្តីថា ๑ ខែ នៃតិថី ๑๕ កើត ខែអាសាឍនោះកន្លងទៅហើយ ព្រោះហេតុនោះ ទើបតិថី ๑๕ កើត ខែអាសាឍនោះ ឈ្មោះថា មាន ๑ ខែ កន្លងទៅហើយ ។ កាលតិថី ๑๕ កើត ខែអាសាឍនោះកន្លងទៅហើយ គឺឈានកន្លងហើយ ๑ ខែ អធិប្បាយថា មាន ๑ ខែ ពេញបរិបូណ៌ ។ ព្រោះហេតុនោះ ក្នុងថ្ងៃ ๑ រោចបន្ទាប់អំពីពីរកណ្តាលខែអាសាឍ ឬក្នុងថ្ងៃ ๑ រោចបន្ទាប់អំពីពាក់កណ្តាលខែស្រាពណ៌ អំពីថ្ងៃ ๑๕ កើត ខែអសាឍនោះឯង ដែលភិក្ខុអ្នកចូលវស្សា គប្បីរៀបចំវិហារ ហើយតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ គប្បីធ្វើសាមីចិកម្ម មានថ្វាយបង្គំព្រះចេតិយជាដើមទាំងពួងឲ្យសម្រេចហើយ គប្បីបន្ទឹងវាចាថា **ឥមស្មឹ វិហារេ ឥមំ តេមាសំ វស្សំ อุเปมิ** *ដូច្នេះ ម្តង ឬពីរដងហើយ ចាំវស្សាចុះ ។*

[๓] *វិនិច្ឆ័យក្នុងបទថា* **យោ បក្កមេយ្យ** *នេះ គប្បីជ្រាបដូច្នេះ គប្បីជ្រាបថា ត្រូវអាបត្តិ ព្រោះមិនមានអាល័យ ឬព្រោះឲ្យអរុណរះក្នុងទីដទៃ ។*

[๔] *វិនិច្ឆ័យក្នុងបទថា* **យោ អតិក្កមេយ្យ** *នេះ គប្បីជ្រាបដូច្នេះថា គប្បីជ្រាបថា ត្រូវអាបត្តិជាច្រើនដោយរាប់វត្ត ។*

បើក្នុងថ្ងៃនោះ លោកចូលទៅកាន់ឧបចារវត្ត ๑๐๐ តំបន់ ហើយហួសទៅ គប្បីជ្រាបថា ត្រូវអាបត្តិ ๑๐๐ តែបើហួសឧបចារវត្តទៅហើយ តែនៅមិនទាន់ចូលឧបចារវត្តដទៃ ត្រឡប់មកវិញ គប្បីជ្រាបថា ត្រូវអាបត្តិ ๑ ប៉ុណ្ណោះ ភិក្ខុដែលមិនអាចចាំបុរិមិកាវស្សា ព្រោះអន្តរាយណាមួយ ត្រូវចាំ

ปจฺฉิมิกาวสฺสา ฯ

[๕] *ពីរបទថា* **วสฺสๆ อุกฺกฏฺฐิตุกาเมา** *សេចក្តីថា មានព្រះបំណងនឹងផ្ទាស់ខែដើមរដូវក្តៀងចេញទៅ អធិប្បាយថា មានព្រះបំណងមិនរាប់ខែស្រាពណ៌ នឹងឲ្យរាប់ខែអាសាឍទៀត ។*

ពីរបទថា **อาคเต ชุณฺเห** *អធិប្បាយថា ក្នុងខែអធិកមាស ។*

វិនិច្ឆ័យក្នុងបទថា **อนุชานามิ ภิกฺขเว ชุณฺหํ อนุวตฺติตุ** *នេះ គប្បីជ្រាបដូច្នេះថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតដើម្បីអនុវត្តតាម ដោយទ្រង់ធ្វើក្នុងព្រះទ័យថា ឈ្មោះថា ការវិនាសត្រឹមបន្តិចបន្តួច រមែងមិនមានដល់ភិក្ខុទាំង-ឡាយ ព្រោះផ្ទាស់ប្តូរកាលនៃរដូវក្តៀងចេញទៅ ។ ព្រោះដូច្នោះ ភិក្ខុគួរអនុវត្តតាមក្នុងកម្មដែលជាធម៌ដទៃបាន តែមិនគួរអនុវត្តតាមបុគ្គលណាមួយក្នុងកម្មដែលមិនប្រកបដោយធម៌ ដូច្នេះឯង ។*

សត្តាហកាវណី

[៦] គ្រានោះឯង ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងសំដៅទៅឯក្រុងសាវត្ថី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ស្រុក ទើបបានដល់ទៅក្រុងសាវត្ថី ។ បានឮថា ព្រះមានព្រះភាគគង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះឯង ។ សម័យនោះឯង ក្នុងកោសលជនបទ មានឧបាសកឈ្មោះខទេនបានឲ្យគេធ្វើវិហារចំពោះសង្ឃ ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំង-ឡាយថា សូមឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ជ្បិតខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង ស្តាប់ធម៌ផង និងបានឃើញភិក្ខុទាំងឡាយផង ។ ភិក្ខុទាំង-ឡាយនិយាយយ៉ាងនេះវិញថា នែអាវុសោ ព្រះមានព្រះភាគបានបញ្ញត្តហើយថា ភិក្ខុទាំងឡាយចូលវស្សាហើយ មិនបាននៅចាំបុរិមិកាវស្សាអស់ ៣ ខែ ឬបច្ឆិមិកាវស្សាអស់ ៣ ខែទេ មិនត្រូវចេញដើរទៅកាន់ចារិកឡើយ សូមឲ្យខទេនឧបាសកបង្អង់ចាំសិន ទម្រាំតែភិក្ខុទាំងឡាយនៅចាំវស្សារួច លុះចាំវស្សារួចហើយ មុខជានឹងទៅ បើឧបាសកនោះមានការត្រូវធ្វើជាប្រញាប់ សូមឲ្យធ្វើវិហារទុកក្នុងសំណាក់ភិក្ខុទាំងឡាយដែលនៅក្នុងអាវាស ក្នុងទីនោះសិនចុះ ។ ឯខទេនឧបាសកក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ កាលបើអញបានបញ្ជូនពាក្យបណ្តាំទៅហើយ មិនសមបើនឹងមិននិមន្តមកសោះ ជ្បិតអញជាទាយក ជាកប្បិយការកៈ ជាឧបដ្ឋាករបស់សង្ឃ ។ កាលខទេនឧបាសកកំពុងតែពោលទោស តិះដៀល បន្ទុះបង្អាប់

ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះឯង រួចហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង ៧ ពួក គឺភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ឧបាសក ១ ឧបាសិកា ១ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហកវគ្គ (កិច្ចដែលគួរធ្វើបាន ៧ ថ្ងៃ) កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង ៧ ពួកនេះ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់ក្នុងរវាង ៧ ថ្ងៃ[1] ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើវិហារ ចំពោះសង្ឃហើយ ។ បើឧបាសកនោះបញ្ជូនបម្រើមកក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំកុណាប្រថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅ ដោយសត្តាហកវគ្គបាន កាលបើឥតមានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើរោងអគ្គិសាលាគំពោះសង្ឃ ។បេ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យ

១- សេចក្តីថា ភិក្ខុលើកសត្តាហៈចេញទៅអំពីវត្តហើយ ត្រូវត្រឡប់មកវត្តខាងក្នុងអស់រយៈថ្ងៃទី ៧ វិញ កុំទៅនៅក្រៅវត្តឲ្យហួសអស់រយៈថ្ងៃទី ៧ ឡើយ ។

គេធ្វើប្រាសាទដំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបនូប់ ។ ឲ្យគេធ្វើសាលាសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ (បង្គន់) ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើសាលានៅនាអណ្តូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើសាលាសម្រាប់ ប្រើប្រាស់នៅនាផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីអារាម ។ បើឧបាសកនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំង-ឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រុថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅដោយសត្តាហករណីយបាន កាលបើឥតមានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកចំពោះភិក្ខុច្រើនរូប ។បេ។ បានឲ្យគេធ្វើវិហារចំពោះភិក្ខុ ១ រូប ។ ឲ្យគេធ្វើអឌ្ឍយោគ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបនូប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងសម្រាប់ចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើសាលាសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ ។ ឲ្យគេ

ធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យ គេធ្វើទីជីអារាម ។ បើឧបាសកនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងឲ្យទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិលមកវិញក្នុងរវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសក បានឲ្យគេធ្វើវិហារចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី ១ រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា ១ រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ ១ រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី ១ រូប ។ បានឲ្យគេធ្វើអឌ្ឍយោគ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទ ជំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីជីអារាម ។ បើឧបាសកនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចម្រើនទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ

ភិក្ខុគប្បីទៅ ដោយសត្តាហកវណីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើទីនៅចំពោះខ្លួនឯងវិញ ។ ឲ្យគេធ្វើផ្ទះសម្រាប់ដេក ។ ឲ្យគេធ្វើឃ្លាំង ។ ឲ្យគេធ្វើប៉ម (បញ្ជា) ។ ឲ្យគេធ្វើប្រាសាទបួនជ្រុង ។ ឲ្យគេធ្វើវានផ្សារ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់បរិភោគ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើផ្ទះសម្រាប់ចម្អិនអាហារ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីជីអារាម ។ មានការជណ្តឹង (កូនស្រី) ដើម្បីកូនប្រុសក្តី មានការជណ្តឹង (កូនប្រុស) ដើម្បីកូនស្រីក្តី គេមានជំងឺក្តី គេប្រាប់ព្រះសូត្រដែលគេដឹងប្រាកដក្តី ។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចម្រើនទាំងឡាយនិមន្តមករៀនយកព្រះសូត្រនេះ កុំឲ្យព្រះសូត្រនេះសាបសូន្យទៅឡើយ ។ ម៉្យាងទៀត ឧបាសកនោះមានកិច្ចឯណានីមួយក្តី មានកិច្ចត្រូវធ្វើ (ខានមិនបាន) ក្តី ។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចម្រើនទាំង-ឡាយនិមន្តមក ខ្ញុំកុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញ

ភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាបានឲ្យគេធ្វើវិហារចំពោះសង្ឃ ។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំកុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាបានឲ្យគេធ្វើអឌ្ឍយោគចំពោះសង្ឃ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់ឆាន់ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើកប្បិយកុដិ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក ។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីដីអារាម ។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំកុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុ

ទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងសាសនានេះ បើមានឧបាសិកាគេបានធ្វើវិហារចំពោះភិក្ខុច្រើនរូប ។បេ។ ចំពោះភិក្ខុ ១ រូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី ១ រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា ១ រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ ១ រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី ១ រូប ។បេ។ បានឲ្យគេធ្វើលំនៅចំពោះខ្លួនឯង ។ ឲ្យគេធ្វើផ្ទះសម្រាប់ដេក ។ ឲ្យគេធ្វើឃ្លាំង ។ ឲ្យគេធ្វើប៉ម (បញ្ចូ) ។ ឲ្យគេធ្វើប្រាសាទបួនជ្រុង ។ ឲ្យគេធ្វើរានផ្សារ ។ ឲ្យគេធ្វើរោងរានផ្សារ ។ ឲ្យគេធ្វើប្រាសាទវែង ។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល ។ ឲ្យគេធ្វើគុហា ។ ឲ្យគេធ្វើបរិវេណ ។ ឲ្យគេធ្វើបន្ទប់ទឹក ។ ឲ្យគេធ្វើរោងសម្រាប់បរិភោគអាហារ ។ ឲ្យគេធ្វើរោងភ្លើង ។ ឲ្យគេធ្វើផ្ទះសម្រាប់ចម្អិនអាហារ ។ ឲ្យគេធ្វើវច្ចកុដិ ។ ឲ្យគេធ្វើទីចង្រ្កម ។ ឲ្យគេធ្វើរោងចង្រ្កម ។ ឲ្យគេធ្វើអណ្តូងទឹក ។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក ។ ឲ្យគេធ្វើស្រះ ។ ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីដីអារាម ។ មានការដណ្តឹង (កូនស្រី) ដើម្បីកូនប្រុសក្តី មានការដណ្តឹង (កូនប្រុស) ដើម្បីកូនស្រីក្តី គេមានជំងឺក្តី គេប្រាប់ព្រះសូត្រដែលគេដឹងប្រាកដក្តី ។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក

เรียนยกอุเทศพระสูตรนี้ ขอพระสูตรนี้จงสาธยายต่อไปเถิด ฯ ก็ดี ภิกษุนั้นมีกิจอย่างอื่นอีกหรือ (ไม่มี) ก็ดี ถ้าอุบาสิกานั้นพึงบอกใช้ภิกษุทั้งหลายว่า ขอพระคุณเจ้าทั้งหลายจงมา ข้าพเจ้าขอถวายทานแด่พระคุณเจ้าทั้งหลาย และจักฟังธรรมของพระคุณเจ้าทั้งหลาย ฯ ท่านผู้เจริญทั้งหลาย ถ้าอุบาสิกานั้นบอกใช้มาแล้ว ภิกษุพึงไปด้วยสัตตาหกรณียะได้ ถ้าภิกษุไม่ไปเสีย ภิกษุนั้นต้องทุกกฏ ฯ ท่านผู้เจริญทั้งหลาย ในศาสนานี้ ถ้าภิกษุมีไว้เพื่อสงฆ์ ภิกษุณีมีไว้เพื่อสงฆ์ สิกขมานามีไว้เพื่อสงฆ์ สามเณรมีไว้เพื่อสงฆ์ สามเณรีมีไว้เพื่อสงฆ์ มีไว้เพื่อภิกษุหลายรูป มีไว้เพื่อภิกษุ ๑ รูป มีไว้เพื่อภิกษุณีสงฆ์ มีไว้เพื่อภิกษุณีหลายรูป มีไว้เพื่อภิกษุณี ๑ รูป มีไว้เพื่อสิกขมานาหลายรูป มีไว้เพื่อสิกขมานา ๑ รูป มีไว้เพื่อสามเณรหลายรูป มีไว้เพื่อสามเณร ๑ รูป มีไว้เพื่อสามเณรีหลายรูป มีไว้เพื่อสามเณรี ๑ รูป ฯลฯ มีไว้เพื่อตนเอง ฯ ให้ทำอัคคยาคาร ฯ ให้ทำโรงฉัน ฯ ให้ทำปราสาทมีเรือนยอดเดียว ฯ ให้ทำถ้ำ ฯ ให้ทำบริเวณ ฯ ให้ทำสระน้ำ ฯ ให้ทำโรงสำหรับบริโภคอาหาร ฯ ให้ทำโรงไฟ ฯ ให้ทำกปิยกุฎี ฯ ให้ทำวัจจกุฎี ฯ ให้ทำที่จงกรม ฯ ให้ทำโรงจงกรม ฯ ให้ทำอ่างน้ำ ฯ ให้ทำโรงสำหรับใช้ประโยชน์ในอ่างน้ำ ฯ ให้ทำสระ ฯ

ឲ្យគេធ្វើមណ្ឌប ។ ឲ្យគេធ្វើអារាម ។ ឲ្យគេធ្វើទីដើអារាម ។ បើសាមណេរី នោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយ និមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុ ទាំងឡាយផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុ មិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។

[๗] សម័យនោះឯង មានភិក្ខុ ១ រូប មានជំងឺ ។ ភិក្ខុនោះបាន បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្បាតខ្ញុំមានជំងឺ សូមភិក្ខុទាំង-ឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ភិក្ខុទាំងឡាយក៏ក្រាប ទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាល ភិក្ខុទាំងឡាយ កាលបើសហធម្មិកបុគ្គលទាំង ៥ ពួក គឺភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មិនបានបញ្ជូនបម្រើមក ក៏ តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហកវណីបាន នឹងនិយាយទៅថ្ងៃដល់ កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ពួកសហ-ធម្មិកបុគ្គលទាំង ៥ ពួកនេះ ទុកជាមិនបានបញ្ជូនបម្រើមក ក៏តថាគត អនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហកវណីបាន នឹងនិយាយទៅថ្ងៃដល់កិច្ចដែល គេបានបញ្ជូនបម្រើមកនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះមានភិក្ខុឈឺ ។ បើភិក្ខុនោះបញ្ជូនបម្រើ ទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្បាតខ្ញុំមានជំងឺ សូមភិក្ខុទាំងឡាយនិមន្តមក

*ข้าพเจ้าขอให้ภิกษุทั้งหลายจงมาเถิด ฯ ดูกรภิกษุทั้งหลาย ถ้าภิกษุไข้นั้นมิได้ส่งคนมา ภิกษุทั้งหลายก็ไม่ควรไปด้วยสัตตาหกรณียะ ควรกล่าวคำนี้ว่า ข้าพเจ้าขอให้ภิกษุไข้จงมาเถิด ฯ ดูกรภิกษุทั้งหลาย ถ้าภิกษุไข้นั้นส่งคนมาแล้ว ภิกษุทั้งหลายก็ไม่ควรไปด้วยสัตตาหกรณียะ ควรกล่าวคำนี้ว่า ข้าพเจ้าขอให้ภิกษุไข้จ

วิญญัตติวาร ๗ วัน ด้วยคิดว่า อาตมาจักให้ปลงอาบัติทุพภาสิตเสียด้วยตนเอง หรือให้ภิกษุอื่นปลงให้ หรือจักให้ทำวัตรแก่ภิกษุนั้น ๆ ดังนี้ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้ ทิฏฐิคตสัมปยุตตะเกิดขึ้นแก่ภิกษุแล้ว ๆ ถ้าภิกษุนั้นประพฤติปริวาสในสำนักภิกษุทั้งหลายว่า ทิฏฐิคตสัมปยุตตะเกิดขึ้นแก่ข้าพเจ้าแล้ว ๆ ขอภิกษุทั้งหลายจงให้ปริวาสแก่ข้าพเจ้า ข้าพเจ้าขอให้ภิกษุทั้งหลายให้ปริวาสแก่ข้าพเจ้า ๆ ดูก่อนภิกษุทั้งหลาย ถ้าภิกษุนั้นประพฤติปริวาสในสำนักภิกษุทั้งหลายแล้ว ก็ภิกษุสงฆ์ให้สัตตาหกรณียะได้ จักให้ปริวาสแก่ภิกษุนั้นเมื่อใด ภิกษุนั้นพึงประพฤติปริวาสในสำนักภิกษุสงฆ์ ๗ วัน ด้วยคิดว่า อาตมาจักให้ปริวาส หรือจักให้ภิกษุอื่นให้ปริวาสแก่ภิกษุนั้น ดังนี้ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้ ภิกษุควรแก่ธรรมแล้ว ควรแก่ปริวาส ๆ ถ้าภิกษุนั้นประพฤติปริวาสในสำนักภิกษุทั้งหลายว่า ข้าพเจ้าควรแก่ธรรมแล้ว ควรแก่ปริวาส

ទាំងឡាយថា ដ្បិតខ្ញុំគួរនឹងទាញអន្តរាបត្តិមកជាក់ក្នុងមូលាបត្តិ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវេលា ๗ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬជាគណបូរកៈ ក្នុងការទាញនូវអន្តរាបត្តិមកជាក់ក្នុងមូលាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុគួរដល់មានត្ត ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំគួរដល់មានត្តហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំចង់ឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វី ដល់កិច្ចដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវេលា ๗ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងការឲ្យមានត្ត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុគួរដល់អព្ភានកម្ម ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំង-ឡាយថា ខ្ញុំគួរដល់អព្ភានកម្មហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវេលា ๗

ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងអព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ចំពោះភិក្ខុហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្មដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន នឹងនិយាយទៅថ្ងៃដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ដោយគិតថា សង្ឃមិនគួរធ្វើនូវកម្ម ឬគួរបង្អោនទៅរកដើម្បីកម្មស្រាលដោយឧបាយដូចម្តេចហ្ន៎ ។ ម៉្យាងវិញទៀត កម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់ភិក្ខុនោះហើយ ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃបានធ្វើនូវកម្មដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន នឹងនិយាយទៅថ្ងៃដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ដោយគិតថា ភិក្ខុនោះគួរប្រព្រឹត្តវត្តដោយប្រពៃ គួរសម្របរោម គួរប្រព្រឹត្តវត្តសមគួរដល់កិរិយារលាស់ខ្លួនចេញចាកទោស សង្ឃគប្បី

រម្ងាប់នូវកម្មនោះចេញ ដោយឧបាយដូចម្តេចហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុនីឈឺ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជំងឺ សូមលោកម្ងាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ងាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងសែ្វងរកគិលានកត្តព្តី សែ្វងរកគិលានុបដ្ឋាកកត្តព្តី សែ្វងរកគិលានភេសជ្ជៈក្តី នឹងសួរជំងឺក្តី នឹងបម្រើជំងឺក្តី ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតឡើងដល់ភិក្ខុនីហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំង-ឡាយថា សេចក្តីអផ្សុកកើតឡើងដល់ខ្ញុំហើយ សូមលោកម្ងាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ងាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីបាន នឹងនិយាយទៅថ្វីដល់ភិក្ខុដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងបំបាត់សេចក្តីអផ្សុករបស់ភិក្ខុនី ឬនឹងឲ្យអ្នកដទៃបំបាត់ ឬនឹងធ្វើធម្មកថាដល់ភិក្ខុនីនោះ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីរង្គៀសកើតឡើងដល់ភិក្ខុនីហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្តីរង្គៀសកើតឡើងដល់ខ្ញុំហើយ សូមលោកម្ងាស់ទាំងឡាយនិមន្តមក ខ្ញុំ

*ประชุมสงฆ์ทั้งสองฝ่ายนิมนต์มาก ฯ ภิกษุณีทั้งสองฝ่าย ถ้าภิกษุณีนั้นมิได้ส่งคืนมาก็ดี

អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការឲ្យនូវមានត្ត ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុនីគួរនឹងទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្បិតខ្ញុំករុណា គួរនឹងទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គិយបាននឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងការទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុនីគួរដល់អព្ភានកម្មហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្បិតខ្ញុំករុណាគួរដល់អព្ភានកម្មហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គិយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងអព្ភានកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សង្ឃចង់ធ្វើកម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ភិក្ខុនី ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃចង់ធ្វើ

กรรมដល់ខ្ញុំករុណាហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីយបាន ទើងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ๗ ថ្ងៃ ដោយគិតថា សង្ឃមិនគួរធ្វើកម្ម ឬគួរតែបង្អោនទៅដើម្បីកម្មស្រាល ដោយឧបាយដូចម្តេចហ្ន៎ ។ មួយទៀត សង្ឃបានធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តីដល់ភិក្ខុនីនោះហើយ ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សង្ឃបានធ្វើកម្មដល់ខ្ញុំករុណាហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន ទើងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ๗ ថ្ងៃ ដោយគិតថា ភិក្ខុនីនោះគួរប្រព្រឹត្តដោយប្រពៃ គួរសម្របរោម គួរប្រព្រឹត្តវត្តសមគួរដល់កិរិយារលាស់ខ្លួនចេញចាកទោស សង្ឃគប្បីរម្ងាប់កម្មនោះដោយឧបាយដូចម្តេចហ្ន៎ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សិក្ខមានាមានជំងឺ ។ បើសិក្ខមានានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជំងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក

ก็ภิกฺขุคปฺปีเตฺวเยว สตฺตาหกรณีปาน ตีหนิยฺยาเตฺวว ปุริมิกาย อุปคนฺตพฺพา ฯ ตโต ปรมฺปิ

วิลวิญญูกุงวาง ๗ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុង ឧបសម្បទាកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរឈឺ ។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាឈឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន ទើងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ๗ ថ្ងៃ ដោយគិតថា អាត្មាអញនឹងជួយស្វែងរកគិលានភត្តក្តី ស្វែងរកគិលានុបដ្ឋាកភត្តក្តី ស្វែងរកគិលានភេសជ្ជៈក្តី សាកសួរជំងឺក្តី បម្រើជំងឺក្តី ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតឡើងដល់សាមណេរ ฯลฯ សេចក្តីរង្គៀសកើតឡើងដល់សាមណេរ ។ ទិដ្ឋិខុសកើតឡើងដល់សាមណេរ ។ សាមណេរមានសេចក្តីប្រាថ្នាដើម្បីសួរនូវវិស្សា ។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាមានការប្រាថ្នាដើម្បីសួរនូវវិស្សា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន ទើងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងវាង ๗ ថ្ងៃ ដោយគិតថា អាត្មាអញនឹងសាកសួរវិស្សា ឬនឹងប្រាប់វិស្សា ។ ម្នាលភិក្ខុ

ទាំងឡាយ ក៏ក្នុងសាសនានេះមានសាមណេរចង់ឧបសម្បទា ។ បើសាមណេរនោះបញ្ជូន បម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្រាបខ្ញុំកុរណា ចង់ឧបសម្បទា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំកុរណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជា គណបូរក:ក្នុងឧបសម្បទាកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរីឈឺ ។ បើសាមណេរីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ជ្រាបខ្ញុំមានជំងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហករណីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងសែ្វងរកគិលានកត្ត ឬសែ្វងរកគិលានុបដ្ឋាកកត្ត ឬសែ្វងរកគិលានភេសជ្ជ: ឬសួរជំងឺ ឬបម្រើជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតទ្បើងដល់សាមណេរី ។ សេចក្តីរង្គៀសកើតទ្បើងដល់សាមណេរី ។ ទិដ្ឋិខុសកើតទ្បើងដល់សាមណេរី ។ សាមណេរីមានសេចក្តីប្រាថ្នាដើម្បីសួរនូវវេស្សា ។ មានសេចក្តីប្រាថ្នាដើម្បីសមាទាននូវសិក្ខា ។ បើសាមណេរីនោះ បញ្ជូនបម្រើ

ទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានសេចក្តីប្រាថ្នាដើម្បីសមាទានទុវសិក្ខា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវណ្ណីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងការសមាទានទុវសិក្ខា ។

[៨] សម័យនោះឯង មាតារបស់ភិក្ខុ ១ រូបមានជំងឺ ។ មាតានោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ដ្បិតខ្ញុំមានជំងឺ ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ ក្នុងវេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា កាលបើជនទាំង ៧ ពួកបានបញ្ជូនបម្រើមកហើយ ភិក្ខុគួរទៅដោយសត្តាហកវណ្ណីបាន កាលបើជនទាំង ៧ ពួកមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ចំណែកឯពួកសហធម្មិកទាំង ៥ វិញ មិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគួរទៅដោយសត្តាហកវណ្ណីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ក៏ឥឡូវមាតារបស់អញនេះមានជំងឺ តែមាតានោះមិនមែនជាឧបាសិកា តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី មាតា បិតា មិនបានបញ្ជូនបម្រើមក ក៏តថាគត

អនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ នេះ មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មាតារបស់ភិក្ខុមានជំងឺ ។ បើមាតានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ជ្ឈឹតខ្ញុំមានជំងឺ សូមលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាមាតាមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលមាតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជំងឺ ឬនឹងបម្រើជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បិតារបស់ភិក្ខុមានជំងឺ ។ បើបិតានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ជ្ឈឹតខ្ញុំមានជំងឺ សូមឲ្យលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ ទុកជាបិតាមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅដោយសត្តាហកវគ្គីបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលបិតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជំងឺ ឬ

นីងបម្រើជំងឺ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនប្រុសរបស់ភិក្ខុមានជំងឺ ។ បើបងប្អូនប្រុសនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាបងប្អូនថា ដ្បិតខ្ញុំមានជំងឺ សូមឲ្យលោកជាបងប្អូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកជាបងប្អូននិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនប្រុសបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន បើបងប្អូនប្រុសមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនស្រីរបស់ភិក្ខុមានជំងឺ ។ បើបងប្អូនស្រីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុថា ដ្បិតខ្ញុំមានជំងឺ សូមឲ្យលោកជាបងប្អូនប្រុសរបស់ខ្ញុំនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកជាបងប្អូនប្រុសនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនស្រីបានបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវណីបាន កាលបើបងប្អូនស្រីមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ញាតិរបស់ភិក្ខុមានជំងឺ ។ បើញាតិនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុថា ដ្បិតខ្ញុំមានជំងឺ សូមឲ្យលោកដ៏ចម្រើននិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកដ៏ចម្រើននិមន្តមក ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើញាតិបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហ-កវណីបាន កាលបើញាតិមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវាង ៧ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ អ្នកធ្វើការឈ្នួលរបស់ភិក្ខុមានជំងឺ ។ បើអ្នកធ្វើការឈ្នួលនោះ

បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាមានជំងឺ សូមឲ្យភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកធ្វើការឈ្នួលបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហកវគ្គិកបាន កាលបើអ្នកធ្វើការឈ្នួលមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងវេលា ๗ ថ្ងៃ ។

[๙] *សម័យនោះឯង មហាវិហាររបស់សង្ឃបាក់បែកទ្រុឌទ្រោមទៅ មានឧបាសកម្នាក់ បានឲ្យគេកាប់យកគ្រឿងឈើនៅក្នុងព្រៃ ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា បើលោកជ័ចម្រើនទាំងឡាយអាចឲ្យគេនាំយកគ្រឿងឈើនោះទៅបាន ខ្ញុំករុណានឹងប្រគេនគ្រឿងឈើនោះ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសង្ឃកវគ្គិ (កិច្ចដែលសង្ឃគួរធ្វើ) បាន ហើយត្រូវធ្វើការត្រឡប់វិលវិញក្នុងវេលា ๗ ថ្ងៃ ។*

ភាណវារសម្តែងអំពីភិក្ខុនៅចាំវស្សាជាបឋម ចប់

អដ្ឋកថា

សត្តាហករណីយ

[៦] *វិនិច្ឆ័យក្នុងសត្តាហករណីទាំងឡាយ គប្បីជ្រាបដូចតទៅនេះ ពីរបទថា* **សត្តាហករណីយេន គន្តុំ** *សេចក្តីថា កិច្ចណាដែលភិក្ខុគប្បីធ្វើខាងក្នុង ៧ ថ្ងៃ កិច្ចនោះឈ្មោះថា* **សត្តាហករណីយ** *តថាគតអនុញ្ញាតដើម្បីទៅដោយសត្តាហករណីយកិច្ចនោះជាហេតុ ។*

ពីរបទថា **បហិតេ គន្តុំ** *សេចក្តីថា កាលបើទូក គឺជនទាំង ៧ ពួកមានភិក្ខុជាដើមនេះបញ្ជូនទៅហើយពិត តថាគតអនុញ្ញាតដើម្បីទៅបាន ។*

ច្រើនបទថា **សត្តាហំ សន្និវត្តោ ករណីយោ** *សេចក្តីថា ភិក្ខុគប្បីត្រឡប់មកវិញក្នុង ៧ ថ្ងៃប៉ុណ្ណោះ អធិប្បាយថា ភិក្ខុមិនគប្បីឲ្យអរុណទី ៨ រះឡើងក្នុងទីនោះទេ ។*

តាំងអំពីបទថា **ភិក្ខុនីសង្ឃំ ឧទ្ទិស្ស** *ជាដើមទៅ រមែងមានការវិនាសរហូតទៅ ៣ យ៉ាង គឺវត្ថុកុដិ ១ ពោងភ្លើង ១ សាលាពោងភ្លើង ១ ។*

ពោងទុកជាក់របស់របរជាដើម ខ្ញុំបានពោលទុកហើយនោះឯងក្នុងសិក្ខាបទទាំងឡាយ មានឧទ្ទេសិតសិក្ខាបទជាដើម ឯពោងភត្ត ព្រះមានព្រះភាគត្រាស់ក្នុងវិស្សូបនាយិកក្ខន្ធកៈនេះថា **រសវតី ។**

បទថា **ភាវេយ្យុំ** *(ការជណ្តើង) ខ្ញុំបានពោលហើយ ក្នុងសញ្ចរិត្ត-សិក្ខាបទ ។*

បទទាំងឡាយថា **បុរាយំ សុត្តន្តោ ន បលុជ្ជតិ** *សេចក្តីថា ជរាបសូត្រនេះនៅមិនទាន់សាបសូន្យ ។*

ប្រើនបទថា **អញ្ញតរំ វា បនสฺส กิจฺจំ โหติ กรณียំ วา** *សេចក្តីថា កិច្ចណាមួយដែលឧបាសកនោះគួរជួសជុល រមែងជាកិច្ចគួរធ្វើ គួរសង្រ្គោះយកបាន ។ ឯក្នុងទូតដែលគេបញ្ជូនមកទាំងពួង កាលបើឧបាសកនោះបញ្ជូនអ្នកបម្រើដោយកប្បិយ ដោយពាក្យនេះថា ខ្ញុំប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង គួរភិក្ខុទៅបាន ឬដោយវេវចនៈនៃកប្បិយពាក្យទាំងនោះក៏បាន ។ អ្នកសិក្សាគប្បីជ្រាបលំដាប់នៃបេយ្យាលយ៉ាងនេះ ពាក្យថា ឧបាសកឲ្យគេសាងវិហារជាដើមចំពោះភិក្ខុសង្ឃ ចំពោះភិក្ខុច្រើនរូប ចំពោះភិក្ខុមួយរូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនីមួយរូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានាមួយរូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរមួយរូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរីមួយរូប ឧបាសកឲ្យគេសាងលំនៅដើម្បីប្រយោជន៍ខ្លួនដែលព្រះតថាគតសម្តែងហើយយ៉ាងនេះ អ្នកសិក្សាគប្បីពោលពាក្យទាំងពួងថា គឺឧបាសិកា ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ... ចំពោះសង្ឃ ក៏យ៉ាងនោះដែរ ក្នុងករណីមានប្រការ ๗ នោះ កាលបើអ្នកទាំងអស់នោះ បញ្ជូនបម្រើមកហើយ ភិក្ខុគួរទៅបាន ។*

[๗-๘] *បទថា* **បฺหฺเน สตฺตาหกรณียេน** *សេចក្តីថា កាលសហធម្មិកមិនបានបញ្ជូនទូតមកនិមន្ត ភិក្ខុក៏គួរទៅ ដោយហេតុដែលព្រះមានព្រះភាគទ្រង់សម្តែងទុកពិស្តារខាងមុខ ដោយន័យជាដើមយ៉ាងនេះថា អាត្មាអញនឹងស្វែងរកគិលានកត្ត ឬគិលានុប្បដ្ឋាកកត្ត ឬកេសជ្ជៈដល់សហធម្មិក*

ទាំង ๕ មានភិក្ខុជាដើមទាំងនោះក្តី នឹងសួរជំងឺក្តី នឹងព្យាបាលក្តី ។ សូម្បីក្នុងទីនៃមាតាបិតា ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកហើយខាងមុខក៏នយនេះដូចគ្នា ។ តែក្នុងអន្ធកអដ្ឋកថាពោលថា ជនទាំងឡាយណា ជាឧបដ្ឋាករបស់មាតាបិតា ដែលជាញាតិក្តី មិនមែនញាតិក្តី កាលជនទាំងនោះ មិនបានបញ្ជូនទូតមកនិមន្ត ភិក្ខុទោះទៅក៏គួរ ។ ពាក្យនោះលោកមិនបានពោលទុកឡើយ ក្នុងអដ្ឋកថាក្តី ក្នុងបាលីក្តី ព្រោះជួបច្នោះ មិនគួរកាន់យក ។

បទថា **ភិក្ខុភតិកោ** *បានដល់ បុរសដែលនៅជាមួយភិក្ខុទាំងឡាយក្នុងវត្តជាមួយគ្នា ។*

[๙] បទថា **ឧទ្ទិយតិ** *បានដល់ ទ្រុឌទ្រោម ។*

ពីរបទថា **ភណ្ឌំ ឆេទាបិតំ** *បានដល់ គ្រឿងទុព្វសម្ភារៈដែលគេឲ្យកាត់ទុកហើយ ។*

បទថា **អវហារាបេយ្យុំ** *គឺគប្បីជញ្ជូនមក ។*

បទថា **ឧដ្ឋាហំ** *កាត់បទជា* **ឧដ្ឋេ អហំ ។**

វិនិច្ឆ័យក្នុងបទថា **សង្ឃករណីយេន** *នេះ គប្បីជ្រាបដូច្នេះថា កិច្ចណាមួយ ដែលភិក្ខុគប្បីធ្វើក្នុងសេនាសនៈទាំងឡាយ មានវោងឧបោសថជាដើមក្តី ក្នុងទីដែលទ្រង់អនុញ្ញាត មានឆត្រ និងវេទិកានៃព្រះចេតិយជាដើមក្តី ដោយហោចសូម្បីជាសេនាសនៈផ្ទាល់ខ្លួនរបស់ភិក្ខុ គ្រប់យ៉ាងជាកិច្ចដែលសង្ឃគប្បីធ្វើទាំងអស់ ។ ព្រោះជួបច្នោះ ដើម្បីឲ្យកិច្ចនោះសម្រេច ភិក្ខុគួរទៅដើម្បីជញ្ជូនទុព្វសម្ភារៈជាដើមមក ឬដើម្បីឲ្យវេយ្យាវច្ចៈឲ្យថ្លៃឈ្នួល និង*

រង្វាន់ជាដើមដល់ជនទាំងឡាយ មានជាឯឈើជាដើម ។

វិនិច្ឆ័យក្នុងវត្តិច្ឆេទដែលផុតអំពីបាលី ក្នុងសត្តាហកវណីយោធិការ គប្បីជ្រាបដូចតទៅនេះថា ភិក្ខុដែលគេមិនបាននិមន្តដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ មិនសមគួរទៅ តែបើភិក្ខុបានធ្វើការសន្យាគ្នាទុកមុនហើយ ក្នុងអាវាសជំមួយកន្លែងថា យើងទាំងឡាយគប្បីប្រជុំគ្នាក្នុងថ្ងៃឈ្មោះនោះ ដូច្នេះ ក៏ឈ្មោះថា ជាបុគ្គលដែលគេនិមន្តហើយ ទោះទៅក៏គួរ ។ បើទៅដោយគិតថា អញនឹងបោក ជ្រលក់ចីវរ មិនគួរ ។ តែបើអាចារ្យ និងឧបជ្ឈាយ៍ប្រើទៅ គួរ ។ វត្តនៅក្នុងទីមិនឆ្ងាយ លោកទៅក្នុងវត្តនោះដោយតាំងចិត្តថា អញនឹងត្រឡប់មកក្នុងថ្ងៃនេះឯង តែមិនអាចនឹងមកឲ្យទាន់បាន គួរ ។ រមែងមិនបានដើម្បី នឹងទៅសូម្បីដើម្បីប្រយោជន៍ដល់ខន្ធសេ និងបរិបុច្ឆាជាដើម ។ តែតែងបានដើម្បីនឹងទៅដោយគិតថា អញនឹងសួរសុខទុក្ខអាចារ្យ បើអាចារ្យពោលជាមួយលោកថា លោកចូរកុំទៅក្នុងថ្ងៃនេះឡើយ ដូច្នេះ ទោះមិនត្រឡប់ ក៏គួរ ។ រមែងមិនបានដើម្បីទៅសួរសុខទុក្ខត្រកូលឧបដ្ឋាក ឬត្រកូលញាតិឡើយ ។

អន្តរាយជាហេតុចៀសចេញទៅ

[๑๐] *សម័យនោះឯង ភិក្ខុទាំងឡាយបានចាំវស្សាក្នុងអាវាស ๑ ក្នុងកោសលជនបទ ពួកសត្វសាហាវតែងទៅបៀតបៀន ។ ពួកសត្វសាហាវនោះមកចាប់ភិក្ខុទាំងនោះខ្លះ មកចោមព័ទ្ធបង្កើលភិក្ខុទាំងនោះខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយ មានពួកសត្វសាហាវមកបៀតបៀន ។ ចាប់យកភិក្ខុទាំងនោះទៅក្តី មកចោមព័ទ្ធបង្កើលភិក្ខុទាំងនោះក្តី ។ ភិក្ខុទាំងឡាយត្រូវធ្វើទុកក្នុងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះជាប់វស្សាតែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយ ពួកសត្វមានពិស[1] មកបៀតបៀន ។ សត្វទីយជាតិទាំងនោះ ខាំភិក្ខុខ្លះ មកចោមព័ទ្ធបង្កើលភិក្ខុទាំងនោះខ្លះ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះជាប់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បើភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកចោរមកបៀតបៀន ។ ចោរទាំងនោះប្លន់ភិក្ខុទាំងឡាយខ្លះ វាយសំពងភិក្ខុទាំងឡាយខ្លះ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះជាប់វស្សាតែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកបិសាចបៀត*

๑- សីរីសបៈ សំដៅយកសត្វលូនវារ ដែលមានពិស មានពស់ ក្អែបជាដើម ។

ปเวน ฯ ปิสาจทำนองนั้นเข้าไป (ในสรีระของภิกษุทำนองนั้น) ข่ม
นำยก (ภิกษุทำนองนั้น) ได้ข่ม ฯ ภิกษุทำนองนั้นพึงตั้งจิตว่า
อาวาสนี้เป็นของมีเสนาสนะ เราจักเข้าจำพรรษา ฯ ภิกษุทำนองนั้น
ควรจำพรรษา ไม่ควรออกพรรษา ฯ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้
ภิกษุทำนองนั้นเข้าจำพรรษาแล้ว ย่อมได้เพียงที่เที่ยวบิณฑบาต ฯ ภิกษุ
ทำนองนั้นก็ยังชีพด้วยอาหารบิณฑบาต ฯ ภิกษุทำนองนั้น พึงตั้งจิตว่า
อาวาสนี้เป็นของมีเสนาสนะ เราจักเข้าจำพรรษา ฯ ภิกษุทำนองนั้น
ควรจำพรรษา ไม่ควรออกพรรษา ฯ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้
ภิกษุทำนองนั้นเข้าจำพรรษาแล้ว ย่อมได้เพียงเสนาสนะ ฯ ภิกษุทำ-
นองนั้นก็ยังชีพด้วยเสนาสนะ ฯ ภิกษุทำนองนั้นพึงตั้งจิตว่า อาวาส
นี้เป็นของมีเสนาสนะ เราจักเข้าจำพรรษา ฯ ภิกษุทำนองนั้น ควร
จำพรรษา ไม่ควรออกพรรษา ฯ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้ ภิกษุ
ทำนองนั้นเข้าจำพรรษาแล้ว ย่อมได้เพียงน้ำฝนที่ตกลงในเขตบ้าน ฯ
ภิกษุทำนองนั้นก็ยังชีพด้วยอาหารบิณฑบาต ฯ ภิกษุทำนองนั้นพึงตั้งจิตว่า
อาวาสนี้เป็นของมีเสนาสนะ เราจักเข้าจำพรรษา ฯ ภิกษุทำนองนั้น
ควรจำพรรษา ไม่ควรออกพรรษา ฯ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้
น้ำฝนที่ตกลงในเขตบ้านของพวกภิกษุที่เข้าจำพรรษาแล้ว ฯ ภิกษุทำ
นองนั้นก็ยังชีพด้วยเสนาสนะ ฯ ภิกษุทำนองนั้นพึงตั้งจิตว่า อาวาส
นี้เป็นของมีเสนาสนะ เราจักเข้าจำพรรษา ฯ ภิกษุทำนองนั้นควร
จำพรรษา ไม่ควรออกพรรษา ฯ ดูก่อนภิกษุทั้งหลาย ก็ในศาสนานี้

តែមិនត្រូវអាបត្តិទេ ។

[១១] សម័យនោះឯង កាលភិក្ខុទាំងឡាយចូលវស្សាហើយក្នុងអាវាស ១ ស្រាប់តែមានពួកចោរមកនៅក្នុងស្រុកជាទីគោចរ ។ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ស្រុកជាទីគោចរមានក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយនៅនៅក្នុងទីនោះចុះ ។ ចំណែកអ្នកស្រុកក៏បែកគ្នាទៅជាពីរផ្នែក ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ អ្នកស្រុកទាំងឡាយមានចំនួនច្រើនជាងនៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយនៅនៅក្នុងទីនោះបាន ។ (ចំណែក) អ្នកស្រុកដែលឥតមានសទ្ធា ឥតមានសេចក្តីជ្រះថ្លាច្រើនជាង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកស្រុកដែលមានសទ្ធាជ្រះថ្លាមាននៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយនៅនៅក្នុងទីនោះឯង ។

[១២] សម័យនោះឯង ក្នុងកោសលជនបទមានពួកភិក្ខុចូលវស្សាក្នុងអាវាស ១ ក៏មិនដែលបានភោជនសៅហ្មង ឬឧត្តមឲ្យបានឆ្អែតពេញលេញម្តងសោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ មិនបានភោជនសៅហ្មង ឬឧត្តមល្មមឆ្អែតពេញលេញទេ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ ហើយចៀស

ចេញទៅចុះ ។ ភិក្ខុទាំងនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុ
ទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយបានភោជន
សៅហ្មង ឬឧត្តមលុមឆ្អែតពេញលេញហើយ តែមិនបានភោជនទាំងឡាយ
ឲ្យជាទីសប្បាយសោះ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមាន
សេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះជាច់វស្សា តែមិន
ត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុចូលវស្សា
ហើយ បានភោជនសៅហ្មង ឬឧត្តមលុមឆ្អែតពេញលេញ បានភោជនទាំង-
ឡាយ ក៏ជាទីសប្បាយ តែមិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយសោះ ។
ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ ហើយចៀស
ចេញទៅចុះ ។ ភិក្ខុទាំងនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុ
ទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ បានភោជន
សៅហ្មង ឬឧត្តម លុមឆ្អែតពេញលេញ បានភោជនទាំងឡាយក៏ជាទីសប្បាយ
បានភេសជ្ជៈទាំងឡាយក៏ជាទីសប្បាយ តែមិនបានអ្នកឧបដ្ឋាកឲ្យសមគួរ
សោះ ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯងមានសេចក្តីអន្តរាយ
ហើយចៀសចេញទៅចុះ ។ ភិក្ខុទាំងនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។
ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្រីមកប្រលោមភិក្ខុដែលចូល
វស្សាហើយថា សូមលោកម្ចាស់និមន្តមក ខ្ញុំកុរណាប្រគេនជ្រាក់លោកក្តី ខ្ញុំ
កុរណាប្រគេនមាសលោកក្តី ខ្ញុំកុរណាប្រគេនស្រែលោកក្តី ខ្ញុំកុរណាប្រគេន
ចម្ការលោកក្តី ខ្ញុំកុរណាប្រគេនគោឈ្មោលលោកក្តី ខ្ញុំកុរណាប្រគេនគោញី

លោកក្តី ខ្ញុំករុណាប្រគេនខ្ញុំប្រុសលោកក្តី ខ្ញុំករុណាប្រគេនខ្ញុំស្រីលោកក្តី ខ្ញុំករុណាប្រគេនកូនស្រីដើម្បីឲ្យជាភរិយាលោកក្តី ខ្ញុំករុណាជាភរិយាលោកក្តី ខ្ញុំករុណានាំយកស្រីដទៃមកឲ្យជាភរិយាលោកក្តី ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតតែងប្រែត្រឡប់រហ័សដោយពិត ក្រែងព្រហ្មចរិយធម៌របស់អាត្មាអញនឹងមានសេចក្តីអន្តរាយ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សាតែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្រីផ្តាមាសមកប្រលោមភិក្ខុដែលចូលវស្សាហើយ ។បេ។ ចុល្លកុមារី (ស្រីចាស់ក្រមុំ) មកប្រលោម ខ្ញើយមកប្រលោម ពួកញាតិមកប្រលោម ពួកស្តេចមកប្រលោម ពួកចោរមកប្រលោម ពួកអ្នកលេងមកប្រលោមថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់និមន្តមក យើងខ្ញុំប្រគេនប្រាក់លោកក្តី យើងខ្ញុំប្រគេនមាសលោកក្តី យើងខ្ញុំប្រគេនស្រែលោកក្តី យើងខ្ញុំប្រគេនចម្ការលោកក្តី យើងខ្ញុំប្រគេនគោឈ្មោលលោកក្តី យើងខ្ញុំប្រគេនគោញីលោកក្តី យើងខ្ញុំប្រគេនខ្ញុំប្រុសលោកក្តី យើងខ្ញុំប្រគេនខ្ញុំស្រីលោកក្តី យើងខ្ញុំប្រគេនកូនស្រីដើម្បីឲ្យជាភរិយាលោកក្តី យើងខ្ញុំនាំយកស្រីដទៃមកឲ្យជាភរិយាលោកក្តី ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតតែងប្រែត្រឡប់រហ័សដោយពិត ក្រែងមានសេចក្តីអន្តរាយដល់ព្រហ្មចរិយធម៌របស់អាត្មាអញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុ

ទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ ឃើញកំណប់ទ្រព្យឥតមានម្ចាស់ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាតតែងប្រែប្រួលរហ័សដោយពិត ក្រែងមានសេចក្តីអន្តរាយដល់ព្រហ្មចរិយធម៌របស់អញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ ឃើញភិក្ខុច្រើនរូបកំពុងព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា សង្ឃភេទព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអញឡើយ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ពួកភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអញឡើយ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយបានឮដំណឹងថា ក្នុងអាវាសឯណោះមានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះជាមិត្តរបស់អាត្មាអញ អាត្មាអញនឹងនិយាយនឹងភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា

មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះមុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះមិនមែនជាមិត្តរបស់អាត្មាអញមែន ប៉ុន្តែថាភិក្ខុទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុទាំងឡាយនោះ ភិក្ខុទាំងនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះលុះអាត្មាអញបាននិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះមុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះហើយត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាច់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែកព្រោះភិក្ខុច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះជាមិត្តរបស់អញៗ នឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ការបំបែកសង្ឃមានទោសធ្ងន់ លោកដ៏មានអាយុទាំងឡាយកុំចូល

ចិត្តនឹងការបំបែកសង្ឃឡើយ កិក្ខុទាំងនោះនឹងធ្វើតាម នឹងជ្រាបថ្វាដើម្បីស្តាប់ពាក្យរបស់អញ នឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ កិក្ខុនោះជាចំវស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែកព្រោះភិក្ខុច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងឡាយនោះឯងមិនមែនជាមិត្តរបស់អាត្មាទេ ប៉ុន្តែថា ភិក្ខុទាំងឡាយណា ដែលជាមិត្តរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះលុះអាត្មាអញនិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះ មុខជានឹងធ្វើតាម មុខជានឹងជ្រាបថ្វាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ កិក្ខុនោះជាចំវស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុនីច្រើនរូប ព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីទាំងនោះជាមិត្តរបស់អាត្មាអញពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់នាងកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ។ ពួកភិក្ខុនីនោះមុខ

ជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ កិក្ខុនោះជាប់វស្សាតែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយបានឮដំណឹងថា ក្នុងអាវាសឯណោះមានភិក្ខុនីច្រើនរូប ព្យាយាមដើម្បីបំបែកសង្ឃ ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះមិនមែនជាមិត្តរបស់អាត្មាអញមែន ប៉ុន្តែថា ភិក្ខុនីណាដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះលុះអាត្មាអញនិយាយទៅហើយ មុខជានិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ ពួកនាងកុំចូលចិត្តនឹងការបំបែកសង្ឃទ្បើយ ពួកភិក្ខុនីនោះមុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅចុះ ។ កិក្ខុនោះជាប់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះសង្ឃមុខជានឹងបែកព្រោះពួកភិក្ខុនីច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ ជាមិត្តរបស់អាត្មាអញដោយពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់ទាំងនាង កុំចូលចិត្តនឹងការបំបែកសង្ឃទ្បើយ ភិក្ខុនីទាំងនោះមុខជានឹងធ្វើតាម មុខ

ជាប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះ ហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាប់វស្សា តែមិនត្រូវអាបត្តិទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សា ហើយបានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែកព្រោះភិក្ខុនីច្រើនរូប ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះមិនមែនជាមិត្តរបស់អាត្មាអញពិតមែន ប៉ុន្តែថា ភិក្ខុនីទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងឡាយនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះ លុះអាត្មាអញនិយាយទៅហើយ នឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មានទោសធ្ងន់ ពួកនាងកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុនីទាំងនោះមុខជានឹងធ្វើតាម មុខជាប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្អៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន ។ ភិក្ខុនោះជាប់វស្សា តែមិនត្រូវអាបត្តិទេ ។

[๑๓] *សម័យនោះឯង ភិក្ខុ ๑ រូបមានសេចក្តីប្រាថ្នាដើម្បីចូលវស្សាក្នុងលំនៅរបស់គង្វាលគោ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងលំនៅរបស់គង្វាលគោបាន ។ ឯលំនៅរបស់គង្វាលគោក៏រើចេញទៅ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ លំនៅគង្វាល*

คោទៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទៅក្នុងទីនោះបាន ។ សម័យនោះឯង មានភិក្ខុ ๑ រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយពួកឈ្មួញរនេះ[๑] ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងពួកឈ្មួញរនេះបាន ។ សម័យនោះឯង មានភិក្ខុ ๑ រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយទូក ។ ភិក្ខុ ទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងទូកបាន ។

[๑๔] សម័យនោះឯង មានភិក្ខុ ๑ រូបចូលវស្សាក្នុងរូងឈើ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកបិសាច ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ភិក្ខុមិនត្រូវចូលវស្សាក្នុងរូងឈើទេ ភិក្ខុណាចូល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាលើប្រគាបឈើ ។ ពួកមនុស្សក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកព្រានម្រឹគ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាលើប្រគាបឈើទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

๑- ក្នុងដីកាថា ប្រជុំជន ។

[๑๕] สมัยนั้นแล ภิกษุทั้งหลายจูลวัสสาในที่วิกาล ฯ ครั้นเวลาใกล้ค่ำมาถึง ภิกษุทั้งนั้น ก็ซุกซ่อนอยู่ตามโคนต้นไม้บ้าง ตามกองหญ้าบ้าง (ตามที่ต่างๆ) ฯ ภิกษุทั้งหลายกราบทูลเรื่องนี้แด่พระผู้มีพระภาค ฯ พระองค์ทรงมีพระดำรัสว่า ดูก่อนภิกษุทั้งหลาย ภิกษุไม่ควรจูลวัสสาในที่วิกาลเลย ภิกษุใดจูล ต้องอาบัติทุกกฏ ฯ สมัยนั้นแล ภิกษุทั้งหลายจูลวัสสาในที่ไม่มีเสนาสนะเลย ก็ลำบากด้วยยุงบ้าง ด้วยเหลือบบ้าง ฯ ภิกษุทั้งหลายกราบทูลเรื่องนี้แด่พระผู้มีพระภาค ฯ พระองค์ตรัสว่า ดูก่อนภิกษุทั้งหลาย ภิกษุไม่ควรจูลวัสสาในที่ไม่มีเสนาสนะเลย ภิกษุใดจูล ต้องอาบัติทุกกฏ ฯ สมัยนั้นแล ภิกษุทั้งหลายจูลวัสสาในร่มเงาเกวียน ฯ มนุษย์ทั้งหลายก็เพ่งโทษติเตียน ตำหนิว่า ภิกษุทั้งนั้นดุจพวกคนขนสินค้าเกวียน ฯ ภิกษุทั้งหลายกราบทูลเรื่องนี้แด่พระผู้มีพระภาค ฯ พระองค์ตรัสว่า ดูก่อนภิกษุทั้งหลาย ภิกษุไม่ควรจูลวัสสาในร่มเงาเกวียนเลย ภิกษุใดจูล ต้องอาบัติทุกกฏ ฯ สมัยนั้นแล ภิกษุทั้งหลายจูลวัสสาในแถวต้นไม้ ฯ มนุษย์ทั้งหลายก็เพ่งโทษติเตียน ตำหนิว่า ภิกษุทั้งนั้นดุจพวกคนเลี้ยงโค ฯ ภิกษุทั้งหลายกราบทูลเรื่องนี้แด่พระผู้มีพระภาค ฯ พระองค์ตรัสว่า ดูก่อนภิกษุทั้งหลาย ภิกษุไม่ควรจูลวัสสาในแถวต้นไม้เลย ภิกษุใดจูล ต้องอาบัติทุกกฏ ฯ สมัยนั้นแล ภิกษุทั้งหลายจูลวัสสาในที่ใกล้น้ำ ฯ มนุษย์ทั้งหลายก็เพ่งโทษติเตียน ตำหนิว่า ภิกษุ

ទាំងនោះដូចជាពួកតិរ្ថិយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងពាងទឹកទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។

បំបាត់ខ្លួនពីមាត់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនីទៅប្រាកដនៅក្នុងវត្តជេតវន
វិញដោយឆាប់រហ័ស ដូចជាបុរសមានកម្លាំងលាដៃដែលខ្ជួនបត់ចូល ឬបត់
ចូលនូវដៃដែលខ្ជួនលាចេញ ឯជីវនោះបំបាត់ខ្លួនអំពីមាត់ស្រះបោក្ខរណីឈ្មោះ

មន្ទាកិនី ទៅប្រាកដនៅក្នុងវត្តជេតពនដែរ ទើបជំរីនោះបានឲ្យព្រះមហា-មោគ្គល្លានដ៏មានអាយុទទួលមើមឈូកនិងក្រអៅឈូក ហើយក៏បំបាត់ខ្លួនអំពីវត្តជេតវនទៅប្រាកដទៀបមាត់ស្រះបោក្ខរណីឈ្មោះមន្ទាកិនីវិញ ។ ចំណែកព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ហុចមើមឈូក និងក្រអៅឈូកទៅព្រះសារីបុត្រដ៏មានអាយុ ។ ឯព្រះសារីបុត្រមានអាយុ កាលបានឆាន់មើមឈូក និងក្រអៅឈូកហើយ ក៏បានសះជាអាពាធដែលដុតរោលរាលក្នុងកាយ ។ មើមឈូក និងក្រអៅឈូកក៏សល់នៅជាច្រើន ។ សម័យនោះឯង កាលស្រុកកើតទុរ្ភិក្ស (អត់បាយ) ភិក្ខុទាំងឡាយក៏ហាមឃាត់វត្ថុបន្ទិចបន្ទួចខ្លះ ពិចារណា ហើយក៏ហាមឃាត់ខ្លះ ម្យ៉ាងទៀត សង្ឃទាំងអស់ក៏បានហាមកត្តរួចហើយ ។ ពួកភិក្ខុមានសេចក្តីរង្កៀសក៏មិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆាន់ហើយ ហាមកត្តរួចហើយ ឆាន់កោជនមិនមែនជារបស់ដែលអំពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលតាំងនៅក្នុងព្រៃ តាំងនៅក្នុងគុម្ពឈូកបាន ។

[๑๐๔] *សម័យនោះឯង ក្នុងក្រុងសាវត្ថី មានវត្ថុសម្រាប់ទំពាស៊ី គឺផ្លែឈើកើតឡើងជាច្រើន តែរកបុគ្គលជាកប្បិយការកៈគ្មាន ។ ពួកភិក្ខុមានសេចក្តីរង្កៀស ក៏មិនហ៊ានឆាន់ផ្លែឈើឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដែលគ្មានពូជ (ផ្លែឈើខ្វី) និង*

ផ្លែឈើដែលគួរបន្ទុចយកពូជចេញ (ដូចផ្លែខ្នុរជាដើម) សូម្បីគេមិនបានធ្វើឲ្យជាកប្បិយ ក៏គួរ (ឆាន់បាន) ។

[๑๐๕] លំដាប់នោះ ព្រះដ៏មានព្រះភាគគង់ទៀបក្រុងសាវត្ថីសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងរាជគ្រឹះ ទ្រង់យាងទៅដោយលំដាប់ទើបបានទៅដល់ក្រុងរាជគ្រឹះ ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង ។ សម័យនោះឯង ភិក្ខុ ๑ រូបកើតអាពាធឫសដូងបាត ។ ពេទ្យឈ្មោះអាកាសគោត្របានធ្វើសត្ថកម្ម (កាត់ឬវះឫសដូងបាតនោះ) ដោយកាំបិត ។ ទំនួលពេលនោះ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ចារិកសេនាសនៈ ក៏បានយាងទៅកាន់លំនៅរបស់ភិក្ខុនោះ ។ ពេទ្យឈ្មោះអាកាសគោត្រ បានឃើញព្រះដ៏មាន ព្រះភាគយាងមកអំពីចម្ងាយ លុះឃើញច្បាស់ហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចម្រើន ទ្រង់យាងមកទតវច្ចមគ្គរបស់ភិក្ខុនេះ ដូចជាមាត់សត្វទន្សង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា មោឃបុរសនេះចំអកឲ្យតថាគតទេតើ ដូច្នេះហើយ ក៏ទ្រង់យាងត្រឡប់ចាកទីនោះទៅ ព្រោះនិទាននេះ ដំណើរនេះ ទើបទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងវិហារឯណោះមានភិក្ខុឈឺដែរឬទេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ មាន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឈឺដូចម្តេច ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន លោកដ៏មាន

อายุนោះកើតឫសដូងបាត ពេទ្យឈ្មោះអាកាសគោត្រក៏បានធ្វើសត្តកម្មឲ្យ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើនៃមោឃ-បុរសនោះមិនសមគួរ មិនទំនង មិនសមបែប មិនជារបស់សមណៈ មិនគួរ គប្បី មិនមែនជាកិច្ចត្រូវធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះ មិនគួរនឹងឲ្យគេធ្វើសត្តកម្មក្នុងទីចង្អៀតទេ ម្នាលភិក្ខុទាំងឡាយ ស្បែកក្នុងទីចង្អៀត ជារបស់សុខុមល្អិត មានដំបៅសះបានដោយក្រ កម្របុគ្គលនឹងយកកាំបិតទៅរះក្នុងទីចង្អៀតបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរឲ្យគេធ្វើសត្តកម្មក្នុងទីចង្អៀតទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិថុល្លច្ចយ ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគ ទ្រង់ហាមការធ្វើសត្តកម្មហើយ ទើបឲ្យគេធ្វើវត្តិកម្មវិញ (ការចងរឹតក្បាល ឫសដូងបាតនោះដោយខ្សែ) ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងឲ្យគេធ្វើវត្តកម្មសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើវត្តិកម្ម ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។បេ។ ព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យ

គេធ្វើសត្ថកម្ម ឬវត្ថិកម្ម ក្នុងទីជិតដោយជុំវិញនៃទីចង្អៀត ប្រមាណពីរ ធ្នាប់ទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិថុល្លច្ចយ ។

[๑๐๖] គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះសមគួរតាម ព្រះអធ្យាស្រ័យហើយ ទ្រង់យាងចេញទៅកាន់ចារិកក្រុងពារាណសី កាល ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសីនោះ ។ បានឮថា ព្រះដ៏មានព្រះភាគ គង់នៅព្រៃឥសិបតនមិគទាយវន ជិតក្រុង ពារាណសីនោះ ។ គ្រានោះឯង ក្នុងក្រុងពារាណសីមានជន ๒ នាក់ គឺ ឧបាសក ឈ្មោះសុប្បិយ ๑ ឧបាសិកាឈ្មោះសុប្បិយា ๑ ជាអ្នកមាន សេចក្តីជ្រះថ្លា ជាអ្នកឲ្យទាន ជាអ្នកធ្វើការបម្រើសង្ឃ ។ លំដាប់នោះ សុប្បិយាឧបាសិកា បានទៅកាន់វត្តហើយ ដើរចូលទៅគ្រប់វិហារ គ្រប់ទី បរិវេណ ហើយសួរភិក្ខុ ទាំងឡាយថា បពិត្រលោកម្ចាស់ មានលោកម្ចាស់ អង្គណាឈឺខ្លះដែរ លោកម្ចាស់អង្គណាត្រូវការឲ្យខ្ញុំករុណាយករបស់អ្វីមក ប្រគេនដែរឬ ។ វេលានោះឯង ភិក្ខុ ๑ រូប បានផឹកថ្នាំបញ្ចុះ ។ ភិក្ខុនោះក៏ និយាយនឹងសុប្បិយាឧបាសិកាដូច្នេះថា ម្នាលនាង អាត្មាធាន់ថ្នាំបញ្ចុះ អាត្មា ត្រូវការដោយសាច់ដែលមានឱជារស ។ សុប្បិយាឧបាសិកានិយាយថា ល្អ ហើយលោកម្ចាស់ នឹងឲ្យគេយកមកប្រគេន (និយាយដូច្នេះហើយ) បាន ទៅដល់ផ្ទះហើយ ក៏បង្គាប់កូនក្មួយថា ម្នាលនាយ អ្នកចូរទៅ អ្នកចូរដើង(ចូរ ទិញ) នូវសាច់សត្វដែលស្ងាប់ស្រាប់ ។ បុរសនោះ បានទទួលពាក្យ សុប្បិយាឧបាសិកាថា បាទអ្នកម្ចាស់ ហើយក៏ដើរកសាច់អស់ទាំងក្រុង

ពារាណសី មិនបានឃើញសាច់សត្វ ដែលស្ងាប់ស្រាប់ឡើយ ។ បុរសនោះ បានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយ បាននិយាយដូច្នេះ នឹងសុប្បិយាឧបាសិកាថា បពិត្រអ្នកម្ចាស់ គ្មានសាច់សត្វដែលស្ងាប់ស្រាប់ទេ ព្រោះថ្ងៃនេះគ្មានគេសម្លាប់សត្វសោះ ។ លំដាប់នោះ សុប្បិយាឧបាសិកា មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើភិក្ខុឈឺនេះឯង មិនបានសាច់ដែលមានឱជារសទេ អាពាធក៏រឹងរឹតតែចម្រើនឡើង ឬមួយនឹងធ្វើកាលកិរិយាទៅមិនខាន (ឥឡូវ) អាត្មាអញបានទទួលប្តេជ្ញាថា នឹងប្រគេនសាច់ ដល់ត្រឡប់ជាមិនឲ្យគេយកទៅប្រគេនវិញ កិច្ចនោះ មិនសមគួរដល់អញសោះ ។ សុប្បិយាឧបាសិកាក៏ចាប់យកកាំបិត សម្រាប់ហាន់សាច់ មកអារសាច់ក្លៀ (របស់ខ្លួន) ហើយហុចឲ្យទៅទាសីថា ហ៎ាឯង ចូរយកសាច់នេះទៅចាត់ចែង ហើយយកទៅប្រគេនដល់ភិក្ខុឈឺ ក្នុងវិហារឯណោះចុះ ម្យ៉ាងទៀត (បើមាន) ភិក្ខុណាសួរអញ នាងឯងចូរទូលលោកថា អញឈឺ (និយាយផ្តាំដូច្នេះហើយ) បានរុំក្លៀដោយសំពត់សម្រាប់បង់ក ហើយចូលទៅក្នុងបន្ទប់ដេកលើគ្រែ ។ លំដាប់នោះ សុប្បិយឧបាសក បានទៅកាន់ផ្ទះ ហើយសួរទាសីថា នាងសុប្បិយាទៅណា ។ ទាសីនោះប្រាប់ថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់នោះសម្រាន្តក្នុងបន្ទប់ ។ លំដាប់នោះ សុប្បិយឧបាសកបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយ សួរសុប្បិយាឧបាសិកាយ៉ាងនេះថា ព្រោះហេតុអ្វីបានជានាងដេក ។ សុប្បិយាឧបាសិកាឆ្លើយថា ខ្ញុំឈឺ ។ សុប្បិយឧបាសកសួរថា នាងឈឺអ្វី ។ ទើបសុប្បិយាឧបាសិកាប្រាប់

សេចក្តីនុ៎ះដល់សុប្បិយឧបាសក (ដោយសព្វគ្រប់) ។ លំដាប់នោះ សុប្បិយឧបាសកគិតថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចម្លែកពេកណាស់ សុប្បិយាឧបាសិកានេះ ជាស្រីមានសទ្ធាជ្រះថ្លាមែន អម្បាលសាច់របស់ខ្លួន គង់លះបង់បាន ចំណង់បើវត្ថុតិចតួចឯទៀត ឧបាសិកានេះនឹងមិនឲ្យដូចម្តេចបាន គិតដូច្នេះហើយ ក៏មានចិត្តរីករាយខ្ពស់ឡើង បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសុប្បិយឧបាសក អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងព្រះភិក្ខុសង្ឃនិមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយការៈស្ងៀម ។ លំដាប់នោះ សុប្បិយឧបាសកបានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ សុប្បិយឧបាសកក៏បានតាក់តែងខាទនីយៈ និងភោជនីយាហារដ៏ឧត្តមហើយ ក៏ឲ្យមនុស្សទៅក្រាបបង្គំទូលកាលសមគួរចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពេលសមគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ វេលាព្រឹក ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់ដោយចីវរ និងចីវរ យាងទៅកាន់ផ្ទះសុប្បិយ-ឧបាសក លុះយាងទៅដល់ហើយ គង់លើអាសនៈដែលគេរៀបចំថ្វាយ មួយអន្ទើដោយភិក្ខុសង្ឃ ។ វេលានោះ សុប្បិយឧបាសកបានចូលទៅគាល់ព្រះ

ដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយ ឈរក្នុងទីសមគួរ ។ លុះសុប្បិយឧបាសកឈរនៅក្នុងទីសម គួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានបន្ទូលសួរដូច្នេះថា នាងសុប្បិយានៅក្នុងទីណា ។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាឈឺ ។ ព្រះអង្គទ្រង់មានបន្ទូលថា បើដូច្នោះ (ឲ្យ) នាងសុប្បិយាចូលមក ។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាមិនអាចនឹងមកបានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយចូរគ្រាប់នាំយកមក ។ លំដាប់នោះ សុប្បិយឧបាសក បានគ្រាប់សុប្បិយាឧបាសិកានាំមកថ្វាយ ។ និមិត្ត តែព្រះមានព្រះភាគទ្រង់ទតឃើញ (កាលណា) ជំពៅរបស់នាងដែលធំជាងម្ល៉ោះ ក៏ដុះសាច់សះជា មានសម្បុរល្អ មានរោមដុះពេញខ្លើងវិញមួយរំពេច ។ លំដាប់នោះ សុប្បិយឧបាសក និងសុប្បិយាឧបាសិកាបាននិយាយគ្នាថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចម្លែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន គ្រាន់តែព្រះអង្គទ្រង់បានទតឃើញមួយរំពេច ជំពៅដែលធំជាងម្ល៉ោះ ក៏ដុះសាច់សះជាមានសម្បុរល្អ មានរោមដុះពេញខ្លើងវិញ (អ្នកទាំងនោះ) មានចិត្តរីករាយខ្ពស់ខ្លើង ក៏អង្គាសខាទនីយភោជនីយាហារ (បង្អែមចម្អាប) ដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏នាំគ្នាអង្គុយក្នុងទី

สมควร ฯ ลำดับนั้น พระผู้มีพระภาคได้ทรงสั่งสุปปิยอุบาสก และสุปปิยาอุบาสิกา ให้เห็นชัดแจ้ง ให้ชื่นใจ ให้อาจหาญ ให้ร่าเริง ด้วยธรรมีกถาแล้ว ก็ทรงลุกจากอาสนะเสด็จไป ฯ

[๑๐๗] ครั้งนั้น ในกาลนั้น ที่ประชุมสงฆ์ได้ประชุมกันแล้ว ทรงสอบถามภิกษุทั้งหลายว่า ดูกรภิกษุทั้งหลาย ภิกษุรูปใดรู้ เรื่องสุปปิยาอุบาสิกา ฯ ครั้งนั้น ภิกษุรูปหนึ่งกราบทูลพระผู้มีพระภาคดังนี้ว่า ข้าแต่พระองค์ผู้เจริญ ข้าพระองค์ได้ฟังมาแล้ว ฯ พระผู้มีพระภาคตรัสถามว่า ดูกรภิกษุ เธอได้ฟังมาแล้วหรือ ฯ ภิกษุนั้นกราบทูลว่า ข้าแต่พระองค์ผู้เจริญ ข้าพระองค์ได้ฟังมาแล้ว ฯ พระผู้มีพระภาคตรัสว่า ดูกรภิกษุ เธอได้ให้เขานำยาคูมาแล้วหรือ ฯ ภิกษุนั้นกราบทูลว่า ข้าแต่พระผู้มีพระภาคเจ้า ข้าพระองค์ได้ให้เขานำยาคูนั้นมาแล้ว ฯ พระผู้มีพระภาคตรัสว่า ดูกรภิกษุ เธอได้ฉันแล้วหรือ ฯ ภิกษุนั้นกราบทูลว่า ข้าแต่พระผู้มีพระภาคเจ้า ข้าพระองค์ได้ฉันแล้ว ฯ พระผู้มีพระภาคตรัสว่า ดูกรภิกษุ เธอได้พิจารณาก่อนฉันหรือ ฯ ภิกษุนั้นกราบทูลว่า ข้าแต่พระผู้มีพระภาคเจ้า ข้าพระองค์มิได้พิจารณาก่อนฉัน ฯ พระผู้มีพระภาคทรงตำหนิว่า ดูกรโมฆบุรุษ เธอไม่สมควรมิได้พิจารณาก่อนฉัน ฯ ดูกรโมฆบุรุษ เธอได้ทำให้ศาสนาของเราเสื่อมเสียแล้ว ฯ ดูกรโมฆบุรุษ เธอได้ทำให้ศาสนาของเราเสื่อมเสียแล้ว ฯ ดูกรโมฆบุรุษ เธอได้ทำให้ศาสนาของเราเสื่อมเสียแล้ว ฯ ดูกรโมฆบุรุษ การกระทำของเธอนี้ ไม่เป็นไปเพื่อความเลื่อมใสของบุคคลผู้ยังไม่เลื่อมใส ฯลฯ ทรงตำหนิแล้ว ทรงลุกจากอาสนะเสด็จเข้าไปยังวิหาร ฯ

ទាំងឡាយ ពួកមនុស្សដែលមានសទ្ធា មានសេចក្តីជ្រះថ្លា មនុស្សទាំងនោះ សូម្បីតែសាច់របស់ខ្លួនឯង ក៏គង់លះប្រគេនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់មនុស្សទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិថុល្លច្চ័យ ។ ម្យ៉ាងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

[๑๐๘] សម័យនោះឯង មានជំរឿរបស់ស្តេចស្លាប់ជាច្រើន ។ ជួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ជំរឿ ក៏បានប្រគេនសាច់ជំរឿដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់ជំរឿ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្ត មិនសមបើនឹងហ៊ានឆាន់សាច់ជំរឿសោះ ជំរឿក៏ជាអង្គ (ឃាន) របស់ស្តេច បើស្តេចទ្រង់ជ្រាប មុខជាខ្វាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមិនត្រូវឆាន់សាច់ជំរឿទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង (មាន) សេះរបស់ស្តេចស្លាប់ជាច្រើន ។ ជួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់សេះ ក៏បានប្រគេនសាច់សេះដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់សេះ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហ៊ានឆាន់សាច់សេះទេ ព្រោះសេះជាអង្គ (ឃាន) របស់ស្តេចដែរ បើស្តេចទ្រង់ជ្រាប មុខជាខ្វាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំ

ទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សេះទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង វេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ឆ្កែ ក៏បានប្រគេនសាច់ឆ្កែដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់ឆ្កែ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហ៊ានឆាន់សាច់ឆ្កែសោះ ព្រោះឆ្កែជាសត្វគួរខ្ពើមរអើម ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ឆ្កែទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពេលស្រុកអត់បាយ មនុស្សទាំងឡាយស៊ីសាច់ពស់ ក៏បានប្រគេនសាច់ពស់ដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់ពស់ ។ ពួកមនុស្សពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណសក្យបុត្តមិនសមបើនឹងហ៊ានឆាន់សាច់ពស់សោះ ព្រោះពស់ជាសត្វគួរខ្ពើមរអើម ។ ចំណែកខាងស្តេចនាគឈ្មោះសុបស្ស បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសុបស្សនាគរាជឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នាគទាំងឡាយជាសត្វគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទេ ក្រែងពួកនាគទាំងនោះបៀតបៀនភិក្ខុទាំងឡាយខ្លះមិនខាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមកុំឲ្យលោកម្ចាស់ទាំងឡាយឆាន់

สาច់ពស់ឡើយ ។ លំដាប់នោះ ព្រះមានព្រះភាគញុំាងសុបស្សនាគរាជឲ្យ ឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លុះសុបស្សនាគរាជដែលព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់ យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏ មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ពស់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិ ទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វសីហៈ ហើយស៊ីសាច់ សីហៈ ក៏បានប្រគេនសាច់សីហៈដល់ពួកភិក្ខុដែលគ្រាច់ទៅបិណ្ឌបាត ។ ពួក ភិក្ខុឆាន់សាច់សីហៈហើយ ក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វសីហៈ ធុំក្លិនសាច់ សីហៈ ក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះ ព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ ឆាន់សាច់សីហៈទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួក ព្រានសម្លាប់ខ្លាធំ ហើយស៊ីសាច់ខ្លាធំ ក៏បានប្រគេនសាច់ខ្លាធំដល់ពួកភិក្ខុ ដែលគ្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុឆាន់សាច់ខ្លាធំហើយទៅនៅក្នុងព្រៃ ។ ពួកខ្លាធំបានធុំក្លិនសាច់ខ្លាធំ ក៏សម្លាប់ភិក្ខុជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំ ទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាធំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាដំបង ហើយស៊ីសាច់ខ្លាដំបង ក៏បាន

ประเคนสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็นอนในที่ต่าง ๆ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็มากด้วยการนอน ๆ ภิกษุทั้งหลายกราบบังคมทูลเสด็จพระผู้มีพระภาคเจ้า ๆ พระผู้มีพระภาคเจ้าตรัสว่า ดูกรภิกษุทั้งหลาย ภิกษุไม่ควรฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ภิกษุใดฉัน ต้องอาบัติทุกกฏ ๆ สมัยนั้นแล พวกพราหมณ์สำหรับสัตว์กินน้ำ ๆ ก็ประเคนสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็นอนในที่ต่าง ๆ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็มากด้วยการนอน ๆ ภิกษุทั้งหลายกราบบังคมทูลเสด็จพระผู้มีพระภาคเจ้า ๆ พระผู้มีพระภาคเจ้าตรัสว่า ดูกรภิกษุทั้งหลาย ภิกษุไม่ควรฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ภิกษุใดฉัน ต้องอาบัติทุกกฏ ๆ สมัยนั้นแล พวกพราหมณ์สำหรับสัตว์กินน้ำ ๆ ก็ประเคนสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็นอนในที่ต่าง ๆ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็มากด้วยการนอน ๆ ภิกษุทั้งหลายกราบบังคมทูลเสด็จพระผู้มีพระภาคเจ้า ๆ พระผู้มีพระภาคเจ้าตรัสว่า ดูกรภิกษุทั้งหลาย ภิกษุไม่ควรฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ภิกษุใดฉัน ต้องอาบัติทุกกฏ ๆ

สุปปิยกาณาวาร:ที่ ๒ จบ

[๑๐๙] คราวนั้น พระผู้มีพระภาคเจ้าประทับอยู่ในกรุงพาราณสี สมควรตามพระอัธยาศัยแล้ว ก็เสด็จจาริกไปยังกรุงเวสาลี โดยลำดับ ๆ ท่านพระอานนท์ได้ทราบข่าวว่า ได้ยินว่า พระผู้มีพระภาคเจ้าเสด็จจาริกไปยังกรุงเวสาลี โดยลำดับ ๆ ครั้นแล้วได้ไปยังกรุงเวสาลี ๆ ได้เห็นพระผู้มีพระภาคเจ้าประทับนั่งในที่แจ้ง ๆ ครั้นแล้วได้ปูอาสนะถวายพระผู้มีพระภาคเจ้าประทับนั่งบนอาสนะที่ปูถวายแล้ว ๆ ได้ล้างพระบาทของพระผู้มีพระภาคเจ้าแล้ว ๆ ได้นั่งในที่สมควรข้างหนึ่ง ๆ ครั้นนั่งแล้วได้กราบทูลพระผู้มีพระภาคเจ้าว่า ข้าแต่พระองค์ผู้เจริญ ได้ยินว่า พระผู้มีพระภาคเจ้าเสด็จจาริกไปยังกรุงเวสาลี โดยลำดับ ๆ ข้าแต่พระองค์ผู้เจริญ ขอพระผู้มีพระภาคเจ้าจงทรงรับสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็นอนในที่ต่าง ๆ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็มากด้วยการนอน ๆ ภิกษุทั้งหลายกราบบังคมทูลเสด็จพระผู้มีพระภาคเจ้า ๆ พระผู้มีพระภาคเจ้าตรัสว่า ดูกรภิกษุทั้งหลาย ภิกษุไม่ควรฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ภิกษุใดฉัน ต้องอาบัติทุกกฏ ๆ สมัยนั้นแล พวกพราหมณ์สำหรับสัตว์กินน้ำ ๆ ก็ประเคนสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็นอนในที่ต่าง ๆ ๆ ภิกษุทั้งหลายฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์แล้ว ก็มากด้วยการนอน ๆ ภิกษุทั้งหลายกราบบังคมทูลเสด็จพระผู้มีพระภาคเจ้า ๆ พระผู้มีพระภาคเจ้าตรัสว่า ดูกรภิกษุทั้งหลาย ภิกษุไม่ควรฉันสาช่ายังมัธยมัคคตภิกษุผู้ถือเสนาสนะอันเหลือ ๆ ของสงฆ์ ภิกษุใดฉัน ต้องอาบัติทุกกฏ ๆ

ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណមួយពាន់ពីរយហាសិបរូប ។ សម័យ នោះឯង ពួកមនុស្សអ្នកជនបទបានផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈ ខ្លះ ក្នុងរទេះទាំងឡាយហើយ ក៏បរទៅតាមក្រោយៗ ភិក្ខុសង្ឃមានព្រះពុទ្ធជា ប្រធាន ។ ពួកមនុស្សអ្នកស៊ីដែលប្រមាណជ្រុំរយនាក់ ក៏គិតគ្នាថា (បើ) ពួកយើងបានលំជាប់ (វេន) នៃភត្តក្នុងកាលណា នឹងធ្វើភត្តក្នុងកាល នោះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាមលំជាប់ ក៏ បានទៅដល់អន្ធកវិន្ទប្រទេសនោះ ។ លំជាប់នោះ កាលព្រាហ្មណ៍ម្នាក់មិន បានលំជាប់ (វេន) នៃភត្ត ក៏មានសេចក្តីរិះគិតយ៉ាងនេះថា អាត្មាអញបាន ដើរតាមភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ជាង ២ ខែហើយ ដោយប៉ងថា បើ អាត្មាអញបានលំជាប់ (វេន) នៃភត្តក្នុងកាលណា នឹងធ្វើភត្តក្នុងកាលនោះ ឥឡូវលំជាប់ (វេន) នៃភត្តអាត្មាអញមិនទាន់បាននៅឡើយ ខ្លួនអញទៀត សោត ក៏តែម្នាក់ឯង ទាំងប្រយោជន៍ខាងឃរាវាសរបស់អាត្មាអញទៀត ក៏ សាបសូន្យទៅជាច្រើន បើដូច្នោះមានតែគួរអាត្មាអញទៅត្រួតមើលរោងភត្ត វត្តណាគ្មានក្នុងរោងភត្ត អាត្មាអញក៏នឹងតាក់តែងនូវវត្តនោះ ។ រៀលដែល ព្រាហ្មណ៍នោះទៅមើលរោងភត្ត ក៏មិនឃើញវត្តពីរយ៉ាង គឺបបរនិងនំមាន រសផ្អែមឡើយ[1] ។ ទើបព្រាហ្មណ៍នោះ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ និយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រ ព្រះអានន្ទដ៏ចម្រើន កាលខ្ញុំករុណាមិនបានលំជាប់ (វេន) នៃភត្តក្នុងទីនេះ

๑- ក្នុងជីកាថា នំដែលគេលាយដោយវត្តុមានស្ករជាដើម ។

ក៏ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញដើរតាមកិកូសង្ឃមានព្រះពុទ្ធជាប្រធាន ជាង ២ ខែហើយ ដោយប៉ងថា (បើ) អាត្មាអញបានលំជាប់ (វេន) នៃកត្តក្នុងពេលណា នឹងធ្វើកត្តក្នុងពេលនោះ ឥឡូវអាត្មាអញមិនទាន់បានលំជាប់ (វេន) នៃកត្តនៅឡើយ ខ្លួនអញទៀតសោត ក៏តែម្នាក់ឯង ទាំងប្រយោជន៍ខាងយកវាសរបស់អញទៀត ក៏សាបសូន្យទៅជាច្រើន បើដូច្នោះមានតែគួរអាត្មាអញទៅត្រួតមើលរោងកត្ត វត្តណាគ្មានក្នុងរោងកត្ត អាត្មាអញនឹងតាក់តែងវត្តនោះ (យ៉ាងនេះ) បពិត្រព្រះអានន្ទដ៏ចម្រើន កាលខ្ញុំព្រះករុណាទៅមើលរោងកត្តមិនបានឃើញវត្តពីរយ៉ាង គឺបបរ និងនំមានរសផ្អែមឡើយ បពិត្រព្រះអានន្ទដ៏ចម្រើន បើខ្ញុំករុណាតាក់តែងបបរ និងនំមានរសផ្អែមមកថ្វាយ ព្រះគោតមដ៏ចម្រើន ទ្រង់ទទួលរបស់ខ្ញុំករុណាដែរឬ ។ ព្រះអានន្ទក្រាប់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះចាំអាត្មាទូលសួរព្រះដ៏មានព្រះភាគសិន ។ លំជាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះឲ្យព្រាហ្មណ៍នោះតាក់តែងចុះ ។ ទើបព្រះអានន្ទទៅក្រាប់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍បើដូច្នោះ អ្នកចូរតាក់តែងចុះ ។ លុះរាត្រីនោះ កន្លងទៅហើយ ឯព្រាហ្មណ៍នោះតាក់តែងបបរ និងនំមានរសផ្អែមជាច្រើន ក៏បានបង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគ ហើយទូលថា សូមព្រះគោតមដ៏ចម្រើន ទ្រង់ទទួលបបរ និងនំមានរសផ្អែមរបស់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍បើដូច្នោះ អ្នកចូរប្រគេនដល់កិកូទាំងឡាយចុះ ។ ពួកកិកូ

รเฬฺวสะ มิตหีานทุนลุ ฯ ปฺระหะองฺคฺเจฺจ ตฺรัสฺสฺดาจ มฺลาลภิกขุทำงฺพฺลายะ อฺนกฺ ทำงฺพฺลายะ จูวทุนลุจุปะ จูวถานฺดุปะ ฯ ปฺรายหฺมณ์นายหะอฺงฺกาสภิกขุสงฺฆ มาน ปฺระหะพุทธอฺงฺคฺชา ปฺรถานเดายปหา นิงนำมานวสแฝมชาเจฺรน เดายได้รปหสฺ ขฺนเจฺยแฝตสฺกปฺสฺกลฺ ตฺราแตเลากปฺรแกกเลงทุนลุเจต ลุะปฺระหะชีมาน ปฺระหะกาคเจฺงลางปฺระหะหัสฺตสฺเรจเลงลูกเจากฺนงชาตฺรเหีย (ปฺรายหฺมณ์) กอฺงฺกุยกฺนงทีสมคูว ฯ ลุะปฺรายหฺมณ์นายหะอฺงฺกุยกฺนงทีสมคูวเหีย ปฺระหะชีมานปฺระหะกาคเจฺงมานปหทูลดูเจฺจะถา มฺลาลปฺรายหฺมณ์ อานิสงฺสปหปหวนะมาน ๑๐ ยาองฺ อานิสงฺสปหปหว ๑๐ ยาองนายหะ แตดูจแมฺจ กีบุคฺคลอฺนกเจฺยปหปหว ฌายหะถา เจฺยอายุ ๑ เจฺยพณ์สมฺปฺรว ๑ เจฺยสุจกฺตีสุข ๑ เจฺยกมฺงำง กายะ ๑ เจฺยปฺรชฺญา ๑ ปหปหวเดลบุคฺคลหุตเจากเหีย รเมงหามหยาตฺ สุจกฺตีหฺยาน ๑ ปหนูปหงำงสุจกฺตีสฺเรก ๑ ญฺาำงขฺลฺเจฺยเดีวเจากสฺเรล ๑ ญฺาำงสวสุเจฺยสฺนาต ๑ ญฺาำงอาหาวปฺโชีดีสุสสลฺเจฺยวลูย ๑ มฺลาล ปฺรายหฺมณ์ อานิสงฺสปหปหวมาน ๑๐ ยาองนุะงง ฯ

[๑๑๐] *ชนณาถานเจฺยปหปหวเดายคาวพดลฺพกสมณะ: เดลชาอฺนกสเจฺรม อฺนกปหวิโกคคาวชนเดลอฺนกดเทเจฺยกฺนง กาลดีคูว (ชนนายหะ) ฌายหะถา เจฺยนูวเหตุนิอานิสงฺส ทำง ๑๐ ยาองนุ คีอายุ ๑ พณ์สมฺปฺรว ๑ สุจกฺตีสุข ๑ กมฺงำงกาย ๑ ปฺรชฺญาวปสฺบุคฺคลนายหะ แตงเกีตเจฺลีง ๑ ปหปหวนายหะแตงกมฺาตฺปงำงสุจกฺตีหฺยาน ๑ สุจกฺตีสฺเรก ๑*

និងញ៉ាំងខ្យល់ (ឲ្យបានដើរស្រួល) ๑ ញ៉ាំងសរសៃ ឲ្យស្អាត ๑ ញ៉ាំងកត្តឲ្យរលួយ ๑ ฯ នេះជាភេសជ្ជៈ ដែលព្រះសុគត ទ្រង់សរសើរហើយ ฯ ព្រោះហេតុនោះ អ្នកមានសេចក្តីត្រូវការចង់បានសេចក្តីសុខជារបស់មនុស្ស ក្តី ប្រាថ្នាសេចក្តីសុខជារបស់ទិព្វក្តី ចង់បានសេចក្តីល្អរុងរឿងក្នុងមនុស្សក្តី គួរឲ្យបបរជានិច្ចចុះ ฯ

[๑๑๑] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះព្រាហ្មណ៍នោះដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ฯ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុឆាន់) បបរ និងនំមានរសផ្អែមបាន ฯ

[๑๑๒] ពួកមនុស្សបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតបបរនិងនំមានរសផ្អែមដល់ភិក្ខុទាំងឡាយ (ដូច្នោះ) ហើយ ฯ មនុស្សទាំងនោះក៏នាំគ្នាតាក់តែងបបរភោជ្ជ[1] និងនំមានរសផ្អែម ពីព្រឹកព្រហាម (មកប្រគេនភិក្ខុទាំងឡាយ) ฯ ពួកភិក្ខុបានឆាន់បបរភោជ្ជ និងនំមានរសផ្អែម ឆ្អែតពីព្រឹកព្រហាមហើយ លុះទៅឆាន់ក្នុងរោងភត្តទៀត ក៏មិនបានឆ្ងាញ់ពិសា ฯ សម័យនោះឯង មានមហាមាត្យម្នាក់ ជាអ្នកមានសេចក្តី

๑- បបរដែលគេធ្វើអំពីភោជនទាំង ๕ គឺបាយ ๑ នំស្រស់ ๑ នំក្រៀម ๑ ត្រី ๑ សាច់ ๑ ដែលនាំឲ្យកើតបឋវីរណាតាមសិក្ខាបទទី ๕ នៃភោជនវគ្គ ฯ

*ជ្រះថ្លាថ្មី (មិនទាន់មុតមាំ) បាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទុក ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែគួរអាត្មាអញតាក់តែងចង្ហាន់សាច់ចំនួនមួយពាន់ពីរយហាសិបសម្រាប់ (ឲ្យល្មម) ដល់ភិក្ខុមួយពាន់ពីរយហាសិបរូប ហើយប្រគេនចង្ហាន់សាច់មួយសម្រាប់ៗ ដល់ភិក្ខុមួយរូបៗ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះកន្លងរាត្រីនោះទៅ ក៏បានតាក់តែងខាទនីយភោជនីយៈដ៏ឧត្តម និងចង្ហាន់សាច់មួយពាន់ពីរយហាសិបសម្រាប់ ហើយក៏ប្រើបម្រើឲ្យទៅក្រាបបង្គំទូលពេលឆាន់ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពេលនេះល្មមហើយ ភត្តសម្រេចហើយ ។ គ្រានោះ ពេលព្រឹកព្រហាម ព្រះដ៏មានព្រះភាគទ្រង់សម្ពង់ហើយប្រដាប់ដោយបាត្រ និងចីវរ យាងទៅកាន់ផ្ទះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ មួយអន្ទើដោយភិក្ខុសង្ឃ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ បានអង្គាសពួកភិក្ខុក្នុងភោងភត្ត ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរឲ្យ (ភត្ត) តែបន្តិចចុះ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចបានហើយ ។ មហាមាត្យនិយាយថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយកុំទទួលភត្តបន្តិចបន្តួច ដោយគិតថា មហាមាត្យនេះ មានសេចក្តីជ្រះថ្លាថ្មី ខាទនីយភោជនីយៈ ខ្ញុំបានចាត់ចែងទុកហើយជាច្រើន ទាំងចង្ហាន់សាច់មួយពាន់ពីរយហាសិបសម្រាប់ផង ខ្ញុំនឹងប្រគេនចង្ហាន់សាច់

មួយសម្រាប់ៗ ដល់ភិក្ខុមួយរូបៗ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយទទួលជារាបដល់ឆ្អែត ។ ពួកភិក្ខុនិយាយតបថា ម្នាលអាវុសោ យើងទាំងឡាយទទួលភត្តបន្តិចៗ ព្រោះហេតុប៉ុណ្ណោះក៏ទេ យើងទាំងឡាយឆាន់បបរគ្រាជ្ជ និងនំមានរសផ្អែមឆ្អែតអំពីព្រឹកហួចហើយ ព្រោះហេតុនោះបានជាយើងទទួលភត្តតែបន្តិចៗ ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ខ្ញុំបាននិមន្តលោកម្ចាស់ទាំងឡាយរួចហើយ មិនសមបើនឹងទៅឆាន់បបរគ្រាជ្ជរបស់ជនឯទៀតសោះ (លោកម្ចាស់ខ្លាចក្រែង) ខ្ញុំមិនអាចនឹងប្រគេនឲ្យឆាន់ឆ្អែតបានឬ ។ មហាមាត្យនោះមានសេចក្តីក្រោធ តូចចិត្ត ប្រាថ្នានឹងចោទ កាលជាក់ជាត្រភិក្ខុទាំងឡាយពេញហើយ ក៏ដើរទៅនិយាយថា ពួកលោកណាចង់ឆាន់ក្តីនាំយកទៅក្តី (ក៏តាមចិត្តចុះ) ។ លំដាប់នោះ មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយ ភោជនីយដ៏ឧត្តមដោយដៃនៃខ្លួនឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ (មហាមាត្យ) ក៏អង្គុយក្នុងទីសមគួរ ។ លុះមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ អង្គុយនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ ឯមហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ កាលព្រះដ៏មានព្រះភាគយាងចេញទៅមិនយូរប៉ុន្មាន

ก็เกิดสังเวชและความสลดใจว่า อาตมาภาพเป็นคนมีลาภน้อยหนอ ไม่ได้ลาภของตนเสียแล้วหนอ ทั้งเป็นผู้มีบุญน้อย ก็อาตมาภาพได้ยากจริงๆ ไม่ใช่ว่าอาตมาภาพได้ง่ายๆ (เลย) อาตมาภาพมีจิตใจคับแคบ ไม่ได้ความเลื่อมใสเลย (ในพระผู้มีพระภาค) ครั้นแล้วก็ลุกขึ้นจากที่นั่งแล้วกลับไปยังที่อยู่ของตน (ก็ตามใจท่านเถิด) กรรมที่อาตมาภาพได้สั่งสมไว้มากแล้ว (นี้) เป็นบุญหรือเป็นบาปหนอ ฯ ลำดับนั้นแล มหามาตย์ผู้มีความเลื่อมใสนั้น ก็เข้าไปเฝ้าพระผู้มีพระภาคถึงที่ประทับ ครั้นแล้วก็ถวายบังคมพระผู้มีพระภาค แล้วนั่งในที่สมควร ฯ ครั้นมหามาตย์ผู้มีความเลื่อมใสนั้นนั่งในที่สมควรแล้ว ก็กราบทูลพระผู้มีพระภาคดังนี้ว่า ข้าแต่พระองค์ผู้เจริญ เมื่อครู่นี้ พระผู้มีพระภาคเสด็จไปยังที่ประทับไม่นานนัก ข้าพระองค์ก็มีความสลดใจและสังเวชว่า อาตมาภาพเป็นคนมีลาภน้อยหนอ ไม่ได้ลาภของตนเสียแล้วหนอ ทั้งเป็นผู้มีบุญน้อย ก็อาตมาภาพได้ยากจริงๆ ไม่ใช่ว่าอาตมาภาพได้ง่ายๆ (เลย) อาตมาภาพมีจิตใจคับแคบ ไม่ได้ความเลื่อมใสเลย (ในพระผู้มีพระภาค) ครั้นแล้วก็ลุกขึ้นจากที่นั่งแล้วกลับไปยังที่อยู่ของตน (ก็ตามใจท่านเถิด) กรรมที่อาตมาภาพได้สั่งสมไว้มากแล้ว (นี้) เป็นบุญ หรือเป็นบาปหนอ ขอพระผู้มีพระภาคเจ้าผู้เจริญ กรรมที่ข้าพระองค์ได้สั่งสมไว้มากแล้ว (นี้) เป็นบุญหรือ

បាប ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដែលអ្នកបាននិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ដោយចំណែកណា ចំណែកដែលអ្នក បានសន្សំហើយនោះ ក៏ជាបុណ្យយ៉ាងច្រើន គ្រាប់ចាយមួយគ្រាប់ៗ របស់អ្នកដែលភិក្ខុមួយរូបៗ ទទួលហើយដោយចំណែកណា ចំណែកដែលអ្នកបានសន្សំនោះ ក៏ជាបុណ្យយ៉ាងច្រើនហើយ ឈ្មោះថាអ្នកឯងប្រារព្ធយកហានសួគ៌ហើយ ។ ឯមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្នើរនោះក៏គិតថា ប្រហែលជាលាភរបស់អាត្មាអញហើយ ប្រហែលជាអាត្មាអញបានអត្តភាពជាមនុស្សល្អហើយ ប្រហែលជាអាត្មាអញ បានសន្សំបុណ្យជាច្រើនហើយ ប្រហែលជាឈ្មោះថាអាត្មាអញប្រារព្ធយក ហានសួគ៌ហើយ ក៏មានចិត្តរីករាយស្រស់ស្រាយឡើង ក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណរួចចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយ ត្រាស់សួរចំពោះពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា គេបាននិមន្តពួកភិក្ខុទៅ ក្នុងត្រកូលដទៃហើយ ភិក្ខុទាំងនោះទៅឆាន់បបរកោជ្ជរបស់ត្រកូលឯទៀតវិញ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ បាននិមន្តក្នុងត្រកូលដទៃហើយ មិនសមបើនឹងទៅឆាន់បបរកោជ្ជរបស់ត្រកូលឯទៀតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុ

ทำนองว่าอย่างนี้มาว่า ดูก่อนภิกษุทั้งหลาย ภิกษุรับนิมนต์ ในตระกูลใดแล้ว มิได้ถามถึงความเป็นไปของตระกูลอื่นเลย ภิกษุรูปใดถาม ต้องปรับอาบัติทุกกฏแก่ภิกษุนั้นตามธรรม (คือให้ปลงอาบัติ) ฯ

[๑๑๓] *ครั้งนั้น พระผู้มีพระภาคประทับอยู่ในอันธกวินทประเทศตามสมควรแล้ว เสด็จจาริกไปในกรุงราชคฤห์ พร้อมด้วยภิกษุสงฆ์ประมาณห้าร้อยรูป ฯ สมัยนั้นแล ชีวกโกมารภัจจ์ ได้ฟังข่าวนี้ว่า ได้ยินว่า พระสมณโคดมผู้เจริญ เสด็จจาริกไปในกรุงราชคฤห์ พร้อมด้วยภิกษุสงฆ์ประมาณห้าร้อยรูป ฯ ครั้นได้ฟังแล้ว ได้มีความคิดอย่างนี้ว่า ก็กิตติศัพท์อันงามของพระสมณโคดมนี้ ย่อมฟุ้งขจรไปอย่างนี้ว่า แม้เพราะเหตุนี้ ๆ พระผู้มีพระภาคนั้น เป็นพระอรหันต์ ตรัสรู้ชอบเองโดยชอบ ฯ ก็แต่ว่าเราจักได้เห็นพระอรหันต์ทั้งหลายบ้างหรือหนอ ฯ ลำดับนั้นแล ชีวกโกมารภัจจ์ ได้มีความคิดอย่างนี้ว่า ก็ในเวลานี้ เราไม่ควรเพื่อจะเข้าเฝ้าพระผู้มีพระภาค ด้วยเหตุเพียงเท่านี้ (ด้วยเหตุเพียงได้ฟังข่าวเท่านี้) ก็แต่ว่าเราควรเข้าเฝ้าพระผู้มีพระภาค ในเวลาที่ได้เห็นพระอรหันต์ทั้งหลายบ้างเถิด ฯ ลำดับนั้นแล ชีวกโกมารภัจจ์ ได้ฟังข่าวว่า ได้ยินว่า พระผู้มีพระภาคนั้น ประทับอยู่ในอันธกวินทประเทศตามสมควรแล้ว

បានយកកម្មស្ការអំពៅមកហើយ បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ការអំពៅដល់ភិក្ខុទាំងឡាយចុះ ។ វេលាដែកច្ចានទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយប្រគេនស្ការអំពៅដល់ភិក្ខុទាំងឡាយ រួចក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានប្រគេនស្ការអំពៅដល់ពួកភិក្ខុរួចហើយ ឥឡូវស្ការអំពៅនេះនៅសល់ជាច្រើន បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះអ្នកឯងចូរប្រគេនស្ការអំពៅដល់ពួកភិក្ខុជរាបជល់អស់ចំណង់ចុះ ។ វេលាដែកច្ចានទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយបានប្រគេនស្ការអំពៅដល់ពួកភិក្ខុ ជរាបជល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានប្រគេនស្ការអំពៅដល់ពួកភិក្ខុជរាបដល់អស់ចំណង់ហើយ តែស្ការអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យពួកភិក្ខុឆាន់ឆ្អែតស្កប់ស្កល់ ដោយស្ការអំពៅទាំងឡាយចុះ ។ វេលាដែកច្ចានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះ-ករុណាព្រះអង្គ ហើយបានញុំងពួកភិក្ខុឲ្យឆ្អែតស្កប់ស្កល់ដោយស្ការអំពៅទាំងឡាយ ។ ភិក្ខុពួកខ្លះ ជាក់ពេញជាត្រេកើមាន វេចនីងសំពត់តម្រងទឹកក៏មាន ជាក់ពេញចង់យាមក៏មាន ។ លុះវេលាដែកច្ចានបានឲ្យពួកភិក្ខុឆាន់ឆ្អែតស្កប់

ស្គាល់ដោយស្គរអំពៅទាំងឡាយ ហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យពួកកិកូធាន់ឆ្អែតស្គប់ស្គាល់ ដោយស្គរអំពៅទាំងឡាយហើយ តែថា ស្គរអំពៅនេះក៏នៅសល់ច្រើន បពិត្រ ព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្គរអំពៅដល់ពួកមនុស្សអ្នកស៊ី ដែលផងចុះ ។ វេលាដែកច្ចានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះ ករុណាព្រះអង្គហើយ ឲ្យស្គរអំពៅដល់ពួកមនុស្សអ្នកស៊ីដែល រួចក្រាបបង្គំ ទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យស្គរ អំពៅដល់ពួកមនុស្សអ្នកស៊ីដែលហើយ តែថាស្គរអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យស្គរអំពៅដល់ពួកមនុស្សអ្នក ស៊ីដែលជរាបដល់អស់ចំណង់ចុះ ។ វេលាដែកច្ចានបានទទួលព្រះបន្ទូលព្រះដ៏ មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យស្គរអំពៅដល់ពួកមនុស្សអ្នក ស៊ីដែលជរាបដល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យស្គរអំពៅដល់ពួកមនុស្សអ្នកស៊ី ដែលជរាបដល់អស់ចំណង់ហើយ តែថាស្គរអំពៅនេះ ក៏នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្គប់ ស្គាល់ដោយស្គរអំពៅទាំងឡាយចុះ ។ វេលាដែកច្ចានបានទទួលព្រះបន្ទូលព្រះ

ដ៏មានព្រះភាគ ដោយពាក្យថា ព្រះកុរុណាព្រះអង្គ ហើយឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅទាំងឡាយ ។ ពួកមនុស្សអ្នកស៊ីដែលខ្វះ ជាក់ពេញក្រឡក៏មាន ជាក់ពេញក្អមក៏មាន រោចនឹងសំពត់កម្រាលក៏មាន ជាក់ពេញថ្នក់ក៏មាន ។ លំដាប់នោះ វេលាដ្ឋកថ្ងានបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅទាំងឡាយ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ដោយស្ករអំពៅទាំងឡាយហើយ តែថាស្ករអំពៅនេះនៅសល់ច្រើន បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកថ្ងាន ក្នុងលោកព្រមទាំងទេវតា ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេព និងមនុស្ស តថាគតមិនដែលឃើញអ្នកណាមួយ ឆាន់ស្ករអំពៅហើយស្ករអំពៅនោះរលួយទៅដោយស្រួលទេ លៀរលែងតែតថាគតឬសាវកបស់តថាគតប៉ុណ្ណោះ ម្នាលកថ្ងាន បើដូច្នោះ ចូរអ្នកឯងចោលស្ករអំពៅនោះទៅក្នុងទីដែលគ្មានស្មៅស្រស់ ឬចាក់ចោលទៅក្នុងទឹកដែលគ្មានសត្វក៏បាន ។ វេលាដ្ឋកថ្ងានបានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះកុរុណាព្រះអង្គ ហើយចាក់ចោលស្ករអំពៅ នោះទៅក្នុងទឹកដែលគ្មានសត្វ ។ ឯស្ករអំពៅដែលវេលាដ្ឋកថ្ងានដាក់ចុះទៅក្នុង ទឹកនោះក៏លាន់ឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាស គួរនាដូចជាផាលនង្គ័លនៅហាលថ្ងៃអស់មួយថ្ងៃហើយ បុគ្គលដាក់ចុះទៅក្នុងទឹក រមែងឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយ

ផ្សែងឡើងដេរដាសយ៉ាងណាមិញ ស្តេរអំពៅនោះដែលបុគ្គលដាក់ចុះទៅក្នុងទឹកហើយ រមែងឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាសដូច្នោះដែរ ។ លំដាប់នោះឯង វេលដ្ឋកច្ចាន មានសេចក្តីស្តុតចិត្តកើតព្រឺព្រួចអស់ទាំងរោម ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ ។ លុះវេលដ្ឋកច្ចានអង្គុយនៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សម្តែងអនុបុព្វីកថា គឺទ្រង់ប្រកាសអំពីទាន ១ អំពីសីល ១ អំពីស្ថានសួគ៌ ១ អំពីទោសដ៏លាមកសៅហ្មងរបស់កាមទាំងឡាយ ១ និងអានិសង្សក្នុងការចេញចាកកាម ១ ។ វេលាណាព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា វេលដ្ឋកច្ចានមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តស្រស់ស្រាយឡើង មានចិត្តជ្រះថ្លា វេលានោះ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងប្រកាសចំពោះព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គ-សច្ច ។ គួរនាដូចជាសំពត់សស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អ យ៉ាងណាមិញ ឯវេលដ្ឋកច្ចានក៏បានកើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកគ្រឿងសៅហ្មង លើអាសនៈនោះឯង ដូច្នេះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះក៏តែងរលត់ទៅវិញជាធម្មតា យ៉ាងនោះដែរ ។ គ្រាដែលវេលដ្ឋកច្ចានបានឃើញសច្ចធម៌ហើយ បានដល់ សច្ចធម៌ហើយ បានដឹងច្បាស់សច្ចធម៌ហើយ បានយាងចុះកាន់សច្ចធម៌ហើយ បានឆ្លងវិចិកិច្ឆា កម្ចាត់បង់នូវសេចក្តី

ងឿងឆ្ងល់ដល់នូវភាវៈជាអ្នកក្បៀវក្បា មិនជឿបុគ្គលជនៃក្នុងសាសនានៃព្រះ-
សាស្តា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏
ចម្រើន កាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន កាសិត
របស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន គួរនាដូចជាមនុស្សចាប់
របស់ដែលគេផ្តាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់
ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេង ឬ
ក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យមនុស្សដែល
មានភ្នែកភ្លឺមើលឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលព្រះដ៏មាន
ព្រះភាគទ្រង់ប្រកាសហើយ ដោយអនេកបរិយាយក៏យ៉ាងនោះដែរ បពិត្រ
ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង
ព្រះសង្ឃផងថាជាទីពឹង ទីរលឹក សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំថា ជា
ឧបាសកអ្នកដល់ (នូវព្រះរតនត្រ័យ) ថាជាទីពឹង ស្មើដោយជីវិតតាំងអំពី
ថ្ងៃនេះជាដើមទៅ ។

[๑๑๔] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ចារិកតាម
លំដាប់ បានដល់ទៅក្រុងរាជគ្រឹះនោះ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុង
វត្តវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះ ។ សម័យនោះឯង ស្តរ
អំពៅកើតឡើងជាច្រើនក្នុងក្រុងរាជគ្រឹះ ។ ពួកភិក្ខុក៏រង្កៀសថា ស្តរអំពៅ
ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតចំពោះតែភិក្ខុមានជំងឺប៉ុណ្ណោះ មិនបានទ្រង់
អនុញ្ញាតដល់ភិក្ខុគ្មានជំងឺឡើយ ក៏មិនហ៊ានឆាន់ស្តរអំពៅ ។ ពួកភិក្ខុក្រាប

បង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្ករអំពៅដល់ភិក្ខុមានជំងឺ (អនុញ្ញាត) ទឹកស្ករអំពៅដល់ភិក្ខុគ្មានជំងឺ ។

[๑๑๕] លំដាប់នោះ ព្រះមានព្រះភាគទ្រង់គង់ក្នុងក្រុងរាជគ្រឹះតាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបយាងចេញទៅកាន់ចារិកនៃបាដលិ-គ្រាម មួយអន្ទើដោយភិក្ខុសង្ឃច្រើនប្រមាណមួយពាន់ពីរយហាសិបរូប ។ គ្រាកាលព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅបាដលិគ្រាមនោះ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់យាងមកដល់បាដលិគ្រាមហើយ ។ គ្រានោះ ពួកឧបាសកនៅក្នុងបាដលិគ្រាម បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះពួកឧបាសកអ្នកនៅក្នុងបាដលិគ្រាម អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ពួកឧបាសកអ្នកនៅក្នុងបាដលិ-គ្រាម លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលយកភេសជ្ជៈសំណាក់របស់យើងខ្ញុំទាំងឡាយ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយការៈស្ងៀម ។ លំដាប់នោះ ពួកឧបាសកអ្នកនៅក្នុងបាដលិ-

គ្រាម បានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏នាំគ្នាក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅកាន់ភេងសំណាក់ លុះចូលទៅដល់ហើយ ក៏បានក្រាលភេងសំណាក់ដោយគ្រឿងកម្រាលសព្វគ្រប់ហើយ ក៏តែងតាំងអាសនៈទាំងឡាយ និងតម្កល់ក្អមទឹក តែងតាំងប្រទីបប្រេង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ ពួកឧបាសក អ្នកនៅក្នុងជាដលិគ្រាម បានឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឯភេងសំណាក់យើងខ្ញុំបានក្រាលកម្រាលសព្វគ្រប់ហើយ អាសនៈទាំងឡាយយើងខ្ញុំបានតែងតាំងស្រេចហើយ ក្អមទឹកយើងខ្ញុំបានតម្កល់ទុកហើយ ប្រទីបប្រេងយើងខ្ញុំបានតែងតាំងស្រេចហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្គាល់កាលដ៏គួរនឹងនិមន្តទៅក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ហើយ ប្រដាប់ដោយបាត្រ និងចីវរ យាងទៅកាន់ភេងសំណាក់ជាមួយនឹងភិក្ខុសង្ឃ លុះយាងទៅដល់ហើយ ទ្រង់លាងព្រះបាទទាំងគូហើយ ក៏យាងចូលទៅកាន់ភេងសំណាក់ ទ្រង់គង់ផ្អែកនឹងសសរកណ្តាល បែរព្រះភក្ត្រទៅទិសខាងកើត ។ ពួកភិក្ខុក៏បានលាងជើង ហើយចូលទៅកាន់ភេងសំណាក់ដែរ ហើយអង្គុយផ្ចាប់នឹងជញ្ជាំងទិសខាងលិច បែរមុខទៅទិសខាងកើត ឈមមុខត្រង់ទៅរកព្រះដ៏មានព្រះភាគ ។ ចំណែកពួកឧបាសកអ្នកនៅក្នុងជាដលិគ្រាម ក៏បានលាងជើងហើយនាំគ្នាចូលទៅកាន់

ភេងសំណាក់ ហើយអង្គុយផ្ទាប់នឹងជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច ឈមមុខត្រង់ ទៅរកព្រះដ៏មានព្រះភាគដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកឧបាសកអ្នកនៅក្នុងបាដលិគ្រាមមក ហើយទ្រង់ត្រាស់ថា ។

[๑๑๖] ម្នាលគហបតីទាំងឡាយ ទោសទាំង ๕ ប្រការនេះ ជាទោសនៃបុគ្គលទ្រុស្តសីល[๑] ឬវិបត្តិចាកសីល ។ ទោសទាំង ๕ ប្រការនោះ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលក្នុងលោកនេះ តែងបាននូវសេចក្តីវិនាសនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ ។ នេះជាទោសទី ๑ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្ត-សីល ឬវិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទអាក្រក់ ឮខ្ចរខ្ចាយទៅ ។ នេះជាទោសទី ๒ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណបរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏គ្មានភ្លៀវក្លា មានតែមុខឱនចុះ ហើយដើរចូលទៅ ។ នេះជាទោសទី ๓ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ វេលាទៀបស្លាប់តែង

๑- ក្នុងតតិយសារត្តទីបនីដីកា តតិយសមន្ត អធិប្បាយពីរយ៉ាង គឺបុគ្គលមិនបានសមាទានសីល ឬសមាទានសីលហើយ ធ្វើសីលឲ្យដាច់ទៅវិញ ។

วาเจ๋งฆ์สฺวาราตี ฯ นេះជាទោសទី ๔ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ฯ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ លុះរំលាងខន្ធ បន្ទាប់អំពីមរណៈ រមែងទៅកាន់អបាយ[๑] (តិរច្ឆាន) ទុគ្គតិ[๒] (ប្រេត) វិនិបាត[๓] (អសុរកាយ) និរយ (នរក) ฯ នេះជាទោសទី ๕ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ฯ ម្នាលគហបតីទាំងឡាយ ទោសទាំង ๕ ប្រការនេះឯង ជាទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ฯ

[๑๑๗] ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ๕ ប្រការនេះ ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល ฯ អានិសង្សទាំង ๕ ប្រការនោះ តើដូចម្តេចខ្លះ ฯ ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ឬបរិបូណ៌ដោយសីល ក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ ฯ នេះជាអានិសង្សទី ๑ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល ฯ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះ ឮខ្ចរខ្ចាយទៅ ฯ នេះជាអានិសង្សទី ๒ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល ฯ ម្នាលគហបតីទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជា

๑- ប្រទេសប្រាសចាកសេចក្តីសុខ ฯ ๒- ទីគឺបណ្តិតគប្បីខ្ពើម ฯ ๔- អសុរកាយដែលមានមហិទ្ធិវិប្ផូរដូចភាពអរិនទូជាដើម ฯ

ขตฺติยปริสฺวาปิ ชาปริสฺวาปิ พฺราหฺมณปริสฺวาปิ คหปติปริสฺวาปิ สมณปริสฺวาปิ ก็เกรงกลัวมิอิดหนาบ้างเลย คือว่า มิกระด้างกระเดื่องเลย แล้วเข้าไป ฯ นี้เป็นอานิสงส์ที่ ๓ แห่งบุคคลมีศีล ถึงพร้อมด้วยศีล ฯ ดูกรคหบดีทั้งหลาย อีกประการหนึ่ง บุคคลมีศีล ถึงพร้อมด้วยศีลแล้ว ย่อมไม่หลงทำกาลกิริยา ฯ นี้เป็นอานิสงส์ที่ ๔ แห่งบุคคลมีศีล ถึงพร้อมด้วยศีล ฯ ดูกรคหบดีทั้งหลาย อีกประการหนึ่ง บุคคลมีศีล ถึงพร้อมด้วยศีลแล้ว ย่อมทำกาลกิริยา ไม่หลงจากมนุษย์โลกนี้ ไปสู่เทวโลก ฯ นี้เป็นอานิสงส์ที่ ๕ แห่งบุคคลมีศีล ถึงพร้อมด้วยศีล ฯ ดูกรคหบดีทั้งหลาย อานิสงส์ ๕ ประการนี้แล เป็นอานิสงส์แห่งบุคคลมีศีล ถึงพร้อมด้วยศีล ฯ

[๑๑๘] *ครั้งนั้น พระผู้มีพระภาคทรงชี้แจงให้อุบาสกทั้งหลายในกรุงชาวลิให้เห็นแจ้ง ให้ชาวลิยกขึ้นสู่ความดี ให้ชื่นชมยินดี ให้ร่าเริงด้วยธรรมีกถา ตลอดราตรีเป็นอันมาก แล้วทรงพระดำรัสกับพระผู้มีพระภาคว่า ดูกรคหบดีทั้งหลาย ราตรี (ปฐมยาม) ล่วงไปแล้ว พวกท่านจงกระทำกาลอันสมควรในบัดนี้เถิด ฯ อุบาสกทั้งหลายในกรุงชาวลิทูลรับพระดำรัสพระผู้มีพระภาคว่า ดูกรท่านผู้เจริญ ดีละ แล้วลุกจากที่นั่งถวายอภิวาทพระผู้มีพระภาค กระทำประทักษิณแล้วหลีกไป ฯ ครั้งนั้น อุบาสกทั้งหลายในกรุงชาวลิ-*

គ្រាម ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះអង្គក៏ទ្រង់យាងចូលទៅកាន់សុញ្ញាគារដ្ឋាន (គឺផ្ទះស្ងាត់) ។

[๑๑๙] សម័យនោះឯង មហាមាត្យនៅក្នុងដែនមគធឈ្មោះសុនីធៈ ๑ វស្សការៈ ๑ នាំគ្នាកសាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារពួកវជ្ជីត្រកូលដែលនៅក្នុងដែនវជ្ជី ។ ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ទតដោយទិព្វចក្ខុដ៏ស្អាត កន្លងលើសចក្ខុរបស់មនុស្ស បានឃើញពួកទេវតាជាច្រើន កំពុងគយគន់មើលទីកន្លែងសង់ផ្ទះក្នុងបាដលិគ្រាម ។ ទេវតាមានសក្តិធំ គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យដែលមានសក្តិធំទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាល គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យ ដែលមានសក្តិជាកណ្តាលទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅ ក្នុងប្រទេសនោះដែរ ទេវតាមានសក្តិទាបគយគន់មើលទីកន្លែងសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យដែលមានសក្តិទាបទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់សួរថា ម្នាលអានន្ទ ជនពួកណាហ្ន៎ គេសាងក្រុងក្នុងបាដលិគ្រាម ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មហាមាត្យក្នុងដែនមគធៈឈ្មោះសុនីធៈ និងវស្សការៈ សាងក្រុងក្នុងបាដលិគ្រាមដើម្បីនឹងការពារនូវ

ពួកវាជត្រកូល ដែលនៅក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះ សុនីធៈ និងវស្សការៈ បានប្រឹក្សាគ្នានឹងពួកទេវតាក្នុងស្ថានតាវត្តិង្ស[1] ថា យ៉ាងណាមិញ ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះ សុនីធៈនិងវស្សការៈ សាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារនូវពួកវាជត្រកូលក្នុងដែនវជ្ជីយ៉ាងនោះដែរ ម្នាលអានន្ទ តថាគតក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ក្នុងសុញ្ញាគារដ្ឋាន (ផ្ទះស្ងាត់) នេះហើយមើលដោយទិព្វចក្ខុដ៏ស្អាត កន្លងលើសចក្ខុរបស់មនុស្ស បានឃើញពួកទេវតាជាច្រើន កំពុងគយគន់មើលទីកន្លែងសង់ផ្ទះក្នុងបាដលិគ្រាម ។ ពួកទេវតាមាន សក្តិធំគយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យដែលមានសក្តិធំ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាលគយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យដែលមានសក្តិជាកណ្តាលក៏បង្អោនទៅ ដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិទាបគយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យដែលមានសក្តិទាប ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ម្នាលអានន្ទ ទីប្រជុំរបស់អរិយបុគ្គលទាំងឡាយដែលមានទាំងអម្បាលម៉ាន និងផ្លូវជំនួញដែលមានទាំងអម្បាលម៉ាន បាដ-

---

๑- អដ្ឋកថា និងដីកាថា ពួកមហាមាត្រដែលសាងក្រុងក្នុងបាដលិគ្រាម ក៏ហាក់ដូចជាបានទៅប្រឹក្សាគ្នានឹងទេវតាក្នុងស្ថានតាវត្តិង្ស ។

លិបុត្តនេះ ក៏ជាក្រុងប្រសើរជាងទីប្រជុំព្រះអរិយបុគ្គល និងផ្លូវជំនួញអម្បាលនោះ ម៉្យាងទៀត ជាកន្លែងបែកធ្លាយ ឬរបូតបង្ខូចទ្រព្យ ម្នាលអានន្ទ ក្រុងបាដលិបុត្រ មុខជានឹងមានសេចក្តីអន្តរាយ ៣ យ៉ាង គឺអន្តរាយអំពីភ្លើង ១ អន្តរាយអំពីទឹក ១ អន្តរាយអំពីហេតុខាងក្នុង គឺបែកចាកគ្នានឹងគ្នា ១ ។

[១២០] គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ (នាំគ្នា) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរជាទីរីករាយ និងពាក្យគួរជាទីរលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ទើបឋិតនៅក្នុងទីសមគួរ ។ លុះមហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលពាក្យដូច្នេះនឹងព្រះដ៏មានព្រះភាគថា សូមព្រះគោតមដ៏ចម្រើន ទទួលភត្តរបស់ខ្ញុំព្រះអង្គទាំងឡាយដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្ទៅដោយភិក្ខុសង្ឃ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយការៈស្ងៀម ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈ និងវស្សការៈដ៏ឯថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកទីអង្គុយ ហើយដើរចេញទៅ ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម (រួចហើយ) ចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលដ៏គួរដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាល (នេះជាកាលគួរហើយ)

ภตฺตกึ์สเมฺรจเหีย ฯ คฺราเนาะ ฺระเมานฺระกาคเรฺงสฺบเรฺงเหียปฺรเดาะ เดายเยาตฺราตฺรเนิงจีวร กฺนุงเวฬาฺรึก เยางจูลเตากาล่ำเนาะเมหามาตฺย เนา กฺนุงเดฺรนมคธะ:เฌฺงาะสุนีธะ: นิงวาสฺการ: ลุะเยางจูลเตาเดฬ่เหีย กึ์ คงฺเลีอาสน:เดฺรลเคเรฺบจำเจฺวาย ชามูยนึงภิกฺขุสงฺฆ ฯ คฺราเนาะ เมหามาตฺยเนาะกฺนุงเดฺรนมคธะ:เฌฺงาะสุนีธะ: นิงวาสฺการ: กึ์องฺคาสภิกฺขุสงฺฆ เมานฺระพุทฺธชาปฺรธาน เดายขาทนียเภาชนียาหาร ชึ์ฉาญ่เพิสาเดาย เดฺรเนฺรขฺญน คฺราเตาะภิกฺขุสงฺฆเหามยาต่ ลุะกำณต่ชึงถา ฺระเมานฺระกาคเรฺง เสาะยฺรูจเหีย ชากฺ่ระหสฺตจุะจากตฺราเหีย กึ์องฺคุยเนาะกฺนุงทีชึ์สม คูร ฯ ลุะเมหามาตฺยเนาะกฺนุงเดฺรนมคธะ:เฌฺงาะสุนีธะ: นิงวาสฺการ: องฺคุย เนาะกฺนุงทีชึ์สมคูรเหีย เทีบฺระเมานฺระกาคเรฺงอนุโมทนาเดายฺระคาถา ทำงฺลายเนะถา

> [๑๒๑] มนุสฺสชาบณฺฑิตชาติ ฺรเมงสเมฺรจนูวาเรเน กฺนุงปฺรเทสณาเหีย กึ์เตงเงฺยพุกบุคฺคลอฺกมานสีล เดฺรลสเฺรมลฺม ปฺรเพฺรึตฺตธมฺชึ์ปฺรเสีร เงฺยบริโภคกฺนุง เลำเนาะเรบสฺ่ญน เหียจานทำงอุทิสผลทกฺขิณาทาน (เงฺย จำณกบุณฺย) ชล่พุกเทวาดาเดฺรลเนาะกฺนุงปฺรเทสเนาะ (เถมเตาะ) ฯ เทวาดาทำงเนาะเตงบูชาจำพาะมนุสฺส เดฺรลจานบูชาชลฺ่ญน เตงภาบ่อานจำพาะมนุสฺส เดฺรล ภาบ่อานชลฺ่ญน เตงอนุเคฺราะมนุสฺสเนาะ ชูจชามาตา

អនុគ្រោះបុត្រ ដែលខ្លួនបីថ្នមផ្ចាប់នឹងទ្រូងឲ្យចម្រើនឡើង ។ មនុស្សដែលទេវតាបានអនុគ្រោះហើយ ក៏តែងឃើញនូវសេចក្តីចម្រើនសព្វកាលៗ ។

[១២២] លំដាប់នោះ ព្រះមានព្រះភាគទ្រង់អនុមោទនាដោយព្រះគាថាទាំងឡាយនេះ ចំពោះមហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ (ចប់ហើយ) ក៏ទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។ សម័យនោះឯង មហាមាត្យនៅក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈ ដើរតាមព្រះមានព្រះភាគអំពីក្រោយៗ ដោយគិតថា ក្នុងថ្ងៃនេះព្រះសមណគោតមនឹងយាងចេញទៅតាមទ្វារណា ទ្វារនោះនឹងបានឈ្មោះថា គោតមទ្វារ នឹងឆ្លងស្ទឹងគង្គា តាមកំពង់ណា កំពង់នោះនឹងបានឈ្មោះថា គោតមតិត្ថ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងចេញតាមទ្វារណា ទ្វារនោះក៏ឈ្មោះថា គោតមទ្វារជាប្រាកដ (ដល់សព្វថ្ងៃនេះ) ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ស្ទឹងគង្គា ។ ស្ទឹងគង្គាមានទឹកពេញប្រៀបត្រឹមស្មើនឹងមាត់ច្រាំង ល្មមសត្វក្អែកផឹកបាន ។ មនុស្សពួកខ្លះរកទូក មនុស្សពួកខ្លះរកផែ មនុស្សពួកខ្លះចងក្បួន ប្រាថ្នានឹងឆ្លងអំពីត្រើយខាងអាយទៅកាន់ត្រើយខាងនាយ ។ ព្រះដ៏មានព្រះភាគទ្រង់បានឃើញមនុស្សទាំងនោះ គឺមនុស្សពួកខ្លះកំពុងរកទូក មនុស្សពួកខ្លះកំពុងរកផែ មនុស្សពួកខ្លះកំពុងចងក្បួន ប្រាថ្នានឹងឆ្លងអំពីត្រើយខាងអាយទៅត្រើយខាងនាយ លុះព្រះដ៏មានព្រះភាគទ្រង់ឃើញហើយ ក៏និម្មិតព្រះអង្គជាត់ (មួយរំពេច) អំពីត្រើយខាងអាយនៃ

ស្ទឹងគង្គា ទៅប្រាកដនៅត្រើយខាងនាយជាមួយនឹងភិក្ខុសង្ឃ គួរនាដូចជាបុរសមានកម្លាំងលាចេញនូវដើមដៃដែលបត់ចូល ឬបត់ចូលនូវដើមដៃដែលលាចេញ ឆាប់រហ័សដូច្នោះឯង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្តីនោះហើយ ទើបបន្ទឺឡើងនូវឧទានគាថានេះ ក្នុងវេលានោះថា

> *ពួកជនណាឆ្លងស្ទឹងគឺតណ្ហា ដ៏ជ្រៅធ្លាយទូលាយបាន (ពួកជននោះឯង) តែងធ្វើស្ពាន គឺអរិយមគ្គ មិនឲ្យប៉ះពាល់ទីជាទំនាបទាំងឡាយហើយឆ្លងបាន សេចក្តីពិតថា ជនធម្មតា (ដែលប្រាថ្នានឹងឆ្លងទឹកបន្តិចបន្តួច) តែងចងក្បួន (ទើបឆ្លងទៅបាន) ឯជនជាអ្នកប្រាជ្ញទាំងឡាយ គឺព្រះពុទ្ធ និងសាវកបស់ព្រះពុទ្ធលោកបានឆ្លងរួចស្រេចហើយ ។*

[๑๒๓] *គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់កោដិគ្រាម[๑] ។ បានឮថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកោដិគ្រាមនោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងកោដិគ្រាមនោះមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅនិងត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ๔ អរិយសច្ចទាំង ๔ ដូចម្តេចខ្លះ ម្នាលភិក្ខុទាំង-*

๑- *ក្នុងតតិយសារត្តទីបនីដីកាតតិយសមន្ត ពន្យល់សេចក្តីថា កោដិគ្រាមនោះនៅត្រង់កន្លែងកំពូលប្រាសាទនៃស្តេចបហាបនាទដែលលិចចុះទៅក្នុងផែនដី (មើលមង្គលត្ថទីបនីក្នុងតតិយ-គាថាសិប្បកថា) ។*

ឡាយ តថាគត និងអ្នកទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយ នេះដូច្នេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ច នូវទុក្ខសមុទយ អរិយសច្ច ។បេ។ នូវទុក្ខនិរោធអរិយសច្ច ។បេ។ តថាគត និងអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយនេះដូច្នេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបាន ត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា តថាគតនិងអ្នកទាំងឡាយដកឡើងហើយ ខៀរ គឺ តណ្ហាសម្រាប់ដឹកនាំទៅក្នុងភពក៏អស់ហើយ ឥឡូវនេះគ្មានភពថ្មីទៀតទេ ។

[១២៤] ការអន្ទោលទៅកាន់ផ្លូវឆ្ងាយក្នុងជាតិទាំងឡាយនោះៗ ឯង ព្រោះមិនបានឃើញនូវអរិយសច្ចទាំង ៤ ជាធម៌ពិត ។ អរិយសច្ចទាំង ៤ នេះឯង តថាគត និងអ្នកទាំងឡាយបានឃើញហើយ តណ្ហាជាអ្នកដឹកនាំទៅកាន់ភពក៏តថាគត និងអ្នកទាំងឡាយគាស់រំលើងហើយ ឫសនៃសេចក្តីទុក្ខ ក៏តថាគត និងអ្នករាល់គ្នាផ្តាច់ចោលហើយ ឥឡូវនេះគ្មានភពថ្មីទៀតទេ ។

[១២៥] នាងអម្ពបាលីជាស្រីផ្កាមាសបានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរមកកាន់កោដិគ្រាម ។ លំដាប់នោះឯង នាងអម្ពបាលីជាស្រីផ្កាមាស បានប្រើគេឲ្យទឹមយានដ៏ថ្លៃថ្លាហើយ ក៏ឡើងជិះយានដ៏ថ្លៃថ្លាចេញទៅអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លាទាំងអម្បាលនោះ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ហើយដាក់យានទុកក្នុងទីមួយ រួចចុះអំពីយានដើរទៅដោយជើងទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងអម្ពបាលីជាស្រីផ្កាមាស ដែលអង្គុយក្នុងទីសមគួរ (នោះ) ឯង ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរដោយធម្មីកថា ។ លំដាប់នោះ នាងអម្ពបាលីជាស្រីផ្កាមាស លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរដោយធម្មីកថាហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្ទើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់បានទទួលនិមន្តន៍ដោយតុណ្ហីភាព ។ គ្រានោះ នាងអម្ពបាលីជាស្រីផ្កាមាស ដឹងថាព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ទើបក្រោកចាកទីអង្គុយថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ពួកស្តេចលិច្ឆវីក្រុងវេសាលីបានឮដំណឹងថា ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរមកដល់កោដិ-គ្រាម ។ ពួកស្តេចលិច្ឆវីក្រុងវេសាលី ក៏ឲ្យពួកសារថីទឹមយានដ៏ថ្លៃថ្លា ហើយ

ទ្បើងគង់លើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ទៅដោយយានដ៏ថ្លៃថ្លាទាំងអម្បាលនោះ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ។ ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ខៀវ មានសម្បុរខៀវ(១) ទ្រង់ព្រះពស្ត្រខៀវ(២) មានគ្រឿងតែងខ្លួនក៏ខៀវ(៣) ស្តេចលិច្ឆវីពួកខ្លះ លាបពណ៌លឿង មានសម្បុរលឿង ទ្រង់ព្រះពស្ត្រលឿង មានគ្រឿងតែងខ្លួនក៏លឿង ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ក្រហម មានសម្បុរក្រហម ទ្រង់ព្រះពស្ត្រក្រហម មានគ្រឿងតែងខ្លួន ក៏ក្រហម ស្តេចលិច្ឆវីពួកខ្លះលាបពណ៌ស មានសម្បុរស ទ្រង់ព្រះពស្ត្រស មានគ្រឿងតែងខ្លួនក៏ស ។ លំដាប់នោះ នាងអម្ពបាលីជាស្រីផ្កាមាស ប្រជល់ចន្ទោលដោយចន្ទោល បំប៉ះនឹមដោយនឹម បំប៉ះកង់ដោយកង់ បំប៉ះក្ដៅដោយក្ដៅ (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះៗ ។ គ្រានោះ ពួកស្តេចលិច្ឆវីទាំងនោះ និយាយនឹងនាងអម្ពបាលីជាស្រីផ្កាមាសថា ម្នាលមេអម្ពបាលី ព្រោះហេតុអ្វី បានជានាងមកប្រជល់ចន្ទោលដោយចន្ទោល បំប៉ះនឹមដោយនឹម បំប៉ះកង់ដោយកង់ បំប៉ះក្ដៅដោយក្ដៅ (នៃយាន) របស់យើងជាស្តេចលិច្ឆវីកំលោះៗ ។ នាងអម្ពបាលីតបថា បពិត្រអយ្យបុត្ត(៤) ទាំងឡាយ ព្រោះថា ខ្ញុំបាននិមន្តកិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ស្តេចលិច្ឆវីទាំងអម្បាលនោះ មានព្រះបន្ទូលថា ម្នាលមេអម្ពបាលី ចូរនាងឲ្យកត្តនេះមកយើងចុះ (យើងនឹងឲ្យតម្លៃនាង)ចំនួន ១ សែន កហាបណៈ

១-២-៣- ក្នុងតតិយសារត្តទីបនីដីកាតតិយសមន្តថា សូម្បីរាជវេ-ទង់-សេះ-ដងជន្លួញ ក៏សឹងប្រដាប់ដោយមាស និងកែវមានសម្បុរខៀវទាំងអស់ ទាំងលឿង-ក្រហម-ស ក៏ដូចគ្នា ។

៤- អយ្យបុត្ត គឺព្រះអង្គម្ចាស់ ។

នាងអម្ពបាលីតបថា បពិត្រ អយ្យបុត្ត ទុកជាព្រះអង្គប្រទានក្រុងវេសាលី ព្រមទាំងសួយសារអាករ ដែលមាននៅក្នុងជនបទមកខ្ញុំ ខ្ញុំក៏មិនព្រមថ្វាយ កត្តនោះឡើយ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ទះម្រាមព្រះហស្តហើយ ពោលថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន យើងចាញ់មាតុគ្រាមហើយ ម្នាលគ្នាយើងដ៏ចម្រើន យើងចាញ់មាតុគ្រាមហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ (ក៏នាំគ្នា) ចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះ កំពុងយាងមកអំពីចម្ងាយ លុះឃើញហើយ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាដែលមិនធ្លាប់ឃើញទេវតាក្នុងហានតាវត្តិង្សទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមិលមើលពួកលិច្ឆវីបរិសទ្យចុះ អ្នកទាំងឡាយចូរមិលមើលពួកលិច្ឆវីបរិសទ្យរឿយៗចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរប្រៀបធៀបពួកលិច្ឆវីបរិសទ្យ ទៅនឹងពួកទេវតាក្នុងជាន់តាវត្តិង្ស មើលចុះ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ក៏ជាក់យានទុកក្នុងទីមួយ ហើយចុះអំពីយានដើរទៅដោយជើងទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកស្តេចលិច្ឆវីដែលអង្គុយក្នុងទីសមគួរនោះឯង ឲ្យឃល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថា ។ ឯស្តេចលិច្ឆវីទាំងនោះដែលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ ឲ្យឃល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថា

ហើយ ក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលភត្តពួកខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគតបានទទួលភត្តរបស់នាងអម្ពបាលី ជាស្រីផ្កាមាសក្នុងថ្ងៃស្អែករួចទៅហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះទម្រាមព្រះហស្តហើយ ពោលថា ម្នាលគ្នាយើងដ៏ចម្រើន យើងចាញ់មាតុគ្រាមហើយ ម្នាលគ្នាយើងដ៏ចម្រើន យើងចាញ់មាតុគ្រាមហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ត្រេកអរវីរភាយតាមភាសិតរបស់ព្រះដ៏មានព្រះភាគហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងកោដិគ្រាមគួរតាមព្រះអធ្យាស្រ័យហើយ យាងទៅកាន់នាទិកាប្រទេស ។ ព្រះអង្គទ្រង់គង់នៅក្នុងរោងឥដ្ឋក្នុងនាទិកាប្រទេសនោះឯង ។ លុះព្រលឹមឡើង នាងអម្ពបាលីជាស្រីផ្កាមាសក៏តាក់តែងខាទនីយភោជនីយាហារ (បង្អែមចម្អាប) ក្នុងអារាម (ផ្ទះ) របស់ខ្លួន ហើយចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលគួរដល់ព្រះដ៏មានព្រះភាគថា ពេលគួរហើយព្រះអង្គ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រលឹម យាងតម្រង់ទៅកាន់ទីអង្គាស (ចង្ហាន់) របស់នាងអម្ពបាលីជាស្រីផ្កាមាស លុះយាងទៅដល់ហើយទើប គង់លើអាសនៈដែលគេក្រាលថ្វាយ ព្រមទាំងភិក្ខុសង្ឃ ។ គ្រានោះ នាងអម្ពបាលីជាស្រីផ្កាមាស អង្គាសថ្វាយខាទនីយភោជនីយាហារ (បង្អែមចម្អាប) ដ៏ឆ្ងាញ់

ពីសាដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ត្រាតែព្រះដ៏មានព្រះភាគទ្រង់ឈប់ទទួលសោយ ស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ទើប (នាង) អង្គុយនៅក្នុងទីសមគួរ ។ កាលបើនាងអម្ពបាលីជាស្រីផ្កាមាស អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយនូវអម្ពបាលិវនេះ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនូវអារាម (នោះ) ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងអម្ពបាលីជាស្រីផ្កាមាសឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យត្រេកអរ ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈយាងទៅកាន់ព្រៃមហាវន ។ បានឮថា ព្រះមានព្រះភាគ គង់នៅក្នុងកូដាគារសាលានាមហាវន ជិតក្រុងវេសាលីនោះឯង ។

ภาณวารที่ ๑๐ จบ

[๑๒๖] សម័យនោះឯង ពួកស្តេចលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ[๑] ពោលសរសើរគុណព្រះធម៌[๒] ពោលសរសើរគុណ

๑- ក្នុងដីកាពន្យល់សេចក្តីថា ពោលសរសើរគុណដោយចរិយា ๓ គឺញាតត្ថចរិយា ๑ លោកត្ថចរិយា ๑ ពុទ្ធត្ថចរិយា ๑ ។ ๒- ពោលសរសើរធម្មគុណដោយចំណែកនិកាយ ๕ បិដក ๓ នវង្គសត្ថុសាសនៈ ๙ ធម្មក្ខន្ធ ๘๔๐๐๐ ។

ព្រះសង្ឃ[๑] ដោយបរិយាយជាច្រើន ។ សម័យនោះ សីហសេនាបតិជាសាវកនិគ្រន្ថក៏អង្គុយនៅក្នុងកណ្តាលបរិសទ្យនោះដែរ ។ ទើបសីហសេនាបតិត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធ ប្រាកដឥតសង្ស័យឡើយ ព្រោះហេតុនោះពួកស្តេចលិច្ឆវីទាំងនេះ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលក្បៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន បើដូច្នោះមានតែអាត្មាអញចូលទៅជើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ (ល្អងមើល) ។ លំដាប់នោះ សីហសេនាបតិចូលសំដៅទៅត្រង់ទីដែលនិគន្ថនាដបុត្រនៅ លុះចូលទៅដល់ហើយ ក៏សំពះនិគន្ថនាដបុត្រ ហើយអង្គុយនៅក្នុងទីសមគួរ ។ លុះសីហសេនាបតិអង្គុយនៅក្នុងទីសមគួរហើយ ទើបនិយាយទៅនឹងនិគន្ថនាដបុត្រថា បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅឃើញព្រះសមណគោតម (ម្តងមើល) ។ និគន្ថនាដបុត្រពោលថា នែអ្នកសីហៈ អ្នកឯងជាអ្នកនិយាយចំពោះកិច្ចការថាត្រូវធ្វើ នឹងចូលទៅមើលសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើដូចម្តេចបាន ម្នាលអ្នកសីហៈ ព្រោះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើ

๑- ពោលសរសើរសង្ឃគុណដោយអំណាចបព្វជ្ជាថា កទ្ធិយរាជ មហាកប្បិនរាជ បុក្កុសយសកុលបុត្ត សោណសេដ្ឋីបុត្ត រដ្ឋបាលកុលបុត្ត (លោកទាំងអម្បាលម៉ាននេះជាដើម) ស្តាប់ធម៌ហើយបានទទួលសទ្ធា លះស្ទេត្រតត្រារាជសម្បត្តិ លះទីសេនាបតី ទីជាសេដ្ឋី ទីជានាយហ្វូងចេញបួសក្នុងសាសនារបស់ព្រះសាស្តា ។

สម្តែងធម៌ហាមកិច្ចការថាមិនត្រូវធ្វើ និងទូន្មានសាវកទាំងឡាយដោយពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើនោះដែរ ។ ឯការរៀបចំដំណើរបស់សីហសេនាបតិដើម្បីនឹងទៅឃើញ ព្រះដ៏មានព្រះភាគ (នុ៎ះ) ក៏អាក់ខានទៅ ។ ពួកស្តេចលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន អស់វារៈជាគម្រប់ពីរដងផង ។បេ។ អស់វារៈជាគម្រប់បីដងផង ។ ឯសីហសេនាបតិក៏មានសេចក្តីត្រិះរិះក្នុងវារៈជាគម្រប់បីដងថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធ ប្រាកដឥតសង្ស័យឡើយ ព្រោះហេតុនោះហើយ បានជាពួកស្តេចលិច្ឆវីទាំងនេះ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន និគ្រន្ថទាំង (នេះ) ទោះអញលាក្តី មិនលាក្តី នឹងធ្វើអ្វីអញ បើដូច្នោះ អាត្មាអញមិនបាច់លានិគ្រន្ថទាំង (នេះ) ទេ គួរតែចូលទៅឃើញព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះតែម្តង ។ លំដាប់នោះ សីហសេនាបតិចេញទៅអំពីក្រុង វេសាលីដោយរថ ៥០០ ក្នុងវេលាថ្ងៃ ដើម្បីនឹងឃើញព្រះដ៏មានព្រះភាគ ហើយជាក់យានទុកក្នុងទីសមគួរ ទើបចុះអំពីយានដើរទៅដោយជើងទេ ចូលតម្រង់ទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះ

ภาค ទើបអង្គុយក្នុងទីសមគួរ ฯ លុះសីហាសេនាបតិអង្គុយក្នុងទីសមគួរ ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណគោតមជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ សម្តែងធម៌ហាមកិច្ចការថាមិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឱ្យាយដោយពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើដូច្នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន គេទាំងឱ្យាយតែងពោលយ៉ាងនេះថា ព្រះសមណគោតម ជាអ្នកពោលឃាត់កិច្ចការថាមិនត្រូវធ្វើ សម្តែងធម៌ហាមកិច្ចការថាមិនត្រូវធ្វើ ទាំងទូន្មានសាវក ទាំងឱ្យាយដោយពោលពាក្យឃាត់កិច្ចការថាមិនត្រូវធ្វើដូច្នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន គេទាំងនោះពោលត្រង់តាមពាក្យរបស់ព្រះអង្គ មិនមែនពោលបង្កាច់ព្រះអង្គដោយពាក្យមិនពិតទេឬ ដ្បិតព្រះអង្គតែងពោលជាក់ច្បាស់នូវធម៌សមគួរដល់ធម៌ ប្រសិនបើមានសហធម្មិកណាមួយ បាននិយាយត្រូវតាមព្រះពុទ្ធដីកាដែលព្រះអង្គបានពោល (នោះ) ក៏មិនបានដល់នូវហេតុតំណិះដំណៀលឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះហើយ បានជាយើងខ្ញុំព្រះអង្គមិនចង់ពោលបង្កាច់ព្រះដ៏មានព្រះភាគ ฯ

[๑๒๗] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសីហៈ មានហេតុជាទំនង គួរឱ្យអ្នកផងថា ចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ សម្តែងធម៌ហាមកិច្ចការថាមិនត្រូវធ្វើ ទាំងទូន្មានសាវក ទាំងឱ្យាយដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ ฯ ម្នាលសីហៈ មានហេតុជាទំនងគួរឱ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណ-

គោតមជាអ្នកពោលថា ត្រូវធ្វើកិច្ចការ សម្តែងធម៌ថា ត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិលទេតើ សម្តែងធម៌ដើម្បីកាត់ផ្តាច់ផ្តិលទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិលនោះដែរ ដែលថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណាគោតមជាអ្នកខ្ពើមរអើម សម្តែងធម៌ដើម្បីខ្ពើមរអើមទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា គួរខ្ពើមរអើមនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណាគោតមជាអ្នកបំផ្លាញទេតើ សម្តែងធម៌ដើម្បីបំផ្លាញទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវបំផ្លាញនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណាគោតមជាអ្នកជុតកម្តៅទេតើ សម្តែងធម៌ដើម្បីជុតកម្តៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវជុតកម្តៅនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណាគោតមជាមនុស្សត្រឥតកំណើត សម្តែងធម៌ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយដោយពាក្យមិនមានកំណើតនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណាគោតមជាអ្នកទំនុកបម្រុង សម្តែងធម៌ដើម្បី

ទំនុកបម្រុង ទាំងទូន្មានសាវកទាំងឮ្យដោយពាក្យថា ឲ្យទំនុកបម្រុងនោះដែរ ដែលគេថានោះត្រូវហើយ ฯ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលពាក្យថា មិនត្រូវធ្វើ សម្តែងធម៌ហាមថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឮ្យដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ម្នាលសីហៈ ដ្បិតតថាគតពោលថា មិនត្រូវធ្វើចំពោះតែកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងពោលឃាត់កិច្ចការថា មិនត្រូវធ្វើចំពោះតែអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលឃាត់កិច្ចការថាមិនត្រូវធ្វើ សម្តែងធម៌ហាមថាមិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឮ្យដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ ฯ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលថា ត្រូវធ្វើ សម្តែងធម៌ថាត្រូវធ្វើ ទាំងទូន្មានសាវកទាំងឮ្យដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ฯ ម្នាលសីហៈ ដ្បិតតថាគតពោលថា ត្រូវធ្វើចំពោះតែកាយសុចរិត វចីសុចរិត មនោសុចរិត និងពោលថា ត្រូវធ្វើចំពោះតែកុសលធម៌ដែលមានប្រយោជន៍ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលថា ត្រូវធ្វើ សម្តែងធម៌ថាត្រូវធ្វើ ទាំងទូន្មានសាវកទាំងឮ្យដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះត្រូវហើយ ฯ ម្នាលសីហៈ ទំនង

ដែលគួរឲ្យអ្នកផងថា ព្រះសមណគោតមជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល សម្តែងធម៌ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិល ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ជ្បិតតថាគតពោលថា ត្រូវកាត់ផ្តាច់ផ្តិលរាគៈ ទោសៈ មោហៈ និងពោលថា ត្រូវកាត់ផ្តាច់ផ្តិលនោះ ចំពោះតែអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល សម្តែងធម៌ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិល ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម សម្តែងធម៌ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវខ្ពើមរអើមនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតខ្ពើមចំពោះតែកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងខ្ពើមចំពោះសេចក្តីប្រកបចិត្ត ផ្តេកផ្តិតទៅរកអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម សម្តែងធម៌ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយដោយការខ្ពើមរអើមនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកបំផ្ងាញ សម្តែងធម៌ដើម្បីបំផ្ងាញ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវបំផ្ងាញនោះដែរ ដែលគេថា

នោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ និងសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិបំផ្លាញបង់ នូវអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកបំផ្លាញ សម្តែងធម៌ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវបំផ្លាញនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថា ចំពោះតថាគតថា ព្រះសមណគោតមជាអ្នកជុតកម្តៅ សម្តែងធម៌ដើម្បីជុតកម្តៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថាត្រូវជុតកម្តៅនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតពោលថា កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ ម្នាលសីហៈ អកុសលធម៌ដ៏អាក្រក់ទាំងឡាយដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) បើអ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្រៃបែលគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបកាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកជុតកម្តៅ ម្នាលសីហៈ អកុសលធម៌ដ៏អាក្រក់ទាំងឡាយដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) តថាគតឯងបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យ

អស់រលើង ដូចដើមត្នោតដែលគេក្រៃលែគាស់រំលើង ឲ្យលែងដុះតទៅទៀត ហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមាន កំណើតតទៅខាងមុខហើយ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យ អ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកជុតកម្តៅ សម្តែងធម៌ ដើម្បីជុតកម្តៅ ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ត្រូវជុតកម្តៅនោះ ដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថា ចំពោះតថាគតថា ព្រះសមណគោតមជាអ្នកអត់កំណើត សម្តែងធម៌ដើម្បី មិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា មិនឲ្យមាន កំណើតនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅខាងមុខទៀត បើ អ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុ សម្រាប់កើតទៀតឲ្យអស់រលើង ដូចដើមត្នោតដែលគេ ក្រៃលែគល់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលសីហៈ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុង ភពតទៅខាងមុខទៀត តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់ អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលើង ដូចដើមត្នោតដែល គេក្រៃលែ គាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមាន បែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀត

ហើយ ម្នាលសីហៈ ទំនងនេះឯងហើយដែលគួរឲ្យអ្នកផងថាចំពោះតថាគត ថា ព្រះសមណគោតមជាអ្នកឥតកំណើត សម្តែងធម៌ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យមិនឲ្យមានកំណើតនោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកទំនុកបម្រុងពួក សម្តែងធម៌ដើម្បីទំនុកបម្រុង ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ឲ្យទំនុកបម្រុងនោះដែរ ដែលគេថានោះត្រូវហើយ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះតថាគតជាអ្នកទំនុកបម្រុងពួក សម្តែងធម៌ដើម្បីទំនុកបម្រុង ដោយសេចក្តីទំនុកបម្រុងដ៏ឧត្តម[1] ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ឲ្យទំនុកបម្រុងនោះដែរ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតមជាអ្នកទំនុកបម្រុង សម្តែងធម៌ដើម្បីទំនុកបម្រុង ទាំងទូន្មានសាវកទាំងឡាយដោយពាក្យថា ឲ្យទំនុកបម្រុងនោះដែរ ដែលគេថានោះត្រូវហើយ ។

[๑๒๘] កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សីហសេនាបតិក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន កាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ គួរនាដូចជាមនុស្សចាប់បើករបស់ដែលគេ

๑- ក្នុងដីកាថា ទំនុកបម្រុងដើម្បីឲ្យបានសម្រេចមគ្គ ๔ និងផល ๔ ។

ផ្តាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជាមនុស្សអ្នកប្រាប់ផ្លូវដល់អ្នកវង្វេង ឬក៏ដូចជាមនុស្សកាន់ប្រទីបប្រេងទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានភ្នែក មើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងថា ជាទីរលឹក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់ហើយនូវព្រះរតនត្រ័យថាជាទីរលឹកស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកឯងចូរធ្វើនូវការគិតសញ្ជឹងមើលសិន ឯការគិតសញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយដូចអ្នកឯង (នេះ) ។ សីហសេនាបតិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រេកអរពេកពេញជាច្រើនលើសជាងប្រមាណតាមព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនេះ ដ្បិតព្រះមានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតសញ្ជឹងមើលសិន ឯការគិតសញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចម្រើន តិរ្ថិយដទៃទាំងឡាយបានខ្ញុំព្រះអង្គជាសាវកមុខជាគេនាំគ្នាលើកទង់ជុំវិញក្រុងវេសាលីទាំងអស់ រួច (គេប្រកាសសេចក្តី) ថា យើងទាំងឡាយបានសីហសេនាបតិមកជាសាវកហើយ ក៏ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ)

ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីរលឹក ជាគម្រប់ពីរដង សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់ព្រះរតនត្រ័យជាទីរលឹក ស្មើដោយជីវិតតាំងអំពីថ្ងៃនេះទៅ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ ត្រកូលរបស់អ្នកជាអណ្តូង បម្រុងពួកនិគ្រន្ថជាយូរណាស់មកហើយ អ្នកសម្គាល់ថា បានអ្នកណានឹងឲ្យបិណ្ឌបាតដល់តិរ្ថិយដែលចូលមកនោះ ។ សីហសេនាបតិក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រេកអរក្រៃពេកយ៉ាងច្រើនលើសប្រមាណ តាមពុទ្ធដីការបស់ព្រះដ៏មានព្រះភាគនេះ ដ្បិតព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ត្រកូលរបស់អ្នកជាអណ្តូង បម្រុងពួកនិគ្រន្ថជាយូរណាស់មកហើយ អ្នកសម្គាល់ថា បានអ្នកណានឹងឲ្យបិណ្ឌបាតដល់និគ្រន្ថដែលចូលមកនោះវិញ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គស្តាប់បានហើយថា ព្រះសមណគោតមទ្រង់ត្រាស់នឹងខ្ញុំយ៉ាងនេះថា អ្នកត្រូវឲ្យទានដល់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកនិគ្រន្ថដទៃទេ អ្នកត្រូវឲ្យទានដល់សាវករបស់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាវករបស់ពួកនិគ្រន្ថដទៃទេ ទានដែលអ្នកឲ្យហើយដល់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយដល់ពួកនិគ្រន្ថដទៃ ជាទានមិនមានផលច្រើនទេ ទានដែលអ្នកឲ្យហើយដល់ពួកសាវករបស់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយដល់ពួកសាវករបស់និគ្រន្ថដទៃ

ជាទានមិនមានផលច្រើនទេ ក៏ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគបបួលខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគ្រន្ថ (វិញ) បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែខ្ញុំព្រះអង្គដឹងកាលដ៏សមគួរក្នុងការឲ្យទាននេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីរលឹកជាគម្រប់បីដង សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់ព្រះរតនត្រ័យថាជាទីរលឹក ស្មើដោយជីវិតតាំងអំពីនេះទៅ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់សម្តែងអនុបុព្វីកថាដល់សីហសេនាបតិ គឺ សម្តែងនូវទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញបួស ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សីហសេនាបតិមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយ មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ក្នុងកាលនោះ ព្រះអង្គក៏សម្តែងនូវធម្មទេសនាដែលព្រះពុទ្ធទាំងឡាយតែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺ (សម្តែង) ទុក្ខ ទុក្ខសមុទយ និរោធ មគ្គ ។ ធម្មតាសំពត់សស្អាតមិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អបាន យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សីហសេនាបតិ ក្នុងទីអង្គុយនោះឯងថា ធម្មជាតណាមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះតែងរលត់ទៅវិញជាធម្មតា ក៏មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ សីហសេនាបតិបានឃើញធម៌ហើយ បានដល់ធម៌ហើយ បានត្រាស់ដឹងធម៌ហើយ

ឈមចុះកាន់ធម៌ស៊ប់ហើយ កន្ធងផុតសេចក្តីសង្ស័យហើយ កាត់បង់នូវសេចក្តីងឿងឆ្ងល់ ជាអ្នកដល់នូវសេចក្តីក្លាហាន លែងជឿស្តាប់បុគ្គលដទៃក្នុងសាសនារបស់ព្រះសាស្តា ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ គ្រានោះ សីហសេនាបតិដឹងថាព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយ ដើរចេញទៅ ។ ទើបសីហសេនាបតិបង្គាប់បុរសម្នាក់ថា នែនាយ អ្នកឯងចូរទៅរកសាច់សត្វស្រាប់ស្រាប់មក ។ លុះកន្ធងរាត្រីយប់នោះហើយ ទើបសីហសេនាបតិតាក់តែងខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ហើយចាត់បម្រើឲ្យទៅក្រាបទូលនូវភត្តកាលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន (កាលនេះ) ជាកាលសមគួរហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះ ក្នុងបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយទ្រង់បាត្រចីវរយាងទៅកាន់ផ្ទះសីហសេនាបតិ លុះចូលទៅដល់ហើយគង់លើអាសនៈ ដែលគេក្រាលបម្រុងទុក ព្រមទាំងភិក្ខុសង្ឃ ។ សម័យនោះឯង និគ្រន្ថទាំងឡាយច្រើន (នាំគ្នានៅ) គ្រប់ច្រក នៅគ្រប់ផ្លូវត្រឡែងកែងក្នុងក្រុងវេសាលី ហើយផ្គងដៃឡើងកន្ទក់កន្ទេញថា ថ្ងៃនេះសីហសេនាបតិសម្លាប់សត្វចិញ្ចឹមដ៏ធាត់ៗ ធ្វើភត្តបម្រុងសមណគោតម សមណគោតមដឹងថា សាច់គេធ្វើចំពោះខ្លួន ក៏នៅតែធាន់សាច់នោះដែរ ។ គ្រា

นោះ មានបុរសម្នាក់ចូល ទៅរកសីហសេនាបតិ លុះចូលទៅដល់ហើយ និយាយនឹងសីហសេនាបតិថា បពិត្រលោកដ៏ចម្រើន សូមលោកជ្រាបចុះ ពួកនិគ្រន្ថទាំងអម្បាលនេះជាច្រើន (នាំគ្នានៅ) គ្រប់ច្រក នៅគ្រប់ផ្លូវត្រឡែងកែងក្នុងក្រុងវេសាលី ហើយផ្គងដៃឡើងកន្ទក់កន្ទេញថា ថ្ងៃនេះ សីហសេនាបតិសម្លាប់សត្វចិញ្ចឹមដ៏ធាត់ៗ ធ្វើកត្តបម្រុងសមណគោតម សមណគោតមដឹងថាសាច់គេធ្វើចំពោះខ្លួនហើយ ក៏នៅតែឆាន់សាច់នោះដែរ ។ សីហសេនាបតិនិយាយថា ម្នាលអ្នក ចូរកុំនិយាយឡើយ លោកដ៏មានអាយុទាំងអម្បាលនោះប្រាថ្នានឹងពោលទោសព្រះពុទ្ធ ប្រាថ្នានឹងពោលទោសព្រះធម៌ ប្រាថ្នានឹងពោលទោសព្រះសង្ឃ អស់កាលជាយូរមកហើយ លោកដ៏មានអាយុទាំងអម្បាលនោះ ពោលបង្កាច់ព្រះដ៏មានព្រះភាគនោះដោយរបស់ដែលមិនមាន ដោយការទទេ ដោយពាក្យមុសាវាទ ដោយពាក្យមិនពិត មិនអស់មិនហើយឡើយ ក៏ឯការពិត (នោះ) យើងមិនក្លែងផ្តាច់បង់ជីវិតសត្វព្រោះហេតុជីវិត (របស់ខ្លួន) ទេ ។ គ្រានោះ សីហសេនាបតិអង្គាសកិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយដ៏ផ្ចិតផ្ចង់ គ្រាតែព្រះដ៏មានព្រះភាគទ្រង់ឈប់ទទួលសោយជាស្រេច ជាក់ព្រះហស្តអំពីបាត្រ ទើបអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់សីហសេនាបតិដែលអង្គុយហើយក្នុងទីសមគួរ ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈយាងចេញទៅ ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើ

ធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទ្រង់ (បញ្ញត្ត) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដឹងថា សាច់គេធ្វើចំពោះ (ខ្លួន) កុំគប្បីបរិភោគ ភិក្ខុណាបរិភោគ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រីនិងសាច់ ដែលបរិសុទ្ធដោយបំផុត ៣ យ៉ាង គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។

[๑๒๙] សម័យនោះឯង ក្រុងវេសាលីមានជាយបរិបូណ៌ មានសន្ទឹងល្អ មានបិណ្ឌបាតបានស្រួលងាយនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានដោយការស្វែងរក និងការព្យាយាម ។ គ្រានោះ ព្រះមានព្រះភាគទ្រង់យាងទៅកាន់ទីស្ងាត់ សម្ងំនៅក្នុងព្រះកម្មដ្ឋាន ទើបទ្រង់ត្រិះរិះដោយព្រះទ័យយ៉ាងនេះថា ខាទនីយភោជនីយៈទាំងឡាយណាដែលតថាគតបានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយក្នុងកាលដែលស្រុកមានអំណត់ មានសន្ទឹងមិនល្អ មានបិណ្ឌបាតបានដោយលំបាក គឺខាទនីយភោជនីយៈដែលទុកជាក់ខាងក្នុង (អកប្បិយកុដិ) ចម្អិនខាងក្នុង (អកប្បិយកុដិ) ភិក្ខុចម្អិនដោយខ្លួនឯង ភិក្ខុទទួលរបស់ជាឧគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត វត្តនៅក្នុងព្រៃ វត្តនៅក្នុងស្រុះ ក៏ក្នុងថ្ងៃនេះ ភិក្ខុទាំងឡាយនៅបរិភោគភត្តទាំងនោះឬ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគចេញអំពីការសម្ងំ នៅក្នុងព្រះកម្មដ្ឋានក្នុងវេលារសៀលហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ទ្រង់ (សួរ) ថា ម្នាលអានន្ទ ខាទនីយភោជនីយៈទាំងឡាយណាដែលតថាគតបានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ក្នុងកាល

*มานอำณาต์ มานสนฺถงมินลฺ มานบิณฺฑปาตปานเดายลำปาก คือขาทนียโภชนียะไดลทุกชาก์ขางกฺน นิงจมฺนินขางกฺน (อกปฺปิยกุฎิ) ภิกฺขุจมฺนเดายขฺนงง ภิกฺขุทฺลุวบส์ชาอุคฺคหิตไดลเคนำมกอำพีทีโนะ ไดล ภิกฺขุทฺลุปเคนกฺนเวลามุนภตฺต วตฺนีกฺนไพร วตฺนีกฺนสฺระ ก็กฺนโถ่ นีะ เตภิกฺขุทำงฺปายนีบริโภคภตฺตทำงโนะหฺอ ฯ พฺระอานนฺทูกราบบงฺคุลถา บพิตฺรพฺระดิ์มานพฺระภาค ภิกฺขุทำงฺปายนีบริโภคนีเพฺรีย ฯ เพฺราะนิทานนีะ ดำเณีรนีะ เทีบพฺระดิ์มานพฺระภาคทฺรง์เถฺงีนูวธมฺมีกถา ตฺราสฺ์เหาภิกฺขุทำงฺปายมก เหีายทฺรง์บญฺญตฺถา มฺนาลภิกฺขุทำงฺปาย ขาทนียโภชนียะทำงฺปายณา ไดลตถาคตอนุญฺญาตเหีายดล์ภิกฺขุทำงฺปายกฺนกาลมานอำณาต์ มานสนฺถงมินลฺ มานบิณฺฑปาตปานเดายลำปาก คือ ขาทนียโภชนียไดลทุกชาก์ขางกฺน นิง จมฺนินขางกฺน (อกปฺปิยกุฎิ) ภิกฺขุจมฺนขฺนงง ภิกฺขุทฺลุวบส์ชาอุคฺคหิตไดลเคนำมก อำพีทีโนะ ไดลภิกฺขุทฺลุปเคนกฺนเวลามุนภตฺต วตฺนีกฺนไพร วตฺนีกฺนสฺระ ผลฺวนีะ ตถาคตหามขาทนียโภชนียทำงโนะตำงพีโถ่นีะเท มฺนาลภิกฺขุทำงฺปาย ภิกฺขุกุ่มปฺปีบริโภคนูวขาทนียโภชนียชาอนฺโตวุตฺถ (ทุกชาก์ขางกฺนอกปฺปิยกุฎิ) อนฺโตปกฺข (จมฺนินขางกฺนอกปฺปิยกุฎิ) สามปกฺข (ภิกฺขุเฉฺนขฺนงง) อุคฺคหิตปฺปฏิคฺคหิต (กาน์ชามุนเหีายเทีบเคปเคน) เบีภิกฺขุณาบริโภค ตฺรูวอาบตฺติทุกฺกฏ ฯ มฺนาลภิกฺขุทำงฺปาย มฺย์างเทีต ภิกฺขุธาน์รูจเหีาย หามกตฺเหีาย กุ่มปฺปีธาน์อนติริตฺตโภชน

(ភោជនថ្នាង) គឺខាទនីយភោជនីយដែលទាយកនាំមកអំពីទីនោះ ភិក្ខុទទួលក្នុងវេលាមុនភត្ត វត្តដែលតាំងនៅក្នុងព្រៃ វត្តដែលតាំងនៅក្នុងស្រះ បើភិក្ខុណាបរិភោគ វិនយធរត្រូវកាត់សេចក្តីតាមអាបត្តិ ។

[๑๓๐] សម័យនោះឯង ពួកមនុស្សអ្នកជនបទផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះ ច្រើនមុខក្នុងរនេះទាំងឡាយ ហើយបង្វិលរនេះមកឈប់នៅក្បែរខ្វោងទ្វារខាងក្រៅអារាម ដោយប៉ងថា យើងទាំងឡាយនឹងបាននូវលំដាប់ (ទីកន្លែង) ក្នុងកាលណា យើងនឹងធ្វើភត្ត (ថ្វាយសង្ឃ) ក្នុងកាលនោះ ។ (ជួនពេលនោះ) មហាមេឃក៏ទូទឹមឡើង ។ គ្រានោះ ពួកមនុស្សទាំងអម្បាលនោះ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅជល់ហើយ ទើបទូលព្រះអានន្ទដ៏មានអាយុ ដោយពាក្យដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន មនុស្សអ្នកនៅក្នុងជនបទផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះ ច្រើនមុខក្នុងរនេះទាំងឡាយ ហើយមកឈប់នៅក្បែរខ្វោងទ្វារនេះ ជួនពេលនោះ មហាមេឃក៏ទូទឹមឡើង បពិត្រព្រះអានន្ទដ៏ចម្រើន មនុស្សអ្នកនៅក្នុងជនបទទាំងនោះ គួរប្រតិបត្តិដូចម្តេចទៅ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ណ្ហើយចុះ បើសង្ឃប្រាថ្នានៅទីណា គឺជាវិហារក្តី អឌ្ឍយោគក្តី ប្រាសាទក្តី ប្រាសាទត្រងិលក្តី គុហាក្តី ដែលនៅចុងក្រោយគេ សង្ឃចូរសន្មត (នូវទីនោះ) ឲ្យជាកប្បិយភូមិ ហើយឲ្យអ្នកជនបទទាំងនោះនៅក្នុងទីនោះចុះ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ គឺភិក្ខុ

ជាអ្នកឆ្ងាសប្រតិពលគប្បីប្តឹងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិ ។ ការសន្មតិវិហារឈ្មោះនេះឲ្យជាកប្បិយភូមិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីនិយាយឡើង ។ សង្ឃបានសន្មតវិហារឈ្មោះនេះឲ្យជាកប្បិយភូមិហើយ ។ ការសន្មតិនេះសមគួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ សម័យនោះឯង មនុស្សទាំងឡាយ ជាំបបរ ជាំបាយ ស្ងសម្ល ចិញ្ច្រាំសាច់ ពុះអុស ធ្វើសំឡេងគឹកកងក្នុងកប្បិយភូមិដែលសង្ឃសន្មតឲ្យនោះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់តើនឡើងក្នុងវេលាបច្ចូសសម័យនៃរាត្រីបានឮសំឡេងគឹកកងខ្ទាំងខ្ទៀវខ្ទារ[1] លុះឮហើយ ទើបទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកសួរថា ម្នាលអានន្ទ សំឡេងគឹកកងខ្ទាំងខ្ទៀវខ្ទារនោះ តើជាសំឡេងអ្វី ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ មនុស្សទាំងឡាយជាំបបរជាំបាយស្ងសម្លចិញ្ច្រាំសាច់ពុះអុស ក្នុងកប្បិយភូមិ ដែលសង្ឃសន្មតនោះឯង បពិត្រព្រះដ៏មានព្រះភាគ សំឡេងគឹកកងខ្ទាំងខ្ទៀវខ្ទារនោះ ជាសំឡេងនុ៎ះឯង ។ ព្រោះនិទាននេះ ដំណើរ

๑- *សំឡេងដូចស្លែកកន្ធៀវ* ។

นេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំង-ឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរប្រើប្រាស់នូវកប្បិយ-ភូមិដែលសង្ឃសន្មតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិបីយ៉ាង គឺឧស្សាវនន្តិកា ១ គោនិ-សាទិកា ១ គហបតិកា[1] ១ ។ សម័យនោះឯង យសោជកភិក្ខុដ៏មានអាយុ មានជំងឺ ។ មនុស្សទាំងឡាយនាំកេសជ្ជៈដើម្បីប្រយោជន៍ដល់លោកនោះ ។ ភិក្ខុទាំងឡាយទុកជាក់កេសជ្ជៈទាំងនោះខាងក្រៅ (លំនៅ) ។ សត្វតូចៗ (មានកណ្តុរ) ជាដើមទំពាស៊ីខ្លះ ពួកចោរលួចយកទៅខ្លះ ។ ភិក្ខុទាំង-ឡាយក្រាបបង្គំទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយប្រើប្រាស់នូវកប្បិយ-ភូមិដែលសង្ឃសន្មតឲ្យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិ ៤ យ៉ាង គឺឧស្សាវនន្តិកា ១ គោនិសាទិកា ១ គហបតិកា ១ សម្មតិកា[2] ១ ។

[๑๓๑] សម័យនោះឯង មេណ្ឌកគហបតិនៅអាស្រ័យក្នុងក្រុងកទ្ទិយៈ ។ សេដ្ឋីនោះមានឥទ្ធានុភាពខាងឯកក់ជម្រះនូវសីសៈ (ក្បាល) រួចប្រើគេឲ្យបោសជង្រែកស្រូវ ហើយទើបអង្គុយខាងក្រៅទ្វារ ។ ធារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាសពេញទាំងជង្រែក ។ ឯភរិយា (របស់សេដ្ឋី

๑- សូមមើលអដ្ឋកថាខាងក្រោម ។ ๒- កុដិដែលសង្ឃប្រកាសដោយញត្តិទុតិយកម្ម សន្មតឲ្យជាកប្បិយកុដិ ហៅថា សម្មតិកា ។

นោះ) มានឥទ្ធានុភាពខាងឯចូលទៅអង្គុយជិតថាសមួយ មានចំណុះមួយអាឍ្ឍក[๑] និងថាសមួយសម្រាប់ជាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវបុរសជាទាសកម្មករដោយកត្ត ។ បើសេដ្ឋីកិរិយាមិនទាន់ក្រោកទ្បើង កត្តនោះក៏មិនចេះអស់ទៅ ។ កូនប្រុស (របស់សេដ្ឋីនោះ) មានឥទ្ធានុភាពខាងឯកាន់យកថង់មានចំណុះមួយពាន់ (កហាបណៈ) ហើយឲ្យរង្វាន់ដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ ។ បើថង់នៅតែក្នុងដៃរបស់សេដ្ឋីបុត្រនោះ ជរាបណា រង្វាន់នោះ ក៏មិនចេះអស់ទៅជរាបនោះ ។ កូនប្រសាស្រី (របស់សេដ្ឋីនោះ) មានឥទ្ធានុភាពខាងឯមុខការចូលទៅអង្គុយជិតកញ្ចើមួយ មានចំណុះ ๔ ទោណ[๒] ហើយឲ្យកត្តដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ ។ បើកូនប្រសាស្រីរបស់សេដ្ឋីនោះ មិនទាន់ក្រោកទ្បើងជរាបណា កត្តនោះក៏មិនចេះអស់ទៅជរាបនោះ ។ ខ្ញុំប្រុស (របស់សេដ្ឋីនោះ) មានឥទ្ធានុភាពខាងឯមុខការភ្ជួរស្រែដោយនង្គ័លតែមួយ មានអាចម៍បំណះប្រាំពីរបែកចេញទៅ ។ ព្រះបាទមាគធសេនិយពិម្ពិសារបានឮដំណឹងថា មេណ្ឌកគហបតិនៅក្នុងក្រុងកទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) ថា មានឥទ្ធានុភាពខាងឯកក់ជម្រះនូវសីសៈ រួចប្រើគេឲ្យបោសជង្រែកស្រូវ ហើយទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ធ្លាក់ចុះមកពីអាកាសពេញទាំងជង្រែកបាន កិរិយារបស់សេដ្ឋីនោះ មានឥទ្ធានុភាពខាងឯចូលទៅអង្គុយជិតថាសមួយមានចំណុះមួយអាឍ្ឍក និងថាសមួយសម្រាប់ជាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវបុរសជាទាសកម្មករ

๑- បួននាលិជាមួយអាឍ្ឍក ។ ๒- បួនអាឍ្ឍកជាមួយទោណ គឺ ๑๖ នាឡិ ។

ដោយកត្តុ បើសេដ្ឋីភរិយានោះមិនទាន់ក្រោកឡើងដរាបណា កត្តុនោះក៏មិនចេះអស់ទៅដរាបនោះ កូនប្រុសរបស់សេដ្ឋីនោះ មានឥទ្ធានុភាពខាងឯការនយកថង់ មានចំណុះមួយពាន់កហាបណៈ ហើយឲ្យរង្វាន់ដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ បើថង់នោះនៅតែក្នុងដៃរបស់សេដ្ឋីបុត្រនោះដរាបណារង្វាន់នោះ ក៏មិនចេះអស់ទៅដរាបនោះ កូនប្រសាស្រីរបស់សេដ្ឋីនោះមានឥទ្ធានុភាពខាងឯចូលទៅអង្គុយជិតកញ្ចើមួយមានចំណុះ ๔ ទោណ ហើយឲ្យកត្តុដល់បុរសជាទាសកម្មករអស់ប្រាំមួយខែ បើកូនប្រសាស្រីសេដ្ឋីនោះមិនទាន់ក្រោកឡើងដរាបណា កត្តុនោះក៏មិនចេះអស់ទៅដរាបនោះ ខ្ញុំប្រុសរបស់សេដ្ឋីនោះមានឥទ្ធានុភាពខាងឯការភ្ជួរស្រែដោយនង្គ័លតែមួយ មានអាចម៍បំណះប្រាំពីរបែកចេញទៅ។ ទើបព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ហៅនូវសព្វត្តកមហាមាត្យ[๑] ម្នាក់មកហើយ ទ្រង់មានព្រះឱង្ការថា នែនាយ ឮថា មេណ្ឌកគហបតីនៅក្នុងក្រុងកទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) មានឥទ្ធានុភាពខាងឯកក់ជម្រះនូវសីសៈ រួចប្រើគេឲ្យបោស ជង្រែកស្រូវហើយអង្គុយខាងក្រៅទ្វារ ធារស្រូវស្រាប់តែធ្លាក់ចុះមកអំពីអាកាសពេញទាំងជង្រែក ។បេ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះ មានឥទ្ធានុភាពខាងឯការភ្ជួរស្រែដោយនង្គ័លតែមួយ មានអាចម៍បំណះប្រាំពីរបែកចេញទៅ នែនាយ អ្នកចូរទៅឲ្យដឹងការ (បើ) អ្នកឃើញហើយ ដូចជាយើងឃើញខ្លួនឯងដែរ ។ មហាមាត្យនោះទទួលព្រះរាជឱង្ការនៃព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យដូច្នេះថា

๑- អាមាត្យអ្នកសម្រេចរាជការទាំងអស់ ។

*យ៉ាងហ្នឹងហើយព្រះសម្មតិទេព ហើយត្រាច់សំដៅទៅកាន់ក្រុងកទ្ទិយៈតាមលំដាប់ ជាមួយនឹងសេនាមានអង្គ ៤ ចូលទៅរកមេណ្ឌកគហបតិ លុះចូលទៅដល់ហើយ ទើបនិយាយនឹងមេណ្ឌកគហបតិថា នែគហបតិ យើងនេះឯងព្រះរាជាទ្រង់ត្រាស់បង្គាប់មកថា ម្នាលនាយ ឮថា មេណ្ឌកគហបតិនៅក្នុងក្រុងកទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) មានឥទ្ធានុភាពខាងឯកក់ជម្រះនូវសីសៈ រួចប្រើគេឲ្យបោសជង្រែកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ជារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាសពេញទាំងជង្រែក ។បេ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះមានឥទ្ធានុភាពខាងឯកិច្ចការភ្ជួរស្រែដោយនង្គ័លតែមួយ មានអាចម៍បំណះច្រាំពីរបែកចេញទៅ នែនាយ អ្នកចូរទៅឲ្យដឹងការ (បើ) អ្នកឃើញហើយ ដូចជាយើងឃើញខ្លួនឯងដែរ ម្នាលគហបតិ ឥឡូវនេះ យើងចង់ឃើញឥទ្ធានុភាពរបស់អ្នក ។ គ្រានោះ មេណ្ឌកគហបតិកក់ជម្រះនូវសីសៈរួចប្រើគេឲ្យបោសជង្រែកស្រូវហើយ ទើបអង្គុយខាងក្រៅទ្វារ ជារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាសពេញទាំងជង្រែក ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពរបស់អ្នក យើងក៏បានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពកិរិយារបស់អ្នកទៀត ។ ទើបមេណ្ឌកគហបតិបង្គាប់ទៅកិរិយាថា នែនាង បើដូច្នោះ ចូរនាងអង្គាសនូវសេនាមានអង្គ ៤ ដោយកត្តចុះ ។ លំដាប់នោះ កិរិយារបស់មេណ្ឌកគហបតិ ចូលទៅអង្គុយជិតថាសមានចំណុះមួយអាឡ្ហក និងថាសមួយសម្រាប់ជាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវសេនាមានអង្គ ៤ ដោយកត្ត ។ សេដ្ឋីកិរិយានោះមិនទាន់ក្រោក

ឡើងជរាបណា កត្តនោះក៏មិនចេះអស់ទៅជរាបនោះ ។ មហាមាត្យនិយាយ
ថា ម្នាលគហបតិ ឥន្ទ្រានុភាពភរិយារបស់អ្នក យើងបានឃើញហើយ តែ
យើងចង់ឃើញឥន្ទ្រានុភាពកូនប្រុសរបស់អ្នកទៀត ។ ទើបមេណ្ឌកគហបតិ
បង្គាប់ទៅកូនប្រុសថា នែកូន បើដូច្នោះ អ្នកចូរឲ្យរង្វាន់ដល់សេនាមានអង្គ
៤ អស់ប្រាំមួយខែចុះ ។ លំដាប់នោះ កូនរបស់មេណ្ឌកគហបតិកាន់យកថង់
មានចំណុះមួយពាន់កហាបណៈ ហើយឲ្យរង្វាន់ដល់សេនាមានអង្គ ៤ អស់
ប្រាំមួយខែ ។ ថង់នៅក្នុងដៃរបស់សេដ្ឋិបុត្តនោះជរាបណា រង្វាន់នោះក៏មិន
ចេះអស់ទៅជរាបនោះ ។ មហាមាត្យនិយាយ ថាម្នាលគហបតិ ឥន្ទ្រានុភាព
កូនប្រុសរបស់អ្នក យើងបានឃើញហើយ តែយើងចង់ឃើញឥន្ទ្រានុភាពកូន
ប្រសាស្រីរបស់អ្នកទៀត ។ ទើបមេណ្ឌកគហបតិបង្គាប់ទៅកូនប្រសាស្រីថា
នែនាង បើដូច្នោះ នាងចូរឲ្យនូវភត្តដល់សេនាមានអង្គ ៤ អស់ប្រាំមួយខែ
ចុះ ។ លំដាប់នោះ កូនប្រសាស្រីរបស់មេណ្ឌកគហបតិចូលទៅអង្គុយជិត
កញ្ជើមួយមានចំណុះ ៤ ទោណ ហើយឲ្យនូវភត្តដល់សេនាមានអង្គ ៤ អស់
ប្រាំមួយខែ ។ កូនប្រសាស្រីរបស់សេដ្ឋីនោះ មិនទាន់ក្រោកឡើងជរាបណា
កត្តនោះក៏មិនចេះអស់ទៅជរាបនោះ ។ មហាមាត្យនិយាយថា ម្នាលគហបតិ
ឥន្ទ្រានុភាពកូនប្រសាស្រីរបស់អ្នក យើងបានឃើញហើយ យើងចង់ឃើញ
ឥន្ទ្រានុភាពខ្ញុំប្រុសរបស់អ្នកទៀត ។ មេណ្ឌកគហបតិនិយាយតបថា បពិត្រ
អ្នកជាម្ចាស់ ឯឥន្ទ្រានុភាពខ្ញុំប្រុសរបស់ខ្ញុំ អ្នកត្រូវឃើញក្នុងស្រែ (ឯ
ណោះ) ។ មហាមាត្យក៏និយាយថា ម្នាលគហបតិ ណ្ហើយចុះ ឯឥន្ទ្រានុភាព

ខ្ញុំប្រុសរបស់អ្នក (ទុកដូចជា) យើងបានឃើញហើយដែរ ។ លំដាប់នោះ មហាមាត្យនោះ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ព្រមដោយសេនាមានអង្គ ๔ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ទើបក្រាបទូលជំណើរនុ៎ះដល់ព្រះបាទមាគធសេនិយពិម្ពិសារ (ដោយសព្វគ្រប់)។

[๑๓๒] គ្រានោះឯង ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងវេសាលី គួរតាមព្រះអធ្យាស្រ័យហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ក្នុងក្រុងកទ្ទិយៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុមួយពាន់ពីររយហាសិបរូប ។ ក្នុងកាលនោះ កាលព្រះមានព្រះភាគត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏យាងតម្រង់ទៅកាន់ក្រុងកទ្ទិយៈនោះ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងព្រៃម្ចិះ ទៀបក្រុងកទ្ទិយៈនោះ ។ មេណ្ឌកគហបតិបានឮច្បាស់ (នូវដំណឹងនោះហើយទើបប្រកាសសេចក្តីថា) ម្នាលគ្នាយើង បានឮថា ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវស្តេចមកដល់ក្រុងកទ្ទិយៈដោយលំដាប់ ហើយគង់ក្នុងព្រៃម្ចិះ ទៀបក្រុងកទ្ទិយៈ ក៏កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គធ្វាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីចេះដឹង និងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អទៅកាន់ព្រះ

និព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ថា បុរិ-សទម្មសារថិ ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គ លែងវិលត្រឡប់មកកាន់កំពង់ទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គហើយ ញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹងផង ព្រះអង្គ ទ្រង់សម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង ព្រះអង្គ ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធ អស់ជើង ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មាន សភាពយ៉ាងនោះ ជាការប្រពៃពេក ។ លំដាប់នោះ មេណ្ឌកគហបតិ ឲ្យ មនុស្សទីមយានដ៏ល្អៗ ឡើងជិះយានដ៏ល្អៗ មានយានដ៏ល្អៗ បររេចញទៅពី ក្រុងកទូយៈ ដើម្បីគាល់ព្រះមានព្រះភាគ ។ ពួកតិរ្ថិយជាច្រើនរូប បានឃើញ មេណ្ឌកគហបតិកំពុងមកពីចម្ងាយ លុះឃើញហើយ បាននិយាយពាក្យនេះ នឹងមេណ្ឌកគហបតិថា នែគហបតិ អ្នកទៅណា ។ មេណ្ឌកគហបតិនិយាយ ថា បពិត្រលោកដ៏ចម្រើន ខ្ញុំទៅគាល់ព្រះសមណគោតម ។ ពួកតិរ្ថិយ និយាយថា នែគហបតិ អ្នកឯងជាកិរិយវាទ (អ្នកពោលពាក្យថា ត្រូវធ្វើ

កិច្ចការ) នឹងចូលទៅគាល់សមណគោតមជាអកិរិយវាទ (អ្នកពោលពាក្យ ឃាត់កិច្ចការថាមិនត្រូវធ្វើ) ដូចម្តេចបានគហបតិ ព្រោះសមណគោតមជា អកិរិយវាទ សម្តែងធម៌តាមបែបអកិរិយវាទ ម្យ៉ាងទៀត សមណគោតមនោះ ទូន្មានពួកសាវកតាមបែបអកិរិយវាទនោះដែរ ។ លំដាប់នោះឯង មេណ្ឌក-គហបតិមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះ ច្បាស់ជាអរហំ-សម្មាសម្ពុទ្ធឥតសង្ស័យឡើយ ពួកតិរ្ថិយទាំងនេះឈ្នានីសជាប្រាកដ ភូមិ ប្រទេសនៃយានមានត្រឹមណា ក៏ទៅដោយយានត្រឹមនោះ ហើយចុះចាកយាន ដើរទៅដោយជើងទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ ព្រះមាន ព្រះភាគទ្រង់សម្តែងអនុបុព្វីកថា ដល់មេណ្ឌកគហបតិ ដែលអង្គុយនៅក្នុងទី សមគួរ អនុបុព្វីកថានោះដូចម្តេចខ្លះ (ឯអនុបុព្វីកថានោះ) គឺព្រះមានព្រះ ភាគទ្រង់ប្រកាសទានកថា (សម្តែងអំពីការធ្វើទាន) សីលកថា (សម្តែង អំពីការរក្សាសីល) សគ្គកថា (សម្តែងអំពីស្ថានសួគ៌) ទោសរបស់កាម ទាំងឡាយដ៏ថោកទាប ដ៏សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគបានជ្រាបថា មេណ្ឌកគហបតិមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង មានចិត្តជ្រះថ្លា ហើយ ទើបព្រះអង្គទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់ លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខ សមុទយៈ និរោធ មគ្គ ក្នុង កាលនោះ ។ ធម្មតាសំពត់សស្អាតប្រាសចាកមន្ទិលខ្មៅ គួរទទួលទឹកជ្រលក់

ដោយស្រួលបាន យ៉ាងណាមិញ មេណ្ឌកគហបតិកើតធម្មចក្ខុ គឺសោតា-
បត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិលលើអាសនៈនោះឯង (ហើយ
ពិចារណាឃើញ) ដូច្នេះថា របស់ណាមួយ ដែលមានសេចក្តីកើតឡើងជា
ធម្មតា របស់អស់នោះ ក៏មានសេចក្តីរលត់ទៅជាធម្មតា ក៏មានឧបមេយ្យ
ដូច្នោះដែរ ។ លុះដែលមេណ្ឌកគហបតិបានឃើញធម៌ សម្រេចធម៌ ដឹង
ធម៌ជាក់ច្បាស់ ឈានចុះមុតមាំក្នុងធម៌ហើយ ឆ្លងផុតចាកសេចក្តីសូាក់សៅ
ប្រាសចាកសេចក្តីសង្ស័យ ដល់នូវសេចក្តីក្លៀវក្លាមិនជឿអ្នកដទៃក្នុងសាសនា
នៃព្រះសាស្តា បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គ
ដ៏ចម្រើន ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន
ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន ដូចជា
បុគ្គលផ្ងារបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នក
វង្វេង ឬទ្រោលប្រទីបប្រេងបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែក
(ភ្លឺ) នឹងបានឃើញរូបទាំងឡាយ មានឧបមាយ៉ាងណាមិញ ធម៌ដែលព្រះ
ដ៏មានព្រះភាគប្រកាសហើយដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះ
ឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង
ព្រះធម៌ផង ភិក្ខុសង្ឃផង ថាជាទីរលឹក សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំ
ព្រះអង្គថា ជាឧបាសកដល់ព្រះរតនត្រ័យជាទីរលឹក ស្មើដោយជីវិតក្នុងកាល
មានថ្ងៃនេះជាដើម បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួល
ភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងព្រះភិក្ខុសង្ឃ ។ ព្រះដ៏

មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព (ការស្ងៀម) ។ លំដាប់នោះឯង មេណ្ឌកគហបតិជីឆ ច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ លំដាប់នោះ លុះកន្លងរាត្រីនោះទៅ មេណ្ឌកគហបតិក៏ឲ្យមនុស្សចាត់ចែងខាទនីយភោជនីយាហារដ៏ផ្ងៃតផ្ងង់ ហើយឲ្យអ្នកបម្រើទៅក្រាបបង្គំទូលកាលគួរ ដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាល (នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយទ្រង់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ យាងចូលទៅកាន់លំនៅរបស់មេណ្ឌកគហបតិ លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកហើយ ជាមួយនឹងភិក្ខុសង្ឃ ។ វេលានោះ ប្រពន្ធ កូនប្រុស កូនប្រសាស្រី និងខ្ញុំប្រុសរបស់មេណ្ឌកគហបតិ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ ព្រះមានព្រះភាគទ្រង់សម្តែងអនុបុព្វីកថាដល់ជនទាំងនោះ អនុបុព្វីកថានោះដូចម្តេច ឯអនុបុព្វីកថានោះ គឺព្រះដ៏មានព្រះភាគទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏ថោកទាបដ៏សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគបានទ្រង់ជ្រាបថា ជនទាំងអស់នោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង និងមានចិត្តជ្រះថ្លាហើយ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយ

พระอริยสาวกนั้น คือทุกข์ เหตุให้เกิดทุกข์ ความดับทุกข์ และข้อปฏิบัติเป็นทางไปสู่ความดับทุกข์ในกาลนั้น ฯ ผ้าเช็ดหน้าสะอาดที่ซักด้วยน้ำด่างขาวแล้ว ควรรับน้ำมันที่ปราศจากน้ำมันข้นได้ ฉันใด พวกชนเหล่านั้นเกิดธรรมจักษุ คือ โสดาปัตติมรรค ที่ปราศจากมลทิน ที่ปราศจากธุลี ที่ปราศจากมลทิน ในอาสนะนั้นเอง (แล้วพิจารณาเห็นว่า) สิ่งใดสิ่งหนึ่งที่มีความเกิดขึ้นเป็นธรรมดา สิ่งนั้นทั้งหมดมีความดับไปเป็นธรรมดา ก็มีนัยเปรียบเทียบฉันนั้นเหมือนกัน ชนเหล่านั้นได้เห็นธรรม ได้บรรลุธรรม ได้รู้ธรรมชัดแล้ว ได้ข้ามความสงสัย ปราศจากความลังเลแล้ว ได้ถึงความแกล้วกล้าไม่ต้องเชื่อผู้อื่นในพระศาสนาของพระศาสดา แล้วได้กราบทูลพระผู้มีพระภาคเจ้าว่า ข้าแต่พระองค์ผู้เจริญ ภาษิตของพระองค์ไพเราะนัก ข้าแต่พระองค์ผู้เจริญ ภาษิตของพระองค์ไพเราะนัก ข้าแต่พระองค์ผู้เจริญ ภาษิตของพระองค์ไพเราะนัก ข้าแต่พระองค์ผู้เจริญ ภาษิตของพระองค์ไพเราะนัก เปรียบเหมือนบุคคลหงายของที่คว่ำ เปิดของที่ปิด บอกทางแก่คนหลงทาง หรือตามประทีปน้ำมันในที่มืดด้วยหวังว่าคนมีจักษุจักเห็นรูปได้ ฉันใด ข้าพระองค์ทั้งหลายขอถึงพระผู้มีพระภาคเจ้า พระธรรม และพระภิกษุสงฆ์ว่าเป็นที่พึ่งฉันนั้นเหมือนกัน ขอพระผู้มีพระภาคเจ้าจงทรงจำข้าพระองค์ทั้งหลายว่าเป็นอุบาสกผู้ถึงพระรัตนตรัยว่าเป็น

ទីរលឹកស្មៅដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើម ។ វេលានោះ មេណ្ឌក-គហបតិបានអង្គាស ខាទនីយភោជនីយាហារ (បង្អែមចម្អាប) ជ័ង្ហាញ់ ពីសាដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតិអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគគង់ក្នុងក្រុងភទ្ទិយៈដរាបណា ខ្ញុំព្រះអង្គនឹងផ្គត់ផ្គង់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយភត្តដែលត្រូវថ្វាយជានិច្ចដរាបនោះ ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យមេណ្ឌកគហបតិយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

[๑๓๓] គ្រានោះ ព្រះមានព្រះភាគគង់នៅក្រុងភទ្ទិយៈគួរតាមពុទ្ធអធ្យាស្រ័យហើយ ទ្រង់មិនលាមេណ្ឌកគហបតិ ក៏យាងទៅកាន់ចារិកក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ មេណ្ឌកគហបតិបានឮថា ព្រះដ៏មានព្រះភាគយាងចេញទៅកាន់ចារិកក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួនមួយពាន់ពីររយហា-សិបរូប ។ ទើបមេណ្ឌកគហបតិបង្គាប់ពួកខ្ញុំប្រុស និងពួកអ្នកធ្វើការងារថា ម្នាលអ្នកទាំងឡាយ បើដូច្នោះចូរអ្នកទាំងឡាយផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយខ្លះ ឲ្យច្រើនក្នុងរនេះទាំងឡាយមក ម្យ៉ាងទៀត នាយគោបាល

មួយពាន់ពីរយហាសិបនាក់ ចូរនាំមេគោមួយពាន់ពីរយហាសិបមក (បើ) យើងជួបនឹងព្រះដ៏មានព្រះភាគក្នុងទីណា យើងនឹងនិមន្តព្រះដ៏មានព្រះភាគឲ្យឆាន់ទឹកដោះស្រស់រួតថ្មីៗ ក្នុងទីនោះ ។ មេណ្ឌកគហបតិក៏បានផ្គត់ផ្គង់ព្រះដ៏មានព្រះភាគក្នុងទីកន្តារ[1] ពាក់កណ្តាលផ្លូវ ។ លំដាប់នោះ មេណ្ឌកគហបតិចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតិឈរក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ឯមេណ្ឌកគហបតិដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅ ទើបមេណ្ឌកគហបតិឲ្យមនុស្សគាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ហើយ ក៏ឲ្យក្រាបបង្គំទូលកាលគួរដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាល (នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ហើយទ្រង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ក៏ទ្រង់យាងទៅកាន់ទីអង្គាសរបស់មេណ្ឌកគហបតិ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ ។ ទើបមេណ្ឌកគហបតិបង្គាប់ពួកអ្នកឃ្វាលគោមួយពាន់

១- ផ្លូវដែលដាច់ទឹក បានដល់ ផ្លូវដែលគេទៅមក បានដោយលំបាក ។

ពីរយ៉ាងហាសិបនាក់ថា ម្នាលអ្នកទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយយកមេគោមួយៗ មកបម្រុងទុកដើម្បីតែយកទឹកដោះស្រស់ថ្មីៗ ហើយយើងនឹងប្រគេនភិក្ខុមួយអង្គៗ ឆាន់ ។ ទើបមេណ្ឌកគហបតិអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ និងទឹកដោះស្រស់ដែលតឹតថ្មីៗ ដោយដៃខ្លួនឯង ។ ភិក្ខុទាំងឡាយ មានសេចក្តីរង្កៀសមិនហ៊ានទទួលទឹកដោះស្រស់ ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ ។ លំដាប់នោះឯង មេណ្ឌកគហបតិអង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ និងទឹកដោះស្រស់ដែលតឹតថ្មីៗ ដោយដៃខ្លួន លុះព្រះដ៏មានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះមេណ្ឌកគហបតិ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន គង់មានផ្លូវកន្តារទាំងឡាយដែលមានទឹកតិច មានកក្ខាហារតិច ដែលអ្នកគ្មានស្បៀងមិនអាចនឹងទៅបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាសសូមព្រះដ៏មានព្រះភាគអនុញ្ញាតស្បៀងដល់ភិក្ខុទាំងឡាយ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគឲ្យមេណ្ឌកគហបតិយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគោរស

៥ គឺទឹកដោះស្រស់ ១ ទឹកដោះជូរ ១ ខ្ចាញ់ ១ ទឹកដោះខាប់ ១ ទឹកដោះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ មានផ្លូវកន្តារដែលមានទឹកតិច មានភក្សាហារតិច ដែលអ្នកគ្មានស្បៀងមិនអាចនឹងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុស្វែងរកស្បៀងបាន គឺភិក្ខុត្រូវការអង្ករ ស្វែងរកអង្ករបាន ត្រូវការសណ្តែកបាយ ស្វែងរកសណ្តែកបាយបាន ត្រូវការសណ្តែករាជមាស ស្វែងរកសណ្តែករាជមាសបាន ត្រូវការអំបិល ស្វែងរកអំបិលបាន ត្រូវការស្ករអំពៅស្វែងរកស្ករអំពៅបាន ត្រូវការប្រេង ស្វែងរកប្រេងបាន ត្រូវការទឹកដោះថ្លា ស្វែងរកទឹកដោះថ្លាបាន ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មនុស្សទាំងនោះទុកជាក់មាស និងប្រាក់ក្នុងដៃកប្បិយការកៈទាំងឡាយដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយប្រគេនរបស់នោះដោយមាស និងប្រាក់នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយៈ (ដែលកើត) អំពីមាស និងប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវអ្នកស្វែងរកមាស និងប្រាក់ដូច្នេះ ដោយបរិយាយនីមួយឡើយ ។

[១៣៤] លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់គ្រាច់ទៅកាន់ចារិក ដោយលំដាប់ បានយាងទៅដល់អាបណនិគម ។ ជដិលឈ្មោះកេណិយៈ បានឮដំណឹងថា នែគ្នាយើង ឮថាព្រះសមណគោតមជាសក្យបុត្ត (ចេញ) ចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវមកដល់អាបណនិគមដោយលំដាប់ ក៏កិត្តិសព្ទពីរោះរបស់ព្រះគោតមដ៏ចម្រើននោះឯង ឮខ្ទរខ្ទាយសុសសាយ

យ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថាពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ចំពោះព្រះអង្គហើយ ញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍ ញុំាងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ព្រះអង្គសម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថព្រមទាំងព្យញ្ជនដ៏ពេញបរិបូណ៌ ដ៏បរិសុទ្ធអស់ជើង ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពយ៉ាងនោះ ជាការប្រពៃពេក ។ លំដាប់នោះ កេណិយជដិលមានសេចក្តីត្រិះរិះដូច្នេះថា គួរអញឲ្យគេនាំយកវបស់អ្វីហ្ន៎ ទៅថ្វាយព្រះសមណគោតម ។ ទើបកេណិយជដិលមានសេចក្តីត្រិះរិះដូច្នេះថា ឫសីទាំង-

ទ្បាយណា ដែលជាបុព្វបុរសរបស់ព្រាហ្មណ៍ទាំងទ្បាយ ដែលជាអ្នកកសាងមន្ត ជាអ្នកវាយមន្ត បទមន្តបុរាណនេះដែលពួកឫសីណា បានច្រៀងមកហើយ បានរាយមកហើយ បានសន្សំមកច្រើនហើយ ឥឡូវនេះ ព្រាហ្មណ៍ទាំងទ្បាយតែងស្វាធ្យាយតាមបទមន្តនោះ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងទ្បាយនោះពោលហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងទ្បាយនោះបង្រៀនមកហើយ ដូចជាព្រាហ្មណ៍ឈ្មោះអដ្ឋកៈ ព្រាហ្មណ៍ឈ្មោះវាមកៈ ព្រាហ្មណ៍ឈ្មោះវាមទេវៈ ព្រាហ្មណ៍ឈ្មោះវេស្សាមិត្តៈ ព្រាហ្មណ៍ឈ្មោះយមតគ្គិ ព្រាហ្មណ៍ឈ្មោះអង្គីរសៈ ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ ព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ ព្រាហ្មណ៍ឈ្មោះកស្សបៈ ព្រាហ្មណ៍ឈ្មោះភគុ ពួកព្រាហ្មណ៍ទាំងនោះជាអ្នកវៀរចាកការបរិភោគក្នុងរាត្រីវៀរចាកការបរិភោគខុសកាល (រាប់ពីពេលថ្ងៃត្រង់ទៅដល់អរុណរះ) ត្រេកអរនឹងទឹកបានទាំងទ្បាយ មានសភាពយ៉ាងនេះ សូម្បីព្រះសមណគោតម ក៏ជាអ្នកវៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ព្រះសមណគោតម ក៏គួរត្រេកអរនឹងទឹកបានទាំងទ្បាយមានសភាពយ៉ាងនេះដែរហើយ ក៏ឲ្យគេតាក់តែងទឹកបានជាច្រើន ឲ្យវែកទៅដោយអម្រែកទាំងទ្បាយ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏វីតកាយជាមួយនឹងព្រះដ៏មានព្រះភាគ ហើយពោលនូវពាក្យវាក់ទាក់វីតកាយសំណេះសំណាល គួរលើកគួរចហើយ ក៏បានឈរនៅក្នុងទីគួរមួយ ។ លុះកេណិយជដិលឈរនៅក្នុងទីគួរមួយហើយ បានទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា សូមព្រះគោតមដ៏

ចម្រើន ទទួលទឹកបានរបស់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគមានព្រះបន្ទូលថា នែកោណិយៈ បើដូច្នោះ អ្នកឯងចូរប្រគេនដល់ភិក្ខុទាំងឡាយចុះ ។ ភិក្ខុទាំង-ឡាយរង្គៀស មិនហ៊ានទទួល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទទួលឆាន់ចុះ ។ គ្រានោះ កោណិយជដិលក៏បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយទឹកបានទាំងឡាយដ៏ច្រើន ដោយដៃខ្លួនឯង កាលដឹងថា ព្រះដ៏មានព្រះភាគទ្រង់លាងព្រះហស្ត ហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីគួរមួយ ។ លុះកោណិយជដិលអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ ឯកោណិយជដិល កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃ ទទួលកត្តព្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា នែកោណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួនមួយពាន់ពីរយហាសិបអង្គ អ្នកសោត ក៏ជ្រះថ្លាខ្លាំង ក្នុងព្រាហ្មណ៍ទាំងឡាយហើយ ។ កោណិយជដិលបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគ អស់វារៈជាគម្រប់ពីរដងផងថា បពិត្រព្រះគោតមដ៏ចម្រើន ទុកជាភិក្ខុសង្ឃច្រើនចំនួនមួយពាន់ពីរយហាសិបអង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៍ទាំងឡាយក្តី ក៏សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃទទួលកត្តព្ញុំព្រះអង្គ ដើម្បីឆាន់ក្នុង

ថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួនមួយពាន់ពីរយហាសិបអង្គ អ្នកឯងសោតក៏ជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៍ទាំងឡាយហើយ ។ កេណិយជដិលបានទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគអស់វារៈជាគម្រប់បីដងផងថា បពិត្រព្រះគោតមដ៏ចម្រើន ទុកជាភិក្ខុសង្ឃច្រើន ចំនួនមួយពាន់ពីរយហាសិបអង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៍ទាំងឡាយក្តី ក៏សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃទទួលភត្តខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ កេណិយជដិលដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ ព្រោះនិទាននេះ ជំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយ មកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកបានទាំងឡាយ ៨ យ៉ាង គឺទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែចន្ទ ទឹកក្រអៅឈូក ទឹកផ្លែមាក់ជ្រុង[1] ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្លែឈើគ្រប់យ៉ាង លើកលែងតែផ្លែស្រូវ[2] ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកស្ងឹកឈើគ្រប់យ៉ាង លើកលែងតែទឹកបន្លែដែលឆ្អិនហើយ[3] ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្កាឈើគ្រប់យ៉ាង លើកលែងតែទឹកផ្កាស្រគំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកអំពៅ ។ លុះកន្លង

១-២-៣-សូមមើលអដ្ឋកថាខាងក្រោម ។

*ภตฺตเรนาหเรติ เภณิยชฏิล ยาคุขาทนียโภชนียาหารปฏิยาทาเปตฺวา ตตฺถ อาสเมฯ ปหิเณยฺยาสิ กาลมาโรจาเปยฺยาสิ ภนฺเตติ ภนฺเต ภควา ภตฺตกาโล นิฏฺฐิตนฺติ กาลมาโรจาเปยฺยาสิ ฯ อถ โข ภควา ปุพฺพณฺหสมยนฺติ ปุพฺพณฺหสมยนฺติ ปุพฺพณฺหสมเย ฯ นิวาเสตฺวาติ นิวาเสตฺวา ฯ ปตฺตจีวรมาทายาติ ปตฺตจีวรมาทาย ฯ เภณิยชฏิลสฺส อสฺสมปทนฺติ เภณิยชฏิลสฺส อสฺสมปทนฺติ ปุพฺพณฺหสมเย ฯ ปญฺญตฺเตติ ปญฺญตฺเต ฯ อาสเนติ ตินปณฺณมยาทิเก ฯ ปาทกถลิกายาติ ปาทกถลิกาย ฯ ปาทานิ ปกฺขาเลตฺวาติ ปาทานิ ปกฺขาเลตฺวา ฯ ปาทปีฐนฺติ ปาทปีฐนฺติปิ ปาทกถลิกนฺติปิ ปาทานิ ปกฺขาเลตฺวาติ ปาทานิ ปกฺขาเลตฺวา ฯ

[๑๓๖] *คราโนះឯង ព្រះដ៏មានព្រះភាគគង់ក្នុងអាបណនិគមដោយ គួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងកុសិនារាជាមួយ នឹងភិក្ខុសង្ឃជាច្រើនចំនួនមួយពាន់ពីរយហាសិបរូប ។ ពួកស្តេចមល្លៈទាំង-ទ្បាយនៅក្នុងក្រុងកុសិនារា បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដ៏ច្រើន ចំនួនមួយពាន់ពីរយហាសិបរូប យាងមកកាន់ក្រុងកុសិនារា ។ ពួកមល្លក្សត្រទាំងនោះ បានធ្វើការប្តេជ្ញាគ្នាថា អ្នកណាមិនធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគ អ្នកនោះ ត្រូវពិន័យជាទ្រព្យ ៥០០ កហាបណៈ (មិនខាន) ។ ក៏សម័យនោះឯង មល្លក្សត្រឈ្មោះរោជៈ ជាសម្លាញ់ព្រះអានន្ទដ៏មានអាយុ ។ លំដាប់នោះឯង ព្រះមានព្រះភាគកាលត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ក្រុងកុសិនារានោះ ។ ពួកមល្លក្សត្រនៅក្នុងក្រុងកុសិនារា បានធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគ ។ លំដាប់នោះឯង រោជមល្លក្សត្រក៏ធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគដែរ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយក៏ឈរក្នុងទីសមគួរ ។ ព្រះអានន្ទដ៏មានអាយុបាននិយាយពាក្យនេះនឹងរោជមល្លក្សត្រដែលឈរក្នុងទីសមគួរដូច្នេះថា នែរោជៈដ៏មានអាយុអ្នកបានធ្វើការក្រោកទទួលណា ចំពោះព្រះមានព្រះភាគការក្រោកទទួលនេះជាការប្រពៃរបស់អ្នកហើយ ។ រោជមល្លក្សត្រនិយាយថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនមែនធ្វើ (សេចក្តីគោរព) ច្រើន ព្រោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទេ ប៉ុន្តែពួកញាតិបានធ្វើការប្តេជ្ញាថា អ្នកណាមិនធ្វើការ*

ក្រោកទទួលព្រះមានព្រះភាគ អ្នកនោះនឹងត្រូវពិន័យជាទ្រព្យ ៥០០ កហាបណៈ មិនខាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំបានធ្វើការក្រោកទទួលព្រះមានព្រះភាគយ៉ាងនេះ ព្រោះខ្លាចពិន័យរបស់ពួកញាតិទេ ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ មានសេចក្តីអាក់អន់ចិត្តថា ពោជមល្លក្សត្រ មិនសមបើនឹងហ៊ាននិយាយយ៉ាងនេះសោះ ។ វេលានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពោជ-មល្លក្សត្រនេះជាអ្នកល្បីល្បាញ ជាមនុស្សមានគេស្គាល់ (ច្រើន) មានឫទ្ធិច្រើន ពួកមនុស្សដែលមានគេស្គាល់ច្រើន មានសភាពយ៉ាងនេះ រមែងមានសេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស ពោជមល្លក្សត្រគប្បីជ្រះថ្លាក្នុងធម្មវិន័យនេះយ៉ាងណា សូមព្រះដ៏មានព្រះភាគទ្រង់ធ្វើយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា នែអានន្ទ ពោជមល្លក្សត្រគប្បីជ្រះថ្លាក្នុងធម្មវិន័យនេះ ដោយហេតុណា ហេតុនោះតថាគតមិនលំបាកធ្វើទេ ។ ទើបព្រះដ៏មានព្រះភាគមានព្រះទ័យប្រកបដោយមេត្តាផ្សាយទៅកាន់ពោជមល្លក្សត្រ ហើយទ្រង់ក្រោកចាកអាសនៈយាងចូលទៅកាន់វិហារ ។ ឯពោជមល្លក្សត្រកាលបើព្រះដ៏មានព្រះភាគមានព្រះទ័យមេត្តាផ្សាយមកប៉ះពាល់ហើយ ក៏ចូលទៅគ្រប់វិហារ គ្រប់បរិវេណ ដូចជាមេគោមានកូនខ្ចីដូច្នោះឯង ហើយក៏សួរពួកភិក្ខុថា លោកដ៏ចម្រើន ឥឡូវនេះ

ព្រះដ៏មានព្រះភាគជាអរហំសម្មាសម្ពុទ្ធ ព្រះអង្គគង់ក្នុងទីណា ដ្បិតយើងខ្ញុំចង់ឃើញព្រះដ៏មានព្រះភាគជាអរហំសម្មាសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុជ្រាបថា នែអាវុសោវេជៈ (ព្រះដ៏មានព្រះភាគទ្រង់គង់) ក្នុងវិហារដែលគេបិទទ្វារនោះ ជ្ងួច្នោះ ចូរអ្នកមានសំឡេងតិច ចូលទៅជិតកុំរួសរាន់ ចូលទៅកាន់របៀងក្អកគ្រហែមហើយសឹមគោះសន្ទះទ្វារ ព្រះដ៏មានព្រះភាគនឹងបើកទ្វារឲ្យអ្នក ។ វេលានោះ រោជមល្លក្សត្រចូលទៅកាន់វិហារដែលគេបិទនោះ ដោយស្ងប់ស្ងាត់សំឡេងសន្សឹមៗ ដើរចូលទៅកាន់របៀង ក្អកគ្រហែមហើយគោះសន្ទះទ្វារ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់បើកទ្វារឲ្យ ។ គ្រានោះ រោជមល្លក្សត្រចូលទៅកាន់វិហារ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ ។ លុះរោជមល្លក្សត្រអង្គុយនៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងអនុបុព្វីកថា អនុបុព្វីកថានោះតើដូចម្តេច (ឯអនុបុព្វីកថានោះ) គឺ ព្រះមានព្រះភាគទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមកអាក្រក់ និងអានិសង្សក្នុងការចេញចាកកាម ។ កាលណាបើព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា រោជមល្លក្សត្រមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយ មានចិត្តជ្រះថ្លាហើយ ព្រះអង្គក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខ ហេតុឲ្យកើតទុក្ខ ធម៌ជាគ្រឿងរំលត់ទុក្ខ និងសេចក្តីប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ ក្នុងកាលនោះ ។ ធម្មតាសំពត់ស្អាតប្រាសចាកមន្ទិលខ្មៅ គួរទទួលទឹកជ្រលក់ ដោយស្រួលបានយ៉ាងណាមិញ ធម្មចក្ខុ គឺ

